ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

ឆ្នាំ ២០២០ ប្រចាំឆមាសទី១

ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

០៦៣ ៧៦៥ ៥៧៧ ០៦៣ ៧៦៥ ៥៧៦

info@apsaraauthority.gov.kh apsaraautorite

www.apsaraauthority.gov.kh apsara authority

នាយកដ្ឋានផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា បានកត់ត្រា និងផ្សព្វផ្សាយជាប្រចាំនូវរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំ និង សកម្មភាពការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម របស់អាជ្ញាធរជាតិអប្សរា និងចែកចាយទៅតាមបណ្តាញសារព័ត៌មានជាដៃគូជាច្រើនទៀត ។ ឯកសារទាំងនេះ បានជួតជ្រាបដល់មហាជនទាំងក្នុងឧទ្យានអង្គរ និងមហាជនទូទៅ និងបានបង្កើនការយល់ដឹងអំពីកិច្ចការអភិរក្សបេតិកភណ្ឌ។

រាល់ព្រឹត្តិការណ៍ព័ត៌មាន ដែលមាននៅក្នុងឯកសារនេះ ត្រូវបានដកស្រង់ទាំងស្រុងចេញពីគេហទំព័ររបស់អាជ្ញាធរជាតិអប្សរា សម្រាប់រក្សាទុកតែប៉ុណ្ណោះ។

មាតិកា

ប្រចាំខែមករា

- អាជ្ញាធរជាតិអប្សរាប្រកាសបិទចរាចរណ៍ឡើង-ចុះវង់ទស្សនាជាន់ទី៣ (ប្រាង្គកណ្ដាល) នៃប្រាសាទបាយ័ន្តនៅដើមឆ្នាំ២០២០ .... ១
- ភ្ញៀវទេសចរច្រើនកុះករទស្សនារមណីយដ្ឋានអង្គរនាឱកាសបុណ្យចូលឆ្នាំសកល ២
- ម្ចាស់ភោជនីយដ្ឋាន Chez sophéa & Matthieu អាជីវករគំរូដំបូងគេដែលបានស្ម័គ្រចិត្ត រុះរើសំណង់ដើម្បីរួមចំណែកលើកកម្ពស់សោភ័ណភាពនិងគុណតម្លៃមុខប្រាសាទអង្គរវត្ត ៤
- កំណាយស្រាវជ្រាវអំពីរចនាសម្ពន្ធផ្លូវបុរាណពីអង្គរទៅរលួស ៦
- ក្រុមការងារកាត់ក្រីចុះកាត់ដើមឈើហានិភ័យនៅរមណីយដ្ឋានក្បាលស្ពាន........ ៨
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមអបអរការប្រារព្ធខួបទី៤១ឆ្នាំនៃថ្ងៃ០៧ មករា ១៩៧៩........ ៩
- តំណាងអង្គការ JICA ស្វែងរកការគាំទ្រពីអាជ្ញាធរជាតិអប្សរាក្នុងគម្រោង Smart Cities........ ១០
- ការងាររៀបចំសោភណភាពនៅមុខប្រាសាទព្រះពិធូរនឹងជួយលើកកម្ពស់តម្លៃបេតិកភណ្ឌ និងជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ ១១
- វាលស្មៅប្រាសាទអង្គរនឹងមានភាពបៃតងទាំងខួបប្រាំងខួបវស្សាក្នុងឆ្នាំ២០២០ .... ១២
- និស្សិតស្ថាបត្យកម្មបង្ហាញការប្រកួតប្រជែងស្ថាបត្យកម្មកែលម្អកំណាត់ផ្លូវសម្ដេចវិបុលបញ្ញា សុខ អាន........ ១៤
- គណៈប្រតិភូរមណីយដ្ឋានហ័ងសានបំពេញទស្សនកិច្ចក្នុងរមណីយដ្ឋានអង្គរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌និងទេសចរណ៍........ ១៥
- យុទ្ធសាស្ត្រគន្លឹះសំខាន់ៗដែលនាំឲ្យការគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរ ទទួលបានការជោគជ័យ ១៦
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យតាមដានការងាររៀបចំសណ្ដាប់ធ្នាប់នៅបរិវេណប្រាសាទអង្គរវត្ត........ ១៨
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលរួមពិធីបំពាក់មេដាយជូនរង្វាន់ជ័យលាភី ការប្រកួតកីឡារត់ចម្ងាយឆ្ងាយឆ្លងឧបសគ្គ Angkor Ultra Trial លើកទី៥........ ១៩
- អាជ្ញាធរជាតិអប្សរាមានសុទិដ្ឋិនិយមអំពីកំណើននៃទេសចរណ៍កីឡា ២០
- កំណាយស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុករកឃើញគ្រឿងប្រាសាទ សម្ភារប្រើប្រាស់ និងការតាំងទីរបស់មនុស្សជាង១០០០ឆ្នាំ........ ២២
- លទ្ធផលស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុកត្រូវបានផ្សព្វផ្សាយដល់សិស្សានុសិស្សនិងអ្នកភូមិ........ ២៤
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាបកស្រាយអំពីចម្លាក់សត្វម្ករនៅជើងភ្នំគូលេនក្នុងសិល្បៈចម្លាក់ខ្មែរ........ ២៥
- សេចក្ដីជូនដំណឹងស្ដីពីការរៀបចំសោភ័ណភាព និងបរិស្ថានជុំវិញបរិវេណត្រពាំងសេស ប្រាសាទព្រហ្មកិល ខាងលិចប្រាសាទអង្គរវត្ត(មុខនាគ) និងជុំវិញអាងស្នាក់ខ្សាច់(ប្រកសំពៅលូន) នៅខាងជើងប្រាសាទអង្គរវត្ត........ ២៦
- អាជ្ញាធរជាតិអប្សរាកាត់ដើមចំបក់មួយដើមដែលប្រឈមនឹងហានិភ័យ ដល់ភ្ញៀវចេញពីក្នុងបរិវេណប្រាសាទនាគព័ន្ធ........ ២៧
- អាជ្ញាធរជាតិអប្សរាបើកកម្មវិធីអប់រំបេតិកភណ្ឌដល់កុមារនៅសាលាបឋមសិក្សាក្របីរៀលសម្រាប់ឆ្នាំ២០២០ .... ២៨
- អាជ្ញាធរជាតិអប្សរាបន្តការងារជួសជុល ថែទាំហេដ្ឋារចនាសម្ពន្ធក្នុងរមណីយដ្ឋានអង្គរ........ ២៩
- ពិធីបុណ្យឡើងមាឃ ឬឡើងអ្នកតា ជាទំនៀមមួយក្នុងចំណោមបេតិកភណ្ឌអរូបីជាច្រើនរបស់អ្នកស្រុកអង្គរ ៣០
- សិប្បកម្មឡតដ្ឋក្បឿងអង្គរ ជាសិប្បកម្មតែមួយគត់ដែលផលិតឥដ្ឋជួសជុលប្រាសាទ ៣២
- អាជ្ញាធរជាតិអប្សរាគ្រោងនឹងបញ្ចប់ការជួសជុលប្រាសាទបាតជុំក្នុងដំណាក់កាលទី១ .... ៣៤
- ទិដ្ឋភាពពិធីឡើងអ្នកតានៅប្រាសាទអង្គរវត្ត........ ៣៦
- អ្នកស្រុកចំណុះជើងវត្តអាធ្វានាំគ្នាប្រារព្ធពិធីឡើងអ្នកតាបួងសួងសុំសេចក្ដីសុខតាមទំនៀមពីបុរាណ........ ៣៧

- ម្ចាស់ភោជនីយដ្ឋាន "ផ្ទះបាយតានីខ្មែរអង្គរ" ស្ម័គ្រចិត្តរុះរើសំណង់ប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ ៣៨
- អាជ្ញាធរជាតិអប្សរាកំពុងជួសជុលកែលម្អផ្លូវពីប្រាសាទប្រែរូបមកដល់មុខប្រាសាទបន្ទាយក្ដី ៤០
- គណៈកម្មការជាតិយូណេស្កូ និងសាកលវិទ្យាល័យ Sungkyunkwan នៃប្រទេសកូរ៉េខាងត្បូង ដឹកនាំនិស្សិតមកសិក្សាស្វែងយល់ពីកិច្ចការអាជ្ញាធរជាតិអប្សរា ៤១

ប្រចាំខែកុម្ភៈ

- ការសម្អាតផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ ៤៥
- ក្រុមភ្នាក់ងារទេសចរចូលរួមសម្អាតអនាម័យនៅបរិវេណប្រាសាទអង្គរវត្ត ៤៦
- សេចក្ដីជូនដំណឹងស្ដីពីការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ ដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ ៤៧
- លោកជំទាវ ភឿង សកុណា ចូលជួបធ្វើបដិសណ្ឋារកិច្ចជាមួយអនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ៤៨
- ក្នុងខែមករា ឆ្នាំ២០២០នេះ អ្នកស្រុកអង្គរចំនួន១២២គ្រួសារ ទទួលបានការអនុញ្ញាតឱ្យជួសជុលសំណង់ស្រាល ៤៩
- លោកជំទាវ ភឿង សកុណា ស្នើស្ថាប័នមូលនិធិជប៉ុនថតសិល្បៈរបាំបុរាណខ្មែរក្នុងទម្រង់3D ៥០
- ខែមករា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាផ្ដល់ថវិកាបដិភាគសាងសង់បង្គន់អនាម័យ ជូនប្រជាពលរដ្ឋចំនួន២៩គ្រួសារ ៥១
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមដំណើរការស្ដាបនាផ្លូវវាំងមុខព្រះលានដល់ជំរីនៅដើមខែកុម្ភៈនេះ ៥២
- លោកជំទាវ ភឿង សកុណា ចូលរួមសន្និសីទអន្តរជាតិស្ដីពីទឹកនិងវប្បធម៌ ក្រោមព្រះរាជាធិបតីភាពព្រះចៅអធិរាជជប៉ុន ៥៣
- ប្រាំងកសិន្ធុអង្គរវត្តសរុបប្រវែង៩០ម៉ែត្រដែលអាជ្ញាធរជាតិអប្សរាជួសជុលបានសម្រេចក្នុងរយៈពេល៨ឆ្នាំ ៥៤
- សេចក្ដីជូនដំណឹងស្ដីពីការស្ដារកំណកដីល្បាយខ្សាច់ដោយប្រើប្រាស់ម៉ាស៊ីន Excavator នៅស្រះទឹកខាងជើងនៃប្រាសាទអង្គរវត្ត ៥៥
- អាជ្ញាធរជាតិអប្សរាបានរកឃើញជើងទ្វារបាលនៅប្រាសាទទន្លេស្ងួតក្រោយពីរកឃើញដងខ្លួនកាលពី៣ឆ្នាំមុន ៥៦
- ភ្នាក់ងារទេសចរណ៍សម្អាតបរិស្ថាននិងអនាម័យនៅប្រាសាទអង្គរវត្ត ៥៧
- អាជ្ញាធរជាតិអប្សរាប្រារព្ធខួប២៥ឆ្នាំនៅសប្ដាហ៍ក្រោយ ៥៨
- សវនករស្ថាប័នជានាគុណភាពជប៉ុន ធ្វើសវនកម្មផ្ទៃក្រៅ តាមដានការងារបរិស្ថាន-អង្គរ ៥៩
- អាជ្ញាធរជាតិអប្សរានឹងរៀបចំពិព័រណ៍រូបថតស្ដីពីសកម្មភាព សមិទ្ធផល និងការងារសំខាន់ៗ ក្នុងឱកាសខួបលើកទី២៥ឆ្នាំ (ឆ្នាំ១៩៩៥-ឆ្នាំ២០២០)នៃការបង្កើតអាជ្ញាធរជាតិអប្សរា ៦១
- សវនករស្ថាប័នជានាគុណភាពជប៉ុន (JQA) បង្ហាញថាប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា ពុំមានភាពមិនអនុលោមនោះឡើយ ៦២
- សេចក្ដីជូនដំណឹងស្ដីពីការអនុវត្តគម្រោងរៀបចំប្រព័ន្ធរំដោះទឹក និងកែលម្អផ្លូវនៅមុខប្រាសាទអង្គរវត្ត ៦៣
- អាជ្ញាធរជាតិអប្សរារៀបចំពិធីប្រុងពលីមុខប្រាសាទអង្គរខាងលិចដើម្បីសុំសេចក្ដីសុខសប្បាយ នៅក្នុងឱកាសគម្រប់ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា ៦៤
- ពិព័រណ៍សមិទ្ធផល២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរានឹងអនុញ្ញាតឱ្យសាធារណជន ស្វែងយល់កាន់តែច្បាស់ពីកិច្ចការដែលបាននិងកំពុងធ្វើក្នុងរមណីយដ្ឋានអង្គរ ៦៥
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមពិព័រណ៍រូបថតសកម្មភាពការងារ២៥ឆ្នាំក្នុងរមណីយដ្ឋានអង្គរ ៦៦
- បេតិកភណ្ឌរស់នៃរមណីយដ្ឋានអង្គរជាផ្នែកមួយក្នុងការទាក់ទាញទេសចរក្រៅពីប្រាសាទ ៦៧
- អាជ្ញាធរជាតិអប្សរាកំពុងដំណើរការកែលម្អនិងស្ដាបនាផ្លូវក្នុងបរិវេណអង្គរធំ ៦៨

- អាជ្ញាធរជាតិអប្សរាមានមោទនភាពចំពោះការធ្វើឲ្យប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរមានជីវិតឡើងវិញ..........៦៩
- ពិធីរាប់បាត្រព្រះសង្ឃ១២៥អង្គក្នុងឱកាសគម្រប់ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា ប្រព្រឹត្តទៅយ៉ាងអធិកអធម ៧០
- អាជ្ញាធរជាតិអប្សរាពិនិត្យទីតាំងមុនអនុវត្តគម្រោងប្រព័ន្ធរំដោះទឹកនិងកែលម្អផ្លូវមុខប្រាសាទអង្គរវត្ត ៧១
- អាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េរួមគ្នាបណ្ដុះបណ្ដាលធនធានមនុស្ស និងអភិរក្សប្រាសាទក្នុងរមណីយដ្ឋានអង្គរ ៧២
- និស្សិតសាកលវិទ្យាល័យស្វាយរៀងទស្សនកិច្ចសិក្សានៅអាជ្ញាធរជាតិអប្សរា ៧៣
- សេចក្ដីជូនដំណឹងស្ដីពីការផ្លាស់ប្ដូរពោងបណ្ដែតទឹកចាស់ដែលមានស្នាមប្រេះបែក ជំនួសដោយពោងថ្មីនៅលើស្ពានបណ្ដែតទឹកមុខប្រាសាទអង្គរវត្ត ៧៤
- រយៈពេលពីរសប្ដាហ៍ក្នុងខែកុម្ភៈ អាជ្ញាធរជាតិអប្សរាផ្ដល់បច្ចេកទេស អំពីការសាងសង់លំនៅដ្ឋានចំនួន១២២ ករណីក្នុងតំបន់រមណីយដ្ឋានអង្គរ ៧៥
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមអនុវត្តផែនការកែលម្អផ្លូវ ទេសភាព និងបរិស្ថានបរិវេណខាងលិចប្រាសាទអង្គរវត្ត ៧៦
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមដំណើរការជួលជុលកែលម្អកំណាត់ផ្លូវសម្ដេចវិបុលបញ្ញា សុខ អាន.........................៧៧
- អាជ្ញាធរជាតិអប្សរារៀបចំវគ្គសង្គ្រោះបឋមដល់ភ្នាក់ងារទេសចរណ៍ជាលើកទី៥...៧៨
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាចែករំលែកចំណេះដឹងអំពីប្រវត្តិសាស្ត្រអង្គរ ដល់និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ៣៦០នាក់ ៧៩
- និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផ្នែកសូនរូបស្វែងយល់ពីការងារអភិរក្សប្រាសាទនានាក្នុងតំបន់អង្គរ ៨០
- អាជ្ញាធរជាតិអប្សរាត្រៀមរៀបចំសៀមរាបសង្ក្រាន្តក្រោមប្រធានបទ ‹អង្គរ អតីតកាល បច្ចុប្បន្ន និងអនាគត› ៨១
- ប្រតិភូគណៈកម្មការទី២ នៃរដ្ឋសភាជួបសំណេះសំណាលជាមួយអាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ ៨២
- អាជ្ញាធរជាតិអប្សរាបន្តអបអរសាទរខួប២៥ឆ្នាំដោយធ្វើបទបង្ហាញនិងតាំងពិព័រណ៍រូបភាព នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)...៨៣
- អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាជាមួយប្រធានផ្នែកកិច្ចសហប្រតិបត្តិការ អំពីបេតិកភណ្ឌវប្បធម៌នៃភ្នាក់ងារដើម្បីបេតិកភណ្ឌវប្បធម៌ជប៉ុន...៨៤
- អាជ្ញាធរជាតិអប្សរាដំណើរការអ៊ុតបេតុងកៅស៊ូផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ៨៥
- ប្រតិភូគណៈកម្មការទី២នៃរដ្ឋសភាបំពេញទស្សនកិច្ចស្វែងយល់ពីកិច្ចការអភិរក្សនៅរមណីយដ្ឋានអង្គរ................៨៦
- អាជ្ញាធរជាតិអប្សរាចូលរួមបរិច្ចាគថវិកាជួយប្រជាជនចិនដែលកំពុងរងគ្រោះដោយសារជំងឺ COVID-19...............៨៧
- ការរៀបចំសណ្ដាប់ធ្នាប់ របៀបរៀបរយ និងបរិស្ថាន នៅមុខខាងលិចប្រាសាទព្រះខ័ន.......................................៨៨
- សមិទ្ធផលសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរានៅមុខប្រាសាទអង្គរវត្ត ៨៩
- អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរាបដិសេធ ពុំមានករណីភ្ញៀវទេសចរជប៉ុនស្លាប់ដោយសារជំងឺCovid 19 នៅប្រាសាទអង្គរវត្តនោះទេ! ៩០
- លោកជំទាវ ភឿង សកុណា ដឹកនាំក្រុមអ្នកជំនាញការនៃគណៈកម្មាធិការអោយស៊ីស៊ី-អង្គរ ចូលគាល់ព្រះមហាក្សត្រ...៩១
- អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុនផ្កាឈូក និងមូលនិធិផ្កាឈូករៀបចំពិព័រណ៍ សមិទ្ធផល២៥ឆ្នាំនៃអាជ្ញាធរជាតិអប្សរានៅមជ្ឈមណ្ឌលសហប្រតិបត្តិកម្ពុជា-ជប៉ុន ៩២

ប្រចាំខែមីនា

- ជម្រាបជូនលោក /លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ខេត្តសៀមរាប..៩៧
- មតិសាធារណជនជុំវិញការតាំងពិព័រណ៍ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)...៩៨

- អាជ្ញាធរជាតិអប្សរាទទួលជួបតំណាងអង្គការ JICA ផ្នែកគ្រប់គ្រងទូទៅការិយាល័យអភិវឌ្ឍន៍ទីក្រុង ៩៩
- ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អ្នកស្រុកអង្គរចំនួន២២៩គ្រួសារ
ទទួលបានការអនុញ្ញាតឱ្យជួសជុលសំណង់ស្រាល ១០០
- ប្រមុខរាជរដ្ឋាភិបាលកម្ពុជាថ្លែងអំណរគុណដល់សប្បុរសជន
ដែលបានចូលរួមថែរក្សាការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌..១០១
- សារមន្ទីរកុលាលភាជន៍អង្គរភូមិតានីមានគម្រោងផលិតចម្លងកុលាលភាជន៍បុរាណឡើងវិញ
ដើម្បីលើកស្ទួយស្នាដៃដូនតា ១០២
- ថ្នាក់ដឹកនាំសហភាពសហព័ន្ធយុវជនកម្ពុជាចុះពិនិត្យទីតាំងនៅប្រាសាទអង្គរវត្តដើម្បីរៀបចំសៀមរាបសង្ក្រាន្ត.....១០៣
- អាជ្ញាធរជាតិអប្សរាប្រកាសឱ្យភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរចំនួនបីដោយឥតគិតថ្លៃពេញមួយឆ្នាំ........១០៤
- អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងស្តីពីការកាត់បន្ថយថវិកាឆ្នាំ២០២០ ....១០៥
- សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត..១០៦
- ភ្ញៀវទេសចរបន្តដើរទស្សនានៅរមណីយដ្ឋានអង្គរ...១០៧
- អ្នកជំនាញការអាជ្ញាធរជាតិអប្សរាអនុវត្តគម្រោងអភិរក្សប្រាសាទទន្លេស្ងួតដំណាក់កាលទី២............................១០៨
- ផ្លូវចំណុចមុខប្រាសាទបន្ទាយក្តី ឆ្ពោះទៅស្រះស្រង់មុខបន្ទាយក្តី ប្រវែង ១៤០០ ម៉ែត្រ
អាជ្ញាធរជាតិអប្សរាស្ថាបនាកែលម្អបាន៨០% ១១០
- អាជ្ញាធរជាតិអប្សរាកំពុងមមាញឹករៀបចំសណ្តាប់ធ្នាប់សាធារណៈនៅបរិវេណមុខប្រាសាទអង្គរវត្ត....................១១១
- មន្ត្រី-បុគ្គលិកចំនួន២២រូបនៃអាជ្ញាធរជាតិអប្សរាបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលអប់រំបេតិកភណ្ឌ ១១២
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ទាំងក្នុងនិងក្រៅបរិវេណប្រាសាទអង្គរវត្ត.......១១៣
- អាជ្ញាធរជាតិអប្សរាចូលរួមអបអរសាទរដែលកម្ពុជាត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍
បេតិកភណ្ឌអន្តរជាតិល្អបំផុត...១១៤
- វត្ថុសិល្បៈ៤០ប្រភេទត្រូវបានប្រគល់ជូនវត្តរាជបូព៌វិញបន្ទាប់ពីជួសជុលរួចរាល់..១១៥
- ឆ្នាំ២០១៩ អាជ្ញាធរជាតិអប្សរាផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន និងសាងសង់
សំណង់ស្រាលតូចតាចដល់អ្នកស្រុកអង្គរចំនួន១៧៩៩គ្រួសារ ១១៦
- អាជ្ញាធរជាតិអប្សរាកំពុងដំណើរការសិក្សាជួសជុលខ្លោងទ្វារតាកាវ ១១៧
- ហោត់ទឹកអង្គរនឹងដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅខែមេសាខាងមុខនេះ!...១១៨
- បើទោះបីជារដូវប្រាំងក៏ស្មៅនៅមុខប្រាសាទអង្គរវត្តនៅតែមានពណ៌បៃតង..១១៩
- ការសម្អាតវារីជាតិនៅក្នុងកសិន្ធុនៃប្រាសាទអង្គរវត្ត ១២០
- សកម្មភាពនៃការសម្អាតបរិស្ថាននិងអនាម័យនៅប្រាសាទតាព្រហ្ម...១២១
- សេចក្តីជូនដំណឹងស្តីពីការបិទជាបណ្តោះអាសន្នសារមន្ទីរទាំងបី
ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ១២២
- អាជ្ញាធរជាតិអប្សរាជួសជុលសំណង់ទ្វារទឹកទំនប់បារាំង
ដើម្បីស្តុកទឹកនារដូវប្រាំងមិនឱ្យខ្វះខាតក្នុងតំបន់រមណីយដ្ឋានអង្គរ.. ១២៣
- ក្រុមការងារព្រៃឈើចុះកាត់ក្រីដើមឈើដែលមានហានិភ័យនៅតាមប្រាសាទ...១២៤
- អាជ្ញាធរជាតិអប្សរាបើកការដ្ឋានជួសជុលប្រាសាទកណ្តាលស្រះស្រង់
ក្រោមជំនួយឧបត្ថម្ភរបស់លោកជំទាវឧញ៉ា សៀង ចាន់ហេង ១២៥
- អាជ្ញាធរជាតិអប្សរាបើកការដ្ឋានកំណាយនៅប្រាសាទលលៃ...១២៦
- ការសម្អាតប្រាង្គប្រាសាទអង្គរនៅក្នុងរដូវប្រាំង ១២៧
- អាជ្ញាធរជាតិអប្សរាមមាញឹកជួសជុលជណ្តើរឈើចំនួន៤កន្លែងនៅប្រាសាទអង្គរវត្ត ១២៨
- អាជ្ញាធរជាតិអប្សរាប្រទះឃើញសំណង់ឈើអាយុកាលជិត១០០០ឆ្នាំ
ក្នុងកំណាយស្រាវជ្រាវបុរាណវិទ្យានៅបាតស្រះខាងជើងប្រាសាទអង្គរវត្ត.. ១២៩

- អាជ្ញាធរជាតិអប្សរាមមាញឹករៀបចំប្រព័ន្ធទឹកស្រោចស្រពស្មៅនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ១៣០
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម ចាន់ សារឿន ១៣១

ប្រចាំខែមេសា

- ព្រះបដិមាសីសៈចំនួន២ត្រូវបានលើកចេញពីប្រឡាយទឹកនៅខ្លោងទ្វារខ្មោច...... ១៣៥
- ប្រាសាទអកយំទទួលបានការជួសជុលជាលើកដំបូងពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា...... ១៣៦
- សារលិខិតជូនពរសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១៣៧
- រយៈពេល៣ខែដើមឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាចូលរួមសង់បង្គន់អនាម័យជូនពលរដ្ឋបានចំនួន៧០បង្គន់...... ១៣៨
- កម្រាលឈើក្នុងបរិវេណប្រាសាទអង្គរវត្តត្រូវបានជួសជុល ១៣៩
- អាជ្ញាធរជាតិអប្សរាទទួលអំណោយពីសប្បុរសជន ក្នុងការប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ១៩ ...... ១៤០
- សេចក្តីជូនដំណឹងស្តីពីការលើកពេលថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ២០២០...... ១៤១
- ភាពសម្បូរបែបនៃស្នាដៃបុព្វបុរសដែលប្រទះឃើញនៅប្រាសាទលលៃ ១៤២
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលកែលម្អកំណាត់ផ្លូវ៦០ម៉ែត្រ ១៤៣
- អាជ្ញាធរជាតិអប្សរាជួសជុលកម្រាលឈើថ្មើរជើងនិងសម្អាតស្លាកសញ្ញាបេតិកភណ្ឌពិភពលោក ក្នុងបរិវេណប្រាសាទអង្គរវត្ត ១៤៤
- ក្រុមការងារព្រៃឈើកំពុងកាត់ដកហូតដើមឈើដែលដួលរលំដោយសារខ្យល់កន្ត្រាក់ក្នុងរមណីយដ្ឋានអង្គរ ១៤៥
- សេចក្តីជូនដំណឹងស្តីពីការបើកឲ្យដំណើរការទីតាំងថ្មីរបស់មជ្ឈមណ្ឌលសេវាកម្ម នៃអាជ្ញាធរជាតិអប្សរាស្ថិតនៅភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប ១៤៦
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការងារជួសជុល អភិរក្សនៅប្រាសាទបាគង...... ១៤៧
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការរកឃើញបំណែកបដិមាព្រះពុទ្ធនៅប្រាសាទអង្គរវត្ត ១៤៨
- ជម្រាបជូន លោក លោកស្រី ជាម្ចាស់ទីតាំងតូបលក់ដូរដែលជួលឲ្យក្រុមហ៊ុន ចម្រុះសិប្បករអង្គរ (Artisans Angkor)នៅមុខអង្គរវត្តខាងលិចប្រាសាទអង្គរវត្ត ១៤៩
- អាជ្ញាធរជាតិអប្សរាកំពុងចាប់ផ្តើមគម្រោងជួសជុលប្រាសាទតាអួន...... ១៥០
- បុរាណវិទូអាជ្ញាធរជាតិអប្សរារកឃើញគ្រឹះកំពែងបុរាណនៅជុំវិញប្រាសាទលលៃ ដែលកប់ក្នុងដីជាង១០០ឆ្នាំក្រោមសំណង់សាសនាសម័យក្រោយៗ...... ១៥១
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងសប្បុរសជន ចុះពិនិត្យមើលសមិទ្ធផលរហាត់ទឹក និងការដ្ឋានជួសជុលប្រាសាទកណ្តាលស្រះស្រង់...... ១៥២
- លោកជំទាវឧកញ៉ាបណ្ឌិត សៀង ចាន់ហេង ទទួលជួយឧបត្ថម្ភ គម្រោងជួសជុលខ្លោងទ្វារតាកាវខាងលិចក្រុងអង្គរធំ...... ១៥៣
- ព្រះសង្ឃ និងកិច្ចការពារបេតិកភណ្ឌ ដែលមិនអាចកាត់ថ្លៃបាន!...... ១៥៤
- អាជ្ញាធរជាតិអប្សរារកឃើញឡើងវិញនូវបំណែកហោជាងដែលរលុះបាត់នៅខ្លោងទ្វារប្រាសាទបន្ទាយស្រី...... ១៥៥
- អាជ្ញាធរជាតិអប្សរាបន្តការងារស្តារហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ ១៥៦
- លោកកជំទាវ គឿង សកុណា ប្រគេនបណ្ណថ្លែងអំណរគុណដល់ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ចំពោះការចូលរួមរបស់ព្រះអង្គក្នុងកិច្ចការអភិរក្សបេតិកភណ្ឌជាតិ ពិសេសប្រាសាទលលៃ ១៥៧
- លោកជំទាវ គឿង សកុណា អញ្ជើញទៅវត្តប្រាសាទលលៃដើម្បីថ្លែងអំណរគុណព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តសម្រាប់ការងារបេតិកភណ្ឌជាតិ ១៥៨
- លោកជំទាវ គឿង សកុណា អញ្ជើញចុះពិនិត្យការជួសជុលប្រាសាទកណ្តាលស្រះស្រង់ ១៥៩
- លោកជំទាវ គឿង សកុណា អញ្ជើញចុះពិនិត្យគម្រោងជួសជុលខ្លោងទ្វារតាកាវនៃទីក្រុងអង្គរធំ ១៦០

- លោកជំទាវ គឿង សកុណា តាមដានការងារជួសជុលផ្លូវរាងនៅអង្គរធំនិងអញ្ជើញចុះពិនិត្យ
  ហោត់ទឹកនៅសួនបណ្តុះកូនឈើប្រាសាទតាកែវដែលទើបជួសជុលរួច ១៦១
- លោកជំទាវ គឿង សកុណា អញ្ជើញចុះពិនិត្យសកម្មភាពរៀបចំកែលម្អនៅបរិវេណប្រាសាទអង្គរវត្ត ១៦២
- លោកជំទាវ គឿង សកុណា អញ្ជើញត្រួតពិនិត្យវឌ្ឍនភាពនៃការកសាងផ្លូវឡើងភ្នំគូលែនពីស្រុកស្វាយលើ ១៦៣
- ក្រុមការងារកាត់ក្រីមែកឈើ ចុះកាត់និងដកហូតដើមឈើ៩ដើមនៅស្ពានមេម៉ាយ ១៦៤
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះត្រួតពិនិត្យនិងពិភាក្សាអំពីគម្រោងជួសជុលខ្លោងទ្វារ
  ខាងកើតប្រាសាទតាព្រហ្ម ១៦៥
- អាជ្ញាធរជាតិអប្សរានឹងផ្តល់បច្ចេកទេសជួសជុលកុដិឈើដ៏ចំណាស់នៅវត្តព្រះព្រហ្មរ័ត្ន ១៦៦
- បច្ចេកទេសអំពីការកាត់ដើមឈើធំៗមិនឱ្យមានហានិភ័យដល់ប្រាសាទ ១៦៧
- ក្រុមភ្នាក់ងារសណ្តាប់ធ្នាប់តាមប្រាសាទរៀបចំដាំបង្គោលឈើនៅតាមបរិវេណប្រាសាទ
  នៅក្នុងរមណីយដ្ឋានអង្គរ ១៦៨
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ ១៦៩
- ការអភិរក្សសំណង់ស្ថាបត្យកម្មលំនៅដ្ឋានខ្មែរក្នុងឧទ្យានអង្គរ ១៧០

ប្រចាំខែឧសភា

- ក្រុមគ្រប់គ្រងហានិភ័យដើមឈើចុះកាត់ក្រីដើមឈើក្នុងសាលាបឋមសិក្សាបាយ័ន ១៧៥
- សត្វទោចមកុដ និងសត្វកេ ដែលបានដោះលែងនៅព្រៃឧទ្យានអង្គរកើតបានកូន៣បន្ថែម ១៧៦
- អាជ្ញាធរជាតិអប្សរាគ្រោងដាំនិងចែកចាយកូនឈើចំនួន១១ម៉ឺនដើមក្នុងឆ្នាំ២០២០នេះ ១៧៧
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះនិងសាងសង់សំណង់
  តូចតាចរបស់ប្រជាពលរដ្ឋ បានចំនួន ១១១០គ្រួសារ រយៈពេល៤ខែដើមឆ្នាំ២០២០ ...... ១៧៨
- សាររំលែកមរណទុក្ខ ១៧៩
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលកំណាត់ផ្លូវចាប់ពីរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧
  កាត់តាមមុខព្រលានយន្តហោះ ដល់មុខប្រាសាទអង្គរវត្ត ១៨០
- ការប្រទះឃើញត្រីសូល៍ ចម្លាក់នាគ និងថ្មគ្រីស្តាល់នៅប្រាសាទកណ្តាលស្រះស្រង់ ១៨១
- អាជ្ញាធរជាតិអប្សរាបានបោះបង្គោលព្រំកំណត់តំបន់ការពារត្រពាំងបុរាណ ឈ្មោះ ត្រពាំងហៃផ្កា ១៨២
- អាជ្ញាធរជាតិអប្សរាអ៊ុតកៅស៊ូលើកំណាត់ផ្លូវជុំវិញប្រាសាទបាយ័ន្ត និងផ្លូវបំបែកទៅខ្លោងទ្វារជីផ្នាំង ១៨៣
- អាជ្ញាធរជាតិអប្សរានិងព្រះសង្ឃសហការគ្នាដើម្បីអភិរក្សសំណង់បេតិកភណ្ឌសាសនា ១៨៤
- ព័ត៌មានទាន់ហេតុការណ៍៖ រកឃើញចម្លាក់អណ្តើកមួយបន្ថែមទៀតនៅការដ្ឋាន
  ជួសជុលប្រាសាទកណ្តាលស្រះស្រង់ ១៨៥
- ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម និមន្តពិនិត្យសកម្មភាពជួសជុលប្រាសាទកណ្តាលស្រះស្រង់ ១៨៦
- សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត ១៨៧
- ប្រាសាទក្រហមក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២នៅលើខ្នងភ្នំគូលែនទើបបញ្ចប់ការជួសជុលជាលើកដំបូង ១៨៨
- អាជ្ញាធរជាតិអប្សរាបើកទីតាំងទទួលពាក្យចំនួន៣បន្ថែមទៀត ដើម្បីជួយសម្រួល
  ដល់ការស្នើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ ១៨៩
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការជួសជុលប្រាសាទតាអួន ១៩០
- សារលិខិតថ្វាយព្រះពរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ១៩១
- សួនបណ្តុះកូនឈើមណ្ឌល៣ ត្រៀមកូនឈើប្រមាណ៣ម៉ឺនដើមសម្រាប់ដាំនិងចែកចាយ ១៩២
- សប្តាហ៍ទី១នៃខែឧសភា ក្រុមការងារសហគមន៍អនុញ្ញាតឱ្យប្រជាពលរដ្ឋជួសជុលផ្ទះ
  និងសាងសង់សំណង់តូចតាច ចំនួន២៩គ្រួសារ ១៩៣

- លោកជំទាវ គឿង សកុណា អញ្ជើញពិនិត្យការជួសជុលប្រាសាទតាព្រហ្ម...១៩៤
- លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន អញ្ជើញពិនិត្យការវិវត្តនៃដំណើរការជួសជុលនៅប្រាសាទកណ្ដាលស្រះស្រង់...១៩៥
- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី អញ្ជើញពិនិត្យសមិទ្ធផលនៃការអភិរក្សសំណង់ព្រះវិហារដ៏ចំណាស់នៅវត្តរាជបូណ៌...១៩៦
- គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបពិភាក្សាស្ដីពីស្រូបទាញភ្ញៀវទេសចរជាតិដើម្បីជួយប៉ះប៉ូវដល់អាជីវកម្មទេសចរណ៍ដែលកំពុងរងផលប៉ះពាល់ដោយសារកូវីដ-១៩...១៩៧
- មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន២០រូប បានទទួលវគ្គបណ្ដុះបណ្ដាលជំនាញនិងបច្ចេកទេសនៃការប្រើប្រាស់ Drone...១៩៨
- លោកជំទាវ គឿង សកុណា អញ្ជើញពិនិត្យការកែលម្អផ្លូវនៅប្រាសាទបាគង...១៩៩
- ប្រជាជនក្នុងឧទ្យានអង្គរចំនួន១៥០គ្រួសារ ត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន...២០០
- ក្រុមការងារព្រៃឈើ បាន និងកំពុងកាត់សម្អាតគល់ឈើពុកផុយ និងក្រីមែកឈើដែលមានហានិភ័យខ្ពស់ក្នុងបរិវេណប្រាសាទតាព្រហ្ម...២០១
- អាជ្ញាធរជាតិអប្សរាប្រារព្ធពិធីយោងបំណែកព្រះពុទ្ធបដិមាចេញពីរណ្ដៅកំណាយមកសិក្សាជួសជុលបន្ត...២០២
- អាជ្ញាធរជាតិអប្សរាបន្តរៀបចំទេសភាពបរិស្ថានមុខប្រាសាទអង្គរវត្ត...២០៣
- អាជ្ញាធរជាតិអប្សរាលើកទឹកចិត្តព្រះសង្ឃវត្តកេតកន្សារាមអភិរក្សសំណង់ពុទ្ធសាសនាបែបបុរាណ...២០៤
- អាជ្ញាធរជាតិអប្សរាលើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឧទ្យានអង្គរសង់លំនៅដ្ឋានគំរូខ្មែរបុរាណ...២០៥
- សេចក្ដីជូនដំណឹងស្ដីពីការបើកឲ្យដំណើការឡើងវិញសារមន្ទីរទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយមិនគិតថ្លៃ...២០៦
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមអ៊ុតគំនូសចរាចរណ៍ និងដាំឧបករណ៍ចំណាំងភ្លើងចាប់ពីរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ដល់មុខប្រាសាទអង្គរវត្ត...២០៧
- អាជ្ញាធរជាតិអប្សរាចុះពិនិត្យនិងជួយលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋចំនួន១២០គ្រួសារក្នុងឧទ្យានអង្គរ...២០៨
- ម្ចាស់ភោជនីយដ្ឋាន ផ្ទះបាយតានីខ្មែរអង្គរ ស្ម័គ្រចិត្តរុះរើសំណង់ប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា អភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធនិងសម្បទាទេសចរណ៍ជាលើកទី២...២០៩
- ព្រះសុមង្គល សិលាចារ្យ អាភាករោ ជុំ គឹមឡេង ព្រះមេគណខេត្តសៀមរាបសូមឲ្យបញ្ឈប់សកម្មភាពសាងសង់នៅវត្តទេពប្រណម...២១០
- មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា ចំនួន១០០រូប បានទទួល ការបណ្ដុះបណ្ដាលស្ដីពី "ការរៀបចំដីធ្លី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ"...២១១
- អាជីវករនៅមុខប្រាសាទអង្គរវត្តបន្តរុះរើតូបលក់ដូរ...២១២

ប្រចាំខែមិថុនា

- វត្ថុសិល្បៈចំនួន៧១១បំណែកបានចុះបញ្ជីសារពើភណ្ឌនិង៥៣១បំណែកកំពុងដំណើរការចុះបញ្ជីដើម្បីសម្គាល់អត្តសញ្ញាណ...២១៧
- អាជីវករបន្តស្ម័គ្រចិត្តរុះរើតូបនៅមុខប្រាសាទអង្គរវត្ត...២១៨
- ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបន្តរៀបចំសួនមុខបរិវេណប្រាសាទអង្គរវត្ត...២១៩
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យប្រជាពលរដ្ឋក្នុងឧទ្យានអង្គរជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចចំនួន៤៧១គ្រួសារ...២២០
- អាជ្ញាធរជាតិអប្សរាដំណើរការជួសជុលព្រះវិហារបុរាណវត្តរាជបូណ៌ដំណាក់កាលទី៣...២២១

- សារមន្ទីរទាំង៣របស់អាជ្ញាធរជាតិអប្សរាបើកទ្វារដំណើរការឡើងវិញ ២២២
- សហប្រធានគណៈកម្មការអាយស៊ីស៊ី-អង្គរនិងអាជ្ញាធរជាតិអប្សរា ចុះពិនិត្យតាមដាន
កិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ ២២៣
- ក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំអាណត្តិទី៥ លើកទី១ .... ២២៤
- អាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យប្រជាពលរដ្ឋជួសជុល
និងសាងសង់សំណង់តូចតាចចំនួន១០៨គ្រួសារក្នុងសប្តាហ៍ទី១នៃខែមិថុនា ២២៥
- អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្ត បន្តចូលរួមជាមួយអាជ្ញាធរជាតិអប្សរារុះរើតូប លក់វត្ថុអនុស្សាវរីយ៍
និងភោជនីយដ្ឋានធំៗចំនួន២កន្លែងទៀត ២២៦
- សហប្រធានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បញ្ចប់ការចុះពិនិត្យការដ្ឋានក្នុងរមណីយដ្ឋានអង្គរ ២២៧
- អាជ្ញាធរជាតិអប្សរាកំពុងប្រតិបត្តិការជីកកូនស្រះ បូមភក់ និងដឹកទឹកបញ្ចូលក្នុងកសិន្ទុប្រាសាទបាគង ២២៨
- សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត ២២៩
- ព្រះសង្ឃសហការជាមួយអាជ្ញាធរជាតិអប្សរាដាំកូនឈើ១៥០០ដើមនៅវត្តព្រះឥន្ទទេព.................................... ២៣០
- អាជ្ញាធរជាតិអប្សរានិងមន្ទីរទេសចរណ៍ខេត្តសៀមរាបសហការគ្នារុះរើសំណង់នៅមុខប្រាសាទអង្គរវត្ត ២៣១
- អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាការងារជាមួយនាយកសាលាបារាំងចុងបូព៌ា ២៣២
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើកាត់ដកហូតដើមឈើពាក់កណ្តាលដើម
និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ ២៣៣
- ភ្នាក់ងារការពាររូបភាពអង្គរ និងភ្នាក់ងារទេសចរណ៍ ទទួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ២៣៤
- ប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរស្វែងយល់ពីអាជ្ញាធរជាតិអប្សរាតាមរយៈវេទិកាសាធារណៈ›................. ២៣៥
- សាលិខិតថ្វាយព្រះពរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព
សេចក្តីថ្លៃថ្នូរនិងសុភមង្គល ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ២៣៦
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ............. ២៣៧
- តូបលក់ដូរទី១១ នៅមុខប្រាសាទអង្គរវត្តត្រូវបានអាជីវករបន្តស្ម័គ្រចិត្តរុះរើចេញ ២៣៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន ចុះពិនិត្យនិងដោះស្រាយ
សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៣៩
- សំណើចំនួន២០ករណីត្រូវបានអនុញ្ញាតជូនប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ
ដោយក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា ២៤០
- លោកជំទាវ ភឿង សកុណា ដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាតាមវីដេអូ Conference ២៤១
- សិលាចារឹកមួយផ្ទាំងជាភាសាសំស្ក្រឹតត្រូវបានប្រទះឃើញនៅក្នុងប្រាសាទទន្លេស្ងួតពេលកំពុងជួសជុល ២៤២
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរអនុញ្ញាតសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋបានចំនួន៥ករណី ២៤៣
- ក្រុមការងារគ្រប់គ្រងបរិស្ថាន-អង្គរ បើកកិច្ចប្រជុំតាមដាន និងជំរុញការងារបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ ...២៤៤
- កំពែងក្រុងអង្គរធំចំនួន៧កន្លែង ស្មើនឹង១៣៥ម៉ែត្រត្រូវបានជួសជុលពង្រឹងឱ្យផុតពីគ្រោះថ្នាក់ ២៤៥
- ក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគងពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
របស់ប្រជាពលរដ្ឋបានចំនួន៦សំណើ ២៤៦
- អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងស្តីពី ដំណើរការគ្រប់គ្រងចរន្តឯកសារ
មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា ‹ម.ស.អ› ២៤៧
- ក្រុមហ៊ុន លី ប្រាឌី លីមីធីដ ប្រគល់រថយន្តបោសសម្អាតដីនិងលាងថ្នល់មួយគ្រឿងជូនអាជ្ញាធរជាតិអប្សរា ២៤៨
- សិក្ខាកាម៤៥រូបបានទទួលការបណ្តុះបណ្តាលការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២៤៩
- ខ្លោងទ្វារខាងលិចនៃប្រាសាទបន្ទាយក្តីកំពុងទទួលបានការជួសជុលដោយអ្នកជំនាញជាស្ត្រី ២៥០
- សេចក្តីជូនដំណឹងស្តីពីការប្រើប្រាស់ត្រាថ្មីរបស់ស្ថាប័នអាជ្ញាធរជាតិអប្សរា ២៥១

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមករា



អាជ្ញាធរជាតិអប្សរាប្រកាសបិទចរាចរណ៍ឡើង-ចុះទស្សនាជាន់ទី៣ (ប្រាង្គកណ្តាល) នៃប្រាសាទបាយ័ន្តនៅដើមឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២០

បច្ចុប្បន្នដោយកត្តាអាយុកាល និងកត្តាផ្សេងៗទៀតបានបង្កឱ្យជាន់ទី៣ (ប្រាង្គកណ្តាល) នៃប្រាសាទបាយ័ន្តមានភាពសឹករេចរិលនិងកំពុងប្រឈមនឹងហានិភ័យយ៉ាងធ្ងន់ធ្ងរមួយចំនួន។

ក្នុងស្ថានភាពនេះ អ្នកជំនាញការចំពោះកិច្ចផ្នែកអភិរក្សនៃគណៈកម្មាធិការអន្តរជាតិកិច្ចគាំពារអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ហៅកាត់ថា អាយស៊ីស៊ី-អង្គរ)បានផ្តល់អនុសាសន៍ឱ្យបិទការទស្សនានៅជាន់ទី៣នៃប្រាសាទបាយ័ន្តដើម្បីផ្តល់លទ្ធភាពដល់ក្រុមអ្នកជំនាញសិក្សាអំពីការខូចខាត និងបញ្ហាប្រឈមនានា ដើម្បីរៀបចំផែនទីហានីនិភ័យ ព្រមទាំងកំណត់ទីតាំងអាទិភាពក្នុងការពង្រឹងស្ថានភាព និងជួសជុលផ្នែកដែលប្រឈមនឹងគ្រោះថ្នាក់ទាំងអស់នោះ។

ក្នុងន័យនេះ ដើម្បីថែទាំនិងការពារប្រាសាទ ក៏ដូចជាការគិតគូរយ៉ាងយកចិត្តទុកដាក់ដល់សុវត្ថិភាពភ្ញៀវទេសចរជាតិ-អន្តរជាតិ អាជ្ញាធរជាតិអប្សរា នឹងបិទចរាចរណ៍ឡើងចុះ វង់ទស្សនាជាន់ទី៣ នៃប្រាសាទបាយ័ន្តចាប់ពីថ្ងៃទី១ខែមករា ឆ្នាំ២០២០ នេះតទៅដោយទុកលទ្ធភាពឱ្យក្រុមការងារជំនាញផ្នែកអភិរក្សបំពេញការងាររបស់ខ្លួនរហូតបានរួចរាល់ជាស្ថាពរ។

ចំពោះទីតាំងទស្សនាសំខាន់ៗផ្នែកខាងក្រោមនៃប្រាសាទបាយ័នដែលមានចម្លាក់ក្បូរក្បាច់រចនាដ៏ល្អវិចិត្រ នៅបើកជាប្រក្រតីសម្រាប់ភ្ញៀវទេសចរជាតិ-អន្តរជាតិ៕

ភ្ញៀវទេសចរច្រើនកុះករទស្សនារមណីយដ្ឋានអង្គរនាឱកាសបុណ្យចូលឆ្នាំសកល

ផ្សាយនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២០

វត្តមានភ្ញៀវទេសចរជាតិ-អន្តរជាតិជាច្រើនកុះករ បានមកទស្សនារមណីយដ្ឋានអង្គរ នាឱកាសបុណ្យចូលឆ្នាំសកល ២០១៩-២០២០។ នៅតាមប្រាសាទមួយចំនួនក្នុងរមណីយដ្ឋានអង្គរ ពិសេសប្រាសាទអង្គរវត្ត គឺភ្ញៀវទេសចរបានបង្ហាញនូវស្នាមញញឹមភាពសប្បាយរីករាយជាលក្ខណៈគ្រួសារ ក្នុងឱកាសនៃដំណើរកម្សាន្តសម្រាប់ថ្ងៃឈប់សម្រាករបស់ពួកគេ៕



AIA

ម្ចាស់ភោជនីយដ្ឋាន Chez sophéa & Matthieu អាជីវករគំរូដំបូងគេដែលបានស្ម័គ្រចិត្ត រុះរើសំណង់ដើម្បីរួមចំណែកលើកកម្ពស់សោភ័ណភាពនិងគុណតម្លៃមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ២០២០

ភោជនីយដ្ឋាន Chez sophéa & Matthieu ចំនួន៣ខ្នង នៅមុខប្រាសាទអង្គរវត្ត ដែលបានដំណើរការតាំងពីឆ្នាំ១៩៩៣មក ដែលមានលោកស្រី អៀវ សុភ័ក្រកញ្ញា ជាម្ចាស់បានស្ម័គ្រចិត្តរុះរើសំណង់របស់ខ្លួនទាំងស្រុង ហើយប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ ដើម្បីកែប្រែសោភ័ណភាពនិងរៀបចំសណ្តាប់ធ្នាប់មុខប្រាសាទអង្គរវត្ត។

ដំណើរការរុះរើនេះ ចាប់ផ្តើមនៅព្រឹកថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ ដឹកនាំដោយ **ឯកឧត្តម ឃិត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដោយមានការស្ម័គ្រចិត្ត និងចូលរួមយ៉ាងសកម្មពីម្ចាស់ភោជនីយដ្ឋាន។

លោកស្រី អៀវ សុភ័ក្រកញ្ញា បានលើកឡើងថា «អង្គរប្រៀបដូចជាផ្ទះខ្ញុំ អង្គរបានជួយខ្ញុំច្រើន ហើយក៏ដល់ពេលដែលខ្ញុំត្រូវជួយអង្គរវិញដែរ។ ខ្ញុំស្ម័គ្រចិត្តដោយរីករាយនឹងចូលរួមជាមួយអាជ្ញាធរជាតិអប្សរា ដោយមិនមានភាពថ្នាំងថ្នាក់ឬការបង្ខិតបង្ខំ និងការស៊ូកប៉ាន់ណាមួយឡើយក្នុងការរើសំណង់នេះ។ ខ្ញុំដឹងថា អាជ្ញាធរជាតិអប្សរា នឹងកែលម្អទីនេះឱ្យមានសណ្តាប់ធ្នាប់ បរិស្ថានស្អាត មានអនាម័យល្អ ឱ្យមានកន្លែងលក់ដូរស្តង់ដារតែមួយ ដើម្បីលើកមុខមាត់អង្គរ និងប្រទេសជាតិព្រមទាំងទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើង»។

ម្ចាស់ភោជនីយដ្ឋានរូបនេះ ក៏បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានជួយសម្រួលដល់ការរុះរើនេះ ប្រកបដោយការយោគយល់គ្នាទៅវិញទៅមក។ លោកស្រីក៏សង្ឃឹមថា អាជីវករទាំងអស់នឹងស្ម័គ្រចិត្តចូលរួមកែលម្អសោភ័ណភាពនិងសណ្តាប់ធ្នាប់មុខប្រាសាទអង្គរវត្ត ដើម្បីឱ្យអាជ្ញាធរជាតិអប្សរាងាយស្រួលអនុវត្តការងារបានទាន់ពេលវេលា ដើម្បីជាប្រយោជន៍រួមទាំងពេលបច្ចុប្បន្ន និងទៅអនាគតឱ្យកាន់តែល្អប្រសើរឡើង។

តាំងនាមថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា **ឯកឧត្តម យិត ចាន់ដារដ្ឋ** សូមកោតសរសើរដ៏ស្មោះដល់លោកស្រីសុភ័ក្រកញ្ញា ដែលព្រមសហការជាមួយក្រុមការងារដោយសុធន្ទៈ និងជាគំរូដ៏ល្អគួរឱ្យគោរពចំពោះសណ្តានចិត្ត ក្នុងការប្រគល់ទីតាំងឱ្យអាជ្ញាធរជាតិអប្សរារៀបចំទីតាំងនេះឱ្យក្លាយជាទីលានបដិសណ្ឋារកិច្ចទេសចរណ៍កម្រិតអន្តរជាតិមួយ ដើម្បីសេចក្តីថ្កូវនិងភាពថ្កុំថ្កើងក្នុងរមណីយដ្ឋានអង្គរ។

អាជ្ញាធរជាតិអប្សរានឹងអនុវត្តការដោះស្រាយបញ្ហាប្រឈមនិងការរុះរើសំណង់ជាបណ្តើរៗទៅតាមដំណាក់កាល ដើម្បីរៀបចំសណ្តាប់ធ្នាប់ក្នុងបរិវេណមុខប្រាសាទអង្គរវត្តឱ្យមានមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចត្រឹមត្រូវនិងទេសភាពបរិស្ថានល្អ ដើម្បីលើកមុខមាត់ប្រទេសជាតិ និងរមណីយដ្ឋានអង្គរឱ្យស័ក្តិសមជាបេតិកភណ្ឌពិភពលោក និងដួងព្រលឹងរបស់ជនជាតិខ្មែរគ្រប់រូប៕

ឯកឧត្តមបន្តថា នៅចុងឆ្នាំ២០២០ មជ្ឈមណ្ឌលបដិសណ្ឋារកិច្ចទេសចរណ៍នឹងសាងសង់រួចរាល់ដោយរួមមានទាំងសាលពិព័រណ៍ មណ្ឌលបម្រើសេវាកម្មលំដាប់អន្តរជាតិ កន្លែងលក់ដូរក្នុងស្រុកដែលមានស្តង់ដាររួម និងចំណតយានយន្តល្អស្អាត។ រីឯនៅមុខអង្គរវត្តនឹងរៀបចំឱ្យមានភាពបៃតងដោយការដាំស្មៅនិងកូនឈើដើម្បីឱ្យបរិស្ថានស្អាត និងមានសារមន្ទីរលម្អមួយដែលតាំងដោយរូបចម្លាក់ផ្សេងៗ ដើម្បីឱ្យភ្ញៀវអាចដើរទស្សនាបានទាំងក្នុងនិងក្រៅប្រាសាទ ជំនួសដោយភាពកខ្វក់ និងភាពអនាធិបតេយ្យដែលមាននាពេលបច្ចុប្បន្ន៕

កំណាយស្រាវជ្រាវអំពីរចនាសម្ពន្ធផ្លូវបុរាណពីអង្គរទៅរលួស

ផ្សាយនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២០

ផ្លូវបុរាណមួយខ្សែដែលតភ្ជាប់រាជធានីពីរនៅសម័យអង្គរ គឺរាជធានីយសោធរ (អង្គរ) និងរាជធានីហរិហរាល័យ (រលួស) ស្ថិតនៅភូមិស្ពានក្អែក ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ត្រូវបានអាជ្ញាធរជាតិអប្សរាធ្វើកំណាយស្រាវជ្រាវចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្ដីទីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរបានឱ្យដឹងថា ការធ្វើកំណាយស្រាវជ្រាវរចនាសម្ពន្ធផ្លូវបុរាណពីតំបន់អង្គរទៅតំបន់រលួស គឺក្នុងគោលបំណងប្រៀបធៀបទៅនឹងរចនាសម្ពន្ធនៃផ្លូវបុរាណដទៃទៀតដែលស្ថិតនៅទីតាំងផ្សេង និងពិចារណាក្នុងការលើកគម្រោងអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីលើកតម្លៃកំណាត់ផ្លូវបុរាណនេះឡើងវិញឱ្យក្លាយជាបេតិកភណ្ឌរស់។

លោក រដ្ឋា បន្តថា ក្នុងការស្រាវជ្រាវឱ្យបានច្បាស់អំពីរចនាសម្ពន្ធផ្លូវបុរាណ ក្រុមការងារបានចុះសិក្សាសម្រង់ប្លង់ វាស់វែង និងបើករណ្ដៅកំណាយចំនួន៥ ដើម្បីដឹងពីបច្ចេកទេសនៃការសាងសង់ផ្លូវរបស់បុព្វបុរសខ្មែរ។

ជាលទ្ធផលស្រាវជ្រាវបង្ហាញថា ផ្លូវបុរាណនេះកសាងឡើងដោយការចាក់បង្ហាប់ដីមានបីស្រទាប់ គឺស្រទាប់ក្រោមប្រើល្បាយដីខ្សាច់ជាមួយដីឥដ្ឋ ស្រទាប់កណ្ដាលប្រើល្បាយកម្ទេចថ្មបាយក្រៀម ដីខ្សាច់ និងដីឥដ្ឋ និងស្រទាប់ខាងលើបង្អស់ជាល្បាយដីឥដ្ឋលាយជាមួយដីខ្សាច់ភាគច្រើន ។

ផ្លូវនេះមានទំហំសរុបចន្លោះពី៥៦ទៅ៦៦ម៉ែត្រ ដោយចែកជាទ្រូងផ្លូវទំហំ ពី៣០ទៅ៤០ម៉ែត្រ ជើងទេរ៣ម៉ែត្រសងខាង ប្រឡាយទឹកប្រវែងពី៧ទៅ១០ម៉ែត្រសងខាង និងកម្ពស់ផ្លូវពី១,២០ទៅ១,៥០ម៉ែត្រ។ ក្រៅពីលទ្ធផលបានពីកំណាយខាងលើ តាមរយៈការវាស់វែងលើទីតាំងផ្សេងៗគ្នានៅលើកំណាត់ផ្លូវបុរាណនេះឃើញថា ជាទូទៅផ្លូវមានទំហំសរុបចន្លោះពី៧០ ទៅ ១០០ម៉ែត្រ គិតទាំងប្រឡាយអមផ្លូវផង ដោយឡែកនៅជិតនឹងគល់ស្ពានតួផ្លូវមានទំហំរួមតូចចន្លោះពី៥៦ទៅ៦៦ម៉ែត្រ។

ក្រៅពីគំហើញនៃការធ្វើផ្លូវនៅតាមបណ្ដោយផ្លូវបុរាណនេះ ក៏មានស្ពានបុរាណចំនួនមួយ បើតាមឯកសារបញ្ជីសារពើភណ្ឌរបស់ក្រសួងវប្បធម៌និងវិចត្រសិល្បៈ (CISARK) ហៅថា «ស្ពានថ្ម»។ ស្ពាននេះមិនធ្លាប់ធ្វើកំណាយស្រាវជ្រាវ ឬជួសជុលនោះឡើយ មានតែការចុះបញ្ជីដោយលោក ETIENNE AYMONIER ឆ្នាំ១៩០០ លោក Lunet de la Jonquière ឆ្នាំ១៩១១ លោក Christophe pottier ឆ្នាំ១៩៩៩ និងចុងក្រោយចុះបញ្ជីដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយសាលាបារាំងចុងបូព៌ានៅឆ្នាំ១៩៩៥-២០០៧។ ស្ពានថ្មបាយក្រៀមនេះ មានប្រវែង២១ម៉ែត្រ ទទឹង៦ម៉ែត្រ រន្ធត្រដេវ (រន្ធបង្ហូរទឹក) ចំនួន៨ និងកម្ពស់២ម៉ែត្រ ស្ថិតក្នុងសភាពទ្រុឌទ្រោមជាខ្លាំង។

លោក សួម សុភា បុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរក៏បានបញ្ជាក់ថា ចំពោះសម័យកាលនៃការសាងសង់ស្ពានគឺមិនដឹងច្បាស់ទេ តែបើយោងតាមព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត ផ្លូវបុរាណមួយខ្សែនេះអាចធ្វើក្នុងសម័យកាល២។ ទី១សម័យព្រះបាទយសោវរ្ម័នទី១ ដែលព្រះអង្គបានគ្រោងរាជ្យនៅឆ្នាំ៨៨៩ដល់៩១០នៃគ.ស. ព្រះអង្គបានប្ដូររាជធានីពីរលួសទៅកសាងរាជធានីថ្មីនៅតំបន់អង្គរ ហៅថា «យសោធរ» ដែលមានភ្នំបាខែងជាចំណុចកណ្ដាល។ ក្រោយមកក្នុងឆ្នាំ៨៩៣ ព្រះអង្គក៏បានត្រឡប់មកកសាងប្រាសាទលលៃ ដើម្បីឧទ្ទិសដល់បុព្វការីជនរបស់ព្រះអង្គ។ ទី២ ប្រហែលជាកសាងបន្ថែមទៀតនៅសម័យព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានគ្រងរាជ្យនៅឆ្នាំ១១៨១ដល់១២១៨ នៃគ.ស ។ ផ្លូវនិងស្ពានបុរាណមួយនេះ គឺធ្វើឡើងដើម្បីធ្វើដំណើរឆ្លងកាត់សម្រាប់ភ្ជាប់ពីអង្គរទៅរលួស។ ស្ពាននេះជាសំណង់ធារាសាស្រ្តមួយស្ថិតនៅលើផ្លូវបុរាណប្រវែងប្រហែល១២គីឡូម៉ែត្រដែលនៅសល់ដល់បច្ចុប្បន្ន។ ស្ពាន គឺជាផ្នែកមួយនៃរចនាសម្ព័ន្ធផ្លូវបុរាណនីមួយៗ ដែលតែងតែមានប្រឡាយទឹកអមសងខាងផ្លូវ និងមានទីតាំងទួលមនុស្សរស់នៅ ស្រះទឹក ប្រាសាទ សាលាសំណាក់ មន្ទីរព្យាបាលរោគនៅតាមបណ្ដោយផ្លូវ។

ក្រោយពីកំណាយស្រាវជ្រាវឃើញរចនាសម្ពន្ធផ្លូវបុរាណ អាជ្ញាធរជាតិអប្សរា នឹងពិចារណាក្នុងការលើកគម្រោងអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយដោយចីរភាព ដើម្បីលើកតម្លៃកំណាត់ផ្លូវបុរាណនេះឡើងវិញ ឱ្យក្លាយជាបេតិកភណ្ឌរស់។ បន្ថែមពីនោះនឹងបន្តស្រាវជ្រាវកំណាត់ផ្លូវបុរាណដទៃទៀតដែលស្ថិតនៅក្រៅឧទ្យានអង្គរ ដើម្បីលើកតម្លៃផ្លូវ ស្ពានបុរាណ និងសំណង់បុរាណដែលនៅតាមបណ្ដោយផ្លូវឱ្យបានគង់វង្សសម្រាប់កូនចៅជំនាន់ក្រោយ៕

ក្រុមការងារកាត់ក្រីចុះកាត់ដើមឈើហានិភ័យនៅរមណីយដ្ឋានក្បាលស្ពាន

ផ្សាយនៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២០

ក្រុមការងារកាត់ក្រី នៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាព វប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា សហការជាមួយឆ្មាំ នគរបាលការពារបេតិកភណ្ឌ និងមន្ត្រីឧទ្យានុរក្សដែលប្រចាំការនៅរមណីយដ្ឋានក្បាលស្ពាន បានចុះកាត់ដើមឈើហានិភ័យមួយចំនួនដើម្បីសម្រួលការធ្វើដំណើរដល់ភ្ញៀវទេសចរ។

សកម្មភាពចុះកាត់ក្រីដែលធ្វើឡើងនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ បានចុះកាត់ក្រីនិងដកហូតដើមឈើមួយចំនួនរួមមាន ដើមខ្វិតងាប់៨ដើម ដើមរំដួលងាប់១ដើម ដើមផ្លូវងាប់មួយ១ ដើមក្លងងាប់៦ដើម ដើមត្រសេកងាប់៤ដើម ដើមស្រឡៅងាប់១ដើម ដើមប្រម៉ាស់ងាប់៨ដើម ដើមក្រឡាញ់ងាប់១ដើម និងដើមចង្កំស្វា១ដើម សរុបទាំងអស់៣១ដើម៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមអបអរការប្រារព្ធខួបទី៤១ឆ្នាំនៃថ្ងៃ០៧ មករា ១៩៧៩

ផ្សាយនៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០២០

មកដល់ពេលនេះ៤១ឆ្នាំហើយ (០៧ មករា ១៩៧៩-០៧ មករា ២០២០) ដែលប្រជាជនខ្មែរក្នុងព្រះរាជាណាចក្រកម្ពុជាបានទទួលសុខសន្តិភាព សេរីភាព ការអភិវឌ្ឍគ្រប់វិស័យ ដែលកើតចេញពីការបូជាសាច់ឈាមនិងអាយុជីវិតរបស់អតីតយុទ្ធជននៅលើសមរភូមិសង្គ្រាមនៃរបបយង់ឃ្នង៣ឆ្នាំ ៨ខែ ២០ថ្ងៃ។

ជាសក្ខីភាពនៃសុខសន្តិភាពនិងការរស់រានជាថ្មី នៅព្រឹកថ្ងៃទី០៧ មករា ២០២០ នេះដែរ ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារ ចូលរួមសម្តែងសេចក្តីគោរពដើម្បីរំឭកដល់វិញ្ញាណក្ខន្ធរបស់វីរៈយុទ្ធជនខ្មែរដែលបានពលីជីវិតដើម្បីបម្រើឱ្យបុព្វហេតុជាតិ មាតុភូមិ និងអាយុជីវិតរបស់មនុស្សខ្មែរគ្រប់រូប ដែលប្រារព្ធឡើងក្រោមអធិបតីភាពសម្តេចពិជ័យសេនា ទៀ បាញ់ ថ្នាក់ដឹកនាំខេត្តសៀមរាប និងប្រជាជនជាច្រើននាក់នៅវិមានដំណាក់។

កូនចៅខ្មែរមិនភ្លេចឡើយចំពោះគុណូបការៈរបស់បុព្វបុរសដែលបានបូជាជីវិតជូនជាតិនិងប្រជាជន ឱ្យបានស្គាល់សុខសន្តិភាពរហូតដល់សព្វថ្ងៃនេះ។ ជាក់ស្តែង ៤១ឆ្នាំដែលកើតចេញពីថ្ងៃ០៧ មករា ១៩៧៩ នាំឱ្យមានសុខសន្តិភាពនិងការអភិវឌ្ឍគ្រប់វ័យ។ ក្នុងនោះតំបន់អង្គរក៏បានទទួលនូវការអភិរក្សនិងការបណ្តុះបណ្តាលធនធានមនុស្ស កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការសង្គ្រោះអង្គរឱ្យរួចផុតពីហានិភ័យផងដែរ។

សូមឧទ្ទិសឱ្យថ្ងៃ០៧ មករា ជាថ្ងៃចងចាំពីការរស់រានជាថ្មីរបស់ជនជាតិខ្មែរ និងជាថ្ងៃដឹងគុណដល់វីរៈយុទ្ធជនដែលបានលះបង់ជីវិតសង្គ្រោះជាតិឱ្យផុតពីភ្លើងសង្គ្រាម ព្រមទាំងជាថ្ងៃដែលនាំមកនូវសន្តិភាព ការអភិវឌ្ឍ និងអភិរក្សដល់ប្រទេសជាតិ ប្រជាជនខ្មែរ និងតំបន់អង្គរឱ្យកាន់តែប្រសើរឡើង៕

តំណាងអង្គការ JICA ស្វែងរកការគាំទ្រពីអាជ្ញាធរជាតិអប្សរាក្នុងគម្រោង Smart Cities

ផ្សាយនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៨ ខែមករា ឆ្នាំ២០២០ តំណាងអង្គការ JICA ប្រចាំកម្ពុជា បានជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា។ក្នុងជំនួបដ៏មានសារសំខាន់នោះ លោក តាណាកា កូតារ៉ុ អនុប្រធាន JICA បានបង្ហាញពីគម្រោងរៀបចំ Smart Cities (ទីក្រុងឆ្លាតវៃ) អាស៊ាន-ជប៉ុន ដែលរាជរដ្ឋាភិបាលជប៉ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ២០១៩ ដោយគម្រោងនេះត្រូវអភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តរភាពដោយភ្ជាប់ជាមួយនឹងបច្ចេកវិទ្យា ICT គឺសំដៅដល់ការផ្តល់លទ្ធភាពប្រើប្រាស់ព័ត៌មានដោយប្រើមធ្យោបាយទូរគមនាគមន៍ ដើម្បីដោះស្រាយបញ្ហាមួយចំនួនដូចជា លំនៅដ្ឋានប្រជាជន ការកកស្ទះចរាចរណ៍ និងបរិស្ថាន។ គម្រោងទីក្រុងឆ្លាតវៃដែលអាស៊ានបានជ្រើសរើសនេះរួមមាន ភ្នំពេញ សៀមរាប និងបាត់ដំបង។

បន្ថែមពីនេះ លោក តាណាកា កូតារ៉ុ ក៏បានសុំយោបល់ពីអាជ្ញាធរជាតិអប្សរាលើគោលការណ៍រៀបចំឯកសារផ្សព្វផ្សាយកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងស្ថាប័នជប៉ុនដែលកំពុងចូលរួមកិច្ចការអភិរក្សក្នុងរមណីយដ្ឋានអង្គរ។ ជប៉ុនចង់បង្កើតកម្មវិធីក្នុងទូរសព្ទដៃ និងដាក់បញ្ចូលព័ត៌មានលើការងារនានា ដើម្បីឱ្យមានការផ្សព្វផ្សាយកាន់តែទូលំទូលាយមួយកម្រិតទៀត។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានស្វាគមន៍ និងកោតសរសើរចំពោះគម្រោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការJICA។ ឯកឧត្តមអគ្គនាយកយល់ថា នេះជាកិច្ចការដែលអាជ្ញាធរជាតិអប្សរាចង់បាននាពេលអនាគតដូចជារៀបចំ Smart Cities រួមនិងការចង់ក្រងឯកសារនានាពីកិច្ចការអភិរក្សជាដើម។ឯកឧត្តមអគ្គនាយក ជំរុញឱ្យភាគីទាំងពីរធ្វើការជាមួយគ្នា ដើម្បីឱ្យគម្រោងនេះពន្លឿនការអនុវត្តនាពេលឆាប់ខាងមុខ៕

ការងាររៀបចំសោភណភាពនៅមុខប្រាសាទព្រះពិធូរនឹងជួយលើកកម្ពស់តម្លៃបេតិកភណ្ឌ និងជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២០

ដើម្បីរក្សាសោភណភាពប្រាសាទ និង ឆ្លើយតបនឹងអនុសាសន៍របស់គណៈកម្មាធិការICC-Angkor អាជ្ញាធរជាតិអប្សរាកំពុងរៀបចំសោភណភាពចំណត និងតូបលក់ដូរឡើងវិញនៅមុខប្រាសាទព្រះពិធូរ ក្នុងបរិវេណប្រាសាទអង្គរធំ។ ការងារនេះរៀបចំឡើងដោយគិតគូរទៅលើការលើកកម្ពស់បរិស្ថាន និងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនក្នុងតំបន់អង្គរ។

នារសៀលថ្ងៃទី៩ ខែមករា ឆ្នាំ២០២០ នេះ **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា និងជាប្រធានក្រុមការងារអនុវត្តគម្រោងនេះ បានដឹកនាំក្រុមការងារដើម្បីចុះពិនិត្យទីតាំងជាក់ស្តែងនៅបរិវេណក្រុមប្រាសាទព្រះពិធូរ បន្ទាប់ពីក្រុមការងាបានរៀបចំប្លង់រួចរាល់។

មានប្រសាសន៍ក្នុងឱកាសនេះ ឯកឧត្តម បញ្ជាក់ថា ការរៀបចំសោភណភាពចំណត និងតូបលក់ដូរនេះក្រុមការងារបានគិតគូរលើបរិស្ថាន និងបុរាណវិទ្យាជាសំខាន់។ ជាក់ស្តែង ការរៀបចំប្លង់នេះត្រូវធ្វើឡើងដោយផ្អែកលើការចុះអង្កេតជាក់ស្តែងរបស់ក្រុមការងារគ្រប់គ្រងព្រៃឈើ និងបរិស្ថាន និងការធ្វើកំណាយបុរាណវិទ្យា។

ឯកឧត្តមបន្ថែមថា ការចុះពិនិត្យលើកនេះ គឺដើម្បីកែសម្រួលនូវគំរូប្លង់មួយចំនួន តាមការណែនាំរបស់លោកជំទាវរដ្ឋមន្ត្រី នាជំនួបពិភាក្សាកន្លងទៅថ្មីៗនេះ។ឯកឧត្តមសង្ឃឹមថា មិនយូរទេ ក្រោយគម្រោងនេះត្រូវបានអនុវត្តហើយ ភ្ញៀវទេសចរនឹងបានឃើញ ទិដ្ឋភាពដ៏ស្រស់ត្រកាលនៃប្រាសាទព្រះពិធូរដែលកន្លងមកភ្ញៀវទេសចរជាច្រើនបានដើរលេង៕

វាលស្មៅប្រាសាទអង្គរនឹងមានភាពបៃតងទាំងខួបប្រាំងខួបវស្សាក្នុងឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០

ដើម្បីលើកកម្ពស់សោភ័ណភាព ភាពស្រស់ស្រាយ ទេសភាពបៃតង និងបរិស្ថានល្អក្នុងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបាន និងកំពុងយកចិត្តទុកដាក់កែលម្អបរិស្ថាននៅជុំវិញបរិវេណប្រាសាទអង្គរវត្តដោយចាប់ផ្តើមពីការដាំស្មៅ ដាំកូនឈើ ដាំផ្កាព្រៃ ជួសជុលផ្លូវ និងប្រព័ន្ធរំដោះទឹក ព្រមទាំងរៀបចំប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិវាលស្មៅទាំងខួបប្រាំងខួបវស្សា។

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា លោក ឡុង កុសល បានបង្ហាញពីមោទនភាពចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរានាពេលកន្លងមកក្នុងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់សោភ័ណភាពនិងទេសភាពបៃតង និងផែនការអនាគតរបស់អាជ្ញាធរជាតិអប្សរាដើម្បីបន្តរៀបចំសោភ័ណភាពបរិស្ថាន ទាំងក្នុងនិងក្រៅបរិវេណប្រាសាទអង្គរវត្ត។ ជាក់ស្តែង ក្រុមការងារកំពុងតែបានធ្វើការដកហូតដើមឈើ និងកាត់ក្រីមែកឈើដែលប៉ះពាល់ដល់ទេសភាពប្រាសាទជាទីគយគន់ របស់ភ្ញៀវទេសចរ រៀបចំបង្កើនទេសភាពបៃតងនៅខាងត្បូងប្រាសាទអង្គរវត្ត ការបញ្ចូលទឹកក្នុងស្រះខាងត្បូង។ល។ ដូច្នេះអ្វីដែលអាជ្ញាធរជាតិអប្សរាកំពុងតែអនុវត្តន៍ និងផែនការអនាគតគឺសំដៅលើកកម្ពស់សោភ័ណភាព ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងបង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរ មិនត្រឹមតែប្រាសាទអង្គរវត្តនោះទេតែរមណីយដ្ឋានអង្គរទាំងមូល។

ដោយឡែក អំពីការរៀបចំប្រព័ន្ធស្រោចស្រពវាលស្មៅក្នុងបរិវេណប្រាសាទអង្គរវត្តវិញអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរាបានបញ្ជាក់ថា អាជ្ញាធរជាតិអប្សរានឹងរៀបចំប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិដែលនឹងធ្វើការស្រោចស្មៅឲ្យមានភាពបៃតងទាំងខួបប្រាំងខួបវស្សា ហើយកិច្ចការនេះនឹងត្រូវអនុវត្តន៍ឱ្យរួចរាល់នៅក្នុងឆ្នាំ២០២០។ លើសពីនេះទៀត អាជ្ញាធរជាតិអប្សរារៀបចំឲ្យមានមណ្ឌលបដិសណ្ឋារកិច្ចសម្រាប់ភ្ញៀវទេសចរ ការរៀបចំចំណតត្រឹមត្រូវ ពិសេសរៀបចំសន្តិសុខសណ្តាប់ធ្នាប់ និងការដាំកូនឈើឡើងវិញកែលម្អបរិស្ថាននៅទីនោះឱ្យស័ក្តិសមជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក៕

រូបភាពបច្ចុប្បន្ន

HYUNDAI

និស្សិតស្ថាបត្យកម្មបង្ហាញការប្រកួតប្រជែងស្ថាបត្យកម្ម កែលម្អកំណាត់ផ្លូវសម្តេចវិបុលបញ្ញា សុខ អាន

ផ្សាយនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០

កំណាត់ផ្លូវសម្តេចវិបុលបញ្ញា សុខ អាន (ផ្លូវ៦០ម៉ែត្រ) នឹងត្រូវធ្វើការកែលម្អដោយមានការចូលរួមប្រកួតប្រជែងស្នាដៃរបស់និស្សិតមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាកលវិទ្យាល័យន័រតុន សាកលវិទ្យាល័យវេស្ទើន សាកលវិទ្យាល័យបញ្ញាសាស្ត្រ វិទ្យាស្ថានបច្ចេកទេសកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស នៃរាជធានីភ្នំពេញ។ តាមរយៈការកែលម្អនេះ កំណាត់ផ្លូវសម្តេចវិបុលបញ្ញា សុខ អាន នឹងមានសួនច្បារ ផ្លូវដើរ ផ្លូវកង់ ចិញ្ចើមថ្នល់ស្អាត ដាំដើមឈើបន្ថែម និងធ្វើឱ្យប្រឡាយសងខាងផ្លូវមានទឹកជាប្រចាំ។

ជាក់ស្តែងការប្រកួតប្រជែងនេះមាននិស្សិតផ្នែកស្ថាបត្យកម្មសរុប៤៥នាក់ ចែកជា៩ក្រុម បានធ្វើបទបង្ហាញនូវគំនិតនិងទស្សនៈអំពីគម្រោងកែលម្អកំណាត់ផ្លូវសម្តេចវិបុលបញ្ញា សុខ អាន នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។



ជ័យលាភីដែលទទួលបានលេខមួយនឹងទទួលបានការឧបត្ថម្ភប្រាក់លើកទឹកចិត្តចំនួន ៤,០០០,០០០ រៀល លេខ២ចំនួន១,០០០,០០០ រៀល និងលេខ៣ទឹកប្រាក់ ៥០០,០០០រៀល។បេតិកភណ្ឌពិភពលោក៕

គណៈប្រតិភូរមណីយដ្ឋានហ័ងសានបំពេញទស្សនកិច្ចក្នុងរមណីយដ្ឋានអង្គរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌និងទេសចរណ៍

ផ្សាយនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០២០

ឯកឧត្តម សុខ សង្វារ អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយក អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឲ្យគណៈប្រតិភូរមណីយដ្ឋានហ័ងសាន ខេត្តអានហ៊ុយ នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយ លោក Zhao Ming ប្រធានការិយាល័យកិច្ចការបរទេស ចូលជួបសម្តែងការគួរសម និងពិភាក្សាពីកិច្ចការងារ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ និងទេសចរណ៍ឲ្យកាន់តែប្រសើរជាងមុន ហើយបន្តការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងរមណីយដ្ឋានអង្គរ និងហ័ងសាន នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ។

ក្នុងជំនួបពិភាក្សានេះ **ឯកឧត្តម សុខ សង្វារ** មានប្រសាសន៍ថា កន្លងមកអាជ្ញាធរជាតិអប្សរានិងគណៈប្រតិភូហ័ងសាន បានធ្វើកិច្ចសហប្រតិបត្តិការរវាងរមណីយដ្ឋានអង្គរនិងហ័ងសាន ដោយមានការធ្វើការតាំងពិព័រណ៍រមណីយដ្ឋានហ័ងសាននៅប្រាសាទបន្ទាយស្រី និងបានធ្វើការតាំងពិព័រណ៍រមណីយដ្ឋានអង្គរនៅហ័ងសាន ខេត្តអានហ៊ុយ ប្រទេសចិន។ ឯកឧត្តម បានលើកផងដែរអំពីការពង្រីកនូវការផ្សព្វផ្សាយតំបន់បេតិកភណ្ឌទាំងពីរ ឲ្យបានជ្រួតជ្រាបដល់ពិភពលោក និងធ្វើឲ្យតំបន់បេតិកភណ្ឌទាំងនោះកាន់តែជិតស្និទ្ធនឹងគ្នាថែមទៀត។

លោក Zhao Ming ប្រធានការិយាល័យកិច្ចការបរទេស បានលើកសរសើរនូវភាពអស្ចារ្យនៃ រមណីយដ្ឋានអង្គរ និងកិច្ចការអភិរក្សរបស់អាជ្ញាធរជាតិអប្សរា។ ហើយជាពិសេសទៅទៀតលោកថ្លែងថា លោកនឹងផ្សព្វផ្សាយរមណីយដ្ឋានអង្គរនៅរមណីយដ្ឋានហ័ងសាន និងតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសចិនតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទាក់ទាញទេសចរឲ្យមក ទស្សនាអង្គរ។

ជំនួបលើកនេះជាកិច្ចពិភាក្សាបន្ថែមទៀត ដើម្បីឈានទៅដល់ការបន្តចុះអនុស្សរណៈនៃការយោគយល់គ្នារវាងថ្នាក់ដឹកនាំស្ថាប័នទាំងពីរនាពេលខាងមុខ៕

យុទ្ធសាស្ត្រគន្លឹះសំខាន់ៗដែលនាំឲ្យការគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរ ទទួលបានការជោគជ័យ

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២០

នៅឆ្នាំ២០២០នេះ គឺមានរយៈពេល២៥ឆ្នាំហើយ ដែលអាជ្ញាធរជាតិអប្សរាត្រូវបានបង្កើតឡើង។ សមិទ្ធផលជាច្រើនកើតចេញពីការខិតខំប្រឹងប្រែង របស់អាជ្ញាធរជាតិអប្សរា ធ្វើឱ្យរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ទទួលបានការកោតសរសើរពីសំណាក់បណ្តាប្រទេសជាមិត្ត និងស្ថាប័នអន្តរជាតិជាច្រើនមានដូចជាអង្គការយូណេស្កូ គណៈកម្មាធិការបេតិកភណ្ឌពិភពលោក គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ។

កសិន្ធុទឹកប្រាសាទអង្គរវត្ត

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា លោក ឡុង កុសល លើកឡើងថា រហូតមកដល់បច្ចុប្បន្នដោយអ្នកជំនាញជាតិកាន់តែមានសមត្ថភាពខ្ពស់ដូច្នេះអាជ្ញាធរជាតិអប្សរាមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីទ្រទ្រង់កិច្ចការអភិរក្ស និងជួសជុលប្រាសាទ។បន្ថែមលើនេះកិច្ចការគ្រប់គ្រងទឹកដែលជាភារកិច្ចសំខាន់ដែរនោះក៏ទទួលបានភាពជោគជ័យជាច្រើនផងដែរ។ចាប់ពីឆ្នាំ២០០៤មកអាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមសិក្សាពីរចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រសម័យបុរាណ និងឈានដល់ការស្តារឡើងវិញ។ ជាក់ស្តែងក្នុងឆ្នាំ២០០៨អាជ្ញាធរជាតិអប្សរា បានស្តារប្រព័ន្ធបង្ហូរទឹកដែលមានប្រភពពីភ្នំគូលែនចូលទៅក្នុងបារាយណ៍ជ័យតដាក ឬបារាណយ៍ខាងជើង ដែលបារាយណ៍នេះបានគោកគ្មានទឹកអស់រយៈកាលជាង៥០០ឆ្នាំមកហើយ។

បារាយណ៍ជ័យតដាក

លោក ឡុង កុសល បានបន្ថែមថា ចំណុចនេះគឺមានសារសំខាន់ណាស់ដែលអាជ្ញាធរជាតិអប្សរាប្រឹងប្រែងធ្វើឱ្យប្រព័ន្ធធារាសាស្ត្រសម័យបុរាណមានជីវិតឡើងវិញ ដើម្បីកិច្ចអភិរក្សប្រាសាទ ក៏ដូចជាសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពផលកសិកម្មរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរាក៏បានស្តារកសិន្ធុសំខាន់ៗក្នុងតំបន់រមណីយដ្ឋានអង្គរ រួមមានកសិន្ធុប្រាសាទព្រះខ័ន កសិន្ធុប្រាសាទអង្គរវត្ត និងកសិន្ធុក្រុងអង្គរធំ ដែលពីមុនទីតាំងទាំងនោះមានទឹកតែក្នុងរដូវវស្សាតែប៉ុណ្ណោះ។

លើសពីនេះទៅទៀត អាជ្ញាធរជាតិអប្សរាបានស្តារប្រព័ន្ធធារាសាស្ត្របុរាណសរុបប្រមាណ៥២គីឡូម៉ែត្រ។ តាមរយៈការដំណើរការឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណនេះ ទោះបីជាក្នុងរដូវប្រាំងយ៉ាងណាក្តីរមណីយដ្ឋានអង្គរនៅតែមានទឹកបរិបូរណ៍។ បច្ចុប្បន្ន ទាំងបារាយណ៍និងកសិន្ធុប្រាសាទទាំងអស់អាចផ្ទុកទឹកក្នុងកម្រឹតអតិបរមាជាង១០០លានម៉ែត្រគូប ។ ក្រៅពីប្រើប្រាស់លើការ-អភិរក្សប្រាសាទហើយនោះ អាជ្ញាធរជាតិអប្សរាក៏បានបញ្ជូនចែកចាយទឹកពីបារាយណ៍ទឹកថ្លា ដល់ស្រែប្រជាពលរដ្ឋលើផ្ទៃដី ៧,៥០០ហិកតា ការបង្កបង្កើនផលដំណាំផ្សេងៗរបស់ប្រជាពលរដ្ឋ ក៏ដូចជាចែកចាយដល់រដ្ឋាករទឹកស្អាតដើម្បីផលិតទឹកស្អាតផ្គត់ផ្គង់ការប្រើប្រាស់ប្រចាំថ្ងៃដល់ពលរដ្ឋក្នុងក្រុងសៀមរាបមួយកម្រិតទៀត។

បន្ទាប់ពីជោគជ័យលើការគ្រប់គ្រងទឹកទាំងនេះ តាមការបញ្ជាក់ពីលោក ឡុង កុសល ក្នុងនោះអាជ្ញាធរជាតិក៏មានគោលការណ៍ស្តាររចនាសម្ព័ន្ធធារាសាស្ត្របុរាណផ្សេងទៀតដែលបច្ចុប្បន្នគោករីងទឹកអស់ឲ្យដំណើរការឡើងវិញ ដើម្បីជាប្រយោជន៍អភិរក្សប្រព័ន្ធធារាសាស្ត្របុរាណផង និងជាប្រភពទឹកប្រើប្រាស់សម្រាប់មនុស្សបច្ចុប្បន្នផង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យតាមដានការងាររៀបចំសណ្តាប់ធ្នាប់ នៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំប្រធាននាយកដ្ឋាន មន្ត្រី-បុគ្គលិកជំនាញពាក់ព័ន្ធ ចុះពិនិត្យមើលទីតាំងជុំវិញប្រាសាទអង្គរវត្ត ដើម្បីរៀបចំកែលម្អសណ្តាប់ធ្នាប់ឱ្យកាន់តែប្រសើរឡើង។

ក្នុងការចុះពិនិត្យទីតាំងផ្ទាល់នេះ **ឯកឧត្តម ហង់ ពៅ** បានផ្តល់ជាអនុសាសន៍ឱ្យរុះរើរោងផ្ទាំដែលមិនចាំបាច់ និងកែប្រែទីតាំងនេះសម្រាប់ដាំស្មៅ និងដាំដើមឈើ ដោយកែប្រែរោងអភិរក្សអង្គរវត្តខាងត្បូង រៀបចំឱ្យមានសណ្តាប់ធ្នាប់ ហើយមួយផ្នែកនៃរោងអភិរក្សរៀបចំជាទីស្នាក់ការបុគ្គលិកឆ្មាំ ភ្នាក់ងារទេសចរណ៍វិញ។

សូមបញ្ជាក់ថា ក្រៅពីកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ដោយចីរភាព ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ រៀបចំ កែលម្អ និងស្វែងរកដំណោះស្រាយរួមសំដៅធ្វើយ៉ាងណា ប្រែក្លាយរមណីយដ្ឋានអង្គរឱ្យមានភាពល្អប្រសើរឡើងជាបន្តបន្ទាប់៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលរួមពិធីបំពាក់មេដាយជូនវង្វាន់ជ័យលាភី ការប្រកួតកីឡារត់ចម្ងាយឆ្ងាយឆ្លងឧបសគ្គ Angkor Ultra Trial លើកទី៥

ផ្សាយនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០នេះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចូលរួមពិធីបំពាក់មេដាយជូនរង្វាន់ដល់ជ័យលាភីការប្រកួតកីឡារត់ប្រណាំងចម្ងាយឆ្ងាយនៅតំបន់អង្គរ Angkor Ultra Trial លើកទី៥។ កីឡានេះ អ្នកចូលរួមត្រូវរត់ឆ្លងកាត់ឧបសគ្គ ព្រៃប្រឹក្សា ប្រាង្គប្រាសាទ ភូមិ-ឃុំអ្នកស្រុក និងវាលស្រែមួយចំនួន។

វត្តមានជាអធិបតីភាពក្នុងពិធីនេះ មានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ **ឯកឧត្តម ថោង ខុន**, **លោកជំទាវ អេវ៉ា ឡេវ ម៉ិញ** ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា, **ឯកឧត្តម ពៅ ពិសិដ្ឋ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប, **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំមួយចំនួនទៀត។

ទិវារត់ប្រណាំងចម្ងាយឆ្ងាយ Angkor Ultra Trail 2020 គឺមានវិញ្ញាសាប្រកួតដូចជា រត់១២៨គីឡូម៉ែត្រ, ៦៤គីឡូម៉ែត្រ, ៤២គីឡូម៉ែត្រ, ៣២គីឡូម៉ែត្រ និង ១៦គីឡូម៉ែត្រ ដោយមានអ្នកចូលរួមសរុប ១,២៥៥នាក់ មកពី ៤៥ប្រទេស ។ ចំពោះវិញ្ញាសារត់ចម្ងាយ ១២៨គីឡូម៉ែត្រ ត្រូវចំណាយពេលរត់ប្រមាណ ២៤ម៉ោង ដោយគ្រោងបញ្ចប់នៅថ្ងៃទី១៩ ខែមករាស្អែក៕

អាជ្ញាធរជាតិអប្សរាមានសុទិដ្ឋិនិយមអំពីកំណើននៃទេសចរណ៍កីឡា

ផ្សាយនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២០

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា បានបង្ហាញនូវសុទិដ្ឋិនិយមខ្ពស់ចំពោះកំណើនទេសចរណ៍កីឡា ក្នុងការរៀបចំព្រឹត្តិការណ៍កីឡានិងទេសចរណ៍ផ្សេងៗរបស់ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដែលជះឥទ្ធិពលវិជ្ជមានដល់វិស័យទេសចរណ៍ជាតិ ពិសេសខេត្តសៀមរាប ដើម្បីរួមចំណែកស្រូបទាញកំណើនទេសចរណ៍ឡើងវិញ ។

ការអះអាងបែបនេះ បានធ្វើឡើងក្នុងពិធីប្រគល់មេដាយជ័យលាភីដល់កីឡាករ-កីឡាការិនី រត់ចម្ងាយ ៣២គីឡូម៉ែត្រ និង ១៦គីឡូម៉ែត្រ នៃទិវារត់ប្រណាំងចម្ងាយឆ្ងាយនៅរមណីយដ្ឋានអង្គរ Angkor Ultra Trial លើកទី៥ នៅរសៀល ថ្ងៃទី១៨ ខែមករានេះ ក្រោមវត្តមាន **ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ហើយក៏មានការចូលរួមពី **ឯកឧត្តម ពៅ ពិសិដ្ឋ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប និងឯកអគ្គរដ្ឋទូតស្ថានទូតបារាំងប្រចាំកម្ពុជា ។

ឯកឧត្តម បានបញ្ជាក់ថាព្រឹត្តិការណ៍ទេសចរណ៍កីឡាពិតជាមានការទាក់ទាញ ពិសេសតំបន់អង្គរ គឺជាដែកឆក់មួយដើម្បីទាក់ទាញទេសចរណ៍អន្តរជាតិ ។ ដូច្នេះការយករមណីយដ្ឋានអង្គរជាកន្លែងរៀបចំព្រឹត្តិការណ៍ទេសចរណ៍កីឡាពិតជាទាញផលចំណេញពីការចូលរួម ដ្បិតវត្តមានរបស់អ្នកកីឡាទាំងនោះ ត្រូវចំណាយទាំងពេលវេលា និងធនធានច្រើននៅកម្ពុជា ។

ឯកឧត្តម បន្តថា «ខ្ញុំគិតថា ការកើនឡើង អ្នកចូលរួមលក្ខណៈកីឡានេះនឹងក្លាយជាផលល្អសម្រាប់ទេសចរណ៍ស្រុកយើង ។ ទន្ទឹមជាមួយគ្នា ដើម្បីចូលរួមទាក់ទាញទេសចរណ៍មកស្រុកខ្មែរឲ្យច្រើនជាងមុន អាជ្ញាធរអប្សរារបស់យើង ក៏បានរៀបចំហេដ្ឋារចនាសម្ព័ន្ធច្រើនដែរ ដាក់ស្តែងផែនការឆ្នាំ២០២០ មានការស្តាបនាផ្លូវនិងការធ្វើតំបន់មុខអង្គរវត្តឲ្យបៃតង រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនធំទៀត បន្ទាប់ពីមានផែនការ៤ឆ្នាំកន្លងទៅ ហើយឆ្នាំនេះ យើងនឹងសម្រេចលទ្ធផលឲ្យបាន ដើម្បីស្រូបទាញភ្ញៀវទេសចរបរទេសឲ្យបានច្រើនឡើងវិញ» ។

គួរបញ្ជាក់ថាគិតត្រឹមថ្ងៃទី១៨ខែមករានេះវិញ្ញាសាចំនួន៤បានបញ្ចប់ហើយរួមមានវិញ្ញាសារត់ចម្ងាយ៦៤គីឡូម៉ែត្រ, ៤២គីឡូម៉ែត្រ, ៣២គីឡូម៉ែត្រ និង ១៦គីឡូម៉ែត្រ ។ នៅឡើយតែវិញ្ញាសារត់ចម្ងាយឆ្ងាយ ១២៨គីឡូម៉ែត្រដែលត្រូវបន្តរត់ រហូតដល់រសៀលថ្ងៃទី១៩ ខែមករាស្អែក បន្ទាប់ពីពួកគេ បានចេញដំណើរពីទីលានប្រជល់ដំរីកាលពីវេលាម៉ោង ៤ទាបភ្លឺនៅព្រឹកថ្ងៃសៅរ៍នេះ៕

FINISH
WELCOME TO Angkor
FINISH

FINISH
WELCOME TO Angkor
FINISH

កំណាយស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុករកឃើញគ្រឹះប្រាសាទ សម្ភារប្រើប្រាស់ និងការតាំងទីរបស់មនុស្សជាង១០០០ឆ្នាំ

ផ្សាយនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២០

អ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាសហការជាមួយសាកលវិទ្យាល័យហាវ៉ៃសហរដ្ឋអាមេរិកធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុក ដែលមានទីតាំងស្ថិតនៅខាងលិចប្រាសាទវត្តអធ្វា ស្ថិតក្នុងភូមិទ្រាក សង្កាត់/ខេត្តសៀមរាប កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ នឹងបញ្ចប់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

លោក ទិន ទីណា អនុប្រធានមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា បញ្ជាក់ថា ការស្រាវជ្រាវធ្វើឡើងដើម្បីស្វែងរកភូមិបុរាណ ទីសក្ការៈបូជានិងសម្ភារប្រើប្រាស់នានា ដែលស្ថិតនៅក្រៅរាជធានីអង្គរ ពិសេសនៅជុំវិញខេត្តសៀមរាប។ គំហើញថ្មីៗ នេះជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវ ការយល់ដឹងពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រខ្មែរពីអតីតកាលដល់បច្ចុប្បន្ន ព្រមទាំងរួមចំណែកការពារបុរាណដ្ឋានលើតំបន់ដែលកំពុងអភិវឌ្ឍន៍។

លោក ហេង ពិភាល់ បណ្ឌិតបុរាណវិទ្យានៃសាកលវិទ្យាល័យហាវ៉ៃ និងជាប្រធានគម្រោងស្រាវជ្រាវបានឱ្យដឹងថា ក្រុមការងារបានធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យាចំនួន៥រណ្តៅ ទំហំ១គុណ២ម៉ែត្រ នៅលើទួលដូនប៉ុកផងនិងនៅលើគោកមនុស្សរស់នៅក្បែរទួលនេះផង។ជាលទ្ធផលរណ្តៅកំណាយនៅទួលដូនប៉ុកបានរកឃើញគ្រឹះប្រាសាទធ្វើពីថ្មបាយក្រៀមពីខាងក្រោមនិងឥដ្ឋនៅពីខាងលើដែលកប់ក្នុងដីជម្រៅជាង១ម៉ែត្រ ដែលមានសសរពេជ្រពណ៌ផ្កាឈូក២កំណាត់ និងគំនរថ្មភក់នៅក្នុងខ្ទមអ្នកតា។ តាមការសន្និដ្ឋាន ប្រាសាទគោកដូនប៉ុកបានកសាងឡើងក្នុងស.វ.ទី១០ មានអាយុប្រហាក់ប្រហែលទៅនឹងប្រាសាទបន្ទាយស្រី និងប្រាសាទព្រះឥន្ទ្រកោសីយ៍ដែលជាទីសក្ការៈរបស់មនុស្សនាសម័យនោះ។

លោកបណ្ឌិតបុរាណវិទ្យារូបនេះបន្តថា តាមរយៈលទ្ធផលកំណាយ ប្រាសាទឥដ្ឋនេះដួលរលំនៅរវាងស.វ.ទី១២ ឬ១៣ និងលែងជាកន្លែងប្រារព្ធពិធីសាសនាធំដុំទៀតហើយ ពោលគឺនៅត្រឹមតែជាគោកអ្នកតាប៉ុណ្ណោះ។ ការផ្លាស់ប្តូរនេះ ប្រហែលជួនគ្នានឹងការកសាងវត្តអធ្វានាស.វ.ទី១២ឬទី១៣ដែរ ដោយមនុស្សបានប្តូរទៅគោរពបូជានៅវត្តអធ្វាវិញ។ ក្រៅពីនោះ ទាំងក្នុងរណ្តៅនៅទួលដូនប៉ុកនិងគោកភូមិ ក៏ឃើញមានបំណែកកុលាលភាជន៍ចិនពីស.វ.ទី១២ដល់ទី១៧ និងភាជន៍ខ្មែរផលិតនៅតំបន់នគររាជភ្នំគូលែន និងជើងឯកនៅស.វ.ទី១០ និង១៣ មានភាជន៍ផុយ ភាជន៍រឹងមានស្រទាប់រលោង និងគ្មានស្រទាប់រលោង រួមទាំងរបស់ប្រើប្រាស់ផ្សេងៗ។

ទាំងនេះបញ្ជាក់ថា ទីតាំងដែលពួកគាត់រស់នៅសព្វថ្ងៃ (ទួលដូនប៉ុក) ជាភូមិចាស់តពីដូនតានិងមានមនុស្សរស់នៅតគ្នាជាង១០០០ឆ្នាំមកហើយ ពោលគឺតាំងពីស.វ.ទី១០ដែលមានសំណង់ប្រាសាទឥដ្ឋចំនួន១ និងមានគោកភូមិនៅជុំវិញប្រាសាទចំនួន៦។ ចំណែកបំណែកកុលាលភាជន៍បង្ហាញឱ្យដឹងថា វត្តមានមនុស្សរស់នៅទួលដូនប៉ុកមានយ៉ាងតិចដល់ស.វ.ទី១៨។

លោក វិទូ ភិរម្យ បុរាណវិទូនៃមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា តាមរយៈលទ្ធផលកំណាយនៅទួលដូនប៉ុក គឺបានបង្ហាញភស្តុតាងជាច្រើនទាក់ទងនឹងការរៀបចំភូមិករបស់មនុស្សសម័យបុរាណនៅភាគខាងត្បូងអង្គរ ដែលប្រាសាទគឺជាមជ្ឈមណ្ឌលសំខាន់នៃសហគមន៍មួយ។ ប្រាសាទមានមនុស្សថែរក្សា និងរស់នៅជុំវិញ មានការប្រើប្រាស់សម្ភារផ្សេងៗដែលបម្រើឱ្យជីវភាពប្រចាំថ្ងៃ និងកិច្ចបូជា។ រីឯបំណែកកុលាលភាជន៍អាចឱ្យយើងស្វែងយល់ពីសេដ្ឋកិច្ចនិងការរស់នៅរបស់មនុស្សពីសម័យបុរាណ។ លើសពីនេះ យើងបានដឹងពីចលនាពាណិជ្ជកម្ម និងការប្រើប្រាស់ភាជន៍នាំចូលមកពីស្រុកចិន ដូចជាក្នុងរាជវង្សម៉េងនិងឆេង (តិចតួច) ភាជន៍បៃតងក្នុងរាជវង្សយួននិងសុង រួមទាំងប្រភេទភាជន៍រឹងផលិតក្នុងស្រុកផង។ល។

លោក ភិរម្យ បន្តថា លទ្ធផលទាំងអស់នេះនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ ត្បិតនៅជាលទ្ធផលបឋម ហើយយើងក៏មានគម្រោងស្រាវជ្រាវនាពេលអនាគតដើម្បីស្វែងយល់អំពីទំហំនៃខឿនប្រាសាទដែលយើងឃើញតើវាមានទំហំប៉ុណ្ណា បើប្រៀបធៀបនឹងប្រាសាទផ្សេងៗក្នុងសម័យដំណាលគ្នានោះ? តើនេះជាប្រព័ន្ធនៃការរៀបចំភូមិករនិងប្រាសាទនាស.វ.ទី១០ឬយ៉ាងណា?

បុរាណវិទូខាងលើក៏បានឱ្យដឹងដែរ តាមរយៈកិច្ចសហការជាមួយសាកលវិទ្យាល័យហាវ៉ៃ គឺជាឱកាសដ៏ល្អមួយសម្រាប់ផ្សព្វផ្សាយ និងការពារបុរាណដ្ឋានដែលស្ថិតនៅភាគខាងត្បូងអង្គរ ត្បិតតំបន់នេះសព្វថ្ងៃកំពុងអភិវឌ្ឍន៍ខ្លាំង ហើយតម្រូវការប្រើប្រាស់ដីធ្លីក៏ខ្ពស់ដែលអាចបង្ករហានិភ័យខ្ពស់ដល់បុរាណដ្ឋាននៅក្នុងតំបន់នេះដែរ។ ដូច្នេះ តាមរយៈសកម្មភាពនៃការស្រាវជ្រាវតាមបែបបុរាណវិទ្យាមួយនេះ យើងអាចបង្ហាញពន្យល់ប្រជាពលរដ្ឋឱ្យយល់ពីតម្លៃនិងឱ្យចេះស្រឡាញ់ ការពារសម្បត្តិដូនតាកុំឱ្យមានការបំផ្លិចបំផ្លាញ។ លើសពីនេះទៀតអាចផ្សព្វផ្សាយឱ្យពួកគាត់ដឹងថា ទីតាំងបុរាណដ្ឋាននេះត្រូវការពារដោយអាជ្ញាធរជាតិអប្សរានិងយល់ដឹងពីសារៈសំខាន់របស់ទីទួលបុរាណដែលផ្សារភ្ជាប់ទៅនឹងតំបន់អង្គរ ព្រោះអង្គរមិនសំដៅតែលើរាជធានីដែលមានក្រុមប្រាសាទធំៗទាំងនោះតែមួយមុខទេ គឺជាការរួមផ្សំគ្នានៃប្រាសាទ និងភូមិករតូចៗទាំងអស់នេះឯង៕

លទ្ធផលស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុក ត្រូវបានផ្សព្វផ្សាយដល់សិស្សានុសិស្សនិងអ្នកភូមិ

ផ្សាយនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២០

សិស្សានុសិស្សសាលាបឋមសិក្សាក្រសាំងរលើង និងអ្នកភូមិចំណុះទួលដូនប៉ុកជាង៦០នាក់ ទទួលបានចំណេះដឹងបន្ថែមអំពីការស្រាវជ្រាវបុរាណវិទ្យានៅទួលដូនប៉ុកដោយអ្នកជំនាញមកពីអាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យហាវ៉ៃ។ នេះគឺជាការបញ្ជ្រាបចំណេះដឹងនិងផ្សព្វផ្សាយឱ្យសិស្ស រួមទាំងប្រជាជនក្នុងសហគមន៍បានយល់ច្បាស់ពីការធ្វើកំណាយស្រាវជ្រាវនិងលទ្ធផលដែលទទួលបានដើម្បីបំផុសគំនិតវិជ្ជមានដល់សិស្សនិងអ្នកភូមិឱ្យស្គាល់ពីបុរាណវិទ្យានិងបច្ចេកវិទ្យាវិទ្យាសាស្ត្រក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រ។

ទួលដូនប៉ុកជាភូមិមានមនុស្សរស់នៅជាង១០០០ឆ្នាំមកហើយ ពោលគឺតាំងពីស.វ.ទី១០ មានសំណង់ប្រាសាទឥដ្ឋចំនួន១ និងមានគោកភូមិនៅជុំវិញប្រាសាទចំនួន៦។ តឹកតាងនៃវត្តមានរបស់មនុស្សនៅទីនោះគឺសំណល់កុលាលភាជន៍ ប៉ុន្តែប្រាសាទនៅលើទួលបានដួលរលំនៅស.វ.ទី១២ឬ១៣ និងលែងជាកន្លែងប្រារព្ធពិធីសាសនាទៀតហើយ ពោលគឺនៅត្រឹមតែជាគោកអ្នកតាប៉ុណ្ណោះ។ ការបោះបង់ទួលនេះ ប្រហែលស្របពេលនឹងការកសាងវត្តអាធ្វារនាស.វ.ទី១២ឬទី១៣ដែរ ហើយមនុស្សបានប្តូរទៅគោរពបូជានៅវត្តអធ្វារវិញ។

តាមរយៈការស្រាវជ្រាវនេះ អ្នកជំនាញបង្ហាញថាក្រៅពីប្រាសាទនៅរមណីយដ្ឋានអង្គរ ក៏មានប្រាសាទតូចធំបុរាណដ្ឋានជាច្រើន ហើយមនុស្សបានរស់នៅទីនោះដែលបង្ហាញអត្តសញ្ញាណខ្មែរ ការវិវត្តនៃអរិយធម៌ពីសម័យអង្គរមកដល់សព្វថ្ងៃ និងក៏ជាភស្តុតាងបញ្ជាក់ថា ពួកយើងពិតជាកូនចៅតពីដូនតាសម័យអង្គរមែន។

យុវសិស្ស ហួន គឹមហាន រៀនថ្នាក់ទី៦នៃសាលាបឋមសិក្សាក្រសាំងរលើងមានមតិថានេះជាលើកទី១ដែលបានស្តាប់ការពន្យល់ពីការងារស្រាវជ្រាវបុរាណវិទ្យា បានឃើញគេធ្វើកំណាយនិងបានស្គាល់អំពីវត្ថុបុរាណក្រោមដី ដែលមិនដឹងថាទួលនេះមានថ្មបាយក្រៀម ប្រាសាទ អំបែងចានក្អមទេ ហើយប្តេជ្ញានឹងចូលរួមថែទាំ ក៏ដូចជាសិក្សាពីវាឱ្យបានល្អទៅថ្ងៃអនាគត។

ចំណែកអ្នកស្រី ឈុត គូ នៅភូមិទ្រាក ក៏សប្បាយចិត្តដែលបានឃើញការស្រាវជ្រាវពីប្រវត្តិនៃវត្ថុទាំងនោះ នៅទួលដូនប៉ុកដោយផ្ទាល់ បានស្គាល់ភាជន៍ ក្អម ចាន និងប្រវត្តិរបស់វា។ អ្នកស្រីគាំទ្រសកម្មភាពនេះនិងចង់ឱ្យកូនបានរៀនសូត្រផ្នែកនេះផងពេលកូនធំ ដើម្បីបម្រើប្រយោជន៍ដល់ប្រទេសខ្មែរនិងប្រជាជនខ្មែរបានដឹងពីសាវតារបស់ខ្លួន៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរាបកស្រាយអំពីចម្លាក់សត្វម្ករនៅជើងភ្នំគូលេនក្នុងសិល្បៈចម្លាក់ខ្មែរ

ផ្សាយនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២០

ចម្លាក់ទោល «សត្វម្ករ» ដ៏ធំ ដែលបានចុះផ្សាយដោយបណ្តាញសង្គម កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ កន្លងមកនេះ មានទីតាំងនៅទំនប់ទឹកមុជជាទំនប់ទឹកបុរាណមួយនៅជើងភ្នំគូលេន ដែលស្ថិតនៅទិសពាយ័ព្យនៃរមណីយដ្ឋានប្រាសាទបេងមាលា ក្នុងភូមិសាស្រ្តភូមិទឹកលេច ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប។

តាមការចុះពិនិត្យជាក់ស្តែងរបស់អ្នកជំនាញអាជ្ញាធរជាតិអប្សរា ឃើញមានបំណែកវត្ថុសិល្បៈចំនួន១៤បំណែកដូចជា ចម្លាក់ក្បាលម្ករដ៏ធំ (បណ្តោយទំហំ២១៣០មីលីម៉ែត្រ ទទឹង៩៥០មីលីម៉ែត្រ និងកម្ពស់ទំហំ១០៩០មីលីម៉ែត្រ) ចំនួន០១ រួមទាំងបំណែកដងខ្លួនមានសណ្ឋានជាទរទឹក និងគម្របទរ ព្រមទាំងបំណែកវត្ថុសិល្បៈផ្សេងៗទៀតដែលនៅរាយប៉ាយក្បែរនោះ។ ប្រជាពលរដ្ឋមានជំនឿនិងគោរពបូជាបដិមានេះជាយូរមកហើយរហូតមកដល់បច្ចុប្បន្ន។ ក្រៅពីនោះ ក៏មានស្លាកស្នាមជាការដ្ឋានយកថ្មភក់ពីបុរាណជាច្រើនកន្លែងនៅក្បែរៗនោះដែរ។

លោកបណ្ឌិត ឈាន រដ្ឋា ប្រធានស្តីទីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ បញ្ជាក់ថាអាជ្ញាធរជាតិអប្សរានឹងបន្តការសិក្សាស្រាវជ្រាវបែបបុរាណវិទ្យា ដើម្បីដឹងច្បាស់ពីប្រវត្តិទីតាំងសម្រាប់ចងក្រងជាឯកសារ ការផ្សព្វផ្សាយ និងអភិរក្សដើម្បីលើកតម្លៃបេតិកភណ្ឌជាតិ ព្រមទាំងថែរក្សាជំនឿរបស់ប្រជាពលរដ្ឋក្នុងតំបន់។

លោក អ៊ឹម សុខរិទ្ធី បុរាណវិទូ និងជាប្រធាននាយដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ នៃអាជ្ញាធរអប្សរាបានឱ្យដឹងថា៖ម្ករគឺជាត្រីសមុទ្រមួយប្រភេទមានខ្លួនធំ ក្បាលខ្លីក្រម៉ុប ធ្មេញនិងចង្កូមស្វាញគួរឱ្យសម្ញើម។ ខ្មែរតែងហៅថាត្រីថ្ករឬឆ្លាមម្ករ។ ជាប្រភេទសត្វពេញនិយមតំណាលក្នុងរឿងព្រេងទេវកថារបស់ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។

ខ្មែរបង្ហាញម្ករនៅតាមចម្លាក់លើជញ្ជាំងប្រាសាទ ហោរជាងផ្តែរ និងចម្លាក់ទោល។ តាមទេវកថាព្រះឥសូរ ម្ករជាយានជំនិះរបស់ព្រះនាងគង្គា តំណាងឱ្យទឹកបរិសុទ្ធជាទឹកមន្ត។ ដូច្នោះហើយបានជាម្ករមានវត្តមានយ៉ាងសំខាន់នៅតាមប្រាសាទនិងចម្លាក់។ ម្ករអាចមានទ្រង់ទ្រាយរូបភាពផ្សេងៗអាស្រ័យតាមរចនាបថសិល្បៈ នៃសម័យកាលមួយៗ។ សិល្បករច្នៃប្រឌិតរូបភាពម្ករបន្តិចម្តងៗទៅតាមទេពកោសល្យរបស់ខ្លួន ហើយក៏ឃ្លៀងឃ្លាតពីធម្មជាតិរបស់ខ្លួនទៅ។

គេអាចមើលឃើញម្ករនៅក្នុងចម្លាក់សិល្បៈ នៅលើផ្តែរបង្កាន់ដៃកាំជណ្តើរ លើជញ្ជាំង នៅជ្រុងដំបូលនៃប្រាសាទដែលជាទបង្ហូរទឹក។ ម្ករក៏មានតួនាទីជាអ្នកយាមទ្វារដែរ។ ជាពិសេស ម្ករមានបង្ហាញខ្លួននៅកន្លែងបញ្ចេញទឹកមានទម្រង់ជាទរបង្ហូរទឹក ដែលភាសាបច្ចេកទេសហៅថា «សោមសូត្រ» មានទម្រង់ស្រដៀងតោ ឬនាគ ដោយមានប្រម៉ោយដូចដំរី ហើយបើកចំហរមាត់ផង។

ដោយពិនិត្យលើរចនាបថសិល្បៈរបស់ចម្លាក់ អ្នកជំនាញយល់ថាប្រហែលស្ថិតក្នុងសតវត្សរ៍ទី១១ដោយយោងតាមចម្លាក់បដិមាស្រដៀងនឹងរចនាបថសិល្បៈនៅប្រាសាទបេងមាលា ដែលរូបម្ករនេះទំនងជាធ្លាក់និងរៀបចំជាក្បាលនៃទរទឹករបស់ស្ទឹងទឹកមុជ៕

សេចក្តីជូនដំណឹងស្តីពីការរៀបចំសោភ័ណភាព និងបរិស្ថានជុំវិញបរិវេណត្រពាំងសេស ប្រាសាទព្រហ្មកិលខាងលិចប្រាសាទអង្គរវត្ត(មុខនាគ) និងជុំវិញអាងស្នាក់ខ្សាច់(ច្រកសំពៅលូន) នៅខាងជើងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ.០០៧៦ /អ.ជ.អ.

២០

សេចក្តីជូនដំណឹង

ស្តីពី

ការរៀបចំសោភ័ណភាព និងបរិស្ថានជុំវិញបរិវេណត្រពាំងសេស ប្រាសាទព្រហ្មកិល ខាងលិចប្រាសាទអង្គរវត្ត(មុខនាគ) និងជុំវិញអាងស្នាក់ខ្សាច់(ច្រកសំពៅលូន) នៅខាងជើងប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ជ្រាបថា ដើម្បីលើកតម្លៃមណ្ឌលប្រវត្តិសាស្ត្រអង្គរ ឱ្យកាន់តែល្អប្រសើរ និងមានភាពទាក់ទាញថែមទៀត អាជ្ញាធរជាតិអប្សរា នឹងអនុវត្តការងាររៀបចំសោភ័ណភាព និងបរិស្ថានជុំវិញបរិវេណត្រពាំងសេស ប្រាសាទព្រហ្មកិល ខាងលិចប្រាសាទអង្គរវត្ត (មុខនាគ) និងជុំវិញអាងស្នាក់ខ្សាច់(ច្រកសំពៅលូន)នៅខាងជើងប្រាសាទអង្គរវត្ត ដូចជា៖

- កាត់ដកហូតដើមឈើមួយចំនួនដូចជា ពុទ្រា អំពិលទឹក ដូង ស្វាយ។ល។ និងដាំជំនួសមកវិញដោយដើមធ្នង់ និងគ្រញូង។
- កាត់ក្រីមែកឈើស៊ុបទ្រុបចេញ ដើម្បីឱ្យមានពន្លឺគ្រប់គ្រាន់ មានរបៀបរៀបរយ និងសោភ័ណភាពល្អ
- រៀបចំបំពេញដីសម្រាប់ដាំស្មៅបន្ថែមលើទីតាំងដែលគ្មានស្មៅ។

ការងារនេះនឹងចាប់អនុវត្តពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ និងសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ០៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

Email: info@apsaraauthority.gov.kh

Website: apsaraauthority.gov.kh

Scanned with CamScanner

អាជ្ញាធរជាតិអប្សរាកាត់ដើមចំបក់មួយដើមដែលប្រឈមនឹងហានិភ័យដល់ភ្ញៀវចេញពីក្នុងបរិវេណប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានកាត់ដើមចំបក់មួយដើម ដែលអាចបង្កហានិភ័យខ្ពស់ដល់ភ្ញៀវទេសចរឆ្លងកាត់មកទស្សនាប្រាសាទ នៅទីតាំងផ្លូវចូលប្រាសាទនាគព័ន្ធ។

លោក ឃិន សុវ៉ាត មន្ត្រីជំនាញមកពីនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន មានប្រសាសន៍ថា ដើមចំបក់មួយដើមនេះងាប់ជាយូរមកហើយ មែកនិងគល់របស់វាពុកផុយជាអន្លើ ដែលអាចបាក់ធ្លាក់បង្កហានិភ័យចំពោះភ្ញៀវដើរឆ្លងកាត់ចេញចូលប្រាសាទនាគព័ន្ធនេះ។

លោកកបន្តថា ដោយសារមើលឃើញនូវបញ្ហានេះ ទើបក្រុមការងារសម្រេចកាប់ដើមចំបក់នេះចោល ក្នុងបំណងបង្ការនិងបញ្ចៀសគ្រោះថ្នាក់ផ្សេងៗជាយថាហេតុនាំឱ្យប៉ះពាល់ដល់ភ្ញៀវទេសចរ ការពារកុំឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធប្រាសាទ និងដើម្បីរក្សាសោភណ្ឌបរិវេណប្រាសាទផង។

លោកបញ្ជាក់ថា អំឡុងពេលអនុវត្តកិច្ចការងារនេះ ក្រុមការងារក៏បានរៀបចំផ្លូវវាងដើម្បីសម្រួលដល់ភ្ញៀវឆ្លងកាត់និងបញ្ចៀសនូវគ្រោះថ្នាក់ផ្សេងៗកំពុងពេលកាត់ដើមចំបក់។ អាជ្ញាធរជាតិអប្សរា ក៏បានអំពាវនាវដល់ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ សូមមានការយោគយល់ អធ្យាស្រ័យ និងចូលរួមសហការ ដើម្បីឱ្យការអនុវត្តការងារបានរលូន និងសុវត្ថិភាពខ្ពស់ទាំងអស់គ្នា។

គួរបញ្ជាក់ថា នេះជាការប្រចាំថ្ងៃរបស់អាជ្ញាធរជាតិអប្សរា ដើម្បីថែរក្សាទេសភាពវប្បធម៌ក៏ដូចជាថែរក្សាបរិស្ថានក្នុងរមណីយដ្ឋានអង្គរ៕

អាជ្ញាធរជាតិអប្សរាបើកកម្មវិធីអប់រំបេតិកភណ្ឌ ដល់កុមារនៅសាលាបឋមសិក្សាក្របីរៀលសម្រាប់ឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ក្រុមការងារអប់រំបេតិកភណ្ឌនៃអាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការគាំពារកេរមរតក បានបើកកម្មវិធីអប់រំបេតិកភណ្ឌសម្រាប់ឆ្នាំសិក្សាថ្មី នៅសាលាបឋមសិក្សាក្របីរៀល សង្កាត់ក្របី-រៀល ក្រុងសៀមរាប ដែលមានការអញ្ជើញចូលរួមពីលោកនាយក នាយករង គ្រូបន្ទុកថ្នាក់ ក្រុមការងារអប់រំបេតិកភណ្ឌចំនួន៤រូបនិងសិស្សានុសិស្សចំនួន២២០រូប។

លោក អ៊ុន មណីនីតា តំណាងក្រុមការងារអប់រំបេតិកភណ្ឌ បានពន្យល់ណែនាំពីគោលការណ៍គម្រោង តម្រូវការគម្រោង និងសកម្មភាពគម្រោងឱ្យលោកគ្រូ អ្នកគ្រូ បានស្វែងយល់ជាមុនដើម្បីងាយស្រួលដឹកនាំនិងជំរុញដល់សិស្សសម្រាប់ការអនុវត្តកម្មវិធីនេះ។ លោកបានបន្តថា ក្នុងកម្មវិធីអប់រំបេតិកភណ្ឌសម្រាប់ឆ្នាំសិក្សាថ្មី លោកស្នើសុំបង្រៀនរយៈពេល៨ខែ ចាប់ពីខែមករាដល់ខែកក្កដា ឆ្នាំ២០២០ ដោយបែងចែកការបង្រៀនជា២ផ្នែក គឺបង្រៀនក្នុងថ្នាក់ឱ្យយល់ដឹងពីមូលដ្ឋាននៃបេតិកភណ្ឌវប្បធម៌ និងបង្រៀនក្រៅថ្នាក់ គឺនាំសិស្សទៅសិក្សាស្ថានភាពជាក់ស្តែងនៅតាមរមណីយដ្ឋានវប្បធម៌នានាក្នុងតំបន់អង្គរ។

គោលបំណងនៃកម្មវិធីនេះ បង្កើតឡើងដើម្បីផ្តល់ឱកាសឱ្យកុមារដែលកើតនិងរស់នៅក្នុងតំបន់រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្រ្ត យល់ដឹងពីកេរមរតកវប្បធម៌របស់ខ្លួន និងបណ្តុះគំនិតកុមារឱ្យជ្រួតជ្រាបពីតម្លៃមរតកវប្បធម៌ជាពិសេស ពួកគេអាចធ្វើជាអ្នកស្នងមរតកវប្បធម៌នៅសហគមន៍របស់ខ្លួនលើវិស័យថែរក្សាការពារ គ្រប់គ្រងកេរមរតកវប្បធម៌នាពេល អនាគតបានយ៉ាងល្អ។

អាជ្ញាធរជាតិអប្សរាបន្តការងារជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២០

នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរា បានបន្តកិច្ចការងារថែទាំផ្លូវស្លាកសញ្ញាចរាចរណ៍ ស្លាកព័ត៌មានផ្សេងៗ បោសសម្អាតដីដែលចាក់គរតាមចញ្ចើម និងគែមផ្លូវនានាក្នុងរមណីយដ្ឋានអង្គរ ដើម្បីសម្រួលដល់ការធ្វើចរាចរដល់ប្រជាពលរដ្ឋក៏ដូចជាភ្ញៀវទេសចរ។

ជាក់ស្តែង នៅដើមខែមករា ឆ្នាំ២០២០ នេះ ក្រុមការងារទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ បានចុះអនុវត្តការងារជួសជុលវិថីសម្តេច វិបុល បញ្ញា សុខ អាន និងជូតសម្អាត ផ្លាកសញ្ញាចរាចរណ៍ នៅចំណុចT5 ចាប់ពីរង្វង់មូលអប្សរា រហូតដល់ទីស្នាក់ការអាជ្ញាធរជាតិអប្សរា ព្រមទាំង បោសសម្អាតដីខ្សាច់ម៉ដ្ឋនៅតាមចញ្ចើម និងគែមផ្លូវមុខប្រាសាទអង្គរវត្ត។

អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់លើកិច្ចការងារជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងរមណីយដ្ឋានអង្គរជាប្រចាំ ឱ្យរក្សាបាននូវសុខសុវត្ថិភាពរបស់អ្នកធ្វើដំណើរ និងសោភណភាពថែមទៀត៕

ពិធីបុណ្យឡើងមាឃ ឬឡើងអ្នកតា ជាទំនៀមមួយក្នុងចំណោមបេតិកភណ្ឌអរូបីជាច្រើនរបស់អ្នកស្រុកអង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២០

នៅព្រឹកថ្ងៃសៅរ៍ ១កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ ប្រជាជនទាំងប្រុស ស្រី ចាស់ ក្មេង ប្រមាណ ៥០០ នាក់ បានមកប្រមូលផ្តុំគ្នានៅបឹងធំមួយ ដែលស្ថិតនៅក្នុងភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

បឹងធំមួយនេះ អ្នកភូមិអភិរក្សត្រីទុកមិនឱ្យមានការនេសាទផ្តេសផ្តាសនោះឡើយ គឺសម្រាប់តែរកត្រីរួមគ្នាដើម្បីយកមកធ្វើជាចង្ហាន់ប្រគេនព្រះសង្ឃក្នុងថ្ងៃឡើងមាឃ ឬឡើងអ្នកតាដែលប្រារព្ធធ្វើឡើងនៅថ្ងៃ២៧ ខែមករា ឆ្នាំ២០២០ និងធ្វើម្ហូបសម្រាប់គ្រួសារ ព្រមទាំងទទួលភ្ញៀវ ដែលជាទំនៀមរបស់អ្នកស្រុកអង្គរប្រារព្ធធ្វើជារៀងរាល់ឆ្នាំ។

នៅម៉ោង៧ព្រឹក គណៈកម្មការភូមិ បាញ់កាំជ្រួច បន្លឺស្នូរជាសញ្ញា អនុញ្ញាតឱ្យចុះចាប់ត្រីបានហើយ។ ដោយឡែកការរកត្រីនេះ អនុញ្ញាតឱ្យប្រជាជនក្នុងភូមិបង្កោងតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យតែប្រជាជនភូមិក្រៅចុះចាប់នោះឡើយ និងប្រើប្រាស់តែឧបករណ៍បុរាណទាំងអស់ រួមមានដូចជា ឈ្នាងអង្រុត និងសំណាញ់ជាដើម។

ចំពោះការចាប់ត្រីនេះ គណៈកម្មការបានកំណត់ជាពីរផ្នែក។ ជាដំបូងប្រជាជនទាំងអស់អាចរកត្រីទុកសម្រាប់ខ្លួនឯងផ្ទាល់ រីឯមួយផ្នែកនៃបឹងដែលដាក់សម្រាស់ការពារមិនឱ្យចាប់ពីដំបូងនោះ ត្រូវចាប់ទុករួមសម្រាប់ធ្វើទឹកនំបញ្ចុកប្រគេនព្រះសង្ឃ។

លោក ពេជ្រ ឃិន មេភូមិ ភូមិបង្កោង និងជាគណៈកម្មការរៀបចំ បានរៀបរាប់ថា ដោយនៅឆ្នាំនេះខ្សត់ទឹកភ្លៀង និងមិនមានទឹកជំនន់ផង ទើបមិនសំបូរត្រី ហើយគណៈកម្មការគ្រប់គ្រង និងអភិរក្សបឹងបានប្រលែងកូនត្រីប្រមាណ ១៥០០ក្បាល កាលពីអំឡុងខែ១០ ឆ្នាំ២០១៩ ដើម្បីរក្សាទិន្នផលត្រីដើម្បីបានផ្គត់ផ្គង់កម្មវិធីនៅឆ្នាំនេះបន្ត។

លោកបន្តថា ការចាប់ត្រីឡើងមាឃនេះ មានជាយូរយារមកហើយ រៀងរាល់ខែមាឃ បន្ទាប់ពីបញ្ចប់ការច្រូតកាត់ និងដាក់ស្រូវក្នុងជង្រុករួចរាល់។ លោកបញ្ជាក់ថា ថ្វីបើកម្មវិធីនេះមានជាយូរមកហើយ តែការរៀបចំបានគគ្រឹកគគ្រេងប្រមាណជាង១០ឆ្នាំកន្លងមកនេះ នៅពេលលោកមានតួនាទីជាមេភូមិក្នុងភូមិបង្កោង។ លោកតែងតែអប់រំប្រជាជនក្នុងភូមិ និងអ្នកណាក៏ដោយដែលនឹងក្លាយជាអ្នកដឹកនាំបន្តវេណពីលោក ធ្វើយ៉ាងណាថែរក្សាទំនៀមទម្លាប់នេះឱ្យបានគង់វង្សសម្រាប់កូនចៅជំនាន់ក្រោយនាពេលអនាគត។

លោកស្រី ផៃ ណាត ដៃមមាញឹកចាប់ត្រី ដោយដៃម្ខាងកាន់អង្រុត ដៃម្ខាងរាវរកត្រីក្នុងអង្រុត បាននិយាយដោយទឹកមុខរីករាយថា ខ្ញុំបានមករកត្រីជារៀងរាល់ឆ្នាំ ហើយ ថ្ងៃនេះបានក្រោកមកជាមួយអ្នកភូមិតាំងពីម៉ោង៥ មកម្លេះ។ លោកស្រីបន្តថា ឆ្នាំនេះមិនសូវសំបូរត្រីដូចឆ្នាំមុនៗនោះទេ ដោយសារតែឆ្នាំនេះមិនមានទឹកធំ មានតែទឹកភ្លៀងប៉ុណ្ណោះបណ្តាលឱ្យទិន្និផលត្រីធ្លាក់ចុះ។

តំបន់រមណីយដ្ឋានអង្គរ ជាតំបន់បេតិកភណ្ឌរស់ដែលសម្បូរទៅដោយមរតកអរូបីជាច្រើនហើយត្រូវបានអ្នកស្រុកអង្គរបន្តប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់បច្ចុប្បន្ន។ ពិធីបុណ្យឡើងមាយឬបុណ្យឡើងអ្នកតា ក៏ជាទំនៀមទម្លាប់ប្រពៃណីមួយក្នុងចំណោមបេតិកភណ្ឌអរូបីជាច្រើនប្រតិបត្តិដោយអ្នកស្រុកអង្គរ។

គួរបញ្ជាក់ថា រៀងរាល់ថ្ងៃ១ កើត ខែមាឃ ប្រជាជនតែងតែរកត្រីរួមគ្នាដើម្បីយកត្រីមកធ្វើម្ហូប និងធ្វើចង្ហាន់ប្រគេនព្រះសង្ឃសម្រាប់ថ្ងៃ៣កើត ខែមាឃ ដែលជាថ្ងៃឡើងមាយ ឬឡើងអ្នកតា៕

សិប្បកម្មឡឥដ្ឋក្បឿងអង្គរ ជាសិប្បកម្មតែមួយគត់ដែលផលិតឥដ្ឋជួសជុលប្រាសាទ

ផ្សាយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២០

ជាផ្នែកមួយនៃការចូលរួមអភិរក្សប្រាសាទដូនតាខ្មែរ សិប្បកម្មផលិតឥដ្ឋក្បឿងអង្គរ ដែលស្ថិតនៅភូមិថ្មី ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប បានផលិតឥដ្ឋបុរាណសម្រាប់ការងារជួសជុលប្រាសាទ។ សិប្បកម្មនេះបានចាប់ផ្តើមផលិតឥដ្ឋនេះតាំងពីអំឡុងឆ្នាំ១ ៩ ៩ ៤ មក និងគោរពតាមបច្ចេកទេសដែលអ្នកជំនាញជួសជុលប្រាសាទផ្តល់ឱ្យ។

លោក យិន លិម ជាម្ចាស់សិប្បកម្មផលិតឥដ្ឋក្បឿងអង្គរ បានចាប់ផ្តើមរបរនេះតាំងពីឆ្នាំ១៩៨៩មក ដោយលោកបានកែច្នៃឡបុរាណសល់ពីសង្គមចាស់សម្រាប់ការធ្វើអាជីវកម្មនេះ។ លោកប្រាប់ថា ការផលិតឥដ្ឋនិងក្បឿងក្នុងសិប្បកម្មលោក គឺប្រើប្រាស់វត្ថុធាតុដើមធម្មជាតិសុទ្ធសាធ ហើយបច្ចេកទេសក៏នៅបែបបុរាណផងដែរ។

សម្រាប់ការផលិតឥដ្ឋផ្គត់ផ្គង់ការដ្ឋានជួសជុលប្រាសាទក្នុងរមណីយដ្ឋានអង្គរ លោក យិន លិម ប្រាប់ថា បានចាប់ផ្តើមពីឆ្នាំ១៩៩៤និង១៩៩៥មកដោយសារសិប្បកម្មលោកមានពុម្ពចាស់ និងទទួលបានការផ្តល់ទំនុកចិត្តពីអ្នកជំនាញជួសជុលប្រាសាទ។លោកបន្តថាអង្គការបរទេសដែលសហការជួសជុលប្រាសាទជាមួយអាជ្ញាធរជាតិអប្សរាបានបញ្ជាទិញឥដ្ឋបុរាណនេះដើម្បីជួសជុលប្រាសាទព្រះគោ ហើយការផលិតគឺមានការផ្តល់បច្ចេកទេស និងការសិក្សាត្រឹមត្រូវពីស្ថាប័នទាំងនោះ។

លោក យិន លិម បន្តថា ការផលិតឥដ្ឋបុរាណជួសជុលប្រាសាទដែលលោកកំពុងផលិតគឺមាន៣ខ្នាត។ ខ្នាតទី១ មានទំហំ ១,៦ស.ម គុណ២៣ស.ម គុណ១១ស.ម, ខ្នាតទី២ ទំហំ ៧,៥០ស.ម គុណ២៣ស.ម គុណ១១ស.ម និងខ្នាតទី៣ ទំហំ៥,៥០ គុណ២៣ស.ម គុណ១១ស.ម។

លោក សារាយ គឹមហួល មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា មូលហេតុដែលអាជ្ញាធរជាតិអប្សរាជ្រើសរើសសិប្បកម្មរបស់លោក យិន លិម ក្នុងការផលិតឥដ្ឋជួសជុលប្រាសាទ ពីព្រោះថាសិប្បកម្មនេះគោរពនូវលក្ខខណ្ឌបច្ចេកទេសដែលអ្នកជំនាញផ្តល់ជូន។ លោកបន្តថា ដើមឡើយមុនជ្រើសរើសសិប្បកម្មនេះ អ្នកជំនាញបានចុះទៅទីតាំងផ្ទាល់ ដោយបានផ្តល់បច្ចេកទេស និង ហាមមិនឱ្យយកដីទីទួលបុរាណក្បែរនោះមកផលិតឡើយ។

បន្ថែមពីនេះ តាមការបញ្ជាក់ពីលោក សារាយ គឹមហួល ឥដ្ឋបុរាណដែលយកមកជួសជុលប្រាសាទគឺមានទំហំធំក្រាស់ និងម៉ដ្ឋល្អជាងឥដ្ឋធម្មតា។ ចំណែកការបញ្ជាទិញគឺទៅតាមទំហំនិងគម្រោងប្រចាំឆ្នាំនៅតាមការដ្ឋាននីមួយៗ ហើយការដ្ឋានដែលអាជ្ញាធរជាតិអប្សរាយកមកជួសជុលមានដូចជានៅប្រាសាទព្រះគោ ប្រាសាទបាគង ប្រាសាទលលៃ ប្រាសាទអកយំ ប្រាសាទបាតជុំ។ល។

អាជ្ញាធរជាតិអប្សរាគ្រោងនឹងបញ្ចប់ការជួសជុលប្រាសាទបាតជុំក្នុងដំណាក់កាលទី១

ផ្សាយនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២០

ប្រាសាទបាតជុំកសាងឡើងដោយមន្ត្រីម្នាក់ឈ្មោះ កវិន្ទ្រារីមថនក្នុងរាជព្រះបាទរាជេន្ទ្រវរ្ម័នទី២នាពាក់កណ្តាលសតវត្សរ៍ទី១០ ប្រាសាទនេះសាងអំពីឥដ្ឋមានតួប៉មចំនួនបីស្ថិតនៅលើខឿនថ្មបាយក្រៀម ឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន។ បច្ចុប្បន្នប្រាសាទនេះ កំពុងរងការខូចខាតច្រើនអន្លើដោយសារកត្តាធម្មជាតិ អាយុកាល និងគុណភាពសម្ភារៈសំណង់។

ក្នុងគោលបំណងពង្រឹង សង្គ្រោះប្រាសាទឱ្យជៀសផុតពីហានិភ័យ និងលើកតម្លៃប្រាសាទ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានរៀបចំដំណើរការជួសជុលតាំងពីថ្ងៃទី១៧ ខែកក្កដាឆ្នាំ២០១៩ដែលគ្រោងនឹងបញ្ចប់នៅក្នុងខែមករាឆ្នាំ២០២០នេះ។

កញ្ញា ជយ ពេជ្រជីវ៉ា បុគ្គលិកបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា ប្រាសាទនេះមានសភាពទ្រុឌទ្រោមខ្លាំង ឥដ្ឋរលុះធ្ងន់ធ្ងរនិងច្រើនកន្លែងដូចជានៅផ្នែកខាងលើផ្តែរនៃប៉មខាងជើង ក្បាលសសរផ្តោបនិងគល់សសរផ្តោបជ្រុងខាងកើតនៃប៉មខាងជើងរលុះបាក់ខ្លាំង។ ឥដ្ឋផ្នែកដំបូល ជ្រុងកែងនិងលើជញ្ជាំងមានស្នាមប្រេះរលុះបាក់និងពុកផុយ មានរុក្ខជាតិដុះតាមស្រទាប់ឥដ្ឋនិងទឹកភ្លៀងជ្រាបតាមស្នាមប្រេះធ្វើឲ្យតួប៉មពុកផុយ។ ចំណែកថ្មខឿនរំកិលចេញពីទីតាំងដើម មិនតែប៉ុណ្ណោះសំបុកកណ្តៀរមាននៅក្នុងស្នាមប្រេះទាំងនោះ។

ដើម្បីជួសជុលនិងកាត់បន្ថយហានិភ័យនេះ កញ្ញា ពេជ្រដីរ៉ា បញ្ជាក់ថា ជាដំបូងក្រុមអ្នកជំនាញបានជួសជុលនូវផ្នែកខាងជើងដែលប្រឈមនឹងគ្រោះថ្នាក់ខ្លាំង ជាពិសេសទីតាំងឥដ្ឋក្រៀកហែកចេញពីគ្នារហូតដល់២១សង់ទីម៉ែត្រ នៅជញ្ជាំងខាងជើង។ កញ្ញា បន្ថែមថា បន្ទាប់មកក្រុមអ្នកជំនាញបានជួសជុលបិតភ្ជាប់ស្នាមប្រេះផ្នែកខាងក្នុង និងខាងក្រៅដើម្បីការពារការជ្រាបទឹក ជៀសវាងការខូតខាតណាមួយបន្ថែមទៀត។

ចំពោះបច្ចេកទេស កញ្ញាបានឱ្យដឹងថា ទីតាំងខូចខាតក្រុមការងារបានរុះរើឥដ្ឋដែលពុកផុយនិងជួសជុលពង្រឹងឡើងវិញជាផ្នែកៗដោយរក្សាទម្រង់ដើមរបស់ប្រាសាទនិងរក្សាបច្ចេកទេសបុរាណ ហើយរក្សាតម្លៃប្រវត្តិនៃស្ថាបត្យកម្មប្រាសាទ។ ម្យ៉ាងវិញទៀត យើងបានស្វែងរកឥដ្ឋចាស់ៗនិងប្រើឡើងវិញ រួមទាំងបន្ថែមឥដ្ឋថ្មីស្របតាមកម្រិតខូចខាតនៃសំណង់និងគោរពតាមទ្រឹស្តី និងការអភិរក្សបេតិកភណ្ឌវប្បធម៌(ធម្មនុញ្ញអង្គរ និង អាយស៊ីស៊ី អង្គរ)។ ចំពោះបច្ចេកទេសលាយបាយអរធ្វើតាមរូបមន្តបុរាណនឹងមានកម្មករជំនាញមានបទពិសោធន៍ផ្នែកជួសជុលប្រាសាទឥដ្ឋជាច្រើនឆ្នាំចូលរួមផងដែរ៕

ទិដ្ឋភាពពិធីឡើងអ្នកតានៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២០

ដូចសព្វមួយដង អ្នកស្រុកអង្គរបានរៀបចំពិធីឡើងមាយ ឬឡើងអ្នកតានៅរៀងរាល់ថ្ងៃ៣កើត ខែមាឃ នៅតាមភូមិ ឬតាមទួលអ្នកតាដែលជាទីសក្ការៈបូជា។

ពិធីដូចគ្នានេះក៏ប្រារព្ធធ្វើនៅទីសក្ការៈបូជាលោកតារាជ្យ ក្នុងប្រាសាទអង្គរវត្តផងដែរ។ ប្រជាពលរដ្ឋមកពីទីជិតទីឆ្ងាយ បានជួបជុំគ្នារៀបចំពិធីដោយនាំមកនូវគ្រឿងសំណែនចម្រុះដូចជានំបញ្ចុក នំអន្សម ក្បាលជ្រូក មាន់ ទឹកស្រា បង្អែម និងវណ្ណាប់បូជាផ្សេងៗដើម្បីរៀបចំពិធី។

នៅពេលវេលាម៉ោង៣រសៀល ពិធីបានចាប់ផ្តើមដោយមានចាស់ក្មេងប្រមាណជិត១០០នាក់ចូលរួម។ ពិធីមានការប្រគំតន្ត្រីបុរាណ អាចារ្យសូត្រធម៌ដើម្បីអញ្ជើញអ្នកតាមកពិសារគ្រឿងសំណែន។ ពិធីនេះត្រូវបានអ្នកភូមិអង្គរគោរពធ្វើជារៀងរាល់ឆ្នាំនៅក្រោយរដូវច្រូតកាត់ ឬនៅរាល់ថ្ងៃ៣កើត ខែមាឃ ដើម្បីជាកិច្ចលៀងជូនអ្នកតាដែលបានផ្តល់ទឹកភ្លៀងតាមរដូវ និងផ្តល់ដីមានជីជាតិ ព្រមទាំងថែរក្សាអ្នកស្រុកពេញមួយឆ្នាំឱ្យជួបតែសេចក្តីសុខជារហូតមក៕

អ្នកស្រុកចំណុះជើងវត្តអាធ្វានាំគ្នាប្រារព្ធពិធីឡើងអ្នកតាបួងសួងសុំសេចក្ដីសុខតាមទំនៀមពីបុរាណ

ផ្សាយនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២០

ប្រជាជនចំណុះជើងវត្តអាធ្វា រួមមានភូមិទ្រាក ភូមិកក្រាញ់ ភូមិក្រសាំងរលើង និងភូមិស្ពានជ្រាវ បានមូលមីរជួបជុំគ្នានៅប្រាសាទអាធ្វា ប្រារព្ធពិធីឡើងមាយឬឡើងអ្នកតា រៀងរាល់ថ្ងៃ៣កើត ខែមាឃ តាមទម្លាប់តពីបុរាណ។

កិច្ចពិធីនេះមានរៀបចំបាយសម្ល បង្អែមចង្អាប ក្បាលជ្រូក គ្រឿងរណ្ដាប់ស្លាធម៌ បាយសី វង់ភ្លេង អ្នកស្នងរូប ដើម្បីរាំថ្វាយនិងសែនថ្វាយម្ចាស់ទឹក ម្ចាស់ដី អារក្ស អ្នកតា មានលោកតាមហារាជ ហាជម្ពូ ស្ដេចនាគខៀវ នាគស នាគខ្មៅ នាគក្រហម ស្ដេចអណ្ដើក ស្ដេចហនុមាន តាឥសីម្រេញគង្វាល ស្ដេចយមរាជ។ល។ ដែលថែរក្សាប្រាសាទអាធ្វា។

ចំណុចសំខាន់នៃពិធីនៅប្រាសាទអាធ្វា គឺការចូលរូបដើម្បីបង្កើតទំនាក់ទំនងរវាងមនុស្សនិងទេព ដើម្បីឱ្យទេពបានរាំរែកសប្បាយ ហូបចុកឆ្អែតឆ្អន់ មុននឹងចាកចេញទៅស្រុកលំនៅខ្លួនវិញ។ អ្នកស្រុកជឿថា ការរៀបចំពិធីឡើងមាយឬឡើងអ្នកតានេះ គឺដើម្បីសុំសេចក្ដីសុខចម្រើនចៀសផុតពីរោគាព្យាធិ គ្រោះកាចឧបទ្រពចង្រៃដល់មនុស្សសត្វ។ ម្យ៉ាងទៀតក៏ដើម្បីអរគុណដល់អ្នកតា ម្ចាស់ទឹកម្ចាស់ដីដែលផ្ដល់ទឹកភ្លៀង ដីមានជីជាតិ ធ្វើឱ្យកសិកម្មទទួលបានផលល្អ។

លោកតា កែវ អាយុ ៧០ ឆ្នាំ ជាចាស់ទុំនៅក្នុងភូមិទ្រាកបានឱ្យដឹងថា ឱ្យតែដល់ហេមន្តរដូវ អ្នកស្រុកអ្នកភូមិបានមូលមតិគ្នារៀបចំពិធីឡើងមាយឬឡើងអ្នកតានៅប្រាសាទវត្តអាធ្វាជាប្រចាំ។ លោកតាបន្តថា កម្មវិធីនេះមានជាយូរយារមកហើយ លើកលែងតែអំឡុងពេលប្រទេសមានសង្គ្រាមទេ ដែលមិនអាចរៀបចំបាន។

លោកយាយ ហុង អាយុ៦១ឆ្នាំ មានប្រសាសន៍ថា លោកយាយ តែងតែមកចូលរួមពិធីឡើងអ្នកតាជារៀងរាល់ឆ្នាំមិនដែលខានឡើយ ទោះបីរវល់យ៉ាងណា ក៏ត្រូវមកចូលរួមដែរ។ លោកយាយជឿថា លោកតាមហារាជ និងលោកតាមហាជម្ពូ តែងជួយថែរក្សាភូមិស្រុក និងគ្រួសារលោកយាយបានសុខសប្បាយ។ ម្យ៉ាងការធ្វើដូច្នេះ ក៏ជាគំរូមួយនៃការបង្រៀនកូនចៅជំនាន់ក្រោយឱ្យចេះធ្វើតាម កុំឱ្យទំនៀមនេះបាត់បង់ទៅតាមចាស់ៗដែលស្លាប់ទៅ។

បន្ទាប់ពីបញ្ចប់កិច្ចពិធីឡើងមាយឬឡើងអ្នកតានៅប្រាសាទវត្តអាធ្វា ក៏មានការរៀបចំសែនព្រេន ឡើងមាយ ឬឡើងអ្នកតា ដូចគ្នានេះដែរ នៅទីតាំងទួលតាមឿង និងទួលយាយប៉ុកផងដែរ៕

ម្ចាស់ភោជនីយដ្ឋាន “ផ្ទះបាយតានីខ្មែរអង្គរ” ស្ម័គ្រចិត្តរុះរើសំណង់ ប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍

ផ្សាយនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០២០

នេះជាម្ចាស់ភោជនីយដ្ឋានទី២ហើយដែលបានបានស្ម័គ្រចិត្តរុះរើសំណង់ភោជនីយដ្ឋានចំនួនមួយខ្នង គឺអតីតភោជនីយដ្ឋាន «ភ្នំស្រី» បច្ចុប្បន្នឈ្មោះថា «ផ្ទះបាយតានីខ្មែរអង្គរ» ដើម្បីសម្រួលដល់ការសាងសង់ទីលានបដិសណ្ឋារកិច្ចមុខ ប្រាសាទអង្គរវត្ត កាលពីព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

លោកស្រី មុត រតនា ម្ចាស់ទីតាំងភោជនីយដ្ឋាន «ភ្នំស្រី» ដែលសព្វថ្ងៃបានជួលឱ្យលោក ជ្រុន គឹមសេង ធ្វើអាជីវកម្ម បន្តបានឱ្យដឹងថា លោកស្រីបានបើកភោជនីយដ្ឋាននេះជាង២០ឆ្នាំមកហើយ អនុស្សាវរីយ៍ក៏ច្រើន ហើយទីនេះក៏ជាប្រភពចំណូលនិងភាពមានបានរបស់អ្នកស្រីមកដល់សព្វថ្ងៃឱ្យរស់នៅបានសុខសាន្តជាមួយកូនចៅ។

អ្នកស្រីរីករាយនឹងប្រគល់ដីនេះជូនអាជ្ញាធរជាតិអប្សរាតាមសំណូមពរដើម្បីអភិវឌ្ឍន៍ទីនេះឱ្យកាន់តែល្អប្រសើរ ព្រោះនេះជាកម្មសិទ្ធិរបស់រដ្ឋ និងបានតាំងចិត្តតាំងពីដើមមកថា នឹងប្រគល់ជូនរដ្ឋ ពេលរដ្ឋត្រូវការ។

លោក ជ្រុន គឹមសេង អាជីករភោជនីយដ្ឋាន «ផ្ទះបាយតានីខ្មែរអង្គរ» ដែលបានជួលទីតាំងនេះប្រកបរបរលក់អាហារជិត៣ឆ្នាំមកហើយ បានលើកឡើងថា ការប៉ះពាល់ដល់អង្គរ គឺមិនមែនជាផលប៉ះពាល់តែឆ្នាំងបាយរបស់ខ្ញុំទេ តែជាឆ្នាំងបាយជាតិទាំងមូល និងពិភពលោកដែរ ដូច្នេះការចូលរួមរបស់ខ្ញុំនេះជាចំណែកតូចណាស់ក្នុងការថែរក្សាអង្គរ ក្នុងនាមជាអ្នកទទួលបានផលពីអង្គរ។

លោក គឹមសេង បន្តថា ខ្ញុំស្ម័គ្រចិត្ត សហការជាមួយអាជ្ញាធរជាតិអប្សរានិងរដ្ឋាភិបាលក្នុងការរុះរើសំណង់ ភោជនីយដ្ឋាននេះតាមសំណូមពរ ដោយមិនមានការបង្ខិតបង្ខំទេ ព្រោះកើតចេញពីការជជែករកដំណោះស្រាយមួយដ៏ល្អបំផុតសម្រាប់ជាតិយើងទាំងអស់គ្នា ដើម្បីរួមចំណែកលើកតម្លៃរមណីយដ្ឋានអង្គរឱ្យមានសណ្តាប់ធ្នាប់ល្អ បរិស្ថានស្អាត តាមតម្រូវការវិស័យទេសចរណ៍ទាំងនៅទីនេះទូទាំងប្រទេស និងពិភពលោក។

លោកក៏បានអរគុណអាជ្ញាធរជាតិអប្សរាដែលរកដំណោះស្រាយល្អៗដល់អាជីវករ ហើយក៏សំណូមពរដល់បងប្អូននៅទីនេះ សូមយល់ថាដំណើរការនៃការរៀបចំឧទ្យានអង្គរនេះ គឺឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ចជាតិនិងពិភពលោកជាមួយគ្នា ព្រោះនេះជាមរតកពិភពលោក មិនមែនជាកម្មសិទ្ធិឯកជនណាមួយឡើយ។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ការរុះរើសំណង់ភោជនីយដ្ឋាននេះ គឺស្ថិតនៅចំទីតាំងគម្រោងដ៏ធំរបស់អាជ្ញាធរជាតិអប្សរា ដែលនឹងប្រែក្លាយទីនេះឱ្យមានរបៀបរៀបរយ សណ្តាប់ធ្នាប់ល្អ បរិស្ថានស្អាត មានគម្រោងរៀបចំទីលានបដិសណ្ឋារកិច្ច គម្រោងជួសជុលផ្លូវមុខអង្គរវត្ត គម្រោងដាំឈើ និងវាលស្មៅឱ្យមានភាពបៃតង។ ដូច្នេះ ដើម្បីសម្រេចគម្រោងអាជ្ញាធរជាតិអប្សរាចាំបាច់មានការសម្របសម្រួលជាមួយអាជីវករ សុំឱ្យមានការយោគយល់ និងចូលរួមទាំងអស់គ្នា ដើម្បីឱ្យអាជ្ញាធរជាតិអប្សរាសាងសង់និងរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅទីនេះបានរលូននិងដំណើរការទាន់ពេលវេលា ដែលគ្រោងនឹងបញ្ចប់មុនដំណាច់ឆ្នាំ២០២០ នេះ ដើម្បីផលប្រយោជន៍រួមរបស់ប្រជាជនខ្មែរ និងប្រទេសជាតិទាំងមូល។

ឯកឧត្តមក៏សូមថ្លែងអំណរគុណដល់អ្នកស្រី រតនា និងលោក គឹមសេង ដែលបានយល់ពីកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់អង្គរ និងបានស្ម័គ្រចិត្តចូលរួមដោយឆន្ទៈពិតៗជាមួយអាជ្ញាធរជាតិអប្សរាក្នុងការរុះរើភោជនីយដ្ឋានដើម្បីរៀបចំទីលានបដិសណ្ឋារកិច្ចមុខអង្គរវត្តបានល្អប្រសើរ សមជាប្រជាជាតិមួយដែលស្រឡាញ់មរតកដូនតាមានសណ្តាប់ធ្នាប់ និងមានការយល់ដឹងខ្ពស់ចំពោះបរិស្ថាន៕

អាជ្ញាធរជាតិអប្សរាកំពុងជួសជុលកែលម្អផ្លូវពីប្រាសាទប្រែរូបមកដល់មុខប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២០

តាមរយៈការចុះត្រួតពិនិត្យផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ នាព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ផ្លូវថ្នល់ចំនួន២កំណាត់ គឺចាប់ពីប្រាសាទប្រែរូបមកស្រះស្រង់ប្រវែង១០៧៦ម៉ែត្រនិងពីស្រះស្រង់ដល់មុខប្រាសាទបន្ទាយក្តី ប្រវែង១៤០០ម៉ែត្រ ត្រូវបានអាជ្ញាធរជាតិអប្សរាបាននិងកំពុងយកចិត្តទុកដាក់ជួសជុល ពង្រីក និងកែលម្អទៅតាមបទដ្ឋានបេតិកភណ្ឌ ។

ឯកឧត្តមបន្តថា ការជួសជុលកែលម្អផ្លូវនេះគឺដើម្បីឱ្យផ្លូវមានសោភណ្ឌភាពល្អស្អាត និងសម្រួលដល់ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

ផ្លូវនេះមានទំហំចាប់ពី០៦ម៉ែត្រ ទៅ០៨ម៉ែត្រទៅតាមស្ថានភាពជាក់ស្តែង។ សូមបញ្ជាក់ថាកំណាត់ទី១ ពីប្រាសាទប្រែរូបមកស្រះស្រង់បានអ៊ិតបេតុងកៅស៊ូរួចរាល់ហើយ រីឯកំណាត់ទី២ កំពុងតែបង្ហាប់គ្រឹះ និងគ្រោងនឹងបញ្ចប់ក្នុងខែមីនាខាងមុខនេះ។



គណៈកម្មការជាតិយូណេស្កូ និងសាកលវិទ្យាល័យ Sungkyunkwan នៃប្រទេសកូរ៉េខាងត្បូង ដឹកនាំនិស្សិតមកសិក្សាស្វែងយល់ពីកិច្ចការអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០២០

នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករងតំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធនឹងកិច្ចការអភិរក្សបេតិកភណ្ឌអង្គរ បានទទួលជួបប្រតិភូមកពីប្រទេសកូរ៉េខាងត្បូង ដឹកនាំដោយលោកបណ្ឌិត Cindy Si Yeon Rim អ្នកឯកទេសកម្មវិធីសិក្សាជាន់ខ្ពស់នៃគណៈកម្មការជាតិយូណេស្កូ និងលោក KIM Kwibae ជំនួយការអគ្គលេខាធិការនៃស្ថាប័នសាកលវិទ្យាល័យ Sungkyunkwan នៃប្រទេសកូរ៉េ។

ជំនួបនេះ ក្នុងគោលបំណងស្វែងយល់ផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងវិស័យបេតិកភណ្ឌ និងដំណើរការគ្រប់គ្រងបេតិកភណ្ឌពិភពលោកនៃរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ជាការចែករំលែកចំណេះដឹងទៅដល់សិស្សនិស្សិតកូរ៉េខាងត្បូង។

ក្នុងនោះដែរ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា បានលើកឡើងនូវព័ត៌មានទូទៅរបស់អាជ្ញាធរជាតិអប្សរាទៅកាន់ភាគីប្រទេសកូរ៉េ អំពីតួនាទី និងភារកិច្ចសំខាន់ៗ ព្រមទាំងចែករំលែកនូវបទពិសោធន៍នៃការគ្រប់គ្រងបេតិកភណ្ឌក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរដល់ស្ថាប័នទាំងពីររបស់ប្រទេសកូរ៉េខាងត្បូង។ លើសពីនេះ ក៏មានការលើកឡើងជាសំណួរមកកាន់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា នូវចម្ងល់ផ្សេងៗដើម្បីស្វែងយល់កាន់តែច្បាស់ពាក់ព័ន្ធនឹងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកុម្ភៈ

ការសម្អាតផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់ជាប្រចាំក្នុងការបោស និងលាងសម្អាតផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ ជាពិសេស ផ្លូវមុខប្រាសាទអង្គរវត្ត ដែលប្រលាក់ខ្លាំងដោយសារការបើកបរយានយន្តចូលកន្លែងហាមឃាត់ និងការចតខុសទីតាំងចំណត ព្រមទាំងការយកចិញ្ចើម និងចំណីផ្លូវលក់ដូរ ។

ដូចនេះដើម្បីឱ្យផ្លូវថ្នល់ស្អាតជាប្រចាំ ចាំបាច់ទាមទារឱ្យមានការចូលរួមចំណែកពីអ្នកបើកបរ និងអាជីវករទាំងអស់ ជាមួយនឹងអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរមានសមត្ថកិច្ចពាក់ពន្ធ័៕

ក្រុមភ្នាក់ងារទេសចរចូលរួមសម្អាតអនាម័យនៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ទៅលើសោភ័ណភាព រួមទាំងសុវត្ថិភាពចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលបានមកទស្សនាប្រាសាទនៅក្នុងតំបន់អង្គរ ដែលជាតំបន់បេតិកភណ្ឌពិភពលោក។

ជាក់ស្ដែង ភ្នាក់ងារទេសចរដែលក្រៅពីមានតួនាទីពិនិត្យមើលរបៀបរៀបរយចំពោះភ្ញៀវទេសចរហើយ នៅរដូវក្ដៅនេះ ក្រុមការងារបានសម្អាតធូលីនៅតាមជណ្ដើរឡើងប្រាសាទ និងទីតាំងផ្សេងៗនៃប្រាសាទអង្គរវត្តទាំងមូល ដើម្បីលើកកម្ពស់សោភ័ពភាពក្នុងប្រាសាទ និងសុខុមាលភាពនៃភ្ញៀវទេសចរដែលចូលមកទស្សនាក្នុងប្រាសាទដ៏ល្បីល្បាញមួយនេះ មិនឱ្យមានផលប៉ះពាល់ដល់សុខភាព និងអារម្មណ៍ក្នុងពេលទស្សនា។

នេះជាការលើកកម្ពស់អនាម័យ និងបរិស្ថានក្នុងប្រាសាទអង្គរវត្តឱ្យកាន់តែល្អប្រសើរ ដែលភ្នាក់ងារទេសចរប្រចាំប្រាសាទអង្គរវត្ត ក៏ដូចជាតាមបណ្ដាប្រាសាទគោលដៅក្នុងតំបន់រមណីយដ្ឋានអង្គរបាននាំគ្នាបោសសម្អាត ថែរក្សាអនាម័យបរិស្ថានជាប្រចាំ៕

សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ ដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ០១០៥.../ឃ.សជណ
/២០

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើម និងកាត់ក្រីមែកឈើ
ដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងនៅតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

-កាត់សម្អាតដើមឈើចំនួន **០២ដើម** ដែលបានរលំដួលដោយសារភ្លៀង និងខ្យល់ ស្ថិតនៅជាប់នឹងជើងកំពែងអង្គរធំទិសខាងជើង ខាងកើតខ្លោងទ្វារដីឆ្នាំង។

-កាត់ដកហូតដើមឈើ **០១ដើម** និងកាត់ក្រីមែកឈើចំនួន **០២ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅលើកំពែងអង្គរធំ ខាងកើតខ្លោងទ្វារដីឆ្នាំង កន្លែងជួសជុសកំពែង។

-កាត់ដកហូតដើមឈើចំនួន **០៣ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប។

-កាត់ក្រីមែកឈើចំនួន **០៧ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅសាលាបឋមសិក្សាបាយ័ន ក្នុងបរិវេណវត្តព្រះសេរអារ្យ។

-កាត់ក្រីមែកឈើចំនួន **០២ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅបរិវេណប្រាសាទអកយំ។

-កាត់ក្រីមែកឈើចំនួន **០៩ដើម** ដែលមានហានិភ័យខ្ពស់ ស្ថិតនៅខ្លោងទ្វារតាកាវ។

-កាត់ដកហូតដើមឈើងាប់ **០១ដើម** និងកាត់ក្រីមែកឈើ ០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម។

-កាត់ដកហូតដើមឈើទាលងាប់ **០១ដើម** ដែលមានហានិភ័យខ្ពស់ ដុះនៅជាប់មាត់ផ្លូវ ស្ថិតនៅខាងកើតប្រាសាទបន្ទាយក្តី។

-កាត់ដកហូតដើមឈើចំនួន **១២៦ដើម** ដែលមានហានិភ័យខ្ពស់ លើរចនាសម្ព័ន្ធប្រាសាទ ប៉ះពាល់សោភ័ណភាព និងទេសភាពវប្បធម៌ ស្ថិតនៅក្នុងបរិវេណប្រាសាទអង្គរវត្ត។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២០ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៥កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២០

ភ្នំពេញ:
មហាវិថីសហព័ន្ធរុស្ស៊ី លេខ៨១ សង្កាត់មិត្តភាព ខណ្ឌ៧មករា
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦

អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាននិងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

លោកជំទាវ ភឿង សកុណា ចូលជួបធ្វើបដិសណ្ឋារកិច្ច ជាមួយអនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន

ផ្សាយនៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០

ក្នុងឱកាសដឹកនាំគណៈប្រតិភូបំពេញការងារនៅទីក្រុងតូក្យូប្រទេសជប៉ុន នៅព្រឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរាបានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ **ឯកឧត្តម** NAKAYAMA Norihiro អនុរដ្ឋមន្ត្រីក្រសួងការទេសជប៉ុន លើកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ ការជួសជុលប្រាង្គប្រាសាទបុរាណក្នុងរមណីយដ្ឋានអង្គរ និងការបណ្តុះបណ្តាលធនធានមនុស្ស។

ជំនួបដ៏ថ្លៃថ្លានេះបានពង្រីកបន្ថែមនូវកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងជប៉ុនឱ្យកាន់តែមានភាពខ្លាំងក្លាជាងមុន ព្រមទាំងបង្កើតនូវបរិយាកាសយ៉ាងល្អប្រសើរដើម្បីលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍រវាងគ្នានិងគ្នាទៅលើកិច្ចការវប្បធម៌ និងអនុវត្តន៍នូវគម្រោងអភិរក្សប្រាង្គប្រាសាទបុរាណខ្មែរនៅរមណីយដ្ឋានអង្គរ៕

ក្នុងខែមករា ឆ្នាំ២០២០នេះ អ្នកស្រុកអង្គរចំនួន១២២គ្រួសារ ទទួលបានការអនុញ្ញាតឱ្យជួសជុលសំណង់ស្រាល

ផ្សាយនៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០២០

យោងតាមរបាយការណ៍ក្រុមការងារលេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា ក្នុងខែមករាឆ្នាំ២០២០នេះ ក្រុមការងារបានបន្តការងារចុះពិនិត្យអនុញ្ញាតការជួសជុលសំណង់តូចតាច ដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរបានចំនួន២៤៦ករណី(សំណើ) ក្នុងនោះ សំណង់ស្រាល ដែលត្រូវបានក្រុមការងារអនុញ្ញាតមានចំនួន ១២២ ករណី(សំណើ)។

គោលដៅទាំងនោះ រួមមានស្រុកប្រាសាទបាគង អនុញ្ញាតបានចំនួន២៥ករណី ស្រុកអង្គរធំ អនុញ្ញាតបានចំនួន ១៥ករណី ស្រុកពួក អនុញ្ញាតបានចំនួន២៧ករណី ក្រុងសៀមរាប អនុញ្ញាតបានចំនួន៣៣ករណី និងស្រុកបន្ទាយស្រី អនុញ្ញាតបានចំនួន២២ ករណី។

ការអនុញ្ញាតនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារសហគមន៍បានចុះពិនិត្យទៅដល់ខ្នងផ្ទះដាក់ស្តែងនិងឯកសារពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាមូលដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃថា ពួកគាត់គឺជាប្រជាពលរដ្ឋចាស់រស់នៅក្នុងតំបន់អង្គរពិតប្រាកដនិងមានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-សង្កាត់ ហើយមានតម្រូវការដាក់ស្តែងក្នុងការកែលម្អការរស់នៅឱ្យបានល្អប្រសើរ។

លោកជំទាវ ភឿង សកុណា ស្នើស្ថាប័នមូលនិធិជប៉ុនថតសិល្បៈរបាំបុរាណខ្មែរក្នុងទម្រង់3D

ផ្សាយនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២០

ក្នុងឱកាសដឹកនាំគណៈប្រតិភូបំពេញការងារនៅទីក្រុងតូក្យូប្រទេសជប៉ុន នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរាបានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ លោក Hiroyasu Ando ប្រធានស្ថាប័នមូលនិធិជប៉ុន (JAPAN FOUNDATION)។

ថ្លែងក្នុងជំនួបនេះ លោកជំទាវបានថ្លែងអំណរគុណដល់លោកប្រធានHiroyasuAndoដែលបានគាំទ្រមជ្ឈមណ្ឌលអាស៊ីនៅកម្ពុជា ព្រមទាំងសំណូមពរឱ្យលោកបន្តការគាំទ្រនេះចាប់ពីឆ្នាំ២០២១ជាបន្តទៀត។ ម្យ៉ាងវិញទៀត លោកជំទាវ ក៏សំណូមពរឱ្យលោកប្រធានមូលនិធិជប៉ុនពិចារណាក្នុងការបង្កើតការិយាល័យមជ្ឈមណ្ឌលអាស៊ីនៅប្រទេសកម្ពុជា។



បន្ថែមពីនោះទៀត លោកជំទាវក៏បានសំណូមពរដល់លោកប្រធានមូលនិធិជប៉ុន ផ្តល់អ្នកជំនាញដើម្បីថតជាឯកសារវីដេអូពីសិល្បៈបុរាណខ្មែរ ជាពិសេសរបាំព្រះរាជទ្រព្យ ក្នុងទម្រង់3D ដើម្បីទុកជាឯកសារសម្រាប់បង្ហាត់បង្រៀនកូនចៅខ្មែរជំនាន់ក្រោយ៕

ខែមករា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាផ្ដល់ថវិកាបដិភាគសាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋចំនួន២៩គ្រួសារ

ផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២០

នៅខែមករា ឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរា បានផ្ដល់ថវិកាបដិភាគក្នុងការសាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋរស់នៅរមណីយដ្ឋានអង្គរបានចំនួន២៩ គ្រួសារ នៅភូមិត្នោតពង ឃុំនគរធំ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

បង្គន់ចំនួន២៩នេះ តាមរយៈពីការប្រើប្រាស់ថវិកាបដិភាគរបស់គម្រោងសុវត្ថិកម្មនៃការសម្អាតទឹកនិងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរ PAAGERA នៃអាជ្ញាធរជាតិអប្សរា ចំនួន៤០% និងម្ចាស់សំណើចំណាយ៦០%។

ការចូលរួមចំណែកនេះ គឺដើម្បីឱ្យប្រជាជនដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ មានបង្គន់អនាម័យសម្រាប់ប្រើប្រាស់អោយបានគ្រប់គ្នា ចៀសវាងការបន្ទោរបង់ពាសវាលពាសកាល កាត់បន្ថយជំងឺឆ្លងផ្សេងៗ ជំរុញឱ្យអ្នកស្រុកអង្គរចេះរស់នៅស្អាតមានអនាម័យនិងចូលរួមលើកកម្ពស់បរិស្ថានតំបន់អង្គរទាំងមូលផងដែរ។

សូមរំឭកថា ចាប់តាំងពីខែសីហាឆ្នាំ២០១៨មក ហើយគិតមកដល់ពេលពេលនេះ គម្រោង PAAGERA នៃអាជ្ញាធរជាតិអប្សរាបានចូលរួមបដិភាគក្នុងការសាងសង់បង្គន់អនាម័យបាន ១១១០បង្គន់៕

អាជ្ញាធរជាតិអប្សរាចាប់ផ្តើមដំណើរការស្ថាបនាផ្លូវខាងមុខព្រះលានជល់ដំរីនៅដើមខែកុម្ភៈនេះ

ផ្សាយនៅថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២០

គម្រោងស្ថាបនាផ្លូវកៅស៊ូថ្មីនៅលើគន្លងផ្លូវដីក្រហមចាស់ ដែលមានអាយុកាលតាំងពីឆ្នាំ១៩១២ ដែលមានទីតាំងនៅមុខបរិវេណប្រាសាទសួរព្រ័ត្រ ជំនួសការប្រើប្រាស់ផ្លូវកៅស៊ូបច្ចុប្បន្នមុខព្រះលានជល់ដំរី នឹងចាប់ផ្តើមដំណើរការសាងសង់នៅដើមខែកុម្ភៈ ឆ្នាំ២០២០ នេះ ដោយប្រើរយៈពេល០៥ខែ។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានលើកឡើងថា ការធ្វើផ្លូវវាងនេះគឺដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើចនាសម្ព័ន្ធ នៃព្រះលានជល់ដំរី ដោយសាររំញ័រពីការបើកបររថយន្ត និងផ្សែងពុលពីយានយន្តគ្រប់ប្រភេទ ពិសេសដើម្បីរក្សាសុវត្ថិភាពរបស់ភ្ញៀវទេសចរពេលដើរឆ្លងកាត់ទៅទស្សនាប្រាសាទជៀសវាងមានគ្រោះថ្នាក់ផ្សេងៗ ព្រោះផ្លូវកៅស៊ូចាស់នេះនៅជាប់នឹងព្រះលានជល់ដំរីខ្លាំងពេក។

ឯកឧត្តមបន្ថែមថា ការស្ថាបនាផ្លូវថ្មីនេះមានប្រវែងសរុប ១៤២៧ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទផ្លូវកៅស៊ូពណ៌ក្រហមចាស់ ដែលផ្តើមចេញពីផ្លូវកែងជ្រុងខាងកើតឈៀងខាងជើងនៃប្រាសាទបាយ័ន្ត ឆ្ពោះទៅខ្លោងទ្វារដីឆ្នាំង ដោយបត់ឆ្វេងមុនទៅដល់ប្រាសាទព្រះពិធូរ ភ្ជាប់ទៅនឹងផ្លូវកៅស៊ូចាស់មុខវត្តទេពប្រណម្យ។

ក្រោយពេលសាងសង់ផ្លូវនេះរួចរាល់ អាជ្ញាធរជាតិអប្សរានឹងផ្អាកការប្រើប្រាស់ផ្លូវកៅស៊ូបច្ចុប្បន្នទាំងស្រុង ហើយកែលម្អផ្លូវនោះជាសួនដាំស្មៅ ដើមឈើដើម្បីឱ្យមានទេសភាព និងបរិស្ថានល្អស្អាតនៅមុខព្រះលានជល់ដំរី ក៏ដូចជានៅក្នុងបរិវេណក្រុងអង្គរធំទាំងមូល៕

លោកជំទាវ ភឿង សកុណា ចូលរួមសន្និសីទអន្តរជាតិស្តីពីទឹកនិងវប្បធម៌ ក្រោមព្រះរាជាធិបតីភាពព្រះចៅអធិរាជជប៉ុន

ផ្សាយនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០២០

ក្នុងសន្និសីទអន្តរជាតិស្តីពីទឹក និងវប្បធម៌ក្រោមប្រធានបទ "ការសិក្សាអំពីបេតិកភណ្ឌទឹកដើម្បីការអភិវឌ្ឍប្រចាំតំបន់ប្រកបដោយភាពច្នៃប្រឌិត" **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា បានធ្វើបទអន្តរាគមន៍ស្តីពីវប្បធម៌ និងការគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរទទួលបានការ ចាប់អារម្មណ៍យ៉ាងខ្លាំងពីអង្គសន្និសីទទាំងមូល។

សន្និសីទអន្តរជាតិស្តីពីទឹកនិងវប្បធម៌ រៀបចំឡើងក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ហើយលោក ជំទាវរដ្ឋមន្ត្រី បានចូលរួមធ្វើជាវាគ្មិនគន្លឹះលើប្រធានបទអំពីវប្បធម៌ និងការគ្រប់គ្រងទឹកក្នុងរមណីយដ្ឋានអង្គរ ដោយលោកជំទាវ បានលើកឡើងពីការថែរក្សាការអភិរក្ស បញ្ហាប្រឈម និងដំណោះស្រាយក្នុងការគ្រប់គ្រងទឹក ព្រមទាំងទំនាក់ទំនងរវាងទឹកនិងវប្បធម៌។ តាមរយៈបទអន្តរាគមន៍របស់លោកជំទាវ បានធ្វើឲ្យព្រះចៅអធិរាជជប៉ុននិងអ្នកចូលរួមទាំងអស់ពេញព្រះរាជហឫទ័យ និងពេញចិត្តយ៉ាងខ្លាំង ចំពោះការគ្រប់គ្រងទឹកនៅក្នុងរមណីយដ្ឋានអង្គរទាំងមូល។

សន្និសីទអន្តរជាតិស្តីពីទឹកនិងវប្បធម៌ "ការសិក្សាអំពីបេតិកភណ្ឌទឹក ដើម្បីការអភិវឌ្ឍប្រចាំតំបន់ប្រកបដោយភាពច្នៃប្រឌិត" រៀបចំនិងការចូលរួមពីអ្នកជំនាញជាន់ខ្ពស់របស់ស្ថាប័នធំៗនៃប្រទេសជប៉ុន កូរ៉េ ហូឡង់ ប្រេស៊ីល ចិន អូស្ត្រាលី ឥណ្ឌា បាគីស្ថាន ឥណ្ឌូនេស៊ី សហរដ្ឋអាមេរិក កម្ពុជា និងអង្គការសហប្រជាជាតិ៕



ច្រាំងកសិន្ធុអង្គរវត្តសរុបប្រវែង៩០ម៉ែត្រដែលអាជ្ញាធរជាតិអប្សរា ជួសជុលបានសម្រេចក្នុងរយៈពេល៨ឆ្នាំ

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

ច្រាំងកសិន្ធុអង្គរវត្ត ជ្រុងខាងជើងស្ពានហាលសរុបប្រវែង ៩០ម៉ែត្រ ត្រូវបានអ្នកជំនាញអាជ្ញាធរជាតិអប្សរាជួសជុលសម្រេចបានក្នុងរយៈ៨ឆ្នាំកន្លងមកនេះ។

ការជួសជុលនេះធ្វើឡើងក្នុងបំណងលើកកម្ពស់សោភ័ណភាពទេសភាពប្រាសាទអង្គរវត្តឱ្យកាន់តែមានភាពទាក់ទាញ ពង្រឹងច្រាំងកសិន្ធុឱ្យមានរូបរាងដើមឡើងវិញ ព្រមទាំងជួយលើកសម្រស់ស្ពានហាលសម្រាប់ភ្ញៀវទេសចរជាតិ អន្តរជាតិ ចូលទស្សនាប្រាសាទអង្គរវត្តឱ្យកាន់តែរឹងមាំ។

លោក ម៉ៅ សុខនី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការរបស់អាជ្ញាធរជាតិអប្សរាបានឱ្យដឹងថាមូលហេតុសំខាន់ៗដែលបណ្តាលឱ្យច្រាំងកសិន្ធុខូចរចនាសម្ព័ន្ធ ដោយសារអាយុកាលនៃសំណង់ សត្វកណ្ដៀរពូនលើកាំជណ្តើរ កង្វះការថែទាំជាប្រចាំ ថ្ម គ្រឹះក្រោមពុកផុយនៃស្រទាប់ថ្មបាយក្រៀមខាងក្រោម ហើយដើមឈើធំៗដែលដុះក្បែរច្រាំងបានចាក់ឫសជ្រែកទៅក្នុងថ្ម ធ្វើឱ្យថ្មរំកិលពីទីតាំងដើមនៃច្រាំងកសិន្ធុទៀតផង។

លោក សុខនី បញ្ជាក់ទៀតថា ក្នុងរយៈពេល៨ឆ្នាំមកនេះ អ្នកជំនាញអាជ្ញាធរជាតិអប្សរា បានជួសជុលច្រាំងកសិន្ធុអង្គរវត្តនៅខាងជើងស្ពានហាលជាជំណាក់កាល ដូចជា ចាប់ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៧ ជួសជុលបានប្រវែង ៤០ម៉ែត្រ។ឆ្នាំ២០១៩ ជួសជុលបាន២០ម៉ែត្រ ដែលមាន ១០ម៉ែត្រ ត្រង់ចំណុចប្រព័ន្ធលូ ហើយឆ្នាំ២០២០ គឺជួសជុលបាន២០ម៉ែត្រ។

ក្នុងការជួសជុល អ្នកជំនាញបានប្រើបច្ចេកទេសបុរាណដោយកាយដីចាស់ ដីស្អុយចេញ ហើយចាក់ជំនួសដោយដីថ្មី រួចបុកបង្ហាប់គ្រឹះក្រោមឱ្យមាំជាមួយថ្មភ្នំ ដីខ្សាច់ល្បាយដី កម្ទេចថ្មបាយក្រៀម និងកំបោរស។ ពិសេសបាតគ្រឹះបានតម្រៀបថ្មឆ្លាស់គ្នាទទឹង បណ្តោយដើម្បីជួយទប់កម្លាំងសង្កត់ ព្រមទាំងយកដីឥដ្ឋមកការពារជម្រាបទឹកកុំឱ្យចូលបាតក្រោមជាដើម ដើម្បីឱ្យគ្រឹះនៅរឹងមាំយូរអង្វែង។

កន្លងមក ដៃគូអន្តរជាតិជាច្រើនដូចជា ប្រទេសបារាំង ប្រទេសឥណ្ឌា ប្រទេសអ៊ីតាលី បានមកជួសជុលច្រាំងកសិន្ធុអង្គរវត្ត កាំជណ្តើរ និងផ្លូវចូលខាងមុខប្រាសាទអង្គរវត្ត ថែមទាំងជួយបណ្តុះបណ្តាលអ្នកជំនាញអាជ្ញាធរអប្សរាជាច្រើនរូបដែរ ក្នុងការអភិរក្សសំណង់បុរាណមួយនេះ៕

សេចក្តីជូនដំណឹងស្តីពីការស្តារកំណាកដីល្បាយខ្សាច់ដោយប្រើប្រាស់ម៉ាស៊ីន Excavator នៅស្រះទឹកខាងជើងនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ០២៤៤/២០.អ៧ជ៣

សេចក្តីជូនដំណឹង
ស្តីពី
ការស្តារកំណាកដីល្បាយខ្សាច់ដោយប្រើប្រាស់ម៉ាស៊ីន Excavator នៅស្រះទឹកខាងជើងនៃប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា៖ តាមរយៈការធ្វើកំណាយបុរាណវិទ្យានៅស្រះទឹកខាងជើងនៃប្រាសាទអង្គរវត្ត ក្រុមការងារបានរកឃើញកំណាកដីល្បាយខ្សាច់ប្រហែល១២៦ម៉ែត្រគូប ជាប្រភេទកំណាកដីថ្មី នៅលាយឡំជាមួយសំណល់សម័យថ្មីដូចជា ថង់ប្លាស្ទិក ដបទឹកប្លាស្ទិក គំរបដប និងដបកែវ ។ល។ ក្រុមការងារនឹងធ្វើការស្តារកំណាកដីថ្មីទាំងនេះចេញ ដើម្បីស្វែងយល់បន្ថែមអំពីស្រទាប់ដីបុរាណវិទ្យាដែលមានទំនាក់ទំនងទៅនឹងស្ថានភាពទ្រុឌទ្រោមនៃកាំជណ្តើរមាត់ច្រាំង និងជាមូលដ្ឋានមួយសំខាន់ក្នុងការកំណត់កម្រិតនៃការស្តារស្រះទឹក នៅដំណាក់កាលបន្តបន្ទាប់ ដោយហេតុថាស្រទាប់ដីបុរាណវិទ្យាខ្លះមានប្រយោជន៍ សម្រាប់ការសិក្សាស្រាវជ្រាវអំពីជីវសាស្ត្រចម្រុះសម័យបុរាណ។ ក្នុងន័យនេះ ដើម្បីឱ្យការងារជួសជុលស្រះទឹកខាងជើងនៃប្រាសាទអង្គរវត្តអាចដំណើរការស្របតាមបច្ចេកទេសនៃការងារអភិរក្ស អាជ្ញាធរជាតិអប្សរានឹងស្តារកំណាកដីថ្មីដោយប្រើប្រាស់ម៉ាស៊ីន Excavator ខ្នាតកណ្តាល០៥ មានមុខប៉ែលទំហំ៧៥សង់ទីម៉ែត្រ ចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០នេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ២ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
អាជ្ញាធរជាតិអប្សរា

ភ្នំពេញ៖
អគារលេខ៤៤ ផ្លូវលេខ២១៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៤១/ ០២៣ ២១៥ ៧៧៦
រដ្ឋាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh
សៀមរាប៖
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

Scanned with CamScanner

អាជ្ញាធរជាតិអប្សរាបានរកឃើញជើងទ្វារបាលនៅប្រាសាទទន្លេស្ងួត ក្រោយពីរកឃើញដងខ្លួនកាលពី៣ឆ្នាំមុន

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២០

បំណែកជើងបដិមាមួយ ត្រូវបានក្រុមការងារជួសជុលប្រាសាទទន្លេស្ងួតនៃអាជ្ញាធរជាតិអប្សរា រកឃើញកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

បំណែកជើងបដិមានេះ ត្រូវបានរកឃើញនៅទីតាំងដែលមានចម្ងាយត្រឹមតែ១ម៉ែត្រពីចុងជើងនៃទ្វារបាលដែលបានរកឃើញកាលពីឆ្នាំ២០១៧ ដោយគម្រោងស្រាវជ្រាវរវាងអាជ្ញាធរជាតិអប្សរា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍ នៃប្រទេសសិង្ហបុរី (ISEAS)។

បន្ទាប់ពីការរកឃើញ នៅព្រឹកថ្ងៃទី១០ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីបញ្ជាក់ថាជាបំណែកជើងរបស់បដិមាទ្វារបាល ក្រុមការងារអភិរក្ស និងជួសជុលវត្ថុសិល្បៈ ហៅកាត់ថា I.T.A.L.I.A នៃអាជ្ញាធរជាតិអប្សរា បានធ្វើពុម្ពចម្លងពីបដិមាទ្វារបាលនៅអភិរក្សដ្ឋានអង្គរ មកផ្ទៀបនឹងបំណែកជើងនៅប្រាសាទទន្លេស្ងួត។ តាមរយៈការផ្ទៀបនេះ ក្រុមការងារបញ្ជាក់ថា បំណែកជើងនេះគឺពិតជាផ្នែកមួយនៃបដិមាទ្វារបាល។

បច្ចុប្បន្ន ក្រុមការងារអភិរក្សនិងជួសជុលវត្ថុសិល្បៈ កំពុងរៀបចំឯកសារបច្ចេកទេសដើម្បីយកបំណែកជើងបដិមាមកផ្គុំនឹងទ្វារបាលដែលកំពុងជួសជុលនៅអភិរក្សដ្ឋានអង្គរ៕

ភ្នាក់ងារទេសចរណ៍សម្អាតបរិស្ថាននិងអនាម័យនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២០

ភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទអង្គរវត្ត បាននាំគ្នាសម្អាតបរិស្ថាន រៀបចំអនាម័យនៅក្តារបែន និងតាមបរិវេណប្រាសាទអង្គរវត្តទាំងមូល ដើម្បីលើកកម្ពស់សោភ័ណភាពក្នុងប្រាសាទ និងសុខុមាលភាពភ្ញៀវទេសចរដែលចូលមកទស្សនាក្នុងប្រាសាទដ៏ល្បីល្បាញមួយនេះ មិនឱ្យមានផលប៉ះពាល់ដល់សុខភាពនិងអារម្មណ៍ក្នុងពេលទស្សនា៕

អាជ្ញាធរជាតិអប្សរាប្រារព្ធខួប២៥ឆ្នាំនៅសប្តាហ៍ក្រោយ

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២០

គិតត្រឹមថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ខាងមុខនេះ គឺមានរយៈពេល២៥ឆ្នាំហើយ ដែលអាជ្ញាធរជាតិអប្សរាត្រូវបានបង្កើតឡើង អនុលោមទៅតាមគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំង៥ សម្រាប់លក្ខខណ្ឌនៃការចុះបញ្ជីរមណីយដ្ឋានអង្គរជាសម្បត្តិបេតិកភណ្ឌពិភពលោក។

ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ អាជ្ញាធរជាតិអប្សរាសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងនោះរួមមានការងារអភិរក្សជួសជុលប្រាង្គប្រាសាទ ការអភិវឌ្ឍវិស័យទេសចរណ៍ ការស្តារ និងដាក់ឱ្យប្រើប្រាស់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរ ការជួសជុល និងកសាងប្រព័ន្ធហេដ្ឋារចនាសម្ពន្ធរូបវន្តនានា ជាពិសេសកិច្ចការសហគមន៍ក្នុងក្រុង/ស្រុកទាំង៥ នៃរមណីយដ្ឋានអង្គរ ដែលទាំងអស់នេះ បាននិងកំពុងចូលរួមចំណែកលើកកម្ពស់ធ្វើឱ្យកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់មានការប្រែប្រួល និងរីកចម្រើនគួរឱ្យកត់សម្គាល់។

ដើម្បីរំឭក ព្រមទាំងផ្សព្វផ្សាយពីស្នាដៃសម្រេចបានក្នុងរយៈពេល២៥ឆ្នាំនេះ ក៏ដូចជាចក្ខុវិស័យការងារនាពេលអនាគត អាជ្ញាធរជាតិអប្សរា នឹងរៀបចំស្តង់ផ្តល់ព័ត៌មានដើម្បីបង្ហាញនិងឆ្លើយសំណួរទូទៅ ការតាំងពិព័រណ៍ស្តីពីសមិទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅការងារសម្រាប់រយៈពេលពេញមួយសប្តាហ៍ ចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០ នៅបរិវេណប្រាសាទអង្គរវត្ត និងក្រុងអង្គរធំ។

ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរានឹងបើកទ្វារស្វាគមន៍ដល់សាធារណជន ព្រមទាំងសិស្ស និស្សិត ដើម្បីសិក្សាស្វែងយល់ពីការងារស្ថាប័នដោយផ្ទាល់ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។ ដើម្បីញ៉ាំងឱ្យព្រឹត្តិការណ៍ប្រារព្ធខួប២៥ឆ្នាំនេះ កាន់តែពោរពេញដោយការចងចាំ និងអធឹកអធមបន្ថែមទៀត អាជ្ញាធរជាតិអប្សរានឹងរៀបចំពិធីសាសនានៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ដាក់ចង្ហាន់បិណ្ឌបាត្រប្រគេនព្រះសង្ឃចំនួន២២៥អង្គ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០២០វេលាម៉ោង៧៖៣០នាទីព្រឹកបន្ថែមទៀត។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមស្នើអញ្ជើញសាធារណជនទាំងអស់ ចូលរួមទស្សនាព្រឹត្តិការណ៍ និងពិធីសាសនាដូចមានជម្រាបជូនខាងលើ ឱ្យបានច្រើនកុះករ៕

សវនករស្ថាប័នធានាគុណភាពជប៉ុន ធ្វើសវនកម្មផ្ទៃក្រៅ តាមដានការងារបរិស្ថាន-អង្គរ

ផ្សាយនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២០

សវនកម្មនេះធ្វើឡើងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ចែកជា២ផ្នែកធំៗ ដោយចុះពិនិត្យវាយតម្លៃនៅតាមនាយកដ្ឋានអង្គភាពចំណុះឱ្យអាជ្ញាធរជាតិអប្សរា និងចុះត្រួតពិនិត្យនៅតាមរណីយដ្ឋានអង្គរដោយផ្ទាល់។

តំណាងស្ថាប័ន JQA និងជាសវនករលោក ម៉ាម៉ូរុ យ៉ាម៉ាដា (Mamoru YAMADA) បានលើកឡើងថា គោលបំណងនៃសវនកម្ម គឺដើម្បីតាមដានពិនិត្យភាពអនុលោមជាប្រចាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅក្នុងរយៈពេលនៃសុពលភាព (៣ឆ្នាំ) ស្តង់ដារ ISO14001: 2015 បន្តពីសវនកម្មឆ្នាំទៅមិញ។

លោកបន្តថា ចំណុចយកចិត្តទុកដាក់នៅពេលធ្វើសវនកម្មសាថ្មី រួមមាន៖ ១. ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង បរិស្ថានទាំងមូលឆ្លើយតបនឹងសភាពការប្រែប្រួលផ្ទៃក្រៅ និងផ្ទៃក្នុង។ ២. ភាពទាក់ទងគ្នាជាប្រចាំ ព្រមទាំងលក្ខណៈអាចអនុវត្តបាននៃប្រព័ន្ធគ្រប់គ្រងបរិស្ថានឆ្លើយតបនឹងវិសាលភាពនៃវិញ្ញាប័នបត្រ។ ៣. ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន ព្រមជាមួយការចាត់ចែងបន្តការកែលម្អ ដើម្បីបង្កើនការសម្តែងបរិស្ថានទាំងមូល។ ៤. អំណោយផលនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងទៅលើការសម្រេចគោលនយោបាយបរិស្ថាន និងគោលដៅបរិស្ថានរបស់ស្ថាប័ន

ដើម្បីកែលម្អជាប្រចាំឈរលើការអនុវត្តជាខ្សែសង្វាក់ (មានទំនាក់ទំនងជាមួយគ្នា) ការគោរពច្បាប់ ។ល។ ៥. ពិនិត្យបញ្ជាក់អំពីស្ថានភាពកែលម្អជាប្រចាំតាមរយៈការបង្វិលកង PDCA (Plan, Do, Check, Act)។

ឯកឧត្តម សុខ លក្ខិណា ប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា មានបប្រសាសន៍ថា អាជ្ញាធរជាតិអប្សរាបានធ្វើការជាមួយស្ថាប័ន JQA និងបានអនុវត្តទៅតាមស្តង់ដារ ISO 4001 ដែលចែកចេញជា២ដំណាក់កាល។ ដំណាក់កាលទី១ ចាប់ពីឆ្នាំ២០០៦ ដល់២០១៨ ទទួលបានវិញ្ញាប័នបត្រចំនួន៤។ ឯកឧត្តមបន្តថា ឆ្នាំ២០១៨ យើងបានអនុវត្តនូវស្តង់ដារថ្មី ISO 14001 2015 ហើយតាមស្តងដារថ្មីនេះ ទទួលបានវិញ្ញា-ប័នបត្រមួយ។ ដោយឡែកឆ្នាំទី២នេះ ការពិនិត្យលើការអនុវត្តទៅតាមស្តង់ដារថ្មីរបស់យើង ដើម្បីឱ្យប្រាកដថាតើយើងអាចអនុវត្តបានទៅតាមស្តង់ដារដែរឬអត់ ការធ្វើសវនកម្មនៅពេលនេះ សង្ឃឹមថាយើងនឹងទទួលបានល្អប្រសើរ ដោយហេតុថា ឆ្នាំក្រោយគ្រប់សុពលភាព៣ឆ្នាំ ឈានទៅទទួលបានសុពលភាពថ្មីទៀត។

ឯកឧត្តម ឃិត ចាន់ដារដ្ឋ អគ្គនាយករង តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ជាបន្តបន្ទាប់ តាំងពីឆ្នាំ២006 អាជ្ញាធរជាតិអប្សរាតែងតែទទួលបានវិញ្ញាប័នបត្រ ISO 14001 នេះជាមោទនភាពមួយរបស់អាជ្ញាធរជាតិអប្សរាក្នុងនាមជាស្ថាប័នមួយគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក ហើយ ISO 14001 គឺជាឧបករណ៍មួយដ៏សំខាន់ក្នុងការរួមចំណែកលើកគុណតម្លៃរមណីយដ្ឋានអង្គរដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់មន្ត្រី-បុគ្គលិករបស់អាជ្ញាធរជាតិអប្សរាក្នុងការបំពេញកិច្ចការងារ ឆ្លើយតបទៅនឹងលក្ខណៈវិន្និច្ឆ័យរបស់ស្ថាប័ន JQA ទាំងបីរួមមានលក្ខណៈវិនិច្ឆ័យរបស់ស្ថាប័ន JQA ការអនុវត្តរបស់អង្គភាពEMS និងបទបញ្ញត្តិដែលអាជ្ញាធរជាតិអប្សរាបានដាក់ចេញ៕

អាជ្ញាធរជាតិអប្សរានឹងរៀបចំពិព័រណ៌រូបថតស្តីពីសកម្មភាព សមិទ្ធផល និងការងារសំខាន់ៗ ក្នុងឱកាសខួបលើកទី២៥ឆ្នាំ (ឆ្នាំ១៩៩៥-ឆ្នាំ២០២០)នៃការបង្កើតអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០

នៅទីតាំងមុខប្រាសាទអង្គរវត្តនិងព្រះលានជល់ដំរី ក្នុងបរិវេណក្រុងអង្គរធំ អាជ្ញាធរជាតិអប្សរានឹងរៀបចំពិព័រណ៌រូបថតស្តីពីសកម្មភាព សមិទ្ធផល និងការងារសំខាន់ៗ ក្នុងឱកាសខួបលើកទី២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា ដើម្បីបង្ហាញជូនសាធារណជន ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងប្រជាពលរដ្ឋ ទស្សនាស្វែងយល់បន្ថែមពីការងាររបស់អាជ្ញាធរជាតិអប្សរា។

ការតាំងពិព័រណ៍រូបភាពនេះនឹងប្រព្រឹត្តទៅពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។ ជាមួយនឹងការតាំងពិព័រណ៍រូបភាព អាជ្ញាធរជាតិអប្សរាក៏នឹងបើកការដ្ឋានជួសជុលមួយចំនួនជូនសាធារណជន ភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលទៅទស្សនា សិក្សាស្វែងយល់ដោយផ្ទាល់ពីកិច្ចការអភិរក្ស និងជួសជុលនៅរមណីយដ្ឋានអង្គរ។ ដើម្បីចូលទស្សនាតាមការដ្ឋានខាងលើ សូមពិនិត្យតារាងកម្មវិធីដូចមានភ្ជាប់ជូនមកជាមួយ៕

កម្មវិធីទស្សនកិច្ចនៅតាមការដ្ឋាន
ក្នុងរមណីយដ្ឋានអង្គរក្នុងឱកាសអបអរសាទរខួប២៥ឆ្នាំនៃការបង្កើត
អាជ្ញាធរជាតិអប្សរាដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០
ចាប់ពីម៉ោង៨:០០នាទីព្រឹក ដល់ម៉ោង៤:០០នាទីល្ងាច

កាលបរិច្ឆេទ	អ្នកសម្របសម្រួល	ទីកន្លែង	ម៉ោង	លេខទំនាក់ទំនង
១៥ កុម្ភៈ ២០២០	លោកស្រី នង បូរ៉ៃ	ការដ្ឋានព្រាំងកសិន្ទុប្រាសាទអង្គរវត្ត	៩:០០នាទីព្រឹក	០១២ ៧២១៨០៣
	លោកស្រី ភិន សច្ចា	ការដ្ឋានស្រះខាងជើងប្រាសាទអង្គរវត្ត	៤:០០នាទីរសៀល	០១២ ៦៦១៣០៣
១៦ កុម្ភៈ ២០២០	លោកស្រី ស៊ិម ដានី	ការដ្ឋានកំពែងក្រុងអង្គរធំ	៩:០០នាទីព្រឹក	០១០ ៩៦២៧៥៩
	លោក ជា សារិទ្ធ	ការដ្ឋានប្រាសាទទន្លេស្ងួត	៣:០០នាទីរសៀល	០១២ ៩៣៨៨៣០
១៧ កុម្ភៈ ២០២០	លោក សាក់យគីមហួល	ការដ្ឋានប្រាសាទបាគង	៩:០០នាទីព្រឹក	០១២ ៨៥០០២៦
	លោក មាន់ ដានិត	នៅអាងស្នាក់ខ្សាច់ កសិណប្រាសាទអង្គរវត្ត	៣:០០នាទីរសៀល	០៧៨ ២៦២៥២៧
១៨ កុម្ភៈ ២០២០	លោក ឈុន សំបុ	ការដ្ឋានស្ពានហាលប្រាសាទអង្គរវត្ត	៩:០០នាទីព្រឹក	០១២ ៩០៣៩៦៧
	លោក សយ សុភារិទ្ធ	ការដ្ឋានអភិរក្សថ្មប្រាសាទអង្គរវត្ត	៣:០០នាទីរសៀល	០១២ ៧៣១៨៣១
១៩ កុម្ភៈ ២០២០	លោក ញ៉ែម ស៊ើ	ការដ្ឋានបាកាយណ៍ខាងជើង	៩:០០នាទីព្រឹក	០៩២ ៨៩៧៨៣៦
២០ កុម្ភៈ ២០២០	លោក ពុទ្ធ សុទ្ធ	ការដ្ឋានប្រាសាទក្រហម នៅលើភ្នំគូលែន	៩:០០នាទីព្រឹក	០១២ ៨៥៦០២១
២១ កុម្ភៈ ២០២០	លោក ភ័ណ សោភា	ទីលានបង្ហាញកិច្ចប្រាសាទបន្ទាយស្រី និងមជ្ឈមណ្ឌលបកស្រាយព័ត៌មាន	៩:០០នាទីព្រឹក	០៩៣ ៧៣៣២៧២
២២ កុម្ភៈ ២០២០	លោក ជា សុជាតិ	ការដ្ឋានប្រាសាទអកយំ	៩:០០នាទីព្រឹក	០១២ ៦៩៨៩២៦

បញ្ជាក់៖
- ដើម្បីចូលរួមក្នុងកម្មវិធីខាងលើ សូមមេត្តាចុះឈ្មោះជាមុនតាមលេខទូរស័ព្ទ:០១១ ៥២៣៦៣៦/០៩៦២២២៤០៧៦
- ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីការដ្ឋានខាងលើ សូមទំនាក់ទំនងដោយផ្ទាល់ទៅអ្នកសម្របសម្រួលកម្មវិធី
- សូមធ្វើដំណើរតាមមធ្យោបាយផ្ទាល់ខ្លួនទៅកាន់ការដ្ឋាន

សវនករស្ថាប័នធានាគុណភាពជប៉ុន (JQA) បង្ហាញថា ប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា ពុំមានភាពមិនអនុលោមនោះឡើយ

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០

អស់រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ដែលសវនករស្ថាប័នធានាគុណភាពជប៉ុន (JQA) ធ្វើសវនកម្មផ្ទៃក្រៅតាមដានការងារបរិស្ថាន-អង្គរ ដើម្បីពិនិត្យវាយតម្លៃតាមនាយកដ្ឋាន អង្គភាពចំណុះនៃអាជ្ញាធរជាតិអប្សរា តាមប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា ថាបានអនុលោមតាមចំណុចទាមទារនៃស្តង់ដារ ISO14001:2015 ដែរឬទេនោះ ជាលទ្ធផលពុំមានឃើញភាពមិនអនុលោមទេ។

នេះបើតាមលើកឡើងរបស់លោក ម៉ាម៉ូរុ យ៉ាម៉ាដា (Mamoru YAMADA) តំណាងស្ថាប័ន JQA ក្នុងឱកាសបិទកម្មវិធីសវនកម្មផ្ទៃក្រៅតាមដានការងារបរិស្ថាន-អង្គរ នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

លោក ម៉ាម៉ូរុ យ៉ាម៉ាដា បន្តថា ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គររបស់អាជ្ញាធរជាតិអប្សរានៅតែបន្តត្រឹមត្រូវតាមចំណុចដែលទាមទារ។ ប៉ុន្តែលោកបានផ្តល់អនុសាសន៍៤ចំណុចសម្រាប់កែលម្អ ដូចជាទំនាក់ទំនងផ្ទៃក្នុង ផ្ទៃក្រៅការកំណត់គោលដៅការងារបរិស្ថាន និងគ្រប់គ្រងកំណត់ត្រានៃការកត់ត្រា ដើម្បីបង្កើនប្រសិទ្ធិភាពប្រើប្រាស់ ISO 14001:2015។

ឯកឧត្តម ឃិត ចាន់ដារដ្ឋ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថាលទ្ធផលទាំងនេះបង្ហាញឱ្យឃើញពីការខិតខំ និងការចូលរួម របស់មន្ត្រី-បុគ្គលិកជំរុញបរិស្ថាននៅតាមនាយកដ្ឋាននីមួយៗ រួមទាំងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ បានយកចិត្តទុកដាក់អនុវត្តធ្វើយ៉ាងណាឆ្លើយតបនូវលក្ខខណ្ឌនានាដើម្បីទទួលបានវិញ្ញាប័នបត្រ ISO 14001:2015។

ឯកឧត្តមបានបញ្ជាក់ថា ករណីនេះដូចជាវិញ្ញាសារប្រឡងមួយ កម្រនឹងមានភាពឥតខ្ចោះណាស់តែងមានកំហុសមួយចំនួន តែវាមិនធ្ងន់ធ្ងរដែលមិនអាចកែសម្រួលបានទេ យើងត្រូវទទួលស្គាល់កំហុស ដើម្បីដឹងនូវចំណុចខ្វះខាតរបស់ខ្លួន។ ឯកឧត្តម ក៏បានថ្លែងអំណរគុណចំពោះសវនករស្ថាប័នធានាគុណភាពជប៉ុន (JQA) លោក ម៉ាម៉ូរុ យ៉ាម៉ាដា ដែលបានខិតខំបំពេញការងារនឹងលះបង់ពេលវេលាមកវាយតម្លៃប្រកបដោយវិជ្ជាជីវៈ និងសុក្រិតភាពឆ្លុះបញ្ចាំងការពិតជាក់ស្តែង ដែលអាជ្ញាធរជាតិអប្សរាបានអនុវត្តទៅតាមគោលនយោបាយរបស់ស្ថាប័នធានាគុណភាពជប៉ុន (JQA)៕

សេចក្ដីជូនដំណឹងស្ដីពីការអនុវត្តគម្រោងរៀបចំប្រព័ន្ធរំដោះទឹក និងកែលម្អផ្លូវនៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ០១៦៣/២០ រប.សជណ

សេចក្ដីជូនដំណឹង
ស្ដីពី
ការអនុវត្តគម្រោងរៀបចំប្រព័ន្ធរំដោះទឹក និងកែលម្អផ្លូវនៅមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹង និងអំពាវនាវដល់គ្រប់ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព គ្រឹះស្ថានសិក្សា និស្សិត សិស្សានុសិស្ស សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ អ្នកដឹកជញ្ជូនភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ដើម្បីចូលរួមចំណែកធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ទេសភាព និងបរិស្ថាននៅបរិវេណមុខខាងលិចប្រាសាទអង្គរវត្ត មានភាពល្អប្រសើរ ព្រមទាំងលើកតម្លៃរមណីយដ្ឋានអង្គរដែលជានិមិត្តរូបនៃព្រលឹងជាតិខ្មែរឱ្យកាន់តែល្បីល្បាញ និងសាកសមជាសម្បត្តិបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរានឹងចាប់ផ្ដើមអនុវត្តគម្រោងរៀបចំប្រព័ន្ធរំដោះទឹកសងខាងផ្លូវ និងកែលម្អផ្លូវនៅមុខប្រាសាទអង្គរវត្តដែលមានប្រវែង ២៩០ម៉ែត្រ ទទឹង ៨ម៉ែត្រ ទៅ ១៣ម៉ែត្រ ដោយមានការដាំស្មៅ ដើមឈើ និងរៀបចំសួនផងដែរ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ តទៅ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរានឹងផ្អាកការធ្វើចរាចរណ៍ដោយថ្មើរជើង និងយានយន្តគ្រប់ប្រភេទនៅលើកំណាត់ផ្លូវនេះជាបណ្ដោះអាសន្នរហូតដល់ការដ្ឋានបានបញ្ចប់ជាស្ថាពរ ដើម្បីធានាបាននូវសុវត្ថិភាពជូនសាធារណៈជន និងភ្ញៀវទេសចរ។ ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរានឹងរៀបចំឱ្យមានផ្លូវថ្មើរជើងប្រើប្រាស់ជំនួសវិញដែលស្ថិតនៅលើផ្លូវកៅស៊ូត្រង់ចំណុចចំណតរថយន្ត មកសួនក្រវ៉ាន់ ឆ្ពោះទៅស្ពានបណ្ដែតទឹក។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង-ស្ថាប័ន និងសាធារណជនទាំងអស់ មេត្តាជ្រាប និងចូលរួមសហការ ក៏ដូចជាសម្របសម្រួល អនុវត្តគម្រោងតាមការគួរ។

ថ្ងៃសុក្រ ៦ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២០

ភ្នំពេញ:
អគារលេខ៨៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ: ០២៣ ២១៩ ៧៧១/ ០២៣ ២១៨ ៧៧៦

អាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំដែនដីអង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ: ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

CamScanner

អាជ្ញាធរជាតិអប្សរារៀបចំពិធីប្រុងពលីមុខប្រាសាទអង្គរខាងលិចដើម្បីសុំសេចក្តីសុខសប្បាយ នៅក្នុងឱកាសគម្រប់ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២០

នាល្ងាចថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា ដែលមាន **ឯកឧត្តម ហង់ ពៅ** អគ្គនាយក និងសហការី អាជ្ញាធរជាតិអប្សរា បានរៀបចំពិធីប្រុងពលីដើម្បីសុំសេចក្តីសុខចម្រើននៅផ្លូវចូលខាងលិចប្រាសាទអង្គរវត្តក្នុង ឱកាសគម្រប់ខួប២៥ឆ្នាំនៃអាជ្ញាធរជាតិអប្សរា (១៩ កុម្ភៈ ១៩៩៥-១៩ កុម្ភៈ ២០២០)។

ក្រៅពីនោះ ក្រុមការងារក៏មមាញឹកក្នុងការត្រៀមរៀបចំផ្ទាំងរូបថតបង្ហាញពីសកម្មភាពរបស់អាជ្ញាធរជាតិអប្សរា ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះទាំងការអភិរក្ស ការជួសជុល និងការអភិវឌ្ឍក្នុងរមណីយដ្ឋានអង្គរ ដើម្បីតាំងបង្ហាញជូនសាធារណជនទស្សនាកម្សាន្តនិងស្វែងយល់។

អាជ្ញាធរជាតិអប្សរា សូមស្វាគមន៍ភ្ញៀវជាតិ-អន្តរជាតិ ក្នុងការចូលរួមទស្សនាពីសមិទ្ធផលការងាររយៈពេល២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរាចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។ ដោយឡែកនៅថ្ងៃទី១៩ ក៏មានរៀបចំពិធីរាប់បាត្រព្រះសង្ឃ ចំនួន១២៥អង្គ នៅវេលាព្រឹកម៉ោង៧.៣០នាទីព្រឹកផងដែរ៕

ពិព័រណ៍សមិទ្ធផល២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរានឹងអនុញ្ញាតឱ្យសាធារណជនស្វែងយល់កាន់តែច្បាស់ពីកិច្ចការដែលបាននិងកំពុងធ្វើក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរានៅព្រឹកថ្ងៃទី១៥ ខែកុម្ភៈនេះ បានរៀបចំពិធីបើកពិព័រណ៍ជាផ្លូវការក្នុងការបង្ហាញពីសមិទ្ធផលនានាដែលសម្រេចបាននាពេលកន្លងមក ដើម្បីអបអរខួប២៥ឆ្នាំ ថ្ងៃបង្កើតស្ថាប័នអាជ្ញាធរជាតិអប្សរា ១៩ កុម្ភៈ ១៩៩៥-១៩ កុម្ភៈ ២០២០។ សាធារណជនអាចចូលរួមទស្សនាស្តង់ពិព័រណ៍រយៈពេលពេញមួយសប្តាហ៍ គឺចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី២២ ខែកុម្ភៈ នៅបរិវេណមុខប្រាសាទអង្គរវត្ត និងបរិវេណព្រះលានជល់ដំរី នៃក្រុងអង្គរធំ។

មានប្រសាសន៍ក្នុងពិធីបើកពិព័រណ៍នៅមុខប្រាសាទអង្គរវត្ត **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរាយល់ថា ជាកិច្ចការមួយដ៏សំខាន់ ដែលត្រូវបង្ហាញរាល់សមិទ្ធផលនានាដែលកើតចេញពីការខិតខំរបស់អាជ្ញាធរជាតិអប្សរា ចាប់ពីតាំងពីស្ថាប័ននេះបង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីឱ្យសាធារណទាំងអស់បានដឹង។ ការខិតខំប្រឹងប្រែង ចាប់ពីរមណីយដ្ឋានអង្គរត្រូវបានបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់នៅឆ្នាំ១៩៩២ រហូតក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោកធម្មតានៅឆ្នាំ២០០៤ និងក្លាយជាសម្បត្តិបេតិកភណ្ឌដ៏អស្ចារ្យសម្រាប់ពិភពលោកនាពេលបច្ចុប្បន្ន។

សម្រាប់ឯកឧត្តមអគ្គនាយក ក្នុងរយៈពេល៨ថ្ងៃនៃការតាំងពិព័រណ៍ពីថ្ងៃទី១៥ ដល់ថ្ងៃទី២២ ខែកុម្ភៈនេះ គឺច្បាស់ណាស់ថា មិនអាចបង្ហាញរាល់សមិទ្ធផលច្រើនសន្ធឹកសន្ធាប់ដែលសម្រេចបាននារយៈពេល២៥ឆ្នាំទាំងអស់បានទេ តែអាចឱ្យសាធារណជន ក៏ដូចជាភ្ញៀវទេសចរជាតិ-អន្តរជាតិ អាចស្វែងយល់កាន់តែច្បាស់ពីកិច្ចការដែលអាជ្ញាធរជាតិអប្សរាបាននិងកំពុងធ្វើ ទាំងកិច្ចការបច្ចេកទេស ក៏ដូចជាទស្សនៈវិស័យទៅខាងមុខរបស់ស្ថាប័នជាតិមួយនេះ ថែមមួយកម្រិតទៀតលើកិច្ចការបេតិកភណ្ឌ។ **ឯកឧត្តម ហង់ ពៅ** ពន្យល់ថា សាធារណជនទាំងអស់ នឹងទទួលបានការធ្វើបទបង្ហាញការពន្យល់ពីបច្ចេកទេសការជួសជុលប្រាសាទ ការជួសជុលវត្ថុបុរាណ។ល។ ដោយក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ក្នុងនោះសាធារណជនក៏អាចចុះទៅស្វែងយល់ដោយផ្ទាល់ នៅតាមការដ្ឋាននីមួយៗ ដើម្បីស្វែងយល់ពីកិច្ចការទាំងនោះឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត៕

អាជ្ញាធរជាតិអប្សរាចាប់ផ្តើមពិព័រណ៍រូបថតសកម្មភាពការងារ២៥ឆ្នាំក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០២០

ដើម្បីអបអរសាទរខួបទី២៥ឆ្នាំរបស់ខ្លួន អាជ្ញាធរជាតិអប្សរា បានធ្វើការតាំងបង្ហាញពិព័រណ៍រូបភាពស្តីពីសមិទ្ធផលការងារដែលសម្រេចបានជូនសាធារណជនជាភ្ញៀវជាតិ-អន្តរជាតិដើម្បីទស្សនា និងស្វែងយល់។

ពិព័រណ៍រូបថតនេះ ប្រព្រឹត្តទៅលើទីតាំងពីរផ្សេងគ្នាគឺ មុខប្រាសាទអង្គរវត្ត និងព្រះលានជល់ដំរីក្នុងបរិវេណទីក្រុងអង្គរធំចាប់ពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។

បេតិកភណ្ឌរស់នៃរមណីយដ្ឋានអង្គរជាផ្នែកមួយក្នុងការទាក់ទាញទេសចរក្រៅពីប្រាសាទ

ផ្សាយនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២០

ក្រៅពីប្រាសាទដ៏ល្បីលាញ ឧទ្យានអង្គរនៅមានមរតករស់ ដែលគេហៅថាជា បេតិកភណ្ឌអរូបីដូចជា ទំនៀមទម្លាប់ ប្រពៃណី ពិធីបុណ្យទាន បន់ស្រន់ សាសនា ព្រមទាំង សិប្បកម្ម និងរបៀបរបបរស់នៅប្រចាំថ្ងៃដែលអ្នកស្រុកនៅតំបន់អង្គរបានប្រកាន់ខ្ជាប់ខ្ជួននិងប្រតិបត្តិតៗគ្នារាប់ជំនាន់មកហើយ។

ក្នុងឱកាសគម្រប់ខួប២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានលើកឡើងថា ទាំងនេះសុទ្ធសឹងជាអ្វីដែលភ្ញៀវទេសចរចង់ឃើញ ចង់ដឹង និងចង់ស្រាវជ្រាវស្វែងយល់អំពីមរតករស់ក្រៅពីប្រាសាទ។ការរៀបចំភូមិឋានផ្ទះកន្លែងសិប្បកម្មតាមបែបបុរាណ មធ្យោបាយធ្វើដំណើរតាមរទេះគោ សុទ្ធតែជាផលិតផលបន្ថែមទៀតសម្រាប់ភ្ញៀវទេសចរទស្សនា ដែលទទួលបានបទពិសោធន៍ ហើយនាំអារម្មណ៍ភ្ញៀវទាំងនោះឱ្យមើលឃើញអំពីរបៀបរបប នៃការរស់នៅរបស់ប្រជាជនខ្មែរយើងកាលពីសម័យអង្គរ។

ឯកឧត្តមបន្តទៀតថា បច្ចុប្បន្នប្រពៃណីមួយចំនួនដែលអ្នកនៅតំបន់ផ្សេងៗបានបំភ្លេចចោល ឬមិនសូវយកចិត្តទុកដាក់ ហើយអ្នកស្រុកតំបន់អង្គរនៅតែកំពុងបន្តប្រតិបត្តិនៅឡើយ ដូចជា ពិធីកោរជុក ពិធីឡើងអ្នកតា ពិធីហៅទឹកភ្លៀង ពិធីហៅព្រលឹង។ល។ អាជ្ញាធរជាតិអប្សរា ដែលមានភារកិច្ចគ្រប់គ្រងនិងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ កំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើទំនៀមទាំងអស់នេះ ដោយធ្វើយ៉ាងណាឱ្យទំនៀមទាំងអស់នេះអាចគង់វង្សតកូនតចៅរហូតទៅ និងអាចទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។

គួរបញ្ជាក់ផងដែរថា តំបន់អង្គរ ឬរមណីយដ្ឋានអង្គរ ដែលត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោកនេះនាឆ្នាំ១៩៩២ មានផ្ទៃដីសរុប៤០១ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះរួមមានទាំងប្រាសាទ បុរាណដ្ឋាន ស្ថានីយបុរាណវិទ្យាចំនួន៩១ បរិស្ថាន និងសហគមន៍មនុស្សផងដែរ៕

អាជ្ញាធរជាតិអប្សរាកំពុងដំណើរការកែលម្អនិងស្ថាបនាផ្លូវក្នុងបរិវេណអង្គរធំ

ផ្សាយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២០

តាមការបញ្ជាក់របស់ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ក្នុងពេលចុះពិនិត្យបច្ចេកទេស និងផលប៉ះពាល់នៅការដ្ឋានសាងសង់ នាព្រឹកថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០២០នេះ បានឱ្យដឹងថា អាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលកែលម្អ និងស្ថាបនាថ្មីចំនួន០២ខ្សែ គឺទីមួយ ជុំវិញប្រាសាទបាយ័ន្តប្រវែង១០២៤ម៉ែត្រ ទទឹង០៥ម៉ែត្រ និងទីពីរ ផ្លូវវាំងព្រះលានដល់ដំរី ប្រវែង១៤២៧ម៉ែត្រ ទទឹង៦ម៉ែត្រ ជាប្រភេទអ៊ិតបេតុងកៅស៊ូ (AC) ពណ៌ក្រហម ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរ និងសាធារណជន ជាពិសេសកាត់បន្ថយបញ្ហាចរាចរ និងផលប៉ះពាល់ទៅលើប្រាសាទ និងមនុស្ស ព្រមទាំងរក្សាបាននូវតម្លៃទេសភាពវប្បធម៌ក្នុងតំបន់ប្រាង្គប្រាសាទផងដែរ។ ការកែលម្អ និងស្ថាបនាផ្លូវនេះគ្រោងនឹងបញ្ចប់ក្នុងខែមិថុនាឆ្នាំ២ ០ ២ ០ ខាងមុខនេះ។

អាជ្ញាធរជាតិអប្សរាមានមោទនភាពចំពោះការធ្វើឲ្យប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរមានជីវិតឡើងវិញ

ផ្សាយនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២០

នាឆ្នាំ២០០៤ ស្រះស្រង់ និងកសិន្ធុប្រាសាទអង្គរវត្តត្រូវបានរីងទឹកនារដូវប្រាំង។ នៅពេលនោះ មានសំណួរចំនួន២ ដែលអ្នកជំនាញផ្នែកគ្រប់គ្រងទឹកត្រូវស្វែងរកដំណោះស្រាយ ១)តើបុព្វបុរសបង្កើតកសិន្ធុទឹក និងបារាយណ៍ធំៗមកដើម្បីអ្វីបើគ្មានមធ្យោបាយបញ្ចូលទឹក? ២)តើបុព្វបុរសបង្កើតកសិន្ធុទឹក បារាយណ៍ និងអាងទឹកតាមប្រាសាទដើម្បីអ្វី?

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា លើកឡើងថាតាមរយៈការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់ផ្នែកបុរាណវិទ្យា និងឯកសារផ្សេងៗ និងនៅលើការដ្ឋានផ្ទាល់យើងរកឃើញថា រាល់គ្រឹះប្រាសាទតែងមានស្រទាប់ខ្សាច់ ហើយគ្រឹះស្រទាប់ខ្សាច់ក្រោមប្រាសាទមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទឹកក្រោមដី ព្រោះទឹកក្រោមដីបានជួយស្រទាប់ខ្សាច់បានរឹងមាំ និងទ្រទ្រង់ប្រាសាទដែលមានទម្ងន់មហិមា។

បន្ទាប់ពីសិក្សាស្វែងយល់អំពីតួនាទីដ៏សំខាន់របស់ទឹក នៅក្នុងឆ្នាំ២០០៥ នាយកដ្ឋានគ្រប់គ្រងទឹក ដែលពេលនោះគ្រប់គ្រងផ្ទាល់ដោយឯកឧត្តម បានសម្រេចស្តារប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរឡើងវិញមានដូចជានៅប្រាសាទអង្គរវត្ត ស្រះស្រង់ បន្ទាប់មកឆ្នាំ២០០៧ ចាប់ស្តារបារាយណ៍ខាងជើង។បន្ទាប់មកទៀតយើងក៏បានធ្វើការស្តារឡើងវិញនូវប្រឡាយនិងទំនប់ជាច្រើនដែលមានប្រវែងសរុបជាង៥ ២ គីឡូម៉ែត្រដែលក្នុងនោះមានទ្វារទឹកជាច្រើនដែរ។ ចាប់ពីពេលនោះមក បារាយណ៍ខាងជើងចាប់ផ្តើមមានទឹកឡើងវិញ ក្រោយពីបានគោកគ្មានទឹកនិងបាត់បង់តួនាទីជាង៥០០ឆ្នាំមកហើយ។ ទន្ទឹមនឹងនេះ បារាយណ៍ និងប្រព័ន្ធប្រឡាយទឹកផ្សេងៗក៏ចាប់ផ្តើមស្តារឡើងវិញធ្វើឱ្យទឹកក្នុងរមណីយដ្ឋានអង្គរដូចជាបារាយណ៍ខាងជើង កសិន្ធុប្រាសាទអង្គរវត្ត កសិន្ធុក្រុងអង្គរធំ ស្រះស្រង់ជាដើម មានប្រព័ន្ធបញ្ចូលទឹកឡើងវិញ និងអាចរក្សាទឹកបានទាំងខួបប្រាំងខួបវស្សា។ លើសពីនេះទៀត ការធ្វើឲ្យប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរមានជីវិតឡើងវិញបានធ្វើឲ្យរមណីយដ្ឋានអង្គរលែងប្រឈមនឹងការខ្វះខាតទឹកធានាបានគ្រប់គ្រាន់ទឹកសម្រាប់ទ្រគ្រឹះប្រាសាទនារដូវប្រាំង ព្រមទាំងបញ្ចៀសបាននូវបញ្ហាទឹកជំនន់ទៀតផងចាប់ពីឆ្នាំ២០១២មក។

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាបានបញ្ជាក់បន្ថែមថាអ្វីយើងសម្រេចបាននាពេលនេះគឺគ្រាន់តែយកប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរដែលមានស្រាប់ដែលបន្សល់ពីបុព្វបុរសខ្មែរ មកធ្វើឱ្យវារស់ឡើងវិញតែប៉ុណ្ណោះដែលចំណុចទាំងនេះហើយត្រូវបានអង្គការយូណេស្កូ ក៏ដូចជាអន្តរជាតិឱ្យតម្លៃដល់កម្ពុជា និងតែងតែអញ្ជើញអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាអោយទៅចែករំលែកបទពិសោធន៍គ្រប់គ្រងទឹកដល់ស្ថាប័នអន្តរជាតិផ្សេងៗទៀត៕

ពិធីរាប់បាត្រព្រះសង្ឃ១២៥អង្គក្នុងឱកាសគម្រប់ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា ប្រព្រឹត្តទៅយ៉ាងអធិកអធម

ផ្សាយនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០២០

ក្នុងឱកាសពិធីអបអរសាទរខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា (១៩ កុម្ភៈ ១៩៩៥-១៩ កុម្ភៈ ២០២០) នៅព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងវត្តមានឯកឧត្តមតំណាងក្រុមប្រឹក្សាខេត្ត ឯកឧត្តមតំណាងរដ្ឋបាលខេត្តសៀមរាប ថ្នាក់ដឹកនាំមន្ត្រីរាជការ និងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ព្រមទាំងសាធារណជនយ៉ាងច្រើនកុះករ បាននិមន្តព្រះសង្ឃ១២៥អង្គចម្រើនព្រះបរិត្ត និងរាប់បាត្រសុំសេចក្ដីសុខចម្រើននៅបរិវេណខាងលិចប្រាសាទអង្គរវត្ត។

ក្រៅពីពិធីសាសនាដូចខាងលើ សាធារណជនក៏បានចូលរួមទស្សនាពិព័រណ៍រូបភាពស្តីពីសមិទ្ធផលការងារសំខាន់ៗរយៈពេល២៥ ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរាដែរ ដែលកិច្ចការនេះបានចាប់ផ្ដើមតាំងពីថ្ងៃទី១៥ ខែកុម្ភៈ រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០ នៅបរិវេណខាងលិចប្រាសាទអង្គរវត្តនិងបរិវេណព្រះលានជល់ដំរីនៃក្រុងអង្គរធំ៕

អាជ្ញាធរជាតិអប្សរាពិនិត្យទីតាំងមុនអនុវត្តគម្រោងប្រព័ន្ធរំដោះទឹកនិងកែលម្អផ្លូវ មុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០២០

នៅរសៀលថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការី និងមានការចូលរួមពី លោក នួន ពុទ្ធារ៉ា អភិបាលក្រុងសៀមរាប តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប បានអញ្ជើញចុះពិនិត្យបរិវេណខាងលិចប្រាសាទអង្គរវត្ត ដើម្បីរៀបចំប្រព័ន្ធរំដោះទឹកសងខាងផ្លូវ ដែលគម្រោងនេះនឹងចាប់ផ្តើមពីថ្ងៃទី២០ខែកុម្ភៈខាងមុខ។

ការរៀបចំគម្រោងនេះនឹងធ្វើឡើងដើម្បីរួមចំណែកធ្វើឱ្យហេដ្ឋារចនាសម្ពន្ធ និងសម្បទាទេសចរណ៍ ទេសភាពបរិស្ថាននៅបរិវេណមុខខាងលិចប្រាសាទអង្គរវត្តមានភាពល្អប្រសើរ ព្រមទាំងលើកតម្លៃរមណីយដ្ឋានអង្គរឱ្យសមជាព្រលឹងជាតិខ្មែរ និងសក្តិសមជាសម្បត្តិបេតិកភណ្ឌពិភពលោកផងដែរ។

ក្នុងការអនុវត្តគម្រោងនាពេលខាងមុខ អាជ្ញាធរជាតិអប្សរានឹងផ្អាកចរាចរណ៍ផ្លូវកណ្តាល និងដកហូតដើមឈើមួយចំនួនដើម្បីរៀបចំជាវាលស្មៅបៃតងនាពេលអនាគត។ ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរាក៏នឹងរៀបចំឱ្យមានផ្លូវ និងចំណតយានយន្តសមរម្យសម្រាប់អាជីវករនៅត្រពាំងសេសផងដែរ៕

អាជ្ញាធរជាតិអប្សរានិងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ រួមគ្នាបណ្តុះបណ្តាលធនធានមនុស្សនិងអភិរក្សប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២០

កាលពីព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០នេះ **ឯកឧត្តម ហង់ ពៅ**អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលស្វាគមន៍អគ្គនាយកមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (Korea Cultural Heritage Foundation, KCHF) លោក PARK Hae Soo និងគណៈប្រតិភូនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ខេត្តសៀមរាប។

ជំនួបនេះផ្តោតលើគម្រោងការងារអភិរក្ស និងជួសជុលរបស់ប្រទេសកូរ៉េនៅរមណីយដ្ឋានអង្គរ។ ស្ថាប័នមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ បានជួយជ្រោមជ្រែងអាជ្ញាធរជាតិអប្សរានៅអង្គរតាំងពីឆ្នាំ២០១៥មក តាមរយៈគម្រោងអភិរក្សនិងជួសជុលក្រុមប្រាសាទព្រះពិធូរនៃរមណីយដ្ឋានអង្គរក្នុងដំណាក់កាលទី១។ បច្ចុប្បន្ន កំពុងដំណើរការដំណាក់កាលទី២លើគម្រោងអភិរក្ស និងជួសជុលប្រាសាទជមនៃក្រុមប្រាសាទព្រះពិធូរ និងព្រះលានជល់ដំរី ក្នុងអង្គរធំចាប់ពីឆ្នាំ២០១៩ដល់២០២៣។

គម្រោងការងាររបស់កូរ៉េមិនត្រឹមតែការងារអភិរក្ស និងជួសជុលទេ គឺមានកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស និងបង្កើតមន្ទីរពិសោធន៍ ស្តង់ដារអន្តរជាតិលើការងារអភិរក្ស និងស្រាវជ្រាវវិទ្យាសាស្ត្រផងដែរ។ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានវាយតម្លៃខ្ពស់លើគម្រោងជំនួយលើការបណ្តុះបណ្តាលធនធានមនុស្ស និងមន្ទីរពិសោធន៍នេះ។

ឯកឧត្តមក៏បានស្នើភាគីកូរ៉េឱ្យជួយបណ្តុះបណ្តាលអ្នកជំនាញជាតិលើការរៀបចំកសាងឃ្លាំងរក្សាបុរាណវត្ថុមួយតាមរបៀបនៅប្រទេសកូរ៉េ ដែលអាចការពារអគ្គិភ័យ ទឹកជំនន់ និងគ្រោះធម្មជាតិដទៃទៀត។ សំណើនេះត្រូវបានភាគីកូរ៉េទទួល និងរៀបចំក្នុងកម្មវិធីបណ្តុះបណ្តាលនៅពេលអនាគត។

ទន្ទឹមនឹងនេះ ភាគីកូរ៉េបានស្នើអាជ្ញាធរជាតិអប្សរា ជួយសម្រួលរកទីតាំងសាងសង់រោងពិព័រណ៍ការងារក្នុងដំណាក់ទី២ និងទីតាំងចម្លាក់ថ្មដែលរើពីព្រះលានជល់ដំរីសម្រាប់ការងារជួសជុលទៅអនាគត។ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យប្រើប្រាស់ទីធ្លាខាងមុខព្រះលានជល់ដំរីតាមសំណើសុំ និងអនុញ្ញាតឱ្យកែសម្រួលរោងពិព័រណ៍ដែលមានស្រាប់ ដោយសារទីតាំងនេះល្អសមស្របតាមពេលរៀបចំផ្លូវថ្មីឆ្លងកាត់តំបន់នេះ និងទីតាំងលក់ដូរត្រូវរំកិលទៅខាងជើងដែរ។៚

និស្សិតសាកលវិទ្យាល័យស្វាយរៀងទស្សនកិច្ចសិក្សានៅអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ ក្រុមនិស្សិតនៃសាកលវិទ្យាល័យស្វាយរៀង ដែលសរុបប្រមាណជាង ១០០នាក់ បានមកទស្សនកិច្ចសិក្សានៅស្នាក់ការអាជ្ញាធរជាតិអប្សរាដើម្បីសិក្សាស្វែងយល់ពីការងារទូទៅ ពិសេសកិច្ចការអភិរក្សនិងគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរ។

លោក ភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិកនិងសម្ភារ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះក្រុមនិស្សិត និងគណៈប្រតិភូសាកលវិទ្យាល័យស្វាយរៀង។ លោកបានមានប្រសាសន៍ថា ទស្សនកិច្ចនាពេលនេះគឺប្រព្រឹត្តទៅស្របពេលដែលអាជ្ញាធរជាតិអប្សរាកំពុងប្រារព្ធពិធីរំលឹកខួប២៥ឆ្នាំរបស់ខ្លួន។ ជាមួយគ្នានេះដែរ លោកបានអញ្ជើញនិស្សិតទាំងអស់ទស្សនាការតាំងពិព័រណ៍រូបភាពស្តីពីសមិទ្ធផលការងាររបស់អាជ្ញាធរជាតិអប្សរា ក៏ដូចជាស្វែងយល់ពីកិច្ចការមួយចំនួនទៀតដែលមានបង្ហាញនៅតាមស្តង់នីមួយៗដែលស្ថិតនៅមុខប្រាសាទអង្គរវត្ត។

ក្នុងទស្សនកិច្ចខាងលើនេះដែរ អាជ្ញាធរជាតិអប្សរាក៏មានការធ្វើបទបង្ហាញទាក់ទងនឹងការងារគ្រប់គ្រងទូទៅ បទបង្ហាញ ពីកិច្ចការអភិរក្ស ជួសជុល និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ក៏ដូចជាការងារគ្រប់គ្រងទេសចរណ៍ ដែលមាននាយកដ្ឋានជំនាញឡើងធ្វើបទបង្ហាញទៅកាន់ក្រុមនិស្សិតនៃសាកលវិទ្យាល័យស្វាយរៀង៕

សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរពោងបណ្តែតទឹកចាស់ដែលមានស្នាមប្រេះបែក ជំនួសដោយពោងថ្មីនៅលើស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

APSARA
លេខ ០៤៧/អជអ.ពផ
/២០

សេចក្តីជូនដំណឹង
ស្តីពី
ការផ្លាស់ប្តូរពោងបណ្តែតទឹកចាស់ដែលមានស្នាមប្រេះបែក ជំនួសដោយពោងថ្មី នៅលើស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា៖ ដើម្បីរក្សាសុវត្ថិភាពជូនដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ស្ពានបណ្តែតទឹក ដើម្បីទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរា នឹងធ្វើការផ្លាស់ប្តូរពោងបណ្តែតទឹកចាស់ៗ ដែលមានស្នាមបែកធំ និងបែកតូច ជំនួសដោយពោងថ្មី ចាប់ពីជួរពោងបណ្តែតទឹកទី២៨១ ដល់ជួរទី៣៤៦ ដែលមានរយៈពេល ០២ថ្ងៃ ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២០ ចាប់ពីម៉ោង៦៖០០នាទីល្ងាច រហូតដល់ម៉ោង១២៖០០នាទីយប់ ដូចមានបញ្ជាក់ជូនភ្ជាប់ក្នុងគំនូសប្លង់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃពុធ ១១ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២០

រយៈពេលពីរសប្តាហ៍ក្នុងខែកុម្ភៈ អាជ្ញាធរជាតិអប្សរាផ្តល់បច្ចេកទេស អំពីការសាងសង់លំនៅដ្ឋានចំនួន១២២ ករណីក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

ក្រុមការងារនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យ ពិគ្រោះយោបល់ និងជួយសម្រួលផ្នែកបច្ចេកទេសអំពីការសាងសង់លំនៅដ្ឋាន និងសំណង់ផ្សេងៗចំនួន១២២ករណីបន្ទាប់ពីទទួលបានការអនុញ្ញាតសាងសង់ពីអាជ្ញាធរជាតិអប្សរាសម្រាប់សប្តាហ៍ទី០១ គឺចាប់ពីថ្ងៃទី០១-១៥ ខែកុម្ភៈ ឆ្នាំ២០២០។

សំណង់ដែលអនុញ្ញាតរួមមាន៖ ក្រុងសៀមរាបអនុញ្ញាតចំនួន២៨ករណី ស្រុកប្រាសាទបាគងអនុញ្ញាតចំនួន៤៣ករណី ស្រុកបន្ទាយស្រី ២២ ករណី ស្រុកពួកអនុញ្ញាតចំនួន០៩ករណី និងស្រុកអង្គរធំអនុញ្ញាតចំនួន២០ករណីផងដែរ។

ការស្នើសុំសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ តម្រូវឲ្យម្ចាស់ផ្ទះដាក់ពាក្យស្នើសុំដោយផ្ទាល់នៅច្រកចេញចូលតែមួយក្រុងសៀមរាប ច្រកចេញតែមួយស្រុកប្រាសាទបាគង ច្រកចេញចូលតែមួយស្រុកពួក និងនៅមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា។ ករណីប្រជាពលរដ្ឋបានបំពេញ គ្រប់លក្ខខណ្ឌទាំងអស់ អាជ្ញាធរជាតិអប្សរានឹងផ្តល់នូវលិខិតអនុញ្ញាតឱ្យសាងសង់ ព្រមទាំងគូសប្លង់បច្ចេកទេស និងជួយពិគ្រោះយោបល់សំដៅធ្វើយ៉ាងណាឲ្យការសាងសង់នោះចំគោលដៅ សន្សំសំចៃថវិកា ព្រមទាំងគោរពបានតាមរចនាបថផ្ទះខ្មែរបុរាណទៀតផង។

អាជ្ញាធរជាតិអប្សរាចាប់ផ្តើមអនុវត្តផែនការកែលម្អផ្លូវ ទេសភាព និងបរិស្ថាន បរិវេណខាងលិចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា កំពុងចាប់ផ្តើមអនុវត្តគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្បទាទេសចរណ៍ ទេសភាព និងបរិស្ថាននៅបរិវេណមុខប្រាសាទអង្គរវត្តឱ្យមានភាពល្អប្រសើរ ក្នុងទិសដៅលើកគុណតម្លៃអង្គរដែលជានិមិត្តរូបដួងព្រលឹងជាតិខ្មែរ និងជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក។

ឯកឧត្តម ឃិត ចាន់ដារដ្ឋ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា បានលើកឡើងថា អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមអនុវត្តគម្រោងកែលម្អផ្លូវ រៀបចំប្រព័ន្ធរំដោះទឹកសួនច្បារ និងផ្លូវថ្មើរជើង ត្រង់ចំណុចអក្សរតេ ចាប់ពីចំណុចមុខនាគនៃស្ពានហាលប្រាសាទអង្គរវត្តទៅដល់ផ្លូវបំបែកទៅត្រពាំងសេស ដោយមានប្រវែង២៩០ម៉ែត្រ ទទឹង៨ទៅ១៣ម៉ែត្រ ជាប្រភេទបេតុងកៅស៊ូ (AC)។ ក្រុមការងារកំពុងកាត់ដកហូតដើមឈើងាប់ និងដើមឈើពុំបានការមួយចំនួនដូចជាដើមពុទ្រា ដើមអំពិលទឹកជាដើម និងដាំជំនួសមកវិញនូវដើមឈើប្រណិត ហើយនឹងរៀបចំផ្លូវថ្មើរជើង ដែលមានដាំស្មៅ និងដើមឈើអមសងខាង ឱ្យមានភាពបៃតងជាប្រចាំសម្រាប់ភ្ញៀវជាតិ-អន្តរជាតិធ្វើដំណើរទស្សនាប្រាសាទអង្គរវត្តដោយសោមនស្សរីករាយ។

ក្នុងពេលកំពុងអនុវត្តកិច្ចការងារនេះ ឯកឧត្តមបញ្ជាក់ថាពិតជាមានផលរំខានដល់អាជីវករលក់ដូរនៅទីនេះខ្លះ និងសុំការយោគយល់ពីសំណាក់អាជីវករទាំងអស់ ព្រមទាំងសូមឱ្យមានការចូលរួមដើម្បីកែប្រែសោភ័ណភាព មុខប្រាសាទអង្គរវត្តឱ្យកាន់តែមានភាពទាក់ទាញ។ អាជ្ញាធរជាតិអប្សរាបានរៀបចំផ្លូវថ្មើរជើងបណ្តោះអាសន្ន ចាប់ពីចំណតរថយន្តទៅស្ពានបណ្តែតទឹក សម្រាប់សម្រួលដល់ភ្ញៀវទេសចរ និងរៀបចំច្រកចេញចូលជាបណ្តោះអាសន្នសម្រាប់អាជីវករនៅត្រពាំងសេសផងដែរ។

ឯកឧត្តមបន្ថែមថា គម្រោងដែលកំពុងតែអនុវត្តនេះនឹងបញ្ចប់នៅខែសីហា ឆ្នាំ២០២០ខាងមុខ ហើយវាជាគម្រោងមួយក្នុងចំណោមគម្រោងធំៗផ្សេងៗទៀតនៅបរិវេណនេះដូចជា ការរៀបចំមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចភ្ញៀវទេសចរ ដែលមានកន្លែងទទួលភ្ញៀវ កន្លែងផ្តល់ព័ត៌មាន កន្លែងតាំងពិព័រពណ៌ តូបលក់ដូរសម្រាប់ប្រជាជនក្នុងស្រុក និងកម្រិតអន្តរជាតិ៕

អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមដំណើរការជួសជុលកែលម្អកំណាត់ផ្លូវសម្ដេចវិបុលបញ្ញា សុខ អាន

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្ដម យិត ចាន់ដារដ្ឋ** អគ្គនាយករងជាតំណាង **ឯកឧត្ដម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ក្រុមការងារជួសជុលផ្លូវថ្នល់នៃអាជ្ញាធរជាតិអប្សរា បានចាប់ផ្ដើមបើកការដ្ឋានជួសជុលកែលម្អកំណាត់ផ្លូវ៦០ម (ផ្លូវសម្ដេចវិបុលបញ្ញាសុខអាន) ចាប់ពីរង្វង់មូលអាជ្ញាធរជាតិអប្សរាមកផ្លូវជាតិលេខ៦ ដែលមានប្រវែង១៧៩៥ម៉ែត្រ ទទឹង១០ម៉ែត្រ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដែលផ្លូវនេះមានការខូចខាតខ្លាំងដោយសារអាយុកាល។ ផ្លូវនេះគ្រោងនឹងបញ្ចប់ការជួលជុលកែលម្អក្នុងរយៈពេល៣ខែ៕

អាជ្ញាធរជាតិអប្សរារៀបចំវគ្គសង្គ្រោះបឋមដល់ភ្នាក់ងារទេសចរណ៍ជាលើកទី៥

ផ្សាយនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ ជាលើកទី៥ ហើយ នៃការរៀបចំវគ្គបណ្តុះបណ្តាលសង្គ្រោះបឋមដល់ភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទគោលដៅ ពីសំណាក់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសជប៉ុន (អង្គការ Srolanh project NPO) សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនៃអាជ្ញាធរជាតិអប្សរា។

ឯកឧត្តម សុខ សង្វារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ មានប្រសាសន៍ថា កន្លងមកនាយកដ្ឋានបានរៀបចំវគ្គសង្គ្រោះបឋមបាន៤លើករួចមកហើយ ដែលអ្នកចូលរួមសរុប ១៦០នាក់។ ចំណែកលើកទី៥នេះ មានអ្នកចូលរួម ៤០នាក់ គឺភ្នាក់ងារទេសចរណ៍៣០នាក់ សណ្តាប់ធ្នាប់ ១០នាក់។

ចំពោះវគ្គសង្គ្រោះបឋមនេះ ត្រូវបានរៀបចំ២ដងក្នុងមួយឆ្នាំ គឺរៀងរាល់ខែកុម្ភៈនិងខែកក្កដា ដែលផ្តោតលើមេរៀនសំខាន់ៗដូចជា ការធ្វើចលនាបេះដូង របៀបរុំរបួស ការលើកជនរងគ្រោះ។ល។

ឯកឧត្តមបានបញ្ជាក់ថា ការផ្តល់ចំណេះដឹងផ្នែកសង្គ្រោះបឋមដល់ភ្នាក់ងារទេសចរណ៍តាមប្រាសាទ ជាភារកិច្ចចាំបាច់បំផុតសម្រាប់អាជ្ញាធរជាតិអប្សរា ដើម្បីឱ្យភ្នាក់ងារទេសចរណ៍អាចមើលថែ និងជួយសង្គ្រោះភ្ញៀវទេសចរបានទាន់ពេលវេលា ករណីភ្ញៀវជួបគ្រោះថ្នាក់ជាយថាហេតុ។ កាយវិការនិងការគិតគូរពីសុខទុក្ខ សុវត្ថិភាពចំពោះភ្ញៀវ ដូច្នេះ កន្លងមកទទួលបានការគាំទ្រ ការថ្លែងអំណរគុណ និងការកោតសរសើរយ៉ាងខ្លាំងចំពោះស្ថាប័នមួយនេះ៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរាចែករំលែកចំណេះដឹងអំពីប្រវត្តិសាស្ត្រអង្គរ ដល់និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ៣៦០នាក់

ផ្សាយនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២០

និស្សិតមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយកម្មនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចំនួន៣៦០នាក់ បានមកបំពេញទស្សនកិច្ចសិក្សា និងស្វែងយល់ពីប្រវត្តិសាស្ត្រអង្គរពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងនៅតំបន់រមណីយដ្ឋានអង្គរចាប់ពីថ្ងៃទីថ្ងៃទី២២ ដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។

លោកសាស្ត្រាចារ្យ អ៊ិន សារិន ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យស្ថាបត្យកម្មនិងនគរូបនីយវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានថ្លែងអំណរគុណដល់អ្នកជំនាញអាជ្ញាធរជាតិអប្សរា ដែលបានចំណាយពេលវេលាចែករំលែកចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រអង្គរដល់និស្សិត និងចាប់អារម្មណ៍ជាខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរាលើកិច្ចការអភិរក្ស ជួសជុល និងការអភិវឌ្ឍនៅក្នុងរមណីយដ្ឋានអង្គរ ពិសេសលើការថែរក្សាមរតក វប្បធម៌ ជំនឿអរូបីជាមួយអ្នកស្រុក។

លោកសាស្ត្រាចារ្យ ក៏សង្ឃឹមថា នឹងបានចងស្ពានមេត្រីភាពរវាងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងក្រុមការងារស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរាឱ្យកាន់តែមានទំនាក់ទំនងជិតស្និទ្ធ ដើម្បីផ្ដល់ឱកាស ចំណេះដឹង ការងារដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានរៀនសូត្របន្ថែមពីទីនេះកាន់តែច្រើននៅថ្ងៃអនាគត។

លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ តំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានចែករំលែកចំណេះដឹងទាក់ទងនឹងប្រវត្តិសាស្ត្រអង្គរដល់និស្សិតទាំងអស់ ហើយក៏បានឱ្យដឹងថា អាជ្ញាធរជាតិអប្សរា គឺជាស្ថាប័នការងារមួយបានផ្ដល់ឱកាសដល់និស្សិត នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈច្រើនជាងគេសម្រាប់ហាត់ការរយៈពេលខ្លី និងការងារអចិន្ត្រៃយ៍ផងដែរ ពិសេសមហាវិទ្យាល័យបុរាណវិទ្យា។

លោក រិទ្ធី បន្ថែមថា អាជ្ញាធរជាតិអប្សរារីករាយក្នុងការផ្ដល់កិច្ចសហការការបណ្ដុះបណ្ដាលនិងទទួលយកនិស្សិតទាំងក្នុងពេលកំពុងសិក្សានិងបញ្ចប់ការសិក្សាហើយ ដើម្បីមកអនុវត្តកិច្ចការនៅទីនេះតាមគម្រោងនីមួយៗដែលធ្លាប់បានផ្ដល់ជូនកន្លងមក ហើយនឹងមានជាបន្តបន្ទាប់ទៀត៕

និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈផ្នែកស្ថាបត្យកម្ម សូនរូប ស្វែងយល់ពីការងារអភិរក្សប្រាសាទនានាក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ និស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សរុបប្រមាណ១០៣នាក់ បានមកបំពេញទស្សនកិច្ចសិក្សានៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ដើម្បីសិក្សាស្វែងយល់ពីការងារ អភិរក្សប្រាសាទបុរាណនានាក្នុងតំបន់អង្គរ។

លោកបណ្ឌិត អ៊ា ដារិទ្ធ អនុប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានធ្វើបទបង្ហាញដល់និស្សិតឱ្យយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរនៅសម័យហ្វូណន ចេនឡា អង្គរ ក្រោយអង្គរ លង្វែក ឧដុង្គ និងសម័យបច្ចុប្បន្ន រួមនឹងកិច្ចការអភិរក្សប្រាសាទរបស់អាជ្ញាធរជាតិអប្សរាក្នុងតំបន់អង្គរជាមួយស្ថាប័នអន្តរជាតិ។

លោក សូ ចិន្តា ព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈសូនរូប បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានធ្វើបទបង្ហាញជូននិស្សិតទាំងអស់ហើយតាមរយៈបទបង្ហាញនេះនឹងផ្តល់ចំណេះដឹងដល់និស្សិតទាំងអស់បានយល់ដឹងពីប្រវត្តិសាស្ត្រខ្លួនគ្រប់សម័យកាល ពិសេសកិច្ចការជួសជុលអភិរក្សនៅក្នុងតំបន់រមណីយដ្ឋានអង្គរដោយអ្នកជំនាញជាតិ-អន្តរជាតិរយៈពេល២៥ឆ្នាំកន្លងមកនេះ ដើម្បីយកទៅអភិវឌ្ឍន៍ការសិក្សារបស់ខ្លួននិងប្រទេសជាតិទៅថ្ងៃក្រោយ៕

អាជ្ញាធរជាតិអប្សរាត្រៀមរៀបចំសៀមរាបសង្ក្រាន្ត ក្រោមប្រធានបទ «អង្គរ អតីតកាល បច្ចុប្បន្ន និងអនាគត»

ផ្សាយនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២០

ដើម្បីចូលរួមអបអរសាទរឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងទាក់ទាញទេសចរឱ្យចូលមកទស្សនាតំបន់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាបានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាប្រចាំខេត្តសៀមរាប រដ្ឋបាលខេត្តសៀមរាប និងស្ថាប័នពាក់ព័ន្ធផ្សេងៗ នឹងរៀបចំសៀមរាបសង្ក្រាន្ត នៅបរិវេណប្រាសាទអង្គរវត្ត ក្រោមប្រធានបទ «អង្គរ អតីតកាល បច្ចុប្បន្ន និងអនាគត» ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ៦រោចដល់ថ្ងៃ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៣ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០។

ទាក់ទងនឹងប្រធានបទ «អង្គរ អតីតកាល បច្ចុប្បន្ន និងអនាគត» អាជ្ញាធរជាតិអប្សរានឹងធ្វើពិព័រណ៍បង្ហាញពីការកំណាយបុរាណវិទ្យា សមិទ្ធផលអាជ្ញាធរជាតិអប្សរា និងការអភិវឌ្ឍវិស័យទេសចរណ៍ដែលនឹងផ្តល់ចំណេះដឹងដល់សាធារណជនបានស្គាល់ពីបច្ចេកទេស នៃការប្រើប្រាស់និងកែច្នៃថ្មតាមបែបបុរាណនិងទំនើប ការព្យាបាលថ្ម ការសាងសង់ប្រាសាទខ្មែរ ផែនទីតំបន់អង្គរ និងការស្រាវជ្រាវបុរាណវិទ្យា។ ល។

ការរៀបចំសៀមរាបសង្ក្រាន្ត ក៏មានបញ្ចូលវប្បធម៌ប្រពៃណីរបស់អ្នកស្រុកអង្គរ ការលេងល្បែងប្រជាប្រិយខ្មែរដើម្បីកម្សាន្តសប្បាយនៅក្នុងពិធីថែមទៀត។ពិសេសនឹងបង្ហាញពីការដាប់ឆ្លាក់ចម្លាក់ សិប្បកម្ម ដែលសាធារណជនក៏អាចចូលរួមជាមួយអ្នកជំនាញ និងទិញយកទៅប្រើប្រាស់បានដើម្បីលើកម្ពស់តម្លៃសិល្បៈខ្មែរ និងជីវភាពប្រជាជនផងដែរ៕

ប្រតិភូគណៈកម្មការទី២ នៃរដ្ឋសភា ជួបសំណេះសំណាលជាមួយអាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២០

នៅថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ២០២០ នេះ គណៈកម្មការទី២ នៃរដ្ឋសភា ដឹកនាំដោយ **ឯកឧត្តម គតសេដ្ឋាបណ្ឌិត ជាម យៀប** ប្រធានប្រតិភូគណៈកម្មការទី២ និងសមាជិកប្រតិភូ ជួបសំណេះសំណាលជាមួយអាជ្ញាធរជាតិអប្សរា និងគ្រឹះស្ថានអង្គរ ដើម្បីស្វែងយល់ពីវឌ្ឍនភាពរបស់អាជ្ញាធរជាតិអប្សរា និងវឌ្ឍនភាពរបស់គ្រឹះស្ថានអង្គរ នៅគ្រឹះស្ថានអង្គរ ខេត្តសៀមរាប។

កម្មវិធី
ពិព័រណ៍សមិទ្ធផល២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា
នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)
ថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០២០

«**ពេលព្រឹក**»

ម៉ោង០៨:៣០ ការចុះឈ្មោះអ្នកចូលរួម

ម៉ោង០៩:០០ មតិស្វាគមន៍របស់ **លោក អៀង សុធារ៉ា** ប្រធានក្រុមហ៊ុនផ្កាឈូកនិងមូលនិធិផ្កាឈូក

ម៉ោង០៩:១០ មតិស្វាគមន៍បើកកម្មវិធីរបស់ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា តំណាងដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្រ្តីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា និងប្រកាសបើកពិព័រណ៍រូបភាពស្តីពីសមិទ្ធផល២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា

ម៉ោង០៩:២០ ការទស្សនាពិព័រណ៍រូបភាពស្តីពីសមិទ្ធផល២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរាបន្តអបអរសាទរខួប២៥ឆ្នាំដោយធ្វើបទបង្ហាញនិងតាំងពិព័រណ៍រូបភាព នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)

ផ្សាយនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីវិស័យបេតិកភណ្ឌ ក៏ដូចជាការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរាល់ការងារសំខាន់ៗនិងសមិទ្ធផលក្នុងរយៈពេល២៥ឆ្នាំរបស់ខ្លួន នាថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០២០អាជ្ញាធរជាតិអប្សរានឹងសហការជាមួយក្រុមហ៊ុនផ្កាឈូក និងមូលនិធិផ្កាឈូក ដើម្បីរៀបចំតាំងពិព័រណ៍រូបភាពជាសាធារណៈស្តីពីការងារសំខាន់ៗនិងសមិទ្ធផលជាច្រើនដែលសម្រេចបាននាពេលកន្លងមក នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ដែលស្ថិតក្នុងបរិវេណវិទ្យាស្ថានភាសាបរទេស ចាប់ពីម៉ោង៨:៣០នាទីព្រឹក រហូតដល់ម៉ោង ៥:៣០នាទីល្ងាច។

ទន្ទឹមនឹងពិព័រណ៍រូបថត អាជ្ញាធរជាតិអប្សរាក៏នឹងរៀបចំធ្វើបទបង្ហាញគន្លឹះមួយចំនួនពាក់ព័ន្ធនឹងដំណើរការអាជ្ញាធរជាតិអប្សរា ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍ ការគ្រប់គ្រង និងរៀបចំលំនៅដ្ឋានក្នុងរមណីយដ្ឋានអង្គរ ការចូលរួមរបស់ព្រះសង្ឃក្នុងកិច្ចការពារបេតិកភណ្ឌ ការលើកតម្លៃជាសាកលនៃរមណីយដ្ឋានអង្គរ និងជាពិសេសការចាត់ចែងទឹកពីបុរាណ ការបាត់បង់និងការអញ្ជើញព្រលឹងទឹកមកសណ្ឋិតវិញ ដែលបទបង្ហាញទាំងនេះនឹងធ្វើឡើងដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងអ្នកជំនាញផ្សេងៗទៀត។

ន័យដូចខាងលើ អាជ្ញាធរជាតិអប្សរាសូមគោរពអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ព្រះសង្ឃ អ្នកសារព័ត៌មាន សិស្ស និស្សិត អ្នកស្រាវជ្រាវដែលមានបំណងចង់សិក្សាស្វែងយល់ពីអាជ្ញាធរជាតិអប្សរាក្នុងកិច្ចការគ្រប់គ្រងនៅរមណីយដ្ឋានអង្គរ ចូលរួមឱ្យបានច្រើនកុះករ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាជាមួយប្រធានផ្នែកកិច្ចសហប្រតិបត្តិការ អំពីបេតិកភណ្ឌវប្បធម៌នៃភ្នាក់ងារដើម្បីបេតិកភណ្ឌវប្បធម៌ជប៉ុន

ផ្សាយនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ទទួលជួបលោក ISHIDA Toru ប្រធានផ្នែកកិច្ចសហប្រតិបត្តិការអំពីបេតិកភណ្ឌវប្បធម៌នៃភ្នាក់ងារដើម្បីបេតិកភណ្ឌវប្បធម៌ជប៉ុន ដើម្បីសម្តែងការគួរសម និងថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការរួមគ្នានៃទំនាក់-ទំនងដ៏ល្អប្រសើរ ដែលអាជ្ញាធរជាតិអប្សរាជាមួយស្ថាប័នជប៉ុនបានបំពេញនាពេលកន្លងមកក្នុងតំបន់រមណីយដ្ឋានអង្គរ។

លោក ISHIDA Toru បានបង្ហាញថា នេះជាមោទនភាពសម្រាប់ទាំងអស់គ្នា មិនត្រឹមតែសម្រាប់ជនជាតិជប៉ុនទេ គឺសម្រាប់ប្រទេសកម្ពុជា រួមទាំងសកលលោកទាំងមូល។ ជាមួយគ្នានេះដែរ លោកក៏សង្ឃឹមថា កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ជាមួយបណ្តាស្ថាប័ននានារបស់ជប៉ុនកាន់តែមានភាពរឹងមាំ និងសម្រេចនូវលទ្ធផលល្អប្រសើរបន្ថែមទៀតនាពេលបច្ចុប្បន្ននិងអនាគត។

ជាការឆ្លើយតប **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរាបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងសម្តែងនូវការអរគុណចំពោះលោក ISHIDA Toru ដែលមានចំណាប់អារម្មណ៍មកលើតំបន់រមណីយដ្ឋានអង្គរ។ ឯឧត្តម ក៏បានជម្រាបជូនទៅភាគីជប៉ុនថា អាជ្ញាធរជាតិអប្សរា ក៏ដូចជាប្រជាជនកម្ពុជាមិនដែលភ្លេចទេនូវតួនាទីជាប្រវត្តិសាស្ត្ររបស់ប្រទេសជប៉ុន ក្នុងការជួយជំរុញលើកិច្ចការពារបេតិកភណ្ឌនៅក្នុងតំបន់អង្គរ ជាពិសេសជប៉ុនបានចូលរួមក្នុងការបង្កើតគណៈកម្មការអាយស៊ីស៊ី-អង្គរ និងជាសហប្រធាននៃគណៈកម្មការអាយស៊ីស៊ី-អង្គរ តាំងពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្ន ហើយនឹងសង្ឃឹមថាជប៉ុននៅតែបន្តបំពេញនូវតួនាទីនេះតទៅថ្ងៃអនាគតទៀត។

ឯកឧត្តម បន្តថា រាល់ការងារដែលបានសម្រេចកន្លងមក មិនត្រឹមតែជាទំនាក់ទំនងល្អ រវាងអ្នកជំនាញផ្នែកកិច្ចការងារបេតិកភណ្ឌនៃប្រទេសទាំងពីរនោះទេ ក៏ប៉ុន្តែប្រទេសកម្ពុជា និងប្រទេសជប៉ុន គឺមានទំនាក់ទំនងយូរអង្វែងមកហើយ។ រីឯបច្ចុប្បន្ននេះ រវាងថ្នាក់ដឹកនាំកំពូលជាតិក៏បានបង្ហាញអំពីកិច្ចសហប្រតិបត្តិការយ៉ាងល្អរវាងប្រទេសទាំងពីរ និងប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការលើវិស័យបេតិកភណ្ឌឱ្យកាន់តែល្អប្រសើរជាងមុន៕

អាជ្ញាធរជាតិអប្សរាដំណើរការអ៊ុតបេតុងកៅស៊ូផ្លូវមិត្តភាពកម្ពុជា-កូរ៉េ

ផ្សាយនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា ក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងអន្តរវិស័យកំពុងដំណើរការជួសជុលផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ជំហានទី១ ដែលមានប្រវែងសរុប១៤,៦៧៥ម៉ែត្រ ទទឹង៧ម៉ែត្រ ដោយអ៊ុតបេតុងកៅស៊ូ ចាប់ពីផ្លូវបំបែកផ្លូវជាតិលេខ៦ ចំណុចផ្សារស្វាយធំ រហូតដល់រង្វង់មូលកូនដំរី ស្ថិតក្នុងឃុំព្រះដាក់ ស្រុកបន្ទាយស្រី។

ប្រតិភូគណៈកម្មការទី២នៃរដ្ឋសភាបំពេញទស្សនកិច្ចស្វែងយល់ពីកិច្ចការអភិរក្ស នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២០

នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ គណៈកម្មការទី២ នៃរដ្ឋសភា ដឹកនាំដោយ **ឯកឧត្តម គតសេដ្ឋាបណ្ឌិត ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា អមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញទៅទស្សនកិច្ចស្វែងយល់ពីកិច្ចការអភិរក្ស នៅរមណីយដ្ឋានអង្គរ។

ដំណើរទស្សនកិច្ចនេះ បានទៅកាន់ប្រាសាទភិមានអាកាស និងប្រាសាទអង្គរវត្ត ដោយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាបានបង្ហាញពីកិច្ចការអភិរក្ស ការជួសជុលសំណង់ប្រាសាទជំនឿ និងការគ្រប់គ្រងទីបុរាណដ្ឋានទាំងនេះប្រកបដោយការយកចិត្តទុកដាក់ខ្ពស់៕

អាជ្ញាធរជាតិអប្សរាចូលរួមបរិច្ចាគថវិកាជួយប្រជាជនចិន ដែលកំពុងរងគ្រោះដោយសារជំងឺ COVID-19

ផ្សាយនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២៧ ខែកុម្ភៈ អាជ្ញាធរជាតិអប្សរាបាន ចូលរួមបរិច្ចាគក្នុងកម្មវិធីសម្តែងសិល្បៈសប្បុរសធម៌ ស្វែងរកមូលនិធិជួយដល់ប្រជាជនទីក្រុងវ៉ូហាន ខេត្តហ៊ឺប៉ី នៃសាធារណរដ្ឋប្រជាមានិតចិន ដែលកំពុងប្រឈមនឹងជំងឺកូវីត ១៩ (COVID-19)។ កម្មវិធីសប្បុរសធម៌នៅពេលនោះ ធ្វើឡើងនៅសាលមហោស្រពសិល្បៈអាណាចក្រអង្គរ ក្រោមវត្តមាន **ឯកឧត្តម ឡៅ ស៊ីហា** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ថ្នាក់ដឹកនាំតាមមន្ទីរ ស្ថាប័ន ក្រុមហ៊ុន វិស័យឯកជន សមាគម ព្រមទាំងសិស្សានុសិស្ស សរុបប្រមាណ ៤០០នាក់៕

ការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងបរិស្ថាន នៅមុខខាងលិចប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ក្រុមការងារចម្រុះដឹកនាំដោយ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានចុះរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយនិងបរិស្ថាន នៅមុខខាងលិចប្រាសាទព្រះខ័ន ដើម្បីលើកកម្ពស់គុណតម្លៃរមណីយដ្ឋានអង្គរ និងសម្រួលដល់លំហូរទេសចរ។

ក្នុងនោះដោយមានការចូលរួម និងឯកភាពពីអាជីវករនៅមុខប្រាសាទព្រះខ័ន ក្រុមការងារបានរំកិលតូបទាំងអស់ប្រវែង៦៥ ម៉ែត្រ ទទឹង៧ ម៉ែត្រ ដែលស្ថិតនៅកៀកនឹងផ្លូវពេក ឱ្យខិតចូលទៅក្នុងប្រវែង២៥ម៉ែត្រពីចិញ្ចើមថ្នល់ដើម្បីទុកជាផ្លូវថ្មើរជើង ផ្លូវជិះកង់ រួមទាំងចំណតជំនួសការចតជាប់នឹងប្រាសាទ។

ទន្ទឹមនឹងនោះ ដោយមានកិច្ចសហការពីគ្រឹះស្ថានអង្គរបង្គន់ចល័តមួយចំនួនក៏នឹងត្រូវបានដាក់នៅទីនេះសម្រាប់ទេសចរនិងសាធារណជនផងដែរ។រីឯបរិវេណមុខប្រាសាទនេះនឹងមានការដាំស្មៅឱ្យមានភាពបៃតងវិញផងដែរ ៕

សមិទ្ធផលសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរានៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា កំពុងចាប់ផ្ដើមអនុវត្តគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្បទាទេសចរណ៍ ទេសភាព និងបរិស្ថាននៅបរិវេណមុខប្រាសាទអង្គរវត្តផ្នែកខាងលិចឱ្យមានភាពល្អប្រសើរ ក្នុងទិសដៅលើកតម្កើងគុណតម្លៃអង្គរដែលជានិមិត្តរូប ដួងព្រលឹងជាតិខ្មែរ និងជារមណីយដ្ឋានបេតិកភណ្ឌ។

គម្រោងទាំងនោះរួមមាន៖ កែប្រែដីទំនេរគ្មានស្មៅ និងដើមឈើ ឱ្យក្លាយជាវាលស្មៅ និងសួនឈើដ៏ស្រស់បំព្រងគ្រប់រដូវកាល រៀបចំសណ្ដាប់ធ្នាប់ការលក់ដូរ ដោយធ្វើទីលានបដិសណ្ឋារកិច្ចទទួលភ្ញៀវទេសចរ កន្លែងផ្ដល់ព័ត៌មាន កន្លែងតាំងពិព័រណ៍ តូបលក់ដូរសម្រាប់ប្រជាជនក្នុងស្រុក និងលំដាប់អន្តរជាតិ រៀបចំឡានម៉ូតូ និងរ៉ឺម៉កដែលចតគ្មានសណ្ដាប់ធ្នាប់ ឱ្យចូលចតក្នុងចំណត រៀបចំប្រព័ន្ធរំដោះទឹកមិនឱ្យមានទឹកដក់ភក់ជ្រាំក្នុងរស្សាន្តរដូវ។

ក្នុងនោះដែរ អាជ្ញាធរជាតិអប្សរា ក៏បានរៀបចំដាំដើមឈើអមសងខាងផ្លូវចាប់ពីព្រលានយន្តហោះឆ្ពោះទៅប្រាសាទអង្គរវត្ត កែសម្រួលផ្លូវដោយចាក់បេតុងកៅស៊ូ (AC) និងកាត់ដកហូតដើមឈើងាប់ និងដើមឈើមួយចំនួនទៀត ដូចជា ដើមពុទ្រា ដើមអំពិលទឹកជាដើម ដោយដាំជំនួសមកវិញនូវដើមឈើប្រណីត ហើយនឹងរៀបចំផ្លូវថ្មើរជើងដែលមានដាំស្មៅអមសងខាងផ្លូវផងដែរ៕

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរាបដិសេធ ពុំមានករណីភ្ញៀវទេសចរជប៉ុនស្លាប់ដោយសារជំងឺCovid 19 នៅប្រាសាទអង្គរវត្តនោះទេ!

ផ្សាយនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២០

យោងទៅលើហ្វេសប៊ុកឈ្មោះ Sdam Husen និងទំព័រហ្វេសប៊ុកផ្សេងៗបានចុះផ្សាយថា «ភ្ញៀវទេសចរជនជាតិជប៉ុនម្នាក់បានស្លាប់ដោយ Covid19 នៅប្រាសាទអង្គរវត្តប៉ុន្មាននាទីមុននេះ នាថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០» ដោយប្រើរូបភាពចាស់។

ចំពោះករណីចុះផ្សាយខាងលើនេះ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា សូមបដិសេធថាពុំមែនជាព័ត៌មានពិតទេ។ រីឯរូបភាពដែលបានប្រើប្រាស់នោះ គឺជាព្រឹត្តិការណ៍បានកើតឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ដែលស្ត្រីភ្ញៀវទេសចរជនជាតិជប៉ុនម្នាក់ អាយុ៧២ឆ្នាំ បានកើតខ្យល់នៅចំណុចព្រះពាន់ និងត្រូវបានបញ្ជូនទៅព្យាបាលតាមរថយន្តពេទ្យ Royal Angkor ភ្លាមៗ។

អាជ្ញាធរជាតិអប្សរា ស្នើដល់ម្ចាស់គេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមទាំងអស់ សូមបញ្ឈប់រាល់សកម្មភាពចែកចាយនិងផ្សព្វផ្សាយនូវព័ត៌មានផ្ទុយពីការពិត ដែលនាំមកនូវការខាតបង់ប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ បាត់បង់កិត្តិយសជាតិ រួមនឹងសតិអារម្មណ៍របស់ភ្ញៀវទេសចរ និងប្រជាជាតិខ្មែរ៕



លោកជំទាវ ភឿង សកុណា ដឹកនាំក្រុមអ្នកជំនាញការនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ចូលគាល់ព្រះមហាក្សត្រ

ផ្សាយនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២០

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធាននៃអាជ្ញាធរជាតិអប្សរា អមដំណើរដោយអ្នកជំនាញការនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ រួមទាំងសហប្រធានជប៉ុន បារាំង និងអង្គការយូណេស្កូ បានចូលគាល់ក្រាបថ្វាយបង្គំព្រះមហាក្សត្រ **ព្រះបាទនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទូលថ្វាយនូវលទ្ធផលដ៏ល្អប្រសើរនៃកិច្ចប្រជុំអាយស៊ីស៊ី-អង្គរ កាលពីឆ្នាំ២០១៩កន្លងទៅ៕

អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុនផ្កាឈូក និងមូលនិធិផ្កាឈូករៀបចំពិព័រណ៍សមិទ្ធផល២៥ឆ្នាំនៃអាជ្ញាធរជាតិអប្សរានៅមជ្ឈមណ្ឌលសហប្រតិបត្តិកម្ពុជា-ជប៉ុន

ផ្សាយនៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២០

ព្រឹកថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០២០ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) បានរៀបចំពិពរ័ណ៍សមិទ្ធផលការងាររបស់អាជ្ញាធរជាតិអប្សរា ដើម្បីអបអរខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា (១៩៩៥ - ២០២០)។

ពិព័រណ៍សមិទ្ធផលការងារនេះរៀបចំឡើងដោយមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា តំណាង **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌វិចិត្រសិល្បៈ និងជាប្រធានអាជ្ញាធរជាតិអប្សរា ជាមួយក្រុមហ៊ុនផ្កាឈូកនិងមូលនិធិផ្កាឈូក ដឹកនាំដោយ លោក អៀង សុធារ៉ា។

មានប្រសាសន៍ក្នុងឱកាសនោះ លោក អៀង សុធារ៉ា ប្រធានក្រុមហ៊ុនផ្កាឈូក និងមូលនិធិផ្កាឈូក បានលើកឡើងថា ការស្នើសុំអាជ្ញាធរជាតិអប្សរាយកសមិទ្ធផលការងារ២៥ឆ្នាំក្នុងថ្ងៃបង្កើតស្ថាប័នខ្លួនមកតាំងពិព័រណ៍នៅទីនេះ គឺដើម្បីចូលរួមផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយពីកិច្ចការអភិរក្ស ការជួសជុលប្រាង្គប្រាសាទ ការគ្រប់គ្រងទេសចរណ៍ សហគមន៍ ព្រៃឈើ ទឹក ទេសភាពវប្បធម៌។ល។ ដែលអាជ្ញាធរជាតិអប្សរាសម្រេចបាននៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ នេះជាការកិច្ចមួយដ៏ចាំបាច់ ក្នុងនាមខ្ញុំជាកូនខ្មែរ ត្រូវជួយផ្សព្វផ្សាយពីមរតកដូនតា រួមចំណែកលើកកម្ពស់ ថែរក្សា ផ្សព្វផ្សាយពីសម្បត្តិវប្បធម៌ជាតិ ព្រោះយើងគ្រប់គ្នាសុទ្ធតែទទួលបានចំណែកផលនៃអង្គរ។

ឯកឧត្តមបណ្ឌិត ហង់ ពៅ បានថ្លែងអំណរគុណចំពោះកិច្ចសហការពីក្រុមហ៊ុន និងមូលនិធិផ្កាឈូកក្នុងការជួយផ្សព្វផ្សាយពីលទ្ធផលការងាររបស់អាជ្ញធរជាតិអប្សរា រយៈពេល២៥ឆ្នាំ។ ឯកឧត្តម ក៏បានលើកឡើងថា នេះជាកិច្ចការមួយដ៏សំខាន់ ដែលអាជ្ញាធរជាតិអប្សរា ត្រូវបង្ហាញរាល់សមិទ្ធផលនានាដែលកើតចេញពីការខិតខំរបស់ខ្លួន ឱ្យសាធារណជនដឹងៗ ចាប់ពីតាំងពីស្ថាប័ននេះបង្កើតឡើង រហូតដល់ធ្វើឱ្យរមណីយដ្ឋានអង្គរលែងក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់នៅឆ្នាំ២០០៤។

ឯកឧត្តម បន្តទៀតថា អាជ្ញាធរជាតិអប្សរាគឺលំបាកជាងគេ គឺទីមួយប្រឹងធ្វើយ៉ាងម៉េចដើម្បីអភិរក្សប្រាសាទដាច់ខាតឱ្យបានល្អ រឹងមាំ ផុតពីហានិភ័យព្រោះយើងខ្វះខាតទាំងអ្នកជំនាញ ថវិកា ហើយប្រទេសក៏ស្ថិតក្នុងស្ថានភាពអសន្តិសុខ ពិសេសតំបន់អង្គរ ពេញដោយគ្រាប់មីន។ ទីពីរ គឺប្រឹងជានាការអភិវឌ្ឍឱ្យស្របនឹងការអភិរក្សប្រកបដោយចីរភាព។

គួរបញ្ជាក់ផងដែរថា តំបន់អង្គរឬរមណីយដ្ឋានអង្គរ ត្រូវបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២ មានផ្ទៃដីសរុប៤០១គីឡូម៉ែត្រក្រឡា ដែលក្នុងនោះរួមមានទាំងប្រាសាទ បុរាណដ្ឋាន ស្ថានីយបុរាណវិទ្យាចំនួន៩១ បរិស្ថាន និងសហគមន៍មនុស្សផងដែរ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមីនា

ជម្រាបជូនលោក /លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ០១៧៩/២០ រជ.សណ

ជម្រាបជូន
លោក/លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ខេត្តសៀមរាប

កម្មវត្ថុ៖ សំណើសុំកិច្ចសហការជម្រុញមគ្គុទ្ទេសក៍ទេសចរណ៍ ចូលរួមអនុវត្តសេចក្តីជូនដំណឹង របស់អាជ្ញាធរជាតិអប្សរា ស្តីពី "ការបិទចរាចរណ៍ឡើង-ចុះ វង់ទស្សនាជាន់ទីបី(ប្រាង្គកណ្តាល) នៃប្រាសាទបាយ័ន" និងគោរពតាមវង់ទស្សនាថ្មីនៅប្រាសាទបាយ័ន។

យោង ៖ លិខិតជូនដំណឹងលេខ ៨៧១/១៩រប.សជណ របស់អាជ្ញាធរជាតិអប្សរា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក/លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍** ជ្រាបថា៖ អាជ្ញាធរជាតិអប្សរា បានចេញសេចក្តីជូនដំណឹងស្តីពី "ការបិទចរាចរណ៍ឡើង-ចុះ វង់ទស្សនាជាន់ទីបី(ប្រាង្គកណ្តាល) នៃប្រាសាទបាយ័ន" ចាប់តាំងពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ដោយសារស្ថានភាពសិករិចរិលខ្លាំង ប្រឈមនឹងហានិភ័យយ៉ាងធ្ងន់ធ្ងរ ដែលបង្កឡើងដោយកត្តាអាយុកាល និងកត្តាផ្សេងៗជាច្រើនទៀត ដើម្បីទុកពេលវេលាឱ្យក្រុមការងារជំនាញធ្វើការអភិរក្ស ជួសជុលលើផ្នែកដែលប្រឈមនឹងគ្រោះថ្នាក់ទាំងនោះ។ ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរា បានរៀបចំវង់ទស្សនាថ្មី ដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវជាតិ-អន្តរជាតិ ហើយរយៈពេលជាងមួយខែកន្លងមក អាជ្ញាធរជាតិអប្សរា សង្កេតឃើញថា មគ្គុទ្ទេសក៍ទេសចរណ៍ភាគច្រើនបានចូលរួមសហការអនុវត្តតាមសេចក្តីណែនាំប្រកបដោយភាពរលូន។ ប៉ុន្តែនៅមានមគ្គុទ្ទេសក៍មួយចំនួននៅតែមិនអនុវត្តតាមសេចក្តីណែនាំ ដោយប្រព្រឹត្តសកម្មភាពមិនសមរម្យ និងមិនព្រមណែនាំភ្ញៀវទេសចរឱ្យគោរពតាមសេចក្តីជូនដំណឹងនេះនៅឡើយ ជាហេតុបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ភ្ញៀវទេសចរដែលកំពុងទស្សនា និងបង្កផលលំបាកសម្រាប់អ្នកជំនាញក្នុងពេលបំពេញការងារ។

ដូច្នេះ ដើម្បីទុកលទ្ធភាពឱ្យក្រុមការងារជំនាញផ្នែកអភិរក្សបំពេញការងារ និងរក្សាសុវត្ថិភាពភ្ញៀវទេសចរជាតិ-អន្តរជាតិ ក៏ដូចជាការចូលរួមសហការអនុវត្តលើសេចក្តីជូនដំណឹងរបស់អាជ្ញាធរជាតិអប្សរា ខ្ញុំសូមស្នើ **លោក/លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍** ទាំងអស់ក្នុងខេត្តសៀមរាប ចូលរួមផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពី "ការបិទចរាចរណ៍ឡើង-ចុះ វង់ទស្សនាជាន់ជាន់ទីបី (ប្រាង្គកណ្តាល) នៃប្រាសាទបាយ័ន" ជូនដល់មគ្គុទេសក៍ទេសចរណ៍បានដឹង និងសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក/លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍** មេត្តាជ្រាប និងចូលរួមសហការតាមការគួរ។

សូម **លោក/លោកស្រី ប្រធានសមាគមមគ្គុទ្ទេសក៍ទេសចរណ៍** ទទួលនូវការរាប់អានដ៏ស្មោះស័គ្រពីខ្ញុំ។

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០២០

អគ្គនាយក

ហង់_ពៅ

ចម្លងជូន៖
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- រដ្ឋបាលខេត្តសៀមរាប
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប
- មន្ទីរទេសចរណ៍ ខេត្តសៀមរាប
  «ដើម្បីគោរពជូនជ្រាប»
- គ្រឹះស្ថានអង្គរ
- គ្រប់សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- គ្រប់ក្រុមហ៊ុនទេសចរណ៍ និងសណ្ឋាគារ
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ:
អគារលេខ៨៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/ ០២៣ ២១៥ ៧៧៦

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

មតិសាធារណជនជុំវិញការតាំងពិព័រណ៍ខួប២៥ឆ្នាំនៃការបង្កើតអាជ្ញាធរជាតិអប្សរា នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)

ផ្សាយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២០

ពិព័រណ៍សមិទ្ធផលការងាររយៈពេល២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា ត្រូវបានរៀបចំជាលើកទី២នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) នាថ្ងៃទី២៩ខែកុម្ភៈឆ្នាំ២០២០ដោយស្ថាប័នអាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុនផ្កាឈូក និងមូលនិធិផ្កាឈូក បានទទួលការគាំទ្រយ៉ាងច្រើនពីសាធារណជន។

លោក តែម ចន្ថា មគ្គុទ្ទេសក៍ទេសចរណ៍ខេត្តសៀមរាប បានលើកឡើងថា ការតាំងពិព័រណ៍នេះ បានឱ្យលោកដឹងពីសមិទ្ធផលអភិរក្ស និងអភិវឌ្ឍន៍ជាច្រើនក្នុងរយៈពេល ២៥ឆ្នាំនៅក្នុងរមណីយដ្ឋានអង្គរដូចជា ការជួសជុលអភិរក្សប្រាសាទ ការកំណាយស្រះជ្រោះ ការរៀបចំសួនមុខប្រាសាទអង្គរវត្ត សណ្តាប់តាមប្រាសាទ។ល។

លោកបន្ថែមថា សាធារណជនទាំងអស់គួរតែចូលរួមទស្សនាដើម្បីស្វែងយល់ពីការងាររបស់អាជ្ញាធរជាតិអប្សរា និងការអភិរក្សសម្បត្តិបេតិកភណ្ឌពិភពលោក ដែលជាប្រយោជន៍សម្រាប់អាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ និងអភិវឌ្ឍន៍ចំណេះដឹងផ្ទាល់ខ្លួន។ លោកមានទស្សនៈថា ការបង្កើតឱ្យមានស្ថាប័នជាតិមួយនេះ បានផ្តល់ផលចំណេញដល់ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងផ្នែកសេដ្ឋកិច្ច ទេសចរណ៍ និងការអភិរក្សសម្បត្តិដូនតា បើគ្មានស្ថាប័ននេះទេ ច្បាស់ជាតំបន់អង្គររងការទន្ទ្រានយកដីសាងសង់លំនៅដ្ឋាន ការកាប់បំផ្លាញព្រៃឈើ និងការបំផ្លាញបុរាណដ្ឋានមិនខាន។

លោក ស៊ិន បញ្ញា និស្សិតឆ្នាំទី១នៃសាកលវិទ្យាបញ្ញាសាស្ត្រ បានឱ្យដឹងថា ការតាំងពិព័រណ៍គម្រប់ខួប២៥ឆ្នាំរបស់អាជ្ញាធរជាតិអប្សរា បានឱ្យលោកស្វែងយល់ពីការសាងសង់ ជួសជុលប្រាសាទរបស់ដូនតាឱ្យមានភាពរឹងមាំរាប់រយឆ្នាំមកដល់សព្វថ្ងៃ រួមទាំងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរដែលផ្តល់ជាប្រយោជន៍ដល់រូបលោក ក៏ដូចជាយុវជនសិស្ស និស្សិតផ្សេងៗទៀត។ លោក ស៊ិន បញ្ញា ក៏មានបំណងឱ្យកម្មវិធីតាំងពិព័រណ៍នេះធ្វើឱ្យបានច្រើនដង ដើម្បីផ្សព្វផ្សាយ អប់រំ ចំណេះដឹងដល់សាធារណជនឱ្យស្គាល់ពីតម្លៃសម្បត្តិដូនតានិងជាតិទាំងមូល។

ព្រះតេជគុណ កែវ វីថៃ សាមណសិស្សមកពីសីហនុរាជ្យ ខេត្តបាត់ដំបងមានសង្ឃដីការថា អាត្មាបានស្គាល់អាជ្ញាធរជាតិអប្សរាតាមរយៈកិច្ចការថែទាំបេតិកភណ្ឌ ក្នុងនោះមាន ការជួសជុលអភិរក្សប្រាសាទបុរាណនានា ហើយនឹងតាមរយៈវិស័យទេសចរណ៍ មិនតែប៉ុណ្ណោះសេដ្ឋកិច្ចជាតិមួយផ្នែកធំក៏ទទួលបានតាមរយៈរមណីយដ្ឋានអង្គរ។ ព្រះអង្គបានចាប់អារម្មណ៍ទាក់ទងនឹងការជួសជុលប្រាសាទ និងការគ្រប់គ្រងទឹក ដែលដូនតាខ្មែរបានរៀបចំប្រព័ន្ធធារាសាស្ត្របានយ៉ាងល្អជាយូរមកហើយ និងជាការលើកតម្កើង ពិសេសផ្សព្វផ្សាយទៅកាន់ពិភពលោកពីជាតិសាសន៍ខ្មែរលើឆាកអន្តរជាតិ។ ព្រះអង្គបានសំណូមពរឱ្យមានកម្មវិធីនេះជាបន្តបន្ទាប់ទៀតដើម្បីឱ្យអ្នកសិក្សារៀនសូត្រយល់ដឹងពីសម្បត្តិបេតិកភណ្ឌ និងចូលរួមថែរក្សាទាំងអស់គ្នា។

កញ្ញា គង់ ស្មើ និស្សិតនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ បានឱ្យដឹងថា អាជ្ញាធរជាតិអប្សរាជាស្ថាប័នការពារអភិរក្ស ថែទាំរមណីយដ្ឋានអង្គរ ហើយការដែលបង្កើតកម្មពិធីពិព័រណ៍នេះឡើងគឺពិតជាល្អណាស់ ព្រោះថាប្រជាជនមួយចំនួនតូចមិនបានយល់ច្បាស់ពីកិច្ចការ ដែលស្ថាប័ននេះកំពុងតែធ្វើឡើយ ហើយថែមទាំងមានគំនិតអវិជ្ជមានចំពោះអាជ្ញាធរជាតិអប្សរាទៀតផង ។ កញ្ញាបន្តថា ដោយជាក់ស្តែងអាជ្ញាធរជាតិអប្សរាបានខិតខំបំពេញឡើងវិញនូវទឹកក្នុងកសិន្ធុ និងបារាយណ៍នានាដែលបានស្ងួត និងមានទឹកឡើងវិញគ្រប់រដូវកាល ដែលប្រព័ន្ធធារាសាស្ត្រទាំងនោះជួយពង្រឹងគ្រឹះប្រាសាទបានយ៉ាងល្អ។ ក្នុងនាមជាកូនខ្មែរគ្រប់រូបកុំគិតថា យើងមនុស្សតែម្នាក់ មិនអាចជួយអ្វីបាន ប៉ុន្តែអ្វីក៏ដោយផ្តើមចេញពីពលរដ្ឋម្នាក់ៗ និងទាំងអស់គ្នា និងផ្តើមចេញពីខ្លួនយើង នៅពេលយើងចូលរួមនៅក្នុងការអភិរក្ស នឹងយល់ដឹងនូវតម្លៃសម្បត្តិដូនតា ជួយថែរក្សាទាំងអស់គ្នា ទៅបានធ្វើឱ្យសង្គមជាតិមានការរីកចម្រើន និងមានសន្តិភាព៕

អាជ្ញាធរជាតិអប្សរាទទួលជួបតំណាងអង្គការ JICA ផ្នែកគ្រប់គ្រងទូទៅការិយាល័យអភិវឌ្ឍន៍ទីក្រុង

ផ្សាយនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ **ឯកឧត្តម ជុំ សុខមករា** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ទទួលជួបគណៈប្រតិភូតំណាងអង្គការ JICA ដឹកនាំដោយលោកស្រី Kuniomi HIRANO ប្រធានគ្រប់គ្រងទូទៅការិយាល័យផ្នែកអភិវឌ្ឍន៍ទីក្រុង ដើម្បីធ្វើបទបង្ហាញមូលដ្ឋានសិក្សាថ្នាក់ដំបូងនៃគម្រោង Smart Cities ជូនដល់ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា។

ចំពោះគម្រោងSmartCitiesខេត្តសៀមរាបចែកជាបីតំបន់រួមមានតំបន់ក្រុង តំបន់បេតិកភណ្ឌ និងតំបន់ទន្លេសាប ក្នុងគោលដៅលើកកម្ពស់សន្តិសុខ ការគ្រប់គ្រងសំរាម ការដឹកជញ្ជូន ទេសចរណ៍។ នាពេលអនាគតគម្រោងនេះនឹងបង្កើតគណៈកម្មការតម្រង់ទិស និងក្រុមការងារតម្រូវឱ្យមានសមាសភាពចម្រុះដែលពាក់ព័ន្ធចូលរួម ហើយអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងសាលាខេត្តសៀមរាប ដែលគម្រោងនឹងចាប់ផ្តើមអនុវត្តពីខែមិនា ឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០៣១ ខាងមុខ។

ជាការឆ្លើយតបចំពោះការលើកឡើងខាងលើនេះ **ឯកឧត្តម ជុំ សុខមករា** បានស្វាគមន៍ និងគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការ JICA។ ប៉ុន្តែជាការស្នើសុំ ឯឧត្តមជម្រាបទៅខាងតំណាងអង្គការ JICA ថា ប្រសិនជាគម្រោងនេះទៅដល់ក្នុងតំបន់អង្គរ ហើយជាក់ស្តែងមានផលប៉ះពាល់ខ្លាំង ត្រូវស្នើសុំទៅយន្តការអាយស៊ីស៊ី-អង្គរ ដើម្បីសម្រេច៕

ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ អ្នកស្រុកអង្គរចំនួន២២៩គ្រួសារ ទទួលបានការអនុញ្ញាតឱ្យជួសជុលសំណង់ស្រាល

ផ្សាយនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២០

យោងតាមរបាយការណ៍ក្រុមការងារលេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា ក្នុងខែកុម្ភៈឆ្នាំ២០២០នេះ ក្រុមការងារបានបន្តការងារចុះពិនិត្យអនុញ្ញាតការជួសជុលសំណង់តូចតាច ដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានអង្គរបានចំនួន៣២៧ ករណី(សំណើ) ក្នុងនោះសំណង់ស្រាល ដែលត្រូវបានក្រុមការងារអនុញ្ញាតមានចំនួន២២៩ ករណី(សំណើ)។

គោលដៅទាំងនោះ រួមមានស្រុកប្រាសាទបាគង អនុញ្ញាតបានចំនួន២០ករណី ស្រុកអង្គរធំ អនុញ្ញាតបានចំនួន២០ករណី ស្រុកពួក អនុញ្ញាតបានចំនួន៦២ករណី ក្រុងសៀមរាប អនុញ្ញាតបានចំនួន២៩ករណី និងស្រុកបន្ទាយស្រី អនុញ្ញាតបានចំនួន៩៨ ករណី។

ការអនុញ្ញាតនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារសហគមន៍បានចុះពិនិត្យទៅដល់ខ្នងផ្ទះដាក់ស្តែង និងឯកសារពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាមូលដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃថា ពួកគាត់គឺជាប្រជាពលរដ្ឋចាស់រស់នៅក្នុងតំបន់អង្គរពិតប្រាកដ និងមានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-សង្កាត់ ហើយមានតម្រូវការដាក់ស្តែងក្នុងការកែលម្អការរស់នៅឱ្យបានល្អប្រសើរ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាថ្លែងអំណរគុណដល់សប្បុរសជន ដែលបានចូលរួមថែរក្សាការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌

ផ្សាយនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

ក្នុងទិវា «វប្បធម៌ជាតិ ៣មីនា» លើកទី២២ និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៦ នៅរសៀលថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០នេះ ដែលប្រារព្ធឡើងនៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកោតសរសើរចំពោះសប្បុរសជនមួយចំនួនរួមមាន៖ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច **លោកជំទាវឧកញ៉ា ម៉ៅ ម៉ាល័យ កែ គឹមយ៉ាន** ប្រធានកិត្តិយសសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងការអភិវឌ្ឍខេត្តបន្ទាយមានជ័យ **លោកជំទាវឧកញ៉ាកិត្តិបណ្ឌិត សៀវ ចាន់ហេង** អគ្គនាយិកា ក្រុមហ៊ុន ហេងអភិវឌ្ឍន៍ និង**លោកជំទាវឧកញ៉ា ស៊ុយ ស៊ីផាន** ព្រមទាំងសប្បុរសជនផ្សេងទៀត ដែលបានលះបង់ធនធានថវិកាផ្ទាល់ខ្លួនចូលរួមជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិរក្សប្រាសាទនិងវត្តអារាមមួយចំនួន។

ដោយឡែក សម្រាប់ការអភិរក្សបេតិកភណ្ឌក្នុងតំបន់រមណីយដ្ឋានអង្គរ **លោកជំទាវឧកញ៉ាកិត្តិបណ្ឌិត សៀវ ចាន់ហេង** អគ្គនាយិកា ក្រុមហ៊ុន ហេងអភិវឌ្ឍន៍ បាននិងកំពុងចូលរួមជួយឧបត្ថម្ភថវិកាទៅលើការជួលជុលរហាត់ទឹកដែលមានតាំងពីសម័យទសវត្សរ៍ទី៦០ បានជួសជុលប្រាសាទកណ្តាលស្រះស្រង់ ដែលបានកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧សតវត្សរ៍ទី១២ តំណាងឱ្យភ្នំព្រះសុមេរុ ការដាំដើមឈើ និងកិច្ចការដទៃទៀតផងដែរ។

ការជួយឧបត្ថម្ភពីសប្បុរសជនទាំងអស់នោះ គឺជាសក្ខីភាពដែលបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការចូលរួមថែរក្សាអភិរក្សសម្បត្តិបេតិកភណ្ឌវប្បធម៌និងលើកកម្ពស់ទេសភាពវប្បធម៌ ក្នុងតំបន់រមណីយដ្ឋានអង្គរឱ្យមានភាពលេចធ្លោជាសកល ស្ថិតនៅក្នុងដួងចិត្តកូនខ្មែរគ្រប់ៗ គ្នាជាមួយរាជរដ្ឋាភិបាល ជាពិសេសគឺក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថាប័នអាជ្ញាធរជាតិអប្សរា។

ក្នុងនោះដែរ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអាជ្ញាធរជាតិអប្សរា បានដើរតួយ៉ាងសំខាន់ក្នុងការថែរក្សាអភិរក្ស និងផ្សព្វផ្សាយវប្បធម៌ដ៏សម្បូរបែបរបស់បុព្វបុរសខ្មែរ ដែលបានបន្សល់ទុក ដើម្បីឱ្យកូនខ្មែរទាំងអស់បានយល់ដឹងកាន់តែច្បាស់ និងចូលរួមក្នុងការការពាររក្សានូវមរតកវប្បធម៌ទាំងអស់នោះតរៀងទៅ។

ក្នុងទិវាវប្បធម៌ជាតិ ៣ មីនា លើកទី២២ នេះ អាជ្ញាធរជាតិអប្សរាសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងសាធារណជនទាំងអស់ សូមសិក្សាស្វែងយល់ ចូលរួមឧបត្ថម្ភគាំទ្រ ការការពារ និងថែរក្សាអភិរក្សបេតិកភណ្ឌទាំងអស់គ្នា ព្រោះការងារការពារបេតិកភណ្ឌជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗគ្នា ស្របតាមពាក្យស្លោកថា «វប្បធម៌រលំ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន»៕

សារមន្ទីរកុលាលភាជន៍អង្គរភូមិតានីមានគម្រោងផលិតចម្លងកុលាលភាជន៍បុរាណឡើងវិញ ដើម្បីលើកស្ទួយស្នាដៃដូនតា

ផ្សាយនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

នៅចុងខែ កុម្ភៈកន្លងទៅ អាជ្ញាធរជាតិអប្សរាបានរៀបចំស្តង់ពិព័រណ៍ដើម្បីបង្ហាញពីសមិទ្ធផលនានា ក្នុងការប្រារព្ធពិធីអបអរខួប២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា។ ស្តង់ពិព័រណ៍ត្រូវបានរៀបចំឡើងទៅតាមនាយកដ្ឋានជំនាញនីមួយៗ ក្នុងនោះក៏មានស្តង់របស់នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌមួយដែរ។ ក្នុងស្តង់នេះមានតាំងបង្ហាញនូវសមិទ្ធផលរបស់នាយកដ្ឋាន ក្នុងនោះក៏មានតាំងកុលាលភាជន៍មួយចំនួនដែរ។

លោក វង្ស សារុទ្ធី បុគ្គលិកបច្ចេកទេសនៃសារមន្ទីរកុលាលភាជន៍អង្គរភូមិតានី បានឱ្យដឹងថា កុលាលភាជន៍ដែលយកតាំងបង្ហាញនៅពេលនោះ គឺជាកុលាលភាជន៍ដែលផលិតឡើងវិញ ដោយចម្លងពីកុលាលភាជន៍បុរាណដែលបានរកឃើញពីស្ថានីយបុរាណសម័យអង្គរនានាក្នុងតំបន់អង្គរ។ លោកបន្ថែមថា សារមន្ទីរមានគម្រោងមួយដើម្បីលើកកម្ពស់គម្រោងបុរាណនៅភូមិ ដោយបង្កើតរោងជាងកុលាលភាជន៍ដើម្បីឱ្យប្រជាពលរដ្ឋក្នុងភូមិ មានឱកាសផលិត និងធ្វើឱ្យការផលិតកុលាលភាជន៍រស់ឡើងវិញ ជាប្រយោជន៍ដើម្បីលើកកម្ពស់ជីវភាពប្រជាជនលើវិស័យទេសចរណ៍។ សម្រាប់លោក វង្ស សារុទ្ធី ការងារទាំងនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការរំឭក ស្នាដៃដូនតា ការបង្ហាញពីការស្រឡាញ់ថែទាំ ដ្បិតថាយើងមិនអាចធ្វើតាមទាំងស្រុងតាមបុព្វបុរសយើង តែយ៉ាងណាយើងមានចិត្តចង់លើកស្ទួយ គាំទ្រ និងថែទាំវត្ថុទាំងនោះឱ្យបានគង់វង្សទៅអ្នកជំនាន់ក្រោយទៀត។

លោកបន្ថែមថា មរតកដូនតាខ្មែរមានចំនួនច្រើនសន្ធឹកដែលអាចឱ្យយើងយកមកប្រើប្រាស់ និងលើកស្ទួយឡើងវិញ រាប់មិនអស់ ដូច្នេះគំនិតនៃការចម្លងគំរូកុលាលភាជន៍បុរាណមកប្រើប្រាស់ឡើងវិញ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គឺដូចជារំឭកស្នាដៃដូនតាឡើងវិញ មួយទៀតដើម្បីធ្វើឱ្យមរតកដូនតាបានរស់រវើកឡើងវិញយ៉ាងដូច្នោះដែរ៕

ថ្នាក់ដឹកនាំសហភាពសហព័ន្ធយុវជនកម្ពុជាចុះពិនិត្យទីតាំងនៅប្រាសាទអង្គរវត្ត ដើម្បីរៀបចំសៀមរាបសង្ក្រាន្ត

ផ្សាយនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

កាលពីថ្ងៃទី០៤ ខែមិនា ឆ្នាំ២០២០ **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា អមដំណើរដោយ **ឯកឧត្តម ប្រាក់ សោភ័ណ** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាប និង **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរាតំណាងឯកឧត្តមអគ្គនាយក និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជាវិស័យបេតិកភណ្ឌ ព្រមទាំងថ្នាក់ដឹកនាំ រួមទាំងក្រុមការងារពាក់ព័ន្ធជាច្រើន បានចុះពិនិត្យទីតាំងនៅប្រាសាទអង្គរវត្ត ដើម្បីត្រៀមរៀបចំព្រឹត្តិការណ៍សៀមរាបសង្ក្រាន្តរយៈពេល៣ថ្ងៃ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ៦រោច ដល់ថ្ងៃ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០។

ចំពោះការរៀបចំអបអរសាទរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ អាជ្ញាធរជាតិអប្សរា តែងតែមានកិច្ចសហការយ៉ាងល្អជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា រាល់ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត និងសៀមរាបសង្ក្រាន្តជាច្រើនឆ្នាំកន្លងមក។ **ឯកឧត្តម សុខ សង្វារ** បានលើកឡើងថា សម្រាប់ឆ្នាំនេះដែរ អាជ្ញាធរជាតិអប្សរាក៏នឹងបន្តសហការយ៉ាងល្អ ហើយត្រៀមខ្លួនជាស្រេចក្នុងការរៀបចំសៀមរាបសង្ក្រាន្តជាថ្មីម្តងទៀត។

ជាក់ស្តែងឆ្នាំនេះ ឯកឧត្តមបានឱ្យដឹងថា ដើម្បីចូលរួមអបអរព្រឹត្តិការណ៍សៀមរាបសង្ក្រាន្ត អាជ្ញាធរជាតិអប្សរាមានគម្រោងមួយគឺ អង្គរ អតីត បច្ចុប្បន្ន និងអនាគត។ ចំពោះគម្រោងទាំងនេះ នឹងបង្ហាញអំពីវប្បធម៌ប្រពៃណីខ្មែរ បច្ចេកទេសជួសជុលអភិរក្សប្រាង្គប្រាសាទ សកម្មភាពសាងសង់ប្រាសាទ ការព្យាបាលថ្ម កំណាយបុរាណវិទ្យា សិប្បកម្ម ដែលភ្ញៀវទេសចរអាចចូលរួមធ្វើសកម្មភាពជាមួយអ្នកជំនាញ និងបង្ហាញអំពីសមិទ្ធផលទេសចរណ៍ជាច្រើនសម្រាប់ទស្សនាកម្សាន្ត ហើយបានយល់ដឹងនូវចំណេះដឹងជាប្រយោជន៍សម្រាប់អភិវឌ្ឍខ្លួន និងប្រទេសជាតិបានទៀតផង៕


/២០

សេចក្តីជូនដំណឹង

ស្តីពី

ការចូលទស្សនាសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ
សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី អិម ជី ស៊ី និងសារមន្ទីរកុលាលភាជន៍អង្គរនៅភូមិតានី
ដោយឥតគិតថ្លៃ

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី

អាជ្ញាធរជាតិអប្សរាប្រកាសឱ្យភ្ញៀវជាតិ-អន្តរជាតិចូលទស្សនាសារមន្ទីរចំនួនបី ដោយឥតគិតថ្លៃពេញមួយឆ្នាំ

ផ្សាយនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២០

ដើម្បីចូលរួមអបអរសាទរខួប២៥ឆ្នាំ នៃការបង្កើតអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងបើកសារមន្ទីរចំនួនបី គឺសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី សារមន្ទីរឡតានី ដោយឥតគិតថ្លៃឱ្យភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលទស្សនាដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី៩ ខែមីនា ដល់បំណាច់ឆ្នាំ២០២០។

ទាក់ទងនឹងការបើកសារមន្ទីរទាំងបីឱ្យភ្ញៀវចូលទស្សនាដោយសេរីនេះ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ទី១ គឺដើម្បីចូលរួមលើកកម្ពស់វិស័យទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រនៅក្នុងខេត្តសៀមរាប។ ទី២ បង្កើនចំណេះដឹងតាមរយៈការស្វែងយល់ពីវប្បធម៌ប្រវត្តិសាស្ត្រខ្មែរឱ្យបានទូលំទូលាយដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ពិសេសសិស្សនិស្សិត នៅតាមគ្រឹះស្ថានសិក្សាអប់រំនានា និងទី៣ គឺបង្កើនមោទនភាពជាតិអំពីប្រវត្តិសាស្ត្រ អតីតកាលរបស់ខ្លួនកាន់តែខ្លាំងដល់យុវជនជំនាន់ក្រោយ។

ចំពោះសមុច្ច័យសំខាន់ៗ ដែលបានតាំងបង្ហាញនៅក្នុងសារមន្ទីរនីមួយៗ លោក ឡុង កុសល បញ្ជាក់ថា នៅសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី គឺបានសហការជាមួយ ឥណ្ឌា តាំងបង្ហាញនូវផលិតផលប្រពៃណី មានសម្លៀកបំពាក់ធ្វើពីសូត្រនៅតាមបណ្តាប្រទេសទាំង៦ នៅជុំវិញដងទន្លេមេគង្គដូចជា ថៃ ឡាវ ភូមា កម្ពុជា វៀតណាម និងឥណ្ឌា។ រីឯសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ជាសារមន្ទីរតាំងបង្ហាញនូវបដិមា ដែលកំណាយបានពីប្រាសាទបន្ទាយក្តី បដិមានៅសម័យអង្គរ ពិសេសសមុច្ច័យដែលបានពីកំណាយនៅបារាយណ៍ខាងលិច គោកប៉ាទ្រី និងកន្លែងផ្សេងៗទាក់ទងនឹងការរស់នៅរបស់មនុស្សសម័យបុរាណ ការកប់សព សម្ភារប្រើប្រាស់ផ្សេងៗ ដែលបង្ហាញពីប្រវត្តិសាស្ត្រខ្មែរដ៏ឧត្តុងឧត្តម។ ទី៣ សារមន្ទីរឡតានី ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី គឺជាកន្លែងផលិតកុលាលភាជន៍ ត្រូវបានរកឃើញដោយអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរានាទស្សវត្សរ៍ឆ្នាំ១ ៩ ៩ ០ ។ សារមន្ទីរនេះ បានផ្តល់នូវព័ត៌មានដ៏សំខាន់ពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្មែរបុរាណតាមរយៈការប្រើប្រាស់ភាជន៍ ការរស់នៅប្រចាំថ្ងៃរបស់បុព្វបុរស និងដឹងថាពួកគាត់បានផ្តល់តម្លៃអ្វីខ្លះក្នុងទិដ្ឋិភាពសង្គមនាពេលនោះ។ ទាំងនេះជាការណ៍សំខាន់ណាស់ ដើម្បីឱ្យសាធារណជនបានសិក្សាស្រាវជ្រាវ បណ្តុះស្មារតីស្រឡាញ់ និងចូលរួមថែរក្សាសម្បត្តិវប្បធម៌ជាតិទាំងអស់គ្នា។

ក្នុងនាមជាអ្នកនាំពាក្យ លោក ឡុង កុសល ក៏បានអំពាវនាវដល់សាធារណជន សិស្ស និស្សិត ភ្ញៀវទេសចរជាតិ-អន្តរជាតិ ពិសេសបណ្តាគ្រឹះស្ថានសិក្សាអប់រំនានា សូមអញ្ជើញដឹកនាំសិស្សានុសិស្សមកចូលរួមទស្សនាឱ្យបានច្រើនកុះករ ហើយការមកទស្សនា ស្វែងយល់ផ្ទាល់ជាផ្នែកមួយនៃការអប់រំដ៏សំខាន់ ដែលសិស្សានុសិស្សអាចនឹងទទួលបានចំណេះដឹងថ្មីដែលមិនធ្លាប់ដឹងកន្លងមក៕

អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងស្ដីពីការកាត់បន្ថយថវិកាឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៦ ខែមិនា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដោយមានការចូលរួមពីអគ្គនាយករង ប្រធាននាយកដ្ឋាន មន្ត្រី-បុគ្គលិកពាក់ព័ន្ធនៅតាមនាយកដ្ឋាននីមួយៗ ក្រោមចំណុះនៃអាជ្ញាធរជាតិអប្សរា ដើម្បីប្រជុំពិភាក្សាស្ដីពីការកាត់បន្ថយការចំណាយនៅតាមផ្នែករបស់ខ្លួនរៀងៗខ្លួន។

ស្របទៅតាមអនុសាសន៍របស់ **សម្ដេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសនៅថ្ងៃទី០៤ មិនា ឆ្នាំ២០២០ ដែលស្នើឲ្យគ្រប់ក្រសួងស្ថាប័នរដ្ឋទាំងអស់ត្រូវកាត់បន្ថយការចំណាយ ៥០ភាគរយ លើកលែងតែក្រសួងចំនួន៣ត្រូវកាត់បន្ថយ ២៥ភាគរយនៃថវិកាប្រចាំឆ្នាំ២០២០ ដើម្បីជួយសេដ្ឋកិច្ចកម្ពុជា ដែលរងផលប៉ះពាល់ដោយសារជំងឺឆ្លងកូវីដ-19៕

សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ ០៧២១១/២០ សប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា៖ ដើម្បីថែរក្សាសុខសុវត្ថិភាពជូនដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ស្ពានបណ្តែតទឹកដើម្បីទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរា នឹងធ្វើការថែទាំស្ពានបណ្តែតទឹកនៅពេលយប់ សម្រាប់រយៈពេល០៤ថ្ងៃ គិតចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ចាប់ពីម៉ោង ៦៖០០នាទី ល្ងាច រហូតដល់ម៉ោង១២៖០០នាទីយប់ ដែលមានសកម្មភាពដូចខាងក្រោម៖

១. បិទក្រដាសគ្រើមលើកាំជណ្តើរចុះទៅស្ពានបណ្តែតទឹកនៅផ្នែកខាងកើតនិងខាងលិច
២. បោសសម្អាតលើស្ពានបណ្តែតទឹកក្រោមក្តារស្ពានឈើ និងលើតួស្ពានទាំងមូល
៣. រិតខ្ចៅពោងបណ្តែតទឹកលើតួស្ពានទាំងមូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ...ចន្ទ ១ រោច.......ខែ.ផល្គុន.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី...០៩...ខែមីនា ឆ្នាំ២០២០

ភ្នំពេញ
អគារលេខ៤៤ ផ្លូវលេខ១១៤ សង្កាត់ចិនតឹង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ...

អង្គភាពផ្សព្វផ្សាយ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប
ភូមិក្រវ៉ាន់ ឃុំគោកចក ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ ...

ភ្ញៀវទេសចរបន្តដំណើរទស្សនានៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

ដំណើរទេសចរណ៍របស់ភ្ញៀវទេសចរនៅតែមានជាប្រក្រតីក្នុងរមណីយដ្ឋានអង្គរ។ យើងឃើញថា ភ្ញៀវទេសចរទាំងនោះហាក់មានការយល់ដឹង ការថែទាំសុខភាព និងមិនមានការភ័យខ្លាចក្នុងដំណើរកម្សាន្តដ៏អស្ចារ្យមកកាន់តំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាខេត្តសៀមរាបឡើយ។

ខាងក្រោមនេះ ជាទិដ្ឋភាពជុំវិញភ្ញៀវទេសចរដែលចូលមកកម្សាន្តនៅរមណីយដ្ឋានអង្គរនៅព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ដូចតទៅ៖

អ្នកជំនាញការអាជ្ញាធរជាតិអប្សរាអនុវត្តគម្រោងអភិរក្សប្រាសាទទន្លេស្ងួតដំណាក់កាលទី២

ផ្សាយនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

បន្ទាប់ពីបញ្ចប់គម្រោងអភិរក្សដំណាក់កាលទី១ នៅខែកក្កដា ឆ្នាំ២០១៩ លើកម្មវិធីសិក្សាស្រាវជ្រាវឯកសារ ចុះបញ្ជីថ្មរាយប៉ាយ រកថ្មនិងរៀបផ្គុំសាកល្បង ធ្វើសម្រង់ប្លង់និងការរុះរើថ្ម (តួប្រាសាទទាំងស្រុងចាប់ពីដំបូលរហូតដល់គ្រឹះ) រួចរាល់កាលពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៩ ពេលនេះក្រុមការងារកំពុងបន្តគម្រោងដំណាក់កាលទី២ (ឆ្នាំ២០២០) ដោយចាប់ផ្តើមជួសជុលពង្រឹងគ្រឹះ រៀបផ្គុំថ្មខឿន និងតួប្រាសាទវិញរហូតដល់ស្រទាប់ទី១៥ (ត្រឹមផ្ដឹមទ្វារ) ហើយគម្រោងដំណាក់កាលទី៣ គ្រោងនឹងបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ២០២១។

លោក ជា សារិទ្ធិ បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការនិងជាប្រធានគម្រោងជួសជុលប្រាសាទទន្លេស្ងួតបានឱ្យដឹងថាចំពោះហានិភ័យដែលនាំឱ្យប្រាសាទនេះប្រឈមនឹងការរលំបាក់នោះ គឺដោយសារកត្តាទឹក ដើមឈើ និងអាយុកាលសំណង់ ជាពិសេសគ្រឹះប្រាសាទចុះខ្សោយ ហើយតួប្រាសាទទ្រេតខ្លាំងទៅជ្រុងខាងលិច (លើសពី១៥ដឺក្រេ) ថ្មរចនាសម្ពន្ធជញ្ជាំង និងដំបូលស្ទើរតែទាំងអស់បានរំកិលចេញពីស្ថានភាពដើម (ប្រហោងចន្លោះពី៥ស.ម.ទៅ៤៥ស.ម. ចំណែកថ្មជញ្ជាំង និងដំបូលមួយភាគធំត្រង់ជ្រុងអាគ្នេយ៍ និងពាយ័ព្យរលុះធ្លាក់ដល់ដី។

បន្ទាប់ពីសិក្សាវាយតម្លៃផ្នែកស្ថាបត្យកម្ម តម្រូវឱ្យក្រុមការងារសម្រេចអនុវត្តការជួសជុលជាបន្ទាន់ ដោយមានការឯកភាពពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងអនុសាសន៍ពីអ្នកជំនាញការ Ad hoc របស់អង្គការយូណេស្កូ (UN-ESCO) ដែលអនុញ្ញាតឱ្យរុះរើ និងរៀបផ្គុំឡើងវិញចាប់ពីដំបូលរហូតដល់គ្រឹះប្រាសាទ ហៅថា Anastylosis។

លោក សារិទ្ធ បន្តថា ដើម្បីសង្គ្រោះប្រាសាទឱ្យមានលំនឹងស្មើឡើងវិញ យើងត្រូវជួសជុលពង្រឹងគ្រឹះ ខឿន និងតួប្រាសាទឡើងវិញដោយគោរពទៅតាមលក្ខណៈបច្ចេកទេសនិងសម្ភារបុរាណ។ ដូច្នេះទើបក្រុមការងារមិនបានរើផ្នែកគ្រឹះទាំងស្រុងទេ ដោយរើថ្មជាផ្នែកៗ សម្អាតកំណកដី រួចផ្លាស់ប្តូរចេញនូវថ្មពុកផុយ និងទំហំតូចស្តើង ហើយដាក់ជំនួសវិញនូវថ្មថ្មីដែលមានទំហំធំនិងគុណភាពល្អ។ ទន្ទឹមគ្នានេះ ក្រុមការងារបានរៀបផ្គុំសាកល្បងនូវថ្មស្រទាប់ក្រោមបង្អស់ ដោយប្រើនូវស្នៀតឈើសម្រាប់កល់ឬលើកកម្ពស់ថ្មឱ្យត្រូវគ្នាទៅតាមលំនាំដើមវិញ ហេតុនេះហើយទើបក្រុមការងារមិនអាចរើថ្មអស់ទាំងស្រុង គឺដើម្បីរក្សានូវកម្រិតកម្ពស់ដើមនិងទីតាំងដើមរបស់ថ្មនីមួយៗ។ បន្ទាប់ពីរៀបផ្គុំស្រទាប់ទី១រហូតដល់ស្រទាប់ទី៣ និងស្រទាប់បន្តបន្ទាប់ត្រូវតាមលំនាំដើមរួចរាល់ ក្រុមការងារត្រូវរុះរើថ្មរហូតដល់ស្រទាប់ទី១ចេញវិញ ហើយត្រូវប្តូរថ្មគ្រឹះបាយក្រៀមពុកផុយនិងទំហំតូចស្តើងចេញហើយដាក់ថ្មថ្មីដែលមានទំហំធំជាងមុន តាមអនុសាសន៍របស់អ្នកជំនាញការ Ad hoc នៃអង្គការយូណេស្កូ។

ចំពោះកំណាយសិក្សាគ្រឹះប្រាសាទ និងស្រាវជ្រាវ លោកបណ្ឌិត ជា សុជាតិ បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា ការធ្វើកំណាយនេះគឺមានប្រយោជន៍ដើម្បីសិក្សាអំពីការរៀបចំគ្រឹះប្រាសាទ មូលហេតុដែលនាំឱ្យប្រាសាទស្រុត និងរបៀបនៃការសាងសង់ប្រាសាទ។ ជាលទ្ធផលបានបង្ហាញថា ប្រាសាទទន្លេស្ងួតមិនបានសង់នៅលើដីធម្មជាតិនោះទេ។ ផ្ទុយទៅវិញ គេបានលើកដីមកពូនឱ្យខ្ពស់ដល់កម្ពស់ដែលគេចង់បាន បន្ទាប់មក គេបានកាប់ដីទួលនោះជារណ្តៅដែលមានប្រវែងបណ្តោយនិងទទឹងវែងជាងតួប្រាសាទ និងកម្រាលព័ទ្ធជុំវិញពីខាងក្រៅប្រាង្គប្រមាណជា១,៥០ម៉ែត្រ។ នៅក្នុងរណ្តៅគ្រឹះនេះ គេបានបំពេញស្រទាប់ដីខ្សាច់ដែលបង្ហាប់ឆ្លាស់គ្នាជាមួយស្រទាប់ដីឥដ្ឋលាយខ្សាច់និងស្រទាប់ដីឥដ្ឋលាយថ្មភ្នំ។ ដូច្នេះ មូលហេតុសំខាន់ដែលនាំឱ្យប្រាសាទស្រុតគឺបណ្តាលមកពីការលួយនៃឫសឈើដែលងាប់ក្នុងស្រទាប់ដីបង្ហាប់ធ្វើគ្រឹះនេះ។

លោកសុជាតិបន្តថាកំណាយក៏បានរកឃើញសំណល់គ្រឹះនៃកំពែងថ្មបាយក្រៀមរបស់មន្ទីរពេទ្យដែលជាទូទៅមានបណ្តោយប្រមាណជា៣១ម៉ែត្រនិងទទឹងជាង២០ម៉ែត្រ។ ផ្នែកនៃជញ្ជាំងត្រូវបានបាត់បង់ទាំងស្រុង។ វាប្រហែលជាត្រូវបានគេរុះរើនៅពេលគេឈប់ប្រើប្រាស់មន្ទីរពេទ្យនេះ។ លក្ខណៈបែបនេះក៏ធ្លាប់ជួប និងរកឃើញផងដែរនៅប្រាសាទត្រម៉ូង (មន្ទីរពេទ្យ) នៅខាងលិចខ្លោងទ្វារតាការ។ នៅក្នុងរណ្តៅកំណាយនេះ ក៏រកឃើញបំណែកក្បឿងនៅរាយប៉ាយ ដែលស្លាកស្នាមនេះគឺជាភស្តុតាងនៃការរុះរើសំណង់ស្រាលនៅក្នុងមន្ទីរពេទ្យក្រោយពេលគេឈប់ប្រើប្រាស់វា។ ក្រៅពីនោះ ក៏បានប្រទះឃើញបំណែកកុលាលភាជន៍តិចតួច រួមជាមួយបំណែកថ្មភក់ តែមិនបានប្រទះឃើញមានសំណល់សំបកថ្នាំទំនើបដូចសព្វថ្ងៃឡើយ ដោយសារតែវិជ្ជាពេទ្យសម័យបុរាណប្រើប្រាស់ថ្នាំជារុក្ខជាតិ វល្លិ៍ ឫស សំបក ស្លឹកឈើ ក្នុងការព្យាបាលរោគ៕

ផ្លូវចំណុចមុខប្រាសាទបន្ទាយក្ដី ឆ្ពោះទៅស្រះស្រង់មុខបន្ទាយក្ដី ប្រវែង ១៤០០ ម៉ែត្រ អាជ្ញាធរជាតិអប្សរាស្ដាបនាកែលម្អបាន៨០%

ផ្សាយនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២០

មកដល់ពេលនេះ ក្រុមការងារជួសជុលកែលម្អផ្លូវថ្នល់នៃអាជ្ញាធរជាតិអប្សរា កំពុងយកចិត្តទុកដាក់លើដំណើរការជួសជុលកែលម្អផ្លូវវង់ធំ នៅចំណុចមុខប្រាសាទបន្ទាយក្ដី ឆ្ពោះទៅស្រះស្រង់ដែលមានប្រវែង ១៤០០ ម៉ែត្រ និងទទឹង ៦ទៅ៩ម៉ែត្រ បានចំនួន៨០ភាគរយហើយ ដែលបច្ចុប្បន្នក្រុមការងារបាននិងកំពុងក្រាលថ្ម បុកបង្ហាប់គ្រឹះទៅតាមបច្ចេកទេស និងធ្វើស្នាផ្លូវចុះទៅស្រះស្រង់ដើម្បីការពារទឹកហូរច្រោះពេលមានភ្លៀងធ្លាក់ និងលើកសោភណ្ឌភាពមាត់កសិន្ធុស្រះស្រង់ឱ្យកាន់តែល្អប្រសើរ ហើយត្រៀមនឹងក្រាលកៅស៊ូនាពេលខាងមុខឆាប់នេះ៕

អាជ្ញាធរជាតិអប្សរាកំពុងមមាញឹករៀបចំសណ្តាប់ធ្នាប់សាធារណៈ នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាកំពុងមមាញឹករៀបចំកែលម្អប្រព័ន្ធរំដោះទឹកភ្លៀង ទេសភាពបៃតង សណ្តាប់ធ្នាប់សាធារណៈ មុខបរិវេណប្រាសាទអង្គរវត្ត ដែលកិច្ចការទាំងនេះផ្តោតទៅលើការបញ្ចៀសការដក់ទឹកក្នុងរដូវវស្សា ការពង្រីកវាលស្មៅបៃតង ការដាំកូនឈើប្រណិត ការរៀបចំ អ្នកលក់ដូរចល័ត ការរៀបចំឲ្យចូលទៅចតក្នុងទីតាំងចំណត និង បញ្ឈប់ការចតឬឈប់រថយន្តឬរ៉ឺម៉កកង់បីក្រៅទីតាំងចំណត។

កិច្ចការខាងលើត្រូវបានអនុវត្តចាប់ពីចុងខែកុម្ភៈ មកដើម្បីជាដំណាក់កាលៗ និងគ្រោងបញ្ចប់ជាស្ថាពរមុនដំណាច់ឆ្នាំ២០២០។ ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរាក៏សូមថ្លែងអំណរគុណដល់អាជីវករ អ្នកបើកបររថយន្ត រ៉ឺម៉កកង់បី មគ្គុទ្ទេសក៏ទេសចរណ៍ ភ្ញៀវទេសចរ រួមនិងសាធារណជនទាំងអស់ ដែលសហការចូលរួមក្នុងកិច្ចការរៀបចំសណ្តាប់ធ្នាប់នេះ ដើម្បីធ្វើយ៉ាងណាឱ្យតំបន់រមណីយដ្ឋានអង្គរមានរបៀបរៀបរយ ស័ក្តិសមជាគោលដៅទេសចរណ៍សម្រាប់ពិភពលោក៕

មន្ត្រី-បុគ្គលិកចំនួន២២រូបនៃអាជ្ញាធរជាតិអប្សរា បញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលអប់រំបេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២០

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នាថ្ងៃទី១១ ខែមិនា ឆ្នាំ២០២០ បានរៀបចំពិធីបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល អប់រំបេតិកភណ្ឌដល់សិក្ខាកាមចំនួន២២នាក់ មកពីនាយកដ្ឋានជំនាញចំនួន៨ រួមមានមាន៖ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គ រដ្ឋបាលនិងបុគ្គលិក អភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ អភិវឌ្ឍន៍កសិកម្មនិងសហគមន៍ អភិរក្សប្រាសាទក្រៅឧទ្យានអង្គរ គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ផ្សព្វផ្សាយ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ក្រោមអធិបតីភាព **ឯកឧត្តម តឹម សុផិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា។

លោក អ៊ឹម សុខរិទ្ធី ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ បានឱ្យដឹងថាវគ្គបណ្តុះបណ្តាលនេះបានរៀបចំឡើងជា២វគ្គ ទី១៖ ចាប់ពីថ្ងៃទី១៧-២១ ខែកុម្ភៈ ឆ្នាំ២០២០ សម្រាប់បណ្តុះបណ្តាលសិស្សបឋមសិក្សា ថ្នាក់ទី៥-៦។ វគ្គទី២៖ ចាប់ពីថ្ងៃទី០២-០៦ ខែមីនា ឆ្នាំ២០២០ សម្រាប់បណ្តុះបណ្តាលយុវជនឬសិស្សវិទ្យាល័យ ថ្នាក់ទី ៧-៨-១០-១១។

លោកបន្តទៀតថា វគ្គបណ្តុះបណ្តាលនេះបានលើកយកប្រធានបទសំខាន់ៗដែលមាននៅក្នុងកម្មវិធីអប់រំបេតិកភណ្ឌកន្លងមកយកមកបង្រៀន សម្រាប់ឱ្យគ្រូបង្គោលថ្មីយកទៅអនុវត្តតាមសាលាគោលដៅ។ គោលបំណង និងទិសដៅនៃការបណ្តុះបណ្តាលគ្រូបង្គោល នៃកម្មវិធីអប់រំបេតិកភណ្ឌ គឺដើម្បីចូលរួមអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអប់រំបេតិតកភណ្ឌឱ្យបានច្រើនលើផ្នែកប្រវត្តិសាស្ត្រ អារ្យធម៌អង្គរ បុរាណវិទ្យា ការសិក្សាលើកុលាភាជន៍ ការប្រើប្រាស់ដីធ្លីក្នុងតំបន់បេតិកភណ្ឌអង្គរ ការគ្រប់គ្រងបរិស្ថាន ការងារអភិរក្សនិងជួសជុលសំណង់ប្រាសាទបុរាណ មរតកអរូបី និងប្រពៃណីរបស់អ្នកអង្គរដល់អ្នកជំនាន់ក្រោយបានចេះដឹង ដើម្បីបណ្តុះចិត្តស្រឡាញ់ ចូលរួមការពារសម្បត្តិដូនតាទាំងអស់គ្នា។

មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តម តឹម សុផិន** រំពឹងទុកថា គ្រូបង្គោលនៃកម្មវិធីអប់រំបេតិកភណ្ឌ នឹងទទួលបានចំណេះដឹងកាន់តែល្អប្រសើរពីវគ្គបណ្តុះបណ្តាល ដែលបង្រៀនដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញអប់រំបេតិកភណ្ឌដែលមានបទពិសោធន៍ច្រើនឆ្នាំលើការងារអប់រំបេតិកភណ្ឌ។ ពិសេស យកចំណេះជំនាញទៅផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់យុវសិស្សឱ្យបានយល់ពីតម្លៃ និងកិច្ចការអភិរក្សបេតិកភណ្ឌតំបន់រមណីយដ្ឋានអង្គរ រួមទាំងតួនាទីរបស់ខ្លួនក្នុងកិច្ចការពារសម្បត្តិដូនតាឱ្យបានប្រសើរឡើង។

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ ក្រុមមន្ត្រី-បុគ្គលិកអប់រំបេតិកភណ្ឌចាស់និងថ្មី នឹងរៀបចំផែនការអនុវត្តដើម្បីសម្រេចបានបេសកកម្មនៃអាជ្ញាធរជាតិអប្សរា ក្នុងវិស័យអប់រំបេតិកភណ្ឌដល់អ្នកជំនាន់ក្រោយកាន់តែទូលំទូលាយ។

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ ទាំងក្នុងនិងក្រៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១២ ខែមិនា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការីជំនាញ បានចុះពិនិត្យកិច្ចការអភិរក្ស និងការអភិវឌ្ឍនៅក្នុង និងក្រៅបរិវេណប្រាសាទអង្គរវត្ត។

ដំណើរចុះពិនិត្យនេះ ឯកឧត្តមនិងក្រុមអ្នកជំនាញបានអញ្ជើញទៅការដ្ឋានកំណាយស្រះខាងជើង ដើម្បីតាមដានការវិវឌ្ឍនៃការកាយកំណកដី ការរៀបចំហេដ្ឋារចនាសម្ពន្ធស្រះ និងផ្តល់អនុសាសន៍កែលម្អចំណុចខ្វះខាតផងដែរ។ បន្ទាប់ពីនោះ ក៏បានចុះពិនិត្យមើលប្រព័ន្ធបង្ហូរទឹក និងសម្ភារ (ទុយយោ) សម្រាប់ដាក់ពង្រាយតាមប្រឡាយតូចៗដើម្បីស្រោចស្រពស្មៅក្នុងបរិវេណអង្គរវត្ត។

ជាចុងក្រោយ ឯកឧត្តមក៏បានដឹកនាំក្រុមការងារចុះពិនិត្យកិច្ចការអភិវឌ្ឍន៍នៅខាងលិច នៃប្រាសាទអង្គរវត្តទាក់ទងនឹងការរៀបចំសណ្តាប់ធ្នាប់ជាប់ប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌ មជ្ឈមណ្ឌលបដិសណ្ឋារកិច្ច ការកាត់ក្រីមែកឈើ ការរៀបចំសួនស្មៅ ដើមឈើ និងពិនិត្យការដាក់លូនៅក្នុងប្រព័ន្ធរំដោះទឹកភ្លៀងថែមទៀត។

ឯកឧត្តម ហង់ ពៅ បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នកជំនាញគ្រប់ការដ្ឋាន ដែលបានបំពេញការងារបានល្អប្រសើរ និងសម្រេចផលគួរមោទនភាពក្នុងការរៀបចំបរិស្ថាន សណ្តាប់ធ្នាប់ និងផ្នែកបុរាណវិទ្យាដើម្បីលើកតម្លៃនៃរមណីយដ្ឋានអង្គរ៕



អាជ្ញាធរជាតិអប្សរាចូលរួមអបអរសាទរដែលកម្ពុជាត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍បេតិកភណ្ឌអន្តរជាតិល្អបំផុត

ផ្សាយនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សូមសម្តែងនូវការអបអរសាទរជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងទេសចរណ៍ក្នុងឱកាសដែល កម្ពុជាត្រូវបានចាត់ទុកជាគោលដៅទេសចរណ៍បេតិកភណ្ឌអន្តរជាតិល្អបំផុត (Best Destination-Heritage International) ដែលផ្តល់ដោយសមាគមអ្នកសរសេរអំពីការធ្វើដំណើរក្នុងតំបន់ប៉ាស៊ីហ្វិក (Pacific Area Travel Writers Association-PATWA)។

ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរាប្តេជ្ញាបន្តអនុវត្តនូវភារកិច្ចរបស់ខ្លួនក្នុងការលើកតម្លៃលេចធ្លោជាសកលរបស់រមណីយដ្ឋានអង្គរ និងរក្សាភាពទាក់ទាញជាពិសេសរបស់តំបន់សៀមរាបអង្គរដើម្បីកំណើនវិស័យទេសចរណ៍ និងសេដ្ឋកិច្ចជាតិ៕

វត្ថុសិល្បៈ៤០ប្រភេទត្រូវបានប្រគល់ជូនវត្តរាជបូព៌វិញបន្ទាប់ពីជួសជុលរួចរាល់

ផ្សាយនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០

ក្រុមអភិរក្ស និងជួសជុលវត្ថុសិល្បៈ (I.T.A.L.I.A) នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នៃអាជ្ញាធរជាតិអប្សរា បានប្រគល់វត្ថុសិល្បៈចំនួន៤០ប្រភេទ ដែលក្នុងនោះមានលោហៈចំនួន៣៦ និងកុលាលភាជន៍ចំនួន៤ ពីមន្ទីរពិសោធន៍នៃក្រុមអភិរក្ស និងជួសជុលវត្ថុសិល្បៈ (I.T.A.L.I.A) នៅក្នុងអភិរក្សដ្ឋានអង្គរ ជូនទៅវត្តរាជបូព៌វិញ។

ការប្រគល់ជូនខាងលើនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារនៃអាជ្ញាធរជាតិអប្សរា បានចំណាយពេលវេលាយ៉ាងយកចិត្តទុកដាក់ ក្នុងការសម្អាត និងជួសជុលវត្ថុសិល្បៈទាំងនោះឡើងវិញនាពេលកន្លងមក។ ពិធីប្រគល់នេះធ្វើឡើងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ដោយមានតំណាងពីមន្ត្រីនៃអាជ្ញាធរជាតិអប្សរា និងមានការទទួលដោយផ្ទាល់ពី **ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ** ព្រះរាជាគណៈថ្នាក់ទោ សមាជិកថេរសភាសង្ឃ និងជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជាព្រះចៅអធិការវត្តរាជបូព៌៕

ឆ្នាំ២០១៩ អាជ្ញាធរជាតិអប្សរាផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន និងសាងសង់សំណង់ស្រាលតូចតាចដល់អ្នកស្រុកអង្គរចំនួន១៧៩៩គ្រួសារ

ផ្សាយនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០

យោងតាមរបាយការណ៍នៅក្នុងឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋានសហគមន៍ទាំង៥ ក្រុមនៃអាជ្ញាធរជាតិអប្សរាបានបន្តការងារចុះពិនិត្យចំនួន២៨៦៧ គ្រួសារ ក្នុងនោះក្រុមការងារបានអនុញ្ញាតឱ្យមានការជួសជុលកែលម្អលំនៅដ្ឋាននិងសាងសង់សំណង់ស្រាលតូចតាចបានចំនួន១៧៩៩គ្រួសារ ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ។

ក្នុងចំណោមអ្នកស្រុក១៧៩៩ គ្រួសារ ដែលទទួលបានការអនុញ្ញាតរួមមាន៖ ស្រុកប្រាសាទបាគងចំនួន២៥៩ គ្រួសារ ស្រុកអង្គរធំ ចំនួន២០២គ្រួសារ ស្រុកពួកចំនួន៤៣៦ករណី ក្រុងសៀមរាបចំនួន៦៦០គ្រួសារ និងស្រុកបន្ទាយស្រីចំនួន២៤២គ្រួសារផងដែរ។

ប្រភេទនៃការជួសជុលកែលម្អលំនៅដ្ឋាន និងសាង់សង់សំណង់ស្រាលតូចតាច ដែលទទួលបានការអនុញ្ញាតរួមមានជួសជុលឬប្តូរដំបូល ជួសជុលជញ្ជាំង ប្តូរសសរ ប្តូរជណ្តើរ តសំយ៉ាប កតដ្ឋក្រោមផ្ទះ សាងសង់បង្គន់អនាម័យ ទ្រុងមាន់ ចាក់ដី ក្រោលគោ ទ្រុងជ្រូក ។ល។ និងតម្រូវការផ្សេងៗទៀតដែលចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ។

ការអនុញ្ញាតនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារសហគមន៍បានចុះពិនិត្យទៅដល់ខ្នងផ្ទះដាក់ស្តែងនិងឯកសារចាំបាច់ពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាមូលដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃថាពួកគាត់គឺជាប្រជាពលរដ្ឋរស់នៅក្នុងតំបន់អង្គរពិតប្រាកដតាំងពីយូរយារ មានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-សង្កាត់ និងមានតម្រូវការដាក់ស្តែងក្នុងការកែលម្អការរស់នៅឱ្យបានល្អប្រសើរ។

អាជ្ញាធរជាតិអប្សរាមិនត្រឹមតែផ្តល់ការជួសជុលដល់ផ្ទះចាស់ និងសាងសង់សំណង់ស្រាលតូចតាច ក្នុងនោះក៏បានដោះស្រាយបញ្ហាប្រឈមនានា ការជួយសង្គ្រោះពេលប្រជាជនមានទុក្ខលំបាក រួមទាំងផ្សព្វផ្សាយការយល់ដឹងអំពីបេតិកភណ្ឌ ដល់ប្រជាជនគ្រប់ៗគ្នា។ ពិសេសជាងនេះទៀតនោះ សកម្មភាពទាំងនេះគឺជាការចូលរួមចំណែករបស់អាជ្ញាធរជាតិអប្សរា ក្នុងការបង្វិតសេវាសាធារណៈរបស់រដ្ឋឱ្យចូលទៅជិតបងប្អូនប្រជាពលរដ្ឋ និងកាត់បន្ថយរាល់ការចំណាយទាំងពេលវេលា និងការធ្វើដំណើរទៅមក៕

អាជ្ញាធរជាតិអប្សរា បានបង្កើតក្រុមការងារសហគមន៍នេះឡើង គឺដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរ ដែលគ្របដណ្តប់លើផ្ទៃដី៤០១គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងក្រុង/ស្រុកចំនួន៥ ឃុំចំនួន២១ និងភូមិចំនួន១១២៕

អាជ្ញាធរជាតិអប្សរាកំពុងដំណើរការសិក្សាជួសជុលខ្លោងទ្វារតាកាវ

ផ្សាយនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

ខ្លោងទ្វារតាកាវ ជាខ្លោងទ្វារមួយក្នុងចំណោមខ្លោងទ្វារទាំង៥នៃក្រុងអង្គរធំ ដែលស្ថិតនៅទិសខាងលិចនៃប្រាសាទបាយ័ន្ត។ ដោយសារអាយុកាល អាកាសធាតុ សង្គ្រាមកង្វះការថែទាំ និងការដុះដាលនៃដើមឈើ បណ្តាលឱ្យរូបចម្លាក់បង្កាន់ដៃយក្សនិងទេវតាជាច្រើនដួលរលំ ហើយក៏បានធ្វើឱ្យរចនាសម្ពន្ធរបស់ខ្លោងទ្វារមួយភាគធំ ពិសេសរូបដំរីទាំង៤បានរងនូវការខូចខាតជាខ្លាំង ដែលតម្រូវឱ្យមានការជួសជុលដើម្បីសង្គ្រោះនិងអភិរក្ស។

កញ្ញា ម៉េង សុវណ្ណលីលីន ស្ថាបត្យករនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ហើយជាអ្នកគ្រប់គ្រងការដ្ឋានជួសជុលខ្លោងទ្វារ បានឱ្យដឹងថា បច្ចុប្បន្នមានអ្នកជំនាញស្ថាបត្យកម្ម ក្រុមសម្រង់ប្លង់ ក្រុមរកនិងផ្គុំថ្ម និងក្រុមដំឡើងរន្ទា កំពុងអនុវត្តការងារទល់ទ្ររចនាសម្ពន្ធផ្នែកខាងក្នុងខ្លោងទ្វារ ស្វែងរកបំណែកថ្មនៃតួខ្លោងទ្វារ ដំរីអាទិទេព និងបង្កាន់ដៃ។

ចំណែកក្រុមការងារផ្នែកបុរាណវិទ្យាគ្រោងនឹងធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យាដើម្បីស្វែងរកបំណែកថ្មបន្ថែម ព្រមទាំងសិក្សាពីរចនាសម្ពន្ធគ្រឹះរបស់ខ្លោងទ្វារ និងបង្កាន់ដៃផងដែរនៅពេលរកថ្មនៅស្រទាប់ដីចាក់បង្គរខាងលើបញ្ចប់។ កិច្ចការនេះដំណើរការជួសជុលចាប់តាំងពីខែធ្នូ ឆ្នាំ២០១៩ ហើយគម្រោងនេះត្រូវការរយៈពេលប្រមាណ២ឆ្នាំ ដើម្បីអនុវត្ត។

កញ្ញាបន្តទៀតថា ខ្លោងទ្វារតាកាវរងនូវហានីភ័យខ្ពស់ត្រង់តួនៃខ្លោងទ្វារ ចំណុចដំរីអាទិទេពដោយសារទម្ងន់ពីកំពូលខ្លោងទ្វារសង្កត់ធ្លាក់មកក្រោមចំដំរីទាំង៤។ ដូចនេះការជួសជុលដំណាក់កាលទី១តម្រូវឱ្យមានការជួសជុលនិងពង្រឹងដំរីនេះ ដើម្បីទ្រទ្រង់រចនាសម្ពន្ធនៃខ្លោងទ្វារ។ ដំណាក់កាលទី២ នឹងជួសជុលតួខ្លោងទ្វារ ហើយដំណាក់កាលទី៣ សិក្សា និងពង្រឹងទួលដែលនៅជុំវិញខ្លោងទ្វារ។

កញ្ញា លីលីន បញ្ជាក់ដែរថា ៣ខែកន្លងមកនេះ ក្រុមការងារបានដំឡើងរន្ទាផ្នែកខាងក្នុងបានប្រមាណ៦០% ហើយដើម្បីជួយទ្រទ្រង់រចនាសម្ពន្ធខ្លោងទ្វារនៅពេលរើថ្មដំរីដើម្បីជួសជុល។ បន្ថែមពីនោះ ក៏បានចុះបញ្ជីថ្មរាយប៉ាយទាំង៤ទិស ចែកចេញជា៤តំបន់ទៅតាមទិសនីមួយៗ រកថ្មដំរី រកថ្មដំបូលដែលបាត់ សម្រង់ប្លង់ គូរប្លង់ និងធ្វើប្លង់ហានីភ័យនៃខ្លោងទ្វារ។ ក្នុងនោះដែរ ក្រុមការងារក៏បានសាកល្បងផ្គុំថ្មបង្កាន់ដៃយក្ស ពេលបានប្រទះឃើញបំណែកតួខ្លួននិងប្រអប់ដៃយក្សពេលរកថ្មផងដែរ។ ជាកិច្ចការងារបន្ត ក្រុមការងារក៏នឹងធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យាដើម្បីសិក្សាពីគ្រឹះតួបង្កាន់ដៃនិងបង្ហាប់គ្រឹះឡើងវិញ រួចសិក្សាលើផ្លូវដែលឆ្លងកាត់ដែលជាចំណោទនាំទឹកហូរច្រោះឱ្យរលុះដី ដើម្បីកែប្រែសណ្ឋានដីនិងបុកបង្ហាប់ដីឱ្យស្មើនឹងគ្រឹះនៃបង្កាន់ដៃយក្ស និងទេវតាសងខាងការពារការហូរច្រោះដី។

ចំពោះខ្លោងទ្វារតាកាវកន្លងមក មិនធ្លាប់ទទួលបានការជួសជុលទេ គ្រាន់តែបានទល់ទ្រដំរីអាទិទេពទាំង៤នៅឆ្នាំ២០០៧ ហើយក្រាលកម្រាលឈើដើម្បីធ្វើដំណើរឆ្លងកាត់។ លុះឆ្នាំ២០១៥ ក្រុមការងារក៏បានរុះកម្រាលឈើ ហើយចាក់ដីបំពេញដោយដីក្រហមនិងហាមមិនឱ្យរថយន្តឆ្លងកាត់ ដោយអនុញ្ញាតឱ្យតែម៉ូតូនិងរ៉ឺម៉កក៏ប៉ុណ្ណោះ៕

រហាត់ទឹកអង្គរនឹងដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅខែមេសាខាងមុខនេះ!

ផ្សាយនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

រហាត់ទឹកអង្គរដែលមានអាយុកាលតាំងពីទស្សវត្សរ៍ទី៦០ ស្ថិតក្នុងទីតាំងសួនបណ្ដុះកូនឈើប្រាសាទតាកែវ ត្រូវបានជួសជុលដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា កាលពីខែកញ្ញា ឆ្នាំ២០១៩ ក្រោមជំនួយថវិការបស់ **លោកជំទាវ ឧកញ៉ាមហាឧបាសិកា កិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍នឹងត្រូវបញ្ចប់ការជួសជុលក្នុងពេលឆាប់ៗ ហើយដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ នៅខែមេសា ឆ្នាំ២០២០ខាងមុខ។

បើទោះបីជារដូវប្រាំងក៏ស្មៅនៅមុខប្រាសាទអង្គរវត្តនៅតែមានពណ៌បៃតង

ផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២០

រដូវប្រាំងចូលមកដល់ បានធ្វើឱ្យស្មៅនិងរុក្ខជាតិមួយចំនួនក្រៀមស្វិតស្រពោននៅក្នុងតំបន់រមណីយដ្ឋានអង្គរ ប៉ុន្តែទោះជាយ៉ាងណា ក៏អាជ្ញាធរជាតិអប្សរាបានប្រឹងប្រែងថែទាំស្រោចស្រពស្មៅនៅតាមសួនកសិន្ធុប្រាសាទអង្គរវត្តឱ្យនៅតែមានពណ៌បៃតង។ ក្នុងនោះដែរ ចំពោះវាលស្មៅនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ក៏អាជ្ញាធរជាតិអប្សរា កំពុងរៀបចំប្រព័ន្ធស្រោចស្រពវាលស្មៅទាំងនោះផងដែរ។

ការសម្អាតវារីជាតិនៅក្នុងកសិន្ធុនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២០

បរិស្ថាននៅក្នុងតំបន់រមណីយដ្ឋានអង្គរ ទាំងលើគោក ក្នុងទឹក និងបរិយាកាស ត្រូវបានអាជ្ញាធរជាតិអប្សរា យកចិត្តទុកដាក់ក្នុងការសម្អាតជាប្រចាំ។ ជាក់ស្តែងនៅព្រឹកថ្ងៃទី១៧ ខែមិនា ឆ្នាំ២០២០នេះ ក្រុមការងារអាជ្ញាធរជាតិអប្សរា បានចុះសម្អាតនូវវារីជាតិ ដែលដុះក្នុងទឹកនៃកសិន្ធុប្រាសាទអង្គរវត្ត មានលំចង់ សារ៉ាយ កំប្លោកជាដើម ដើម្បីសម្អាតទឹកឱ្យស្អាត និងធ្វើឱ្យទឹកមានគុណភាពល្អ ជំនួយដល់ភាពធំធាត់ដល់សត្វរស់នៅក្នុងទឹកផង។

ការសម្អាតវារីជាតិនៅក្នុងទឹកនៅតាមកសិន្ធុនៃប្រាសាទអង្គរវត្តនិងប្រាសាទផ្សេងៗ ត្រូវបានសម្អាតជាប្រចាំ ដោយប្រើទូក និងដង្កាវដើម្បីការយករុក្ខជាតិក្នុងទឹកទាំងនោះ។

អាជ្ញាធរជាតិអប្សរាក៏សូមអំពាវនាវដល់សាធារណជន និងភ្ញៀវទេសចរទាំងអស់ សូមកុំបោះសំរាមគ្រប់ប្រភេទចូលក្នុងទឹកកសិន្ធុ ដែលជាហេតុនាំឱ្យទឹកកខ្វក់ ប៉ះពាល់ដល់សោភ័ណភាពប្រាសាទនិងជីវិតសត្វដែលអាស្រ័យក្នុងទឹកផងដែរ៕

សកម្មភាពនៃការសម្អាតបរិស្ថាននិងអនាម័យនៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២០ ក្រុមការងារអាជ្ញាធរជាតិអប្សរាបានបោសសម្អាតដី ប្រមូលសំរាមស្លឹកឈើ និងរៀបចំអនាម័យបរិស្ថាននៅប្រាសាទតាព្រហ្ម ដើម្បីលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថាន និងសុខុមាលភាពរបស់ភ្ញៀវទេសចរដែលមកកម្សាន្តនៅប្រាសាទនេះ។ ការសម្អាតនេះ តែងធ្វើជាប្រចាំ នៅគ្រប់ប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។

សូមទស្សនាកម្រងរូបភាពនៃការអនុវត្តការងារ ដើម្បីភាពស្រស់ស្អាតនៃតំបន់រមណីយដ្ឋានអង្គរ និងសូមចូលរួមថែរក្សាបរិស្ថានឱ្យបានគ្រប់ៗគ្នា!

សេចក្តីជូនដំណឹងស្តីពីការបិទជាបណ្តោះអាសន្នសារមន្ទីរទាំងបី ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ.០២៦០/អប.សជណ
២០

សេចក្តីជូនដំណឹង
ស្តីពី
ការបិទជាបណ្តោះអាសន្នសារមន្ទីរទាំងបី ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា

អនុលោមតាមសេចក្តីណែនាំក្នុងខ្លឹមសារលិខិត របស់ក្រសួងសុខាភិបាលលេខ០៤៣ សខល ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទ KTV ក្លឹបកំសាន្ត រោងភាពយន្ត និងសារមន្ទីរនៅទូទាំងប្រទេស ក្នុងគោលដៅបញ្ចៀសការប្រមូលផ្តុំគ្នា ដែលងាយប្រឈមនឹងហានិភ័យនានា អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង-ស្ថាប័នជាតិ/អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ/អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរា សូមបិទដំណើរការសារមន្ទីរទាំងបីរបស់អាជ្ញាធរជាតិអប្សរា រួមមាន សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ សារមន្ទីរឡុតានី និងសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី មិនអនុញ្ញាតឱ្យភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ ចូលទស្សនា គិតចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២០ នេះតទៅ រហូតដល់ស្ថានភាពជម្ងឺឆ្លងកូវីដ១៩ ធូរស្រាល និងរហូតដល់មានការណែនាំថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធ។

អាស្រ័យហេតុដូចមានជម្រាបជូនខាងលើ សូមក្រសួង-ស្ថាប័នជាតិ/អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ/អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១០កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២០

CS CamScanner

អាជ្ញាធរជាតិអប្សរាជួសជុលសំណង់ទ្វារទឹកទំនប់បារាំង ដើម្បីស្តុកទឹកនារដូវប្រាំងមិនឱ្យខ្វះខាតក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាកំពុងមមាញឹកបញ្ចប់គម្រោងជួសជុលសំណង់ទ្វារទឹកទំនប់បារាំងដែលស្ថិតនៅជងស្ទឹងសៀមរាបខាងជើងប្រាសាទតានៃ ឱ្យបានរួចរាល់ជាស្ថាពរមុនចូលឆ្នាំថ្មីមកដល់។

សំណង់ទ្វារទឹកទំនប់បារាំង ជាកន្លែងស្តុកទឹកដ៏សំខាន់នៅក្នុងរមណីយដ្ឋានអង្គរដើម្បីទុកទឹកប្រើប្រាស់នារដូវប្រាំងមិនឱ្យខ្វះខាត ដោយការប្រមូលប្រភពទឹកមកពីភ្នំគូលែន និងបន្តចែកចាយទៅកាន់ស្ទឹងសៀមរាប បារាយណ៍ កសិន្ទុក្នុងតំបន់អង្គរ និងប្រព័ន្ធស្រោចស្រពនៅក្រោមបារាណ៍ទាំងអស់។ ពិសេស ជារបាំងទប់ទឹក កុំឱ្យមានទឹកជំនន់លិចក្រុងសៀមរាបនារដូវវស្សាផងដែរ។

លោក គឿន សុឃីម អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងនៅព្រឹកថ្ងៃទី១៩ ខែមិនា ឆ្នាំ២០២០ថា បច្ចុប្បន្ន ប្រព័ន្ធស្តុកទឹកនេះបានរងនូវការខូចខាត ចាស់ទ្រុឌទ្រោមផ្នែកក្រោមជាខ្លាំងដោយសារអាយុកាល អាកាសធាតុ ធ្វើឱ្យវត្ថុធាតុដើមនៃសំណង់ និងគ្រឹះសំណង់បាក់ ពុកផុយ បាត់បង់គុណភាព បណ្តាលឱ្យទឹកហូរច្រោះ មិនអាចរក្សាទឹកបានច្រើននៅរដូវប្រាំង។ ដូច្នេះហើយ កាលពីថ្ងៃទី២០ ខែកុម្ភៈ ក្រុមការងារក៏បានជួសជុលគ្រឹះក្រោមជាថ្មី ដោយការចាក់បេតុងដើម្បីបង្កើនភាពរឹងមាំ និងជួសជុលទ្វារទឹក ការពារទឹកច្រោះនៅរដូវប្រាំង ដើម្បីសន្សំទឹក។ គម្រោងនេះនឹងបញ្ចប់ជាស្ថាពរនៅបំណាច់ខែមិនា ឆ្នាំ២០២០ខាងមុខនេះ។

ចំពោះប្រវត្តិនៃសំណង់វិញ អ្នកជំនាញរូបនេះ ក៏បានឱ្យដឹងថា តាមការសាកសួរពីកម្មករចំណាស់ម្នាក់ដែលឪពុកក្មេកធ្លាប់ធ្វើជាកម្មករនៅក្នុងការដ្ឋានសំណង់នេះ បានប្រាប់ថា ទ្វារទឹកទំនប់បារាំង បានកសាងឡើងក្នុងសម័យអាណានិគមបារាំង ចន្លោះឆ្នាំ១៩៣០។ ដំណាក់កាលដំបូងនេះបារាំងបានចាក់បេតុងធ្វើជាទ្វារទឹក បន្ទាប់មកក្នុងទសវត្សរ៍ទី៦០ អាមេរិកកាំងបានដាក់ទ្វារដែកសម្រាប់បិទបើកតាមកម្លាំងទឹក ដោយស្វ័យប្រវត្តិ និងសម្រាប់បង្វែរមុខទឹកបញ្ចូលទៅបារាយណ៍ខាងលិចតាមរយៈប្រឡាយទឹកដែលជីកដោយអាមេរិកកាំង (កាណាល់A)។ នៅឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរាក៏បានជួសជុលគ្រឹះដោយបេតុងថ្មីជំនួសគ្រឹះដែលសាងសង់ឡើងតាំងពីសម័យបារាំងដើម្បីលើកតម្លៃនិងពង្រឹងគុណភាពសំណង់ឱ្យប្រសើរឡើងវិញ៕

ក្រុមការងារព្រៃឈើចុះកាត់ក្រីដើមឈើដែលមានហានិភ័យនៅតាមប្រាសាទ

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ក្រុមការងារចុះកាត់ក្រីមែកឈើនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បានចុះកាត់ក្រីដើមឈើចំនួន៤ដើម ដែលស្ថិតនៅខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី។

លោក ហៃ ហ៊ិត មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ឱ្យដឹងថា ការចុះកាត់ក្រីនេះគឺដើម្បីបង្ការហានិ-ភ័យដល់ប្រាសាទ ក៏ដូចជាភ្ញៀវទេសចរពេលចូលទៅទស្សនាក្នុងប្រាសាទនេះ ពិសេសគឺដើម្បីបង្កភាពងាយស្រួលដល់ក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ដែលគ្រោងចុះសិក្សាលើកគម្រោងសម្រាប់ជួសជុលខ្លោងទ្វារនេះ។

តាមការបញ្ជាក់ពីលោក ហៃ ហ៊ិត ដើមឈើដែលត្រូវកាត់ក្រីនេះមានចំនួន៤ដើម រួមមាន ដើមពង្រ២ដើម ដើមចំបក់១ដើម និងដើមធ្លកចំនួន១ដើម៕

អាជ្ញាធរជាតិអប្សរាបើកការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់ ក្រោមជំនួយឧបត្ថម្ភរបស់លោកជំទាវឧកញ៉ា សៀង ចាន់ហេង

ផ្សាយនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២០

ប្រាសាទកណ្ដាលស្រះស្រង់បានកសាងឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ នាសតវត្សរ៍ទី១២ តំណាងឱ្យភ្នំព្រះសុមេរុ បានចាប់ផ្ដើមបើកការដ្ឋានជួសជុលហើយនៅព្រឹកមិញនេះ ដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរានិងជំនួយឧបត្ថម្ភថវិកាទាំងស្រុងពីវិស័យឯកជន។

នាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ **ឯកឧត្តមបណ្ឌិត ហាង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមនឹងសហការី បានចុះត្រួតពិនិត្យការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់ ដែលក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានរៀបចំពិធីប្រុងពលីសែនព្រេន ដើម្បីបិទទំនប់ទឹក ធ្វើកំណាយស្រាវជ្រាវរចនាសម្ពន្ធប្រាសាទមុននឹងដំណើរការជួសជុល។

ឯកឧត្តមអគ្គនាយកបានឱ្យដឹងថា ការជួសជុលប្រាសាទកណ្ដាលស្រះស្រង់ គឺអនុវត្តដោយក្រុមការងាររបស់អាជ្ញាធរជាតិអប្សរានិងការរួមចំណែករបស់វិស័យឯកជនដែលឧបត្ថម្ភថវិកាទាំងស្រុងដោយ **លោកជំទាវឧកញ៉ាមហាឧបាសិកា កិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុន ហេងអភិវឌ្ឍន៍ បន្ទាប់ពីលោកជំទាវបានជួយសាងសង់រហាត់ទឹកមួយនៅទឹកដីអង្គរផងដែរ។

ឯកឧត្តមបន្តទៀតថា គម្រោងជួសជុលប្រាសាទនេះ គឺដើម្បីអភិរក្សនិងលើកតម្លៃមរតកដូនតា។ ប្រាសាទកណ្ដាលស្រះស្រង់ គឺជាកន្លែងដែលបានចារឹកអំពីព្រះរាជសកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី៧ ពេលព្រះអង្គយាងមកកាន់ទីនេះ។ ពិសេស កំណាយស្រាវជ្រាវនេះដើម្បីស្វែង រកទម្រង់ប្រាសាទឱ្យបានច្បាស់លាស់ថាមានទម្រង់បែបណា ដើម្បីជួសជុលឱ្យបានត្រឹមត្រូវ ព្រោះទម្រង់ប្រាសាទនេះក៏មិនទាន់មានសរសេរនៅក្នុងឯកសារបរទេសណាមួយបង្ហាញថា មានលក្ខណៈបែបណានោះដែរ។

អាជ្ញាធរជាតិអប្សរាបើកការដ្ឋានកំណាយនៅប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

ដើម្បីអភិរក្ស និងលើកតម្លៃប្រាសាទលលៃឱ្យរួចផុតពីហានិភ័យ ដែលរងការខូចខាតដោយសារកត្តាអាកាសធាតុ ការបំផ្លាញដោយរុក្ខជាតិ និងអាយុកាលរបស់សំណង់នោះ នាពាក់កណ្តាលខែមីនា ឆ្នាំ២០២០ កន្លងមកនេះ ក្រុមការងារជួសជុលប្រាសាទរបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីប្រុងពលីសែនព្រេនសុំម្ចាស់ទឹកម្ចាស់ដី ដើម្បីធ្វើកំណាយស្រាវជ្រាវនៅប្រាសាទលលៃ មុននឹងជួសជុលប្រាសាទនេះឡើងវិញ។

ប្រាសាទលលៃ កសាងដោយព្រះបាទយសោវរ្ម័នទី១ នាចុងសតវត្សរ៍ទី៩ នៃគ.ស.៨៩៣ មានទីតាំងស្ថិតនៅកណ្តាលបារាយណ៍ "ឥន្ទ្រតដាក" ដើម្បីឧទ្ទិសដល់ព្រះឥសូរ ៕

ការសម្អាតប្រាង្គប្រាសាទអង្គរនៅក្នុងរដូវប្រាំង

ផ្សាយនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

ការសម្អាតប្រាង្គប្រាសាទតែងតែធ្វើឡើងជាប្រចាំ រៀងរាល់ ១ខែម្តងឬតិចជាងនេះនៅរដូវវស្សានិង១ខែកន្លះម្តងឬច្រើនជាងនេះ នៅរដូវប្រាំង។ ការសម្អាត គឺដើម្បីដកស្មៅ កូនឈើ និងរុក្ខជាតិផ្សេងៗនៅលើប្រាសាទ បង្ការកុំឱ្យវាលូតលាស់ធំមានឫសចាក់ជ្រែកចូលក្នុងរចនាសម្ពន្ធប្រាសាទ ធ្វើឱ្យមានហានីភ័យដល់ប្រាសាទ និងបាត់បង់សោភ័ណភាពប្រាសាទ។

ក្នុងការសម្អាតនេះដែរ ក្រុមពលករជំនាញនៃអាជ្ញាធរជាតិអប្សរា តែងប្រើរន្ទា ខ្សែពួរ ដើម្បីឡើងលើប្រាសាទ និងប្រើដៃ កាំបិត ពូថៅ ក្នុងការដកឬកាត់កូនឈើដែលដុះលើតួប្រាសាទ។

អាជ្ញាធរជាតិអប្សរាមមាញឹកជួសជុលជណ្តើរឈើចំនួន៤កន្លែងនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២០

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានកំពុងតែជួសជុលជណ្តើរឈើឡើងប្រាសាទអង្គរវត្ត ចំនួន៤កន្លែង។

ការជួសជុលទាំងនេះគឺដើម្បីរៀបចំសុវត្ថិភាព សម្រួលការធ្វើដំណើរទេសចរណ៍របស់ភ្ញៀវទេសចរនៅប្រាង្គប្រាសាទបុរាណខ្មែរដ៏ល្អឯកនេះ៕

អាជ្ញាធរជាតិអប្សរាប្រទះឃើញសំណង់ឈើអាយុកាលជិត១០០០ឆ្នាំ ក្នុងកំណាយស្រាវជ្រាវបុរាណវិទ្យានៅបាតស្រះខាងជើងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២០

រចនាសម្ពន្ធសំណង់ឈើដ៏ល្អឆ្នើមមួយ រួមនឹងបដិមានៃព្រហ្មញ្ញសាសនា១អង្គ ត្រូវបានប្រទះឃើញក្នុងកំណាយស្រាវជ្រាវបុរាណវិទ្យា នៅបាតស្រះខាងជើងនៃប្រាសាទអង្គរវត្ត។ ការរកឃើញនេះ ត្រូវបានបុរាណវិទូនៃអាជ្ញាធរជាតិអប្សរាអះអាងថា ជាប្រវត្តិសាស្ត្រដំបូងនៅអង្គរដែលបានរកឃើញសំណង់ឈើនិងបដិមាដូច្នេះ ហើយនេះជាអាថ៌កំបាំងដ៏អស្ចារ្យទាក់ទងនឹងការកសាងស្រះទឹក រួមទាំងស្ថាបត្យកម្មនៃសំណង់អង្គរវត្ត ជំនឿ និងការរស់នៅឥតដាច់របស់ប្រជាជនតាំងពីសតវត្សរ៍ទី១២មកដល់សព្វថ្ងៃ។

មានប្រសាសន៍នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ លោក អ៊ឹម សុខរិទ្ធី បុរាណវិទូនិងជាប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ ឱ្យដឹងថារចនាសម្ពន្ធសំណង់ឈើដែលបានប្រទះឃើញនេះស្ថិតនៅចំកណ្តាលនៃស្រះ ដែលមានអាយុកាលជិត១ពាន់ឆ្នាំហើយ តែនៅមានទ្រង់ទ្រាយល្អដូចដើម និងមានការបញ្ចុះបានយ៉ាងត្រឹមត្រូវ ដោយមានស្រទាប់ខ្សាច់ ស្រទាប់ថ្ម ស្រទាប់កំណករុក្ខជាតិនិងធញ្ញជាតិ ស្រទាប់សត្វសមុទ្រ និងបំណែកកុលាលភាជន៍ជាច្រើនសម័យកាល ដែលបានរៀបចំយ៉ាងស្អាតប្រកបដោយគំនិតសិល្បៈ លាយបញ្ចូលនឹងជំនឿ ព្រោះមានមានតម្កល់បដិមានៃព្រហ្មញ្ញសាសនា១អង្គផង។ បដិមានេះជាទេពតំណាងឱ្យចំណេះដឹង បញ្ញាញាណ និងមន្តអាគម។ ការដែលបញ្ចុះទេពលាយជាមួយដូច្នេះ គឺបង្ហាញពីការគោរពតាមជំនឿដើម្បីជាទីពឹងពាក់របស់មនុស្សនិងដើម្បីឱ្យទីនេះក្លាយជាទីទុកចិត្តក្លាយជាទឹកពិសិដ្ឋ សម្រាប់ប្រោះព្រំអ្នកផងមកសំពះព្រះពិស្ណុលោក។

លោក សុខរិទ្ធី បានបន្តថា ការរកឃើញថ្មីនេះ ជាប្រវត្តិសាស្ត្រនៃការស្រាវជ្រាវដំបូងហើយដែលបានប្រទះឃើញនូវសំណង់ឈើមានស្នាដៃល្អស្អាតនិងព្រះមួយអង្គនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ នេះក៏ជាភស្តុតាងវិទ្យាសាស្ត្រស្រាវជ្រាវបែបបុរាណវិទ្យា ដែលបានបំពេញបន្ថែមទៅលើព័ត៌មានកន្លងមក ដែលយើងពឹងផ្អែកការសិក្សាស្រាវជ្រាវលើសិលាចារឹក បដិមាសាស្ត្រ ប្រវត្តិសិល្បៈ។ល។ ដែលបង្ហាញនូវអាថ៌កំបាំងយ៉ាងធំមួយទាក់ទងនឹងប្រវត្តិនៃការកសាងស្រះទឹក សំណង់ប្រាសាទអង្គរវត្ត បរិស្ថានធម្មជាតិ និងការរស់នៅរបស់មនុស្ស ដែលបង្ហាញឱ្យដឹងថា អង្គរមិនមានការបោះបង់ចោលនោះទេ គឺមានមនុស្សមករស់នៅទីនេះមិនដាច់តាំងពីសម័យកសាងរហូតដល់សម័យទំនើប។

លោកបន្ថែមថា ដំណាក់កាលដំបូងនេះ យើងមិនទាន់កំណត់ឱ្យច្បាស់ថាសំណង់ឈើនេះមានប្រភេទឈើអ្វីខ្លះ? សំណង់មានតួនាទីអ្វីប្រាកដនោះឡើយ គឺរង់ចាំការយកបំណែកឈើទៅពិសោធន៍និងសិក្សាតាមបែបវិទ្យាសាស្ត្រជាមួយអ្នកជំនាញផ្សេងៗទៀត៕

អាជ្ញាធរជាតិអប្សរាមមាញឹករៀបចំប្រព័ន្ធទឹកស្រោចស្រពស្មៅនៅក្នុងបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២០

ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាកំពុងមមាញឹកបង្កប់ទុយោដើម្បីរៀបចំប្រព័ន្ធទឹកសម្រាប់ស្រោចស្រពស្មៅក្នុងបរិវេណប្រាសាទអង្គរវត្ត ដែលមានទំហំជិត១២ហិកតា។

លោក គឿន សុឃីម អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ដំណើរការរៀបចំប្រព័ន្ធទឹកស្រោចស្រពស្មៅក្នុងបរិវេណប្រាសាទអង្គរវត្ត ត្រូវការរយៈពេល២ខែទើបបញ្ចប់។ ឯការបង្កប់ទុយោពីមួយជួរទៅមួយជួរ គឺមានគម្លាត២០ម៉ែត្រពីគ្នា។ ប្រភពទឹកយកមកស្រោចស្មៅ គឺបានពីកសិន្ធុទឹកដែលព័ទ្ធជុំវិញប្រាសាទ នឹងស្រោចនៅពេលល្ងាចដើម្បីចំណេញទឹកនិងមិនរំខានដល់ទេសចរផង។

ក្រោយបញ្ចប់ការងារ លោកជឿជាក់ថា ស្មៅនៅក្នុងបរិវេណប្រាសាទអង្គរវត្តនឹងមានភាពបៃតងស្រស់ ទាំងរដូវប្រាំង និងរដូវវស្សា ពិសេសទាក់ទាញទេសចរឱ្យមកទស្សនាបូជនីយដ្ឋានដ៏ពិសិដ្ឋនេះបានកាន់តែច្រើន។

ក្រៅពីសង្គ្រោះស្មៅ ក្រុមការងារក៏នឹងរៀបចំផ្លូវដើរក្នុងបរិវេណប្រាសាទអង្គរវត្តឱ្យត្រូវតាមគម្រោង ហើយការរៀបចំប្រព័ន្ធទឹកស្រោចស្មៅនេះទៀតសោត ក៏នឹងជានាដល់ការបំពេញទឹកក្នុងស្រះខាងជើងនិងស្រះខាងត្បូងឱ្យមានទឹកគ្រប់គ្រាន់គ្រប់រដូវផងដែរ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម ចាន់ សារឿន

ផ្សាយនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២០ ប្រតិភូអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ**ឯកឧត្តម តឹម សុធិន** អគ្គនាយករង តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្រ្តីមួយចំនួន បានអញ្ជើញចូលគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ចាន់ សារឿន** នៅគេហដ្ឋានឯកឧត្តម ស្ថិតនៅភូមិវិហារចិន សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប។

ឯកឧត្តម ចាន់ សារឿន ជាសមាជិកក្រុមប្រឹក្សាខេត្តសៀមរាប បានទទួលមរណភាពនៅថ្ងៃអាទិត្យ ៦កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែមិនា ឆ្នាំ២០២០ ក្នុងជន្មាយុ៦៨ឆ្នាំ ដោយរោគារពាធ។

យើងខ្ញុំថ្នាក់ដឹកនាំ មន្រ្តី-បុគ្គលិកទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវសេចក្តីក្រៀមក្រំនិងសោកស្តាយជាពន់ពេកជាមួយគ្រួសារសព ចំពោះការបាត់បង់ដ៏ធំធេងនៃសមាជិកគ្រួសារ និងវីរៈភាពរបស់ឯកឧត្តមដែលបានលះបង់កម្លាំងកាយចិត្ត បម្រើប្រយោជន៍ជាតិកាលឯកឧត្តមនៅមានជីវិត។ សូមគោរពលំឱនកាយ បួងសួងដល់វិញ្ញាណក្ខន្ធឯកឧត្តម បានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមេសា

ព្រះបដិមាសីសៈចំនួន២ត្រូវបានលើកចេញពីប្រឡាយទឹកនៅខ្លោងទ្វារខ្មោច

ផ្សាយនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០២០

ព្រះបដិមាសីសៈចំនួន២ មានទេវតាចំនួន១ អសុរា(យក្ស) ចំនួន១ ដែលជាចម្លាក់ទាញព្រ័ត្រនៅខ្លោងទ្វារខ្មោច ត្រូវបានក្រុមការងារចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ និងនគរបាលបេតិកភណ្ឌ ព្រមទាំងភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា នាំគ្នាស្រង់យកចេញពីប្រឡាយទឹកនៅខាងកើតខ្លោងទ្វារខ្មោច នាព្រឹកថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។

លោក ឈូក សុម៉ាឡា មន្ត្រីជំនាញចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ឱ្យដឹងថា លក្ខណៈនៃព្រះបដិមាសីសៈទេវតាដែលបានប្រទះឃើញមាន៤បំណែក គឺព្រះសីសៈទាំងមូលដាច់ត្រឹមមាត់ ហើយខូចខាតផ្នងសក់ បំណែកច្រមុះរបេះពីខ្នង់ និងបំណែកទងត្រចៀកឆ្វេងស្តាំ។ ចំណែកអសុរាវិញមានតែផ្នែកខាងក្រោយជាមួយក្បាច់លម្អសក់ និងពុំមានព្រះភក្ត្រទេ។

ការប្រទះឃើញព្រះបដិមាសីសៈទាំង២នៅក្នុងប្រឡាយទឹកមិនមែនជារឿងចៃដន្យនោះទេបើតាមការបញ្ជាក់របស់លោក សុម៉ាឡា ព្រោះវាបណ្តាលមកពីរចនាសម្ពន្ធទូទៅនៃសំណង់ចម្លាក់ទាញព្រ័ត្រនោះបានខូចខាតដោយសារអាយុកាលនៃសំណង់ កត្តាធម្មជាតិ និងសង្គ្រាម ទើបធ្វើឱ្យចម្លាក់ទាំងនោះធ្លាក់ចូលក្នុងទឹក ខ្លះកប់ក្នុងដី ខ្លះនៅលើដីជាច្រើនទៀត។

ក្រោយធ្វើការប្រគល់ទទួលហើយ ព្រះបដិមាសីសៈទាំង២នេះ ត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរាយកទៅរក្សាទុកជាបណ្តោះអាសន្ន ដើម្បីចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ ហើយនឹងធ្វើការជួសជុល មុននឹងប្រគល់ទៅរក្សាទុកនៅសារមន្ទីរ៕

ប្រាសាទអកយំទទួលបានការជួសជុលជាលើកដំបូងពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០២០

ដំណើរការជួសជុលប្រាសាទអកយំមកដល់ឆ្នាំ២០២០ មានរយៈពេលជិតមួយឆ្នាំហើយ ដែលក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា បានប្រឹងប្រែងសង្គ្រោះឱ្យរួចផុតពីហានីភ័យ ដើម្បីឱ្យបុរាណដ្ឋានមួយនេះមានភាពរឹងមាំស្រស់ស្អាត និងចៀសផុតពីគ្រោះថ្នាក់ផ្សេងៗ សម្រាប់ទទួលស្វាគមន៍ទេសចរគ្រប់ទិសទីមកទស្សនាឱ្យបានច្រើនកុះករ។

លោកបណ្ឌិត ជា សុជាតិ បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងជាប្រធានគម្រោងបានឱ្យដឹងថា ប្រាសាទអកយំរងនូវការខូចខាតតាំងពីមុនបារាំងរកឃើញមកម្ល៉េះ (ឆ្នាំ១៩៣២) ដោយសាររចនាសម្ពន្ធមួយផ្នែកនៃប្រាសាទត្រូវបានកប់ក្រោមខ្ទង់ទំនប់បារាយណ៍។ មិនតែប៉ុណ្ណោះ ដើមឈើនិងឫសឈើក៏បានដុះចាក់ឫសបំផ្លាញប្រាសាទ កម្សោយរចនាសម្ពន្ធគ្រឹះមិនអាចទ្រទម្ងន់សង្កត់របស់តួប្រាសាទទាំងមូល ការលួចជីករកវត្ថុបុរាណ ឥដ្ឋពុកផុយ ការបំផ្លាញដោយបរិស្ថានមានរុក្ខជាតិ ស្លែ ទឹក សីតុណ្ហភាព អាកាសធាតុ លំញ័រយានយន្តដែលបរកាត់បុរាណដ្ឋានបាយអរអស់គុណភាព និងកង្វះការថែទាំជាដើម។

ដើម្បីសង្គ្រោះប្រាសាទនេះឱ្យផុតពីគ្រោះថ្នាក់ អាជ្ញាធរជាតិអប្សរាបានជួសជុលទៅតាមដំណាក់កាល។ ដំណាក់កាលទី១ សម្អាតប្រាសាទ ត្រួសត្រាយព្រៃ សម្អាតកំណកដីសម្រង់ប្លង់ជុំវិញប្រាសាទនិងពង្រឹងខឿនខាងត្បូងនៃប្រាង្គកណ្ដាល។ ដំណាក់កាលទី២ ក្រុមការងារបន្តពង្រឹងប្រាង្គកណ្ដាល ពង្រឹងនិងជួសជុលខឿនផ្នែកខាងត្បូង ខាងលិច ខាងកើត និងខាងជើង។ នៅផ្នែកខាងជើង ក្រុមការងារបានដំឡើងស៊ុមទ្វារដែលធ្វើពីថ្មភក់ឱ្យឈរឡើងវិញ ដែលគេបានធ្វើបន្ថែមលើសំណង់ចាស់កាលពីស.វ.ទី១០ ឱ្យដូចដើម។ បន្ទាប់ពីនោះ ក្រុមការងារបានដកដើមពោធិ៍រើពានព្រះភូមិនៅផ្នែកខាងកើត ដែលជាច្រកចូលដ៏សំខាន់ ហើយពង្រឹងខឿនទី៣ និងកម្រាលខឿនដែលឫសពោធិ៍បានចាក់ចូលធ្វើឱ្យខូចខាត។រួចហើយពង្រឹងនិងជួសជុលខឿនប្រាង្គ ដំឡើងកាំជណ្ដើរថ្មភក់និង ដាក់បង្កាន់ដៃឥដ្ឋសងខាង។ ចំណែកនៅកណ្ដាលប្រាង្គ ក្រុមការងារបានរៀបចំពង្រឹងជើងទម្រនិងលើកបំណែកជើងទម្រមកដាក់នៅទីតាំងដើមវិញ។

ប្រធានគម្រោងរូបនេះបានបញ្ជាក់ថា គោលបំណងនៃការជួសជុលប្រាសាទអកយំ គឺដើម្បីរួមចំណែកលើកតម្លៃប្រាសាទនេះឱ្យផុតពីការបំផ្លាញរបស់ធម្មជាតិ បរិស្ថាន និងមនុស្ស ឱ្យសមតម្លៃជាបេតិកភណ្ឌពិភពលោក។ លោក សុជាតិ សង្ឃឹមថា ក្រោយបញ្ចប់គម្រោងជួសជុលក្នុងពេលឆាប់ៗខាងមុខ នឹងមានភ្ញៀវទេសចរស្គាល់ច្រើនមកទស្សនាច្រើនដូចបារាយណ៍ដែរ ដើម្បីសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រ បរិស្ថាន ការជួសជុល សំណង់ប្រាសាទភ្នំ ដែលមានវ័យចំណាស់ជាងគេនៅក្នុងតំបន់រមណីយដ្ឋានអង្គរ៕

សារលិខិតជូនពរសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

សារលិខិតជូនពរ
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសខួបកំណើតគម្រប់៦៩ឆ្នាំឈានចូល៧០ឆ្នាំ

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសថ្ងៃខួបកំណើតដ៏ឧត្តុងឧត្តមគម្រប់៦៩ឆ្នាំឈានចូល៧០ឆ្នាំ របស់**សម្តេចអគ្គមហាសេនា-បតីតេជោ នាយករដ្ឋមន្ត្រី** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០ ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមអនុញ្ញាតចូលរួមសម្តែងនូវសេចក្តីសោមនស្សរំភើបរីករាយយ៉ាងក្រៃលែង និងសូមគោរពជូនពរសិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមមានអាយុយឺនយូរ សុខភាពល្អបរិបូរណ៍ ប្រាសចាកពីរោគាព្យាធិទាំងឡាយទាំងពួង ដើម្បីដឹកនាំរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសម្រេចបានជោគជ័យថ្មីៗថែមទៀត។

ខ្ញុំបាទសូមសម្តែងនូវមោទកភាពនិងការគោរពកោតសរសើរបំផុតចំពោះ **សម្តេចអគ្គមហាសេនា-បតីតេជោ** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេច ប្រទេសជាតិទទួលបាននូវឯកភាពទឹកដី បង្រួបបង្រួមជាតិ មានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរាល់សមិទ្ធផលជាច្រើនលើគ្រប់វិស័យជូនសង្គមជាតិគ្រប់កាលៈទេសៈ ទាំងនៅក្នុងប្រទេសនិងលើឆាកអន្តរជាតិ បម្រើឱ្យឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាជនរួមរស់ជាមហាគ្រួសារប្រកបដោយសុភមង្គលនិងវិបុលភាព។ ឧត្តមភាពនិងកិត្យានុភាពជាតិនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានលើកកម្ពស់នៅក្នុងក្របខណ្ឌតំបន់ និងពិភពលោកតាមរយៈសកម្មភាពការទូតដ៏ប៉ិនប្រសប់ និងការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់សម្តេច។ ជាក់ស្តែងក្នុងនាមជាប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ **សម្តេច** បានលះបង់ទាំងកម្លាំងកាយចិត្ត ព្រមទាំងធនធានផ្ទាល់របស់សម្តេច ដើម្បីបុព្វហេតុប្រយុទ្ធប្រឆាំងនឹងការរាតត្បាតនៃជំងឺកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏ប្រពៃវិសេសវិសាលនេះផងដែរ ខ្ញុំបាទសូមលើកហត្ថបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយលើលោក ឫទ្ធិបារមីខ្លាំងក្លា ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ ប្រោះព្រំនូវសព្វសាធុការពរជ័យគ្រប់ប្រការជូន **សម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមមានជន្មាយុយឺនយូរ សុខុមាលភាពបរិបូរណ៍ និងសូមសម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់ក្នុងដំណើរការដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅកាន់សុខសន្តិភាព ស្ថិរភាព សម្បូរសប្បាយរុងរឿង និងអភិវឌ្ឍន៍លើគ្រប់វិស័យជានិច្ចនិរន្តរ៍តរៀងរហូតទៅ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ សុក្រ ១១កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០២០

អគ្គនាយកអាជ្ញាធរជាតិអប្សរា

ហង់_ពៅ

ភ្នំពេញ:
អគារលេខ៨៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦

ពេជ្ញាធរដើម្បីការពារមរតកវប្បធម៌ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប:
ភូមិបង្គោង ឃុំកំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/០៦៣ ៧៦៥ ៥៧៦

រយៈពេល៣ខែដើមឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាចូលរួមសង់បង្គន់អនាម័យ ជូនពលរដ្ឋបានចំនួន៧០បង្គន់

ផ្សាយនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០២០

ដោយគិតគូរពីបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់រមណីយដ្ឋានអង្គរជាសំខាន់ អាជ្ញាធរជាតិអប្សរាតាមរយៈគម្រោង PAAGERA បានផ្តល់ថវិកាបដិភាគដល់ប្រជាពលរដ្ឋ ក្នុងការសង់បង្គន់អនាម័យតាមផ្ទះ។ គម្រោងនេះបានផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ឱ្យមានបង្គន់អនាម័យប្រើប្រាស់បានត្រឹមត្រូវ និងកាត់បន្ថយចំណាយលើថ្លៃព្យាបាលជំងឺដែលបង្កឡើងដោយការបន្ទោបង់ពាសវាលពាសកាល។ គម្រោងទទួលបានជំនួយពីប្រទេសបារាំង បាននិងកំពុងបន្តអនុវត្តន៍តាមភូមិរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ហើយក្នុងរយៈពេល៣ខែដើមឆ្នាំ២០២០ គម្រោងនេះបានសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋសរុបមានចំនួន៧០បង្គន់។

លោក ឡៃ ប៉ូទី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹក និងជាប្រធានក្រុមការងារអនុវត្តគម្រោងសុវត្ថិភាពកម្ម និងការគ្រប់គ្រងទឹកក្នុងតំបន់អង្គរ (PAAGERA) បានឱ្យដឹងថា គម្រោង PAAGERA បានចាប់ផ្តើមផ្តល់ថវិកាបដិភាគក្នុងការសាងសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរពីឆ្នាំ២០១៨មក។ ហើយ៣ខែដើមឆ្នាំនេះ គម្រោងសង់បង្គន់៧០ជូនពលរដ្ឋចំនួន៣ឃុំ មាន ឃុំជូនកែវ ២៤បង្គន់ ឃុំរុនតាឯក២៩បង្គន់ និងឃុំបល័ង្ក ១៧បង្គន់។

តាមការបញ្ជាក់ពីលោក ឡៃ ប៉ូទី ក្នុងគម្រោងថវិកាបដិភាគសង់បង្គន់អនាម័យនេះ អាជ្ញាធរជាតិអប្សរាបានផ្តល់នូវជម្រើស៣ប្រភេទសម្រាប់ពលរដ្ឋជ្រើសរើស ដែលជម្រើសទី១អាជ្ញាធរជាតិអប្សរាផ្តល់ថវិកា៤០ភាគរយ, ជម្រើសទី២ ថវិកា៣០ភាគរយ និងទី ៣ ចំនួន២០ភាគរយ។ ប្រជាពលរដ្ឋដែលយកជម្រើសទី១ត្រូវចូលរួមថវិកាសង់បង្គន់ត្រឹមតែចំនួន ១៥៦,០០០រៀល, ជម្រើសទី ២ ថវិកា ២៩៤,០០០រៀល និងជម្រើសទី៣ ថវិកា ៤៦៤,០០០រៀល គឺទៅតាមតម្លៃស្តង់ដាបង្គន់ដែលគម្រោងបានសិក្សាតម្លៃចន្លោះពី ២៦ម៉ឺន, ៤២ម៉ឺន និង ៥៨ម៉ឺនរៀលសម្រាប់ប្រភេទបង្គន់នីមួយៗ។ លោកពន្យល់ទៀតថា គម្រោងនេះមានសារសំខាន់ណាស់ដើម្បីលើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានលើផ្នែកអនាម័យការបន្ទោរបង់ធ្វើយ៉ាងណាឱ្យមានបង្គន់អនាម័យប្រើប្រាស់គ្រប់ផ្ទះ ជៀសវាងការបន្ទោរបង់ពាសវាលពាសកាល ដែលបង្កើតឱ្យមានជំងឺឆ្លងផ្សេងៗ ខាតបង់ថវិកានិងពេលវេលារបស់ប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា តាំងពីឆ្នាំ២០១៨មក អាជ្ញាធរជាតិអប្សរាបានចូលរួមថវិកាបដិភាគដើម្បីសង់បង្គន់អនាម័យជូនប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរបានចំនួន ១,២០០បង្គន់រួចហើយ៕

កម្រាលឈើក្នុងបរិវេណប្រាសាទអង្គរវត្តត្រូវបានជួសជុល

ផ្សាយនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២០

កម្រាលឈើថ្មីដើងនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ត្រូវបានក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ កំពុងរៀបចំជួសជុលផ្លាស់ប្តូរកម្រាលឈើថ្មី។

ការជួសជុលនេះ ត្រូវបានអនុវត្តជាប្រចាំដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរ និងបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរទស្សនាប្រាសាទ៕

អាជ្ញាធរជាតិអប្សរាទទួលអំណោយពីសប្បុរសជន ក្នុងការប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ១៩

ផ្សាយនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២០

នារសៀលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ នេះ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលអំណោយពីលោក ហែម ហេម៉ា ប្រធានក្រុមហ៊ុនយក្សាបោកអ៊ុត ដែលមានសមានចិត្តរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងទៅនឹងជំងឺឆ្លងកូវីដ១៩ (COVID-19) ។ សម្ភារដែលទទួលបានរួមមាន ៖ ដែល លាងដៃសម្លាប់មេរោគ ចំនួន ៦០លីត្រ សាប៊ូលាងដៃ ៤០លីត្រ សាប៊ូដប ៦០០ ដប សាប៊ូកញ្ចប់ (សំអាតទូទៅ) ១៦០ កញ្ចប់ និងសាប៊ូម្សៅ ០២ បាវធំ។

ក្នុងឱកាសនោះឯកឧត្តមអគ្គនាយករង បានកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក ប្រធានក្រុមហ៊ុនយក្សាបោកអ៊ុត ដែលបានលះបង់ទ្រព្យធនផ្ទាល់ខ្លួន ក្នុងការចូលរួមប្រយុទ្ធប្រឆាំងជម្ងឺកាចសាហាវនេះ ជាមួយនឹងអាជ្ញាធរជាតិអប្សរា ហើយជានាពាំនាំនូវអំណោយទាំងអស់នេះចែកជូនដល់ដៃបងប្អូនកម្មករ បុគ្គលិកដែលកំពុងមានភាពខ្វះខាត និងកំពុងបំពេញការងារនៅក្នុងរមណីយដ្ឋានអង្គរ ព្រមទាំងប្រើប្រាស់ក្នុងការលាងសម្អាតកន្លែងផ្ដល់សេវាកម្មទេសចរណ៍ផងដែរ។

សេចក្តីជូនដំណឹងស្តីពីការលើកពេលថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ០៣៤២/២០ រ.ជ.សអល

សេចក្តីជូនដំណឹង
ស្តីពី
ការលើកពេលថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យ
ចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករ នៃអាជ្ញាធរជាតិអប្សរាទាំងអស់មេត្តាជ្រាបថា ដើម្បីបន្ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19) រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចលើកពេលថ្ងៃឈប់សម្រាកចំនួន ០៤ថ្ងៃ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៣ ១៤ ១៥ និង១៦ ខែមេសា ឆ្នាំ ២០២០ ខាងមុខនេះ។ ពាក់ព័ន្ធនឹងករណីនេះ អាជ្ញាធរជាតិអប្សរានឹងធ្វើការជូនដំណឹងជាថ្មីស្តីពីការឈប់សម្រាកជំនួសថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនេះ បន្ទាប់ពីទទួលបានការកំណត់កាលបរិច្ឆេទច្បាស់លាស់ពីរាជរដ្ឋាភិបាលកម្ពុជានាពេលខាងមុខ។

ដូចនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករ នៃអាជ្ញាធរជាតិអប្សរាទាំងអស់ត្រូវមកបំពេញការងារដូចថ្ងៃធម្មតា ដោយពុំទទួលប្រាក់ឧបត្ថម្ភថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាកនោះទេ នៅតាមនាយកដ្ឋាន/អង្គភាព ទីតាំងឈរជើង និងការដ្ឋានរបស់ខ្លួន។ ក្នុងន័យនេះផងដែរ អាជ្ញាធរជាតិអប្សរានឹងមិនអនុញ្ញាតនូវច្បាប់ឈប់សម្រាកជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទេ លើកលែងតែក្នុងករណីចាំបាច់បំផុតដូចជា ជំងឺ មរណភាពសមាជិកក្រុមគ្រួសារណាម្នាក់ និងករណីជាក់ស្តែងមួយចំនួនទៀត ហើយត្រូវមានលិខិតផ្លូវការបញ្ជាក់ច្បាស់លាស់ភ្ជាប់មកជាមួយ ដូចជា លិខិតបញ្ជាក់សុខភាព និងលិខិតផ្លូវការនានាជាដើម ។ល។

ដោយឡែក ចំពោះថ្នាក់ដឹកនាំតាមនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវរៀបចំតារាងកាលវិភាគការងារឱ្យបានច្បាស់លាស់ ដើម្បីធានាថាមន្ត្រី-បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលកររបស់ខ្លួនបំពេញការងារជាធម្មតានៅទីតាំងបំពេញការងារ និងតាមការដ្ឋាននីមួយៗ។ ការឈប់សម្រាកដោយពុំផ្តល់មូលហេតុច្បាស់លាស់ចាត់ទុកជាអវត្តមានគ្មានច្បាប់ ហើយករណីនេះអាជ្ញាធរជាតិអប្សរានឹងចាត់វិធានការរដ្ឋបាល ក្នុងនោះគិតចាប់ពីការដកប្រាក់ឧបត្ថម្ភជាក់ស្តែងតាមចំនួនថ្ងៃអវត្តមានគ្មានច្បាប់ ការអនុវត្តវិធានការក្រុមប្រឹក្សាវិន័យ និងរហូតដល់អាចបញ្ចប់កិច្ចសន្យាការងារជាដើម។ល។

អាជ្ញាធរជាតិអប្សរា មានសេចក្តីជឿជាក់មុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករ នៃអាជ្ញាធរជាតិអប្សរាទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សៀមរាប ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

ភ្នំពេញ: មហាវិថីសហព័ន្ធរុស្ស៊ី លេខ៥១ សង្កាត់មិត្តភាព ខណ្ឌ៧មករា
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៨ ៧៧១/០២៣ ២១៨ ៧៧៦
អាជ្ញាធរជាតិការពារ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh
សៀមរាប: ភូមិបាដោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៩៦៤ ៥៩៩/០៦៣ ៩៦៤ ៥៩៦

ភាពសម្បូរបែបនៃស្ថាដែបុព្វបុរសដែលប្រទះឃើញនៅប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០២០

នៅក្នុងឆ្នាំ២០១៩កន្លងមក ដោយមានការសម្រេចព្រះទ័យពីព្រះគ្រូចៅអធិការវត្តលលៃ និងសម្រេចចិត្តពីអាចារ្យគណៈកម្មការគ្រប់គ្រងវត្តលលៃទាំងអស់ ព្រមទាំងពុទ្ធបរិស័ទ្ធជុំវិញវត្ត ជាពិសេសការឯកភាពពីសំណាក់ **សម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស** ព្រមទាំងការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ ដែលមាន ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ជាព្រះប្រធានកិត្តិយស ព្រះសុមង្គលសិលាចារ្យ អាតាករោ ជុំ គឹមឡេង ជាព្រះប្រធាននៃក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ បានសម្រេចថាសំណង់សាសនាទាំងអស់ត្រូវបានរំកិលចុះមកក្រោមដើម្បីទុកលទ្ធភាពឱ្យអាជ្ញាធរជាតិអប្សរាធ្វើការអភិរក្សនិងស្រាវជ្រាវបុរាណវិទ្យា។

ប្រាសាទលលៃបច្ចុប្បន្នមានទីតាំងនៅភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង គឺជាកោះដ៏ពិសិដ្ឋស្ថិតនៅចំកណ្តាលបារាយណ៍ឥន្ទ្រតដាក (បារាយណ៍លលៃ) នាសម័យបុរាណ។ ទីនេះបានប្រែប្រួលបន្តិចម្តងៗដោយការរៀបចំថ្មីនិងមានសំណង់សាសនាមួយចំនួនតាមរយៈសម័យកាលជាបន្តបន្ទាប់មក។

ជាក់ស្តែងក្នុងខែមីនា ឆ្នាំ២០២០ អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមកិច្ចការស្រាវជ្រាវបុរាណវិទ្យានៅប្រាសាទលលៃ និងបានរកឃើញនូវរចនាសម្ពន្ធបុរាណរបស់ប្រាសាទលលៃកប់ក្នុងដីអស់រយៈពេលជាច្រើនរយឆ្នាំដូចរូបភាពខ្លះៗដែលបង្ហាញអំពីការរកឃើញនាពេលនេះ។

អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលកែលម្អកំណាត់ផ្លូវ៦០ម៉ែត្រ

ផ្សាយនៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ២០២០

កំណាត់ផ្លូវ៦០ម៉ែត្រ ត្រង់ចំណុចរង្វង់មូលអប្សរាមកផ្លូវជាតិលេខ៦ មានប្រវែង១៧៩៥ ម៉ែត្រ និងទទឹង ១០ ម៉ែត្រ ក្រាលបេតុងកៅស៊ូប្រភេទ AC ដែលអាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមដំណើការ កាលពីថ្ងៃទី ២៤ ខែកុម្ភៈ រហូតមកដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០នេះ សម្រេចការជួសជុលកែលម្អទាំងស្រុងរួចរាល់ហើយ។

កំណាត់ផ្លូវនេះគឺជាផ្នែកមួយនៃការភ្ជាប់រមណីយដ្ឋានអង្គរមកក្រុងសៀមរាបតាមផ្លូវជាតិលេខ៦ និងមានតួនាទីសំខាន់ក្នុងសម្រួលដល់ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋក្នុងក្រុងសៀមរាប ក៏ដូចជាភ្ញៀវទេសចរជាតិ-អន្តរជាតិ។ នេះជាសមិទ្ធផលមួយ ក្នុងចំណោមសមិទ្ធផលជាច្រើនផ្សេងទៀត ដែលអាជ្ញាធរជាតិអប្សរាកំពុងមមាញឹកក្នុងការជួសជុលកែលម្អហេដ្ឋារចនាសម្ពន្ធទាំងក្នុងនិងក្រៅតំបន់ការពារនៃរមណីយដ្ឋានអង្គរ ៕

អាជ្ញាធរជាតិអប្សរាជួសជុលកម្រាលឈើថ្មើរជើងនិងសម្អាតស្លាកសញ្ញាបេតិកភណ្ឌពិភពលោក ក្នុងបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២០

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានជួសជុលកម្រាលឈើថ្មើរជើងបន្ថែមទៀតនៅខាងកើតលោកតារាជ ផ្នែកខាងក្នុង។ ជាមួយគ្នានោះ ក្រុមការងារក៏បានសម្អាតស្លាកសញ្ញាបេតិកភណ្ឌពិភពលោកនៅខាងមុខផ្លូវចូលច្រកខាងលិចប្រាសាទអង្គរវត្តផងដែរ។

កិច្ចការផ្លាស់ប្តូរឬជួសជុលកម្រាលថ្មើជើងថ្មី ការសម្អាតស្លាកសញ្ញានានា ការថែទាំរុក្ខជាតិ គឺជាភារកិច្ចប្រចាំថ្ងៃរបស់ក្រុមការងារអាជ្ញាធរជាតិអប្សរាដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរ និងធ្វើឱ្យបរិស្ថានក្នុងបរិវេណប្រាសាទអង្គរវត្តមានសោភ័ណភាពកាន់តែល្អប្រសើរឡើង៕



ក្រុមការងារព្រៃឈើកំពុងកាត់ដកហូតដើមឈើ ដែលដួលរលំដោយសារខ្យល់កន្ត្រាក់ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២០

ដើមឈើមួយចំនួន បានដួលរលំក្នុងបរិវេណប្រាសាទតាព្រហ្ម និងទីកន្លែងមួយចំនួនក្នុងរមណីយដ្ឋានអង្គរ ដោយសារឥទ្ធិពលខ្យល់កន្ត្រាក់នៅល្ងាចថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០។ ការដួលរលំដើមឈើនេះ មិនបង្កគ្រោះថ្នាក់ដល់ប្រាសាទ ឬអាយុជីវិតណាមួយឡើយ។ បច្ចុប្បន្នក្រុមការងារកាត់ក្រីមែកឈើនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌ និងបរិស្ថាន បាននិងកំពុងចុះកាត់ និងសម្អាតដកហូតដើមឈើទាំងនោះចេញពីបរិវេណជុំវិញប្រាសាទ។ កន្លងមកក្រុមការងារកាត់ក្រីមែកឈើ តែងចុះអនុវត្តន៍ការងារកាត់ក្រីជាប្រចាំ ដើម្បីរក្សាតុល្យភាពលំនឹងនៃដើមឈើ ធ្វើយ៉ាងណាទប់ស្កាត់ហានិភ័យខ្លាចមានករណីដួលរលំដូចនៅពេលនេះ៕

សេចក្តីជូនដំណឹងស្តីពីការបើកឲ្យដំណើរការទីតាំងថ្មីរបស់មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរាស្ថិតនៅភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ០៤០/២០ អសអ.លដលា

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឱ្យដំណើរការទីតាំងថ្មីរបស់មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុង-ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជន ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់ជ្រាបថា ក្នុងគោលបំណងលើកកម្ពស់ និងពង្រីកការផ្តល់សេវាសាធារណៈរបស់អាជ្ញាធរជាតិអប្សរា ស្របតាមយន្តការច្រកចេញ-ចូលតែមួយឱ្យមានប្រសិទ្ធភាព និងកាន់តែខិតជិតប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវានានាពាក់ព័ន្ធតំបន់រមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរានឹងបើកឱ្យដំណើរការជាផ្លូវការទីតាំងមជ្ឈមណ្ឌលសេវាកម្មថ្មីមួយកន្លែងទៀត ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (អតីតបញ្ជរលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរ) តាមបណ្តោយផ្លូវហ្វាលដឹហ្គុលឆ្ពោះទៅប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០នេះតទៅ។ ចំពោះការដាក់ពាក្យស្នើសុំសេវាសាធារណៈផ្សេងៗក្នុងតំបន់អង្គរ អ្នកប្រើប្រាស់អាចស្វែងរកនៅ ទីតាំងដូចខាងក្រោម៖

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កាង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំស្រុក-ក្រុងទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។ សូមទាក់ទងតាមរយៈទូរស័ព្ទ+(៨៥៥)៦៣ ៧៦ ៥៥ ៧៧ /អ៊ីម៉ែល៖ sca_apsara@yahoo.com។

ថ្ងៃពុធ...៤...រោច......ខែចេត្រ...ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប ថ្ងៃទី ១៥ ខែមេសា.. ឆ្នាំ២០២០
អាជ្ញាធរជាតិអប្សរា

ភ្នំពេញ:
អាគារលេខ៨៤ ផ្លូវលេខ២១៩ សង្កាត់បឹងកេង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៨១/ ០២៣ ២១៥ ៧៧៦

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កាង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការងារជួសជុល អភិរក្សនៅប្រាសាទបាគង

ផ្សាយនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យតាមដានការវិវឌ្ឍនៃកិច្ចការជួសជុល អភិរក្សនៅប្រាសាទឥដ្ឋ (បណ្ណាល័យ) ជ្រុងអាគ្នេយ៍ប្រាសាទបាគង។

ការចុះពិនិត្យតាមដាននាពេលនេះ បានផ្តោតសំខាន់ទៅលើបច្ចេកទេសជួសជុលប្រាសាទឥដ្ឋដែលរងការខូចខាតជាច្រើនអន្លើរនៅផ្នែកខាងលិច និងខាងត្បូង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការរកឃើញបំណែកបដិមាព្រះពុទ្ធនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២០

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យការរកឃើញបំណែកបដិមាព្រះពុទ្ធជាច្រើនអង្គនៅប្រាសាទអង្គរវត្ត។ បំណែកបដិមាទាំងនេះត្រូវបានកប់ក្នុងដីក្នុងជម្រៅរាក់ និងរកឃើញដោយអ្នកបុរាណវិទូនៃអាជ្ញាធរជាតិអប្សរានាពេលបំពេញភារកិច្ចរៀបចំប្រព័ន្ធស្រោចស្រពស្វ័យប្រវត្តិក្នុងបរិវេណប្រាសាទអង្គរវត្ត៕

ជម្រាបជូន លោក លោកស្រី ជាម្ចាស់ទីតាំងតូបលក់ដូរដែលជួលឲ្យក្រុមហ៊ុន ចម្រុះសិប្បករអង្គរ (Artisans Angkor)នៅមុខអង្គរវត្តខាងលិចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.១៧៣ ៥ៃ២ /អប.សជណ
២០

ជម្រាបជូន

លោក លោកស្រី ជាម្ចាស់ទីតាំងតូបលក់ដូរដែលជួលឱ្យក្រុមហ៊ុន ចម្រុះសិប្បករអង្គរ (Artisans Angkor) នៅមុខខាងលិចប្រាសាទអង្គរវត្ត

កម្មវត្ថុ៖ ករណីការមិនមកចូលរួមធ្វើបច្ចុប្បន្នភាពស្ថិតិតូបអ្នកលក់ដូរអចិន្ត្រៃយ៍នៅបរិវេណប្រាសាទអង្គរវត្ត

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រី ជាម្ចាស់ទីតាំងតូបលក់ដូរដែលជួលឱ្យអាទីសង់អង្គរ នៅមុខខាងលិចប្រាសាទអង្គរវត្ត ជ្រាបថា៖ កាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបានសហការជាមួយអាជ្ញាធរមូលដ្ឋាន រួមមាន តំណាងរដ្ឋបាលខេត្តសៀមរាប រដ្ឋបាលក្រុង សង្កាត់ ភូមិ និងអង្គភាពនគរបាលការពារបេតិកភណ្ឌ ចុះធ្វើបច្ចុប្បន្នភាពតូបអ្នកលក់ដូរអចិន្ត្រៃយ៍នៅប្រាសាទអង្គរវត្តបានរួចរាល់ជាស្ថាពរ ក្នុងនោះគោលដៅសំខាន់គឺដើម្បីរៀបចំកន្លែងអ្នកលក់ដូរថ្មីជូនបងប្អូនអាជីវករទាំងអស់ ឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងបរិស្ថានល្អ នៅបរិវេណប្រាសាទអង្គរវត្ត ឱ្យសាកសមជាសម្បត្តិបេតិកភណ្ឌពិភពលោក។ ដោយឡែក ក្រុមការងារក៏បានទុកពេលវេលាសមស្របជូនបងប្អូនអាជីវករ ដែលពុំបានមកចូលរួមស្រង់ទិន្នន័យ ដើម្បីធ្វើបច្ចុប្បន្នភាពតូបលក់ដូររបស់ខ្លួនផងដែរ។ រហូតមកដល់បច្ចុប្បន្ន ក្រុមការងារចម្រុះបានពិនិត្យឃើញនៅសល់តូបតែមួយគត់ប៉ុណ្ណោះដែលពុំស្គាល់អត្តសញ្ញាណ ហើយម្ចាស់តូបពុំដែលបានចូលខ្លួនមកធ្វើបច្ចុប្បន្នភាពតូបលក់ដូរជាមួយបងប្អូនអាជីវករដទៃទៀតនៅឡើយ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាសូមជូនដំណឹងជាលើកចុងក្រោយ និងទុកពេលជូនលោក លោកស្រីរយៈពេលពីរសប្តាហ៍គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ដើម្បីចូលមកធ្វើបច្ចុប្បន្នភាពតូបលក់ដូរជាកំហិត។ ក្នុងករណីលោក លោកស្រី មិនមកទំនាក់ទំនងក្នុងរយៈពេលជូនដំណឹងនេះ អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការទៅតាមផ្លូវច្បាប់ ហើយនឹងមិនធានាខុសត្រូវក្នុងការបាត់បង់ ឬខូចខាតនៅពេលរុះរើអាគាររបស់លោក លោកស្រី នាពេលខាងមុខឡើយ។

អាជ្ញាធរជាតិអប្សរាសង្ឃឹមថា លោក លោកស្រី ដែលជាម្ចាស់ទីតាំងនឹងចូលមកធ្វើបច្ចុប្បន្នភាពតូបលក់ដូរជាមួយអាជ្ញាធរជាតិអប្សរា ទៅតាមពេលវេលាដែលបានកំណត់ខាងលើ ដើម្បីរកដំណោះស្រាយសមស្របជាមួយបងប្អូនអាជីវករដទៃទៀត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីជ្រាប និងសហការតាមការគួរ។

សូម លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣

សៀមរាប ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២០

ត.ប. អគ្គនាយក

អគ្គនាយករង

ឃិត ចាន់ជារដ្ឋ

សូមទំនាក់ទំនង៖ ០១២ ៨៨៣ ១៣៨

ចម្លងជូន៖

- រដ្ឋបាលខេត្តសៀមរាប
- រដ្ឋបាលក្រុងសៀមរាប
- ស្នងការនគរបាលខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ
- សង្កាត់គោកចក
- ក្រុមហ៊ុន ចម្រុះសិប្បករអង្គរ(Artisans Angkor) "ដើម្បីជូនជ្រាប និងសហការ"
- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ៖ មហាវិថីសហព័ន្ធរុស្ស៊ី លេខ៩៩១ សង្កាត់មិត្តភាព ខណ្ឌ៧មករា ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/០២៣ ២១៥ ៧៧៦

អាជ្ញាធរជាតិសម្រាប់ការការពារ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សៀមរាប៖ ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៤ ៥៧៧/០៦៣ ៧៦៤ ៥៧២

អាជ្ញាធរជាតិអប្សរាកំពុងចាប់ផ្ដើមគម្រោងជួសជុលប្រាសាទតាអួន

ផ្សាយនៅថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០២០

ប្រាសាទព្រៃប្រាសាទឬប្រាសាទតាអួន ជាមន្ទីរពេទ្យមួយក្នុងចំណោមមន្ទីរពេទ្យទាំង១០២ក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ដែលកសាងឡើងនៅចុងសតវត្សរ៍ទី១២។ ប្រាសាទនេះកសាងក្នុងរចនាបថបាយ័ន្ត ឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន និងស្ថិតនៅប្រមាណ៨០០ម៉ែត្រពីជ្រុងពាយ័ព្យនៃកំពែងអង្គរធំ ដែលស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។

បច្ចុប្បន្ន រចនាសម្ពន្ធប្រាសាទរងការខូចខាតយ៉ាងដំណំដោយសារកត្តាអាយុកាល អាកាសធាតុ និងមនុស្ស ដែលតម្រូវឱ្យមានការជួសជុលឱ្យបានទាន់ពេលវេលា ពោលគឺប្រាសាទនេះពុំធ្លាប់ទទួលការជួសជុលនៅឡើយ។

កញ្ញា គាន បញ្ញាវន្តី ស្ថាបត្យករនៃគម្រោងជួសជុលប្រាសាទតាអួនរបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការបានឱ្យដឹងថា ប្រាសាទកំពុងប្រឈមនឹងហានីភ័យខ្ពស់។ កត្តាចម្បងដែលធ្វើឱ្យប្រាសាទទទួលរងការខូចខាតគឺបង្កដោយមនុស្ស។ ដើម្បីសង្គ្រោះប្រាសាទឱ្យផុតពីគ្រោះថ្នាក់ អាជ្ញាធរជាតិអប្សរាបានបើកការដ្ឋានជួសជុល និងរើថ្មនៅច្រកចូលខាងកើត។

កញ្ញា បញ្ញាវន្តី បានបន្តថា ក្រុមការងាបានបញ្ចប់ការងារសម្រង់ប្លង់ប្រាសាទ ថតរូប និងចងក្រងឯកសាររួចហើយ។ ចំណែកកិច្ចការបន្ទាប់គឺរើថ្មដែលក្រៀកនៅផ្នែកខាងកើតចេញដើម្បីជួសជុលនិងពង្រឹងឡើងវិញ រួចធ្វើកំណាយស្រាវជ្រាវដើម្បីសិក្សាគ្រឹះ បង្ហាប់គ្រឹះ បន្ទាប់មករៀបចំផ្គុំថ្មទាំងនោះចូលទីតាំងដើម។ ចុងក្រោយបំផុតគឺក្រុមការងារនឹងសិក្សាលើចំណុចហានីភ័យនៅជ្រុងផ្សេងៗទៀតដើម្បីទល់ទ្រូបន្ទាន់ ឬរុញថ្មនៅផ្នែកខ្លះចូលទីតាំងដើមវិញដើម្បីធានាសុវត្ថិភាព និងកាត់បន្ថយហានីភ័យរបស់ប្រាសាទ។

អាជ្ញាធរជាតិអប្សរា សូមថ្លែងអរគុណចំពោះប្រជាជនរស់នៅជិតប្រាសាទ អាជ្ញាធរមូលដ្ឋាន ដែលបានចូលរួមសហការសម្របសម្រួលគ្រប់ឧបសគ្គដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រុមការងារដំណើរការជួសជុលលើកតម្លៃប្រាសាទតាអួនទុកជាសម្បត្តិរបស់ខ្មែរគ្រប់ៗរូប ៕

បុរាណវិទូអាជ្ញាធរជាតិអប្សរារកឃើញគ្រឹះកំពែងបុរាណនៅជុំវិញប្រាសាទលលៃ ដែលកប់ក្នុងដីជាង១០០ឆ្នាំក្រោមសំណង់សាសនាសម័យក្រោយៗ

ផ្សាយនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០

ប្រាសាទលលៃបច្ចុប្បន្នមានទីតាំងនៅភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង គឺជាកោះដ៏ពិសិដ្ឋស្ថិតនៅចំកណ្តាលបារាយណ៍ឥន្រ្ទតដាក (បារាយណ៍លលៃ) នាបុរាណកាល។

ទីនេះបានប្រែប្រួលបន្តិចម្តងៗដោយការរៀបចំថ្មី និងមានសំណង់សាសនាមួយចំនួនតាមសម័យកាលជាបន្តបន្ទាប់។ ប៉ុន្តែនៅចុងឆ្នាំ២០១៩សំណង់សាសនាទាំងនោះត្រូវបានព្រះគ្រូចៅអធិការវត្តលលៃ អាចារ្យនិងគណៈកម្មការគ្រប់គ្រងវត្តលលៃទាំងអស់ ព្រមទាំងពុទ្ធបរិស័ទជុំវិញវត្ត ជាពិសេសការឯកភាពពីសំណាក់សម្តេចព្រះអគ្គមហាសង្ឃរាជ ទេព វង្ស ព្រមទាំងការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ ដែលមានព្រះមហាវិមលធម្មសិរីសុវណ្ណោ ពិន សែម ជាព្រះប្រធានកិត្តិយស ព្រះសុមង្គល សិលាចារ្យ អាភាករោ ជុំ គឹមឡេង ជាព្រះប្រធាននៃក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ សម្រេចរំកិលចុះមកក្រោមដើម្បីទុកលទ្ធភាពឱ្យអាជ្ញាធរជាតិអប្សរាធ្វើការអភិរក្សនិងស្រាវជ្រាវបុរាណវិទ្យា។

ក្នុងន័យនេះ នាពាក់កណ្តាលខែមីនា ឆ្នាំ២០២០ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមធ្វើការស្រាវជ្រាវ និងប្រទះឃើញអាថ៌កំបាំងដ៏អស្ចារ្យនៃរចនាសម្ពន្ធសំណង់បុរាណជាច្រើនដូចជា ខ្លោងទ្វារចូល កម្រាលឥដ្ឋ កុលាលភាជន៍និងជញ្ជាំងកំពែងដែលបានកប់ក្នុងដីក្រោមសំណង់សាសនាតាំងពីសម័យអាណានិគមបារាំងមក។ ការប្រទះឃើញរចនាសម្ពន្ធដ៏សម្បើមនេះ គឺជាការផ្តល់នូវទិន្នន័យថ្មីៗសម្រាប់កិច្ចការស្រាវជ្រាវបុរាណវិទ្យា ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម និងកិច្ចការអភិរក្ស អភិវឌ្ឍន៍ និងលើកតម្លៃប្រាសាទលលៃឱ្យកាន់តែល្អប្រសើរជាងមុន។

លោក ប៉ូ ប៉ុន ប្រធានក្រុមកំណាយស្រាវជ្រាវនៅប្រាសាទលលៃបានឱ្យដឹងថា ក្រុមការងារបានបើករណ្តៅកំណាយបានចំនួន១០ រណ្តៅនៅក្រោមអតីតសំណង់សាសនានៅផ្នែកខាងកើត ខាងជើង និងខាងលិច ហើយបានប្រទះឃើញរចនាសម្ពន្ធសំណង់ខ្លោងទ្វារចូលទាំង៣ទិសកំពែង៣ជាន់ព័ទ្ធជុំវិញតួប៉មទាំង៤នៃប្រាសាទ រចនាសម្ពន្ធកំពែងប្រាសាទក្នុងក្រៅ កម្រាលថ្មបាយក្រៀម កម្រាលឥដ្ឋជាច្រើនទីតាំង ចម្លាក់ដែលមានក្បាច់លម្អ រួមនឹងភាពខុសគ្នានៃខឿនប្រាសាទត្រង់ព្រះវិហារ។

ទាក់ទងនឹងមូលហេតុនៃការកប់រចនាសម្ពន្ធប្រាសាទនៅក្នុងដីនេះ លោក ប៉ូ ប៉ុន សន្និដ្ឋានថា ប្រហែលបណ្តាលមកពីការសាងសង់នាសម័យក្រោយៗភ្លេចគិតថាមានអ្វីក្រោមដី ព្រោះមានដីលុបពីលើសំណង់បុរាណបាត់អស់។ រីឯការអភិវឌ្ឍសំណង់នាសម័យក្រោយៗ ក៏ពុំបានធ្វើឱ្យសំណង់បុរាណក្រោមដីនេះរងការបំផ្លាញច្រើនទេ ព្រោះចាស់ៗបានរក្សាផ្នែកខាងក្នុងដោយកម្រាលឥដ្ឋ និងខាងក្រៅក្រាលថ្មបាយក្រៀមដើម្បីការពារ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងសប្បុរសជន ចុះពិនិត្យមើលសមិទ្ធផលរហាត់ទឹក និងការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០

នារសៀលថ្ងៃទី១៧ មេសា ឆ្នាំ២០២០ **ឯកឧត្តម ឃិត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និង **លោកជំទាវ ឧកញ៉ាមហាឧបាសិកា កិត្តិបណ្ឌិត សៀវ ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ បានចុះពិនិត្យមើលសមិទ្ធផលរហាត់ទឹកនៅសួនបណ្ដុះកូនឈើប្រាសាទតាកែវ ដែលទើបសម្រេចបានការជួសជុលរួចរាល់ទាំងស្រុងក្រោយរងការខូចខាតជាច្រើនឆ្នាំ។

ឆ្លៀតក្នុងឱកាសនោះ លោកជំទាវអគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក៏បានចុះពិនិត្យការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់ ដែលកំពុងដំណើរការជួសជុលផងដែរ។ គម្រោងទាំងពីរនេះ ទទួលជំនួយឧបត្ថម្ភថវិកាជួសជុលទាំងស្រុងពីលោកជំទាវអគ្គនាយិកាក្រុមហ៊ុន ហេងអភិវឌ្ឍន៍។

នេះជាគំរូភាពនៃវិស័យឯកជន ដែលបានរួមចំណែកលើកិច្ចការថែរក្សាបេតិកភណ្ឌមរតកដូនតាជាមួយរាជរដ្ឋាភិបាល។ អាជ្ញាធរជាតិអប្សរា សូមលើកទឹកចិត្តដល់វិស័យឯកជននានាចូលរួមលើកិច្ចការទាំងនេះ ស្របពេលដែល អាជ្ញាធរជាតិអប្សរាកំពុងបំពេញភារកិច្ចយ៉ាងសកម្មក្នុងការថែរក្សាមរតកដូនតា ហើយជាពិសេសនោះតំឡូវនេះ អាជ្ញាធរជាតិអប្សរាបាននិងកំពុងរកឃើញនូវបេកគំហើញថ្មីៗជាច្រើននៅតាមប្រាសាទក្នុងរមណីយដ្ឋានអង្គរ៕

លោកជំទាវឧកញ៉ាបណ្ឌិត សៀង ចាន់ហេង ទទួលជួយឧបត្ថម្ភគម្រោងជួសជុលខ្លោងទ្វារតាការ ខាងលិចក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២០

បន្ទាប់ពីបានចុះពិនិត្យការដ្ឋានជួសជុលរហាត់ទឹក និងស្រះស្រង់ដោយផ្ទាល់រួចមក **ឯកឧត្តម យិត ចាន់ដារដ្ឋ ឯកឧត្តម តឹម សុផិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និង **លោកជំទាវឧកញ៉ាមហាឧបាសិកាកិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ រួមជាមួយព្រះសទ្ធម្មប្បកាសនី បណ្ឌិត តាត មហាទី ចៅអធិការវត្តព្រះឥន្ទកោសាបានបន្តដំណើរចុះពិនិត្យខ្លោងទ្វារតាការ ដែលស្ថិតនៅបរិវេណខាងលិចនៃរាជធានីអង្គរធំក្នុងតំបន់អង្គរ។ កន្លងមក ខ្លោងទ្វារនេះមានសភាពទ្រុឌទ្រោមដែលអាចបង្កហានិភ័យដល់អ្នកធ្វើដំណើរ ហើយត្រូវបានបិទមិនឱ្យរថយន្តធ្វើដំណើរឆ្លងកាត់ឡើយ។

ដោយសមានចិត្តចង់ចូលរួមចំណែក ក្នុងកិច្ចការអភិរក្សបេតិកភណ្ឌជាតិខ្មែរ **លោកជំទាវឧកញ៉ាមហាឧបាសិកាកិត្តិបណ្ឌិត សៀង ចាន់ហេង** បានប្រកាសជួយផ្តល់ជំនួយឧបត្ថម្ភថវិកា ដើម្បីជួសជុលអភិរក្សខ្លោងទ្វារតាការ ដែលជាកេរ្តិ៍មរតកដូនតាដ៏មានតំលៃមហាសាលមិនអាចកាត់ថ្លៃបាន ឱ្យមានលក្ខណៈដូចដើមឡើងវិញ។ ក្នុងឱកាសនោះ លោកជំទាវក៏ថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរជាតិអប្សរា ដែលបានអនុញ្ញាតឱ្យលោកជំទាវបានចូលរួមក្នុងកិច្ចការបេតិកភណ្ឌទាំងនេះ ដែលធ្វើឱ្យលោកជំទាវមានមោទនភាពជាខ្លាំង ក្នុងការរួមចំណែកថែរក្សាដួងព្រលឹងជាតិខ្មែរ។ គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់ការងារអភិរក្ស និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរជាពិសេសជួយសម្រួលបញ្ហាកកស្ទះចរាចរនៅក្នុងតំបន់អង្គរធំ នាពេលបុណ្យទាន និងរដូវមានភ្ញៀវច្រើនផងដែរ។

គួរបញ្ជាក់ថា នេះជាគម្រោងទី៣ហើយ ដែលលោកជំទាវសៀង ចាន់ហេង ស្ម័គ្រចូលរួមការងារក្នុងរមណីយដ្ឋានអង្គរ ដែលគម្រោងទី១ គឺការជួសជុលរហាត់ទឹកនៅសួនបណ្តុះកូនឈើប្រាសាទតាកែវ ទី២ គម្រោងជួសជុលប្រាសាទកណ្តាលស្រះស្រង់ និងទី៣នេះ គឺគម្រោងជួសជុលខ្លោងទ្វារតាកែវ៕

ព្រះសង្ឃ និងកិច្ចការពារបេតិកភណ្ឌ ដែលមិនអាចកាត់ថ្លៃបាន!

ផ្សាយនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០២០

ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ព្រះរាជាគណៈថ្នាក់ទោ ជាសមាជិកថេរសភាសង្ឃ និងជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកព្រះពុទ្ធសាសនា នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះប្រធានកិត្តិយសក្រុមប្រឹក្សាកិច្ចការវត្តអារាមក្នុងឧទ្យានអង្គរ ព្រះអង្គបរិបូណ៌ដោយទឹកព្រះទ័យក្នុងកិច្ចការអភិរក្សសំណង់បេតិកភណ្ឌ។ ជាសក្ខីភាពនៃការរួបរួមរវាងអាណាចក្រ និងពុទ្ធចក្រ កន្លងមក និងរហូតមកដល់ពេលនេះ ព្រះអង្គបានបង្ហាញនូវតួនាទីយ៉ាងសំខាន់របស់ព្រះសង្ឃក្នុងកិច្ចសម្របសម្រួលការសង្គ្រោះប្រាសាទលលៃដែលរងផលប៉ះពាល់ដោយសំណង់ព្រះពុទ្ធសាសនាបែបទំនើបនៅក្នុងបរិវេណឧទ្យានអង្គរ។

ឆ្លើយតបចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ព្រះមហាវិមលធម្ម ព្រមទាំងព្រះមេគណខេត្តសៀមរាប ដែលជាព្រះប្រធានក្រុមប្រឹក្សាកិច្ចការវត្តអារាមក្នុងឧទ្យានអង្គ និងសមាជិកគ្រប់រូប គណៈសង្ឃគ្រប់គ្រងវត្តប្រាសាទលលៃ អាចារ្យគណៈកម្មការវត្ត ព្រមទាំងពុទ្ធបរិសទ្ធចំណុះជើងវត្តបានស្ម័គ្រព្រះទ័យនិមន្តចុះមកគង់នៅបរិវេណខាងក្រោម និងរំកិលនូវសំណង់ទាំងអស់ដែលមាននៅលើខឿនប្រាសាទលលៃមកខាងក្រោមវិញ ដោយរក្សាទុកតែសំណង់ព្រះវិហារពុទ្ធសាសនាបុរាណតែមួយប៉ុណ្ណោះ ដើម្បីទុកលទ្ធភាពដល់អាជ្ញាធរជាតិអប្សរា បំពេញកិច្ចការអភិរក្សរបស់ខ្លួនបានដោយងាយស្រួលស្របទៅតាមបទដ្ឋាននៃអង្គការយូណេស្កូ។

នៅរសៀលថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ ព្រះមហាវិមលធម្មបាននិមន្តទៅទតការកំណាយសង្គ្រោះប្រាសាទលលៃរបស់អាជ្ញាធរជាតិអប្សរាដោយមានការទទួលបដិសណ្ឋារៈអំពីសំណាក់ព្រះតេជគុណ បរមោ មុត្ត វិបុល ជាព្រះប្រធានគណគ្រប់គ្រងសង្ឃវត្តប្រាសាទលលៃនាបច្ចុប្បន្ន។ ទាំងពីរព្រះអង្គ មានទឹកព្រះទ័យរីករាយនិងកោតសរសើរយ៉ាងក្រៃលែងចំពោះគំហើញនៃលទ្ធផលកំណាយនេះ ដែលជាសក្ដានុពលដ៏មហិមានៃប្រាសាទលលៃដែលកន្លងមកមិនមាននរណាដឹងសោះ ព្រោះត្រូវបានកប់បាត់ក្រោមបាតអគារនៃសំណង់ទំនើប។

ព្រះមហាវិមលធម្ម ព្រះអង្គក៏បានផ្ដល់អនុសាសន៍ដល់ព្រះសង្ឃគ្រប់វត្តអារាមទាំងអស់ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនិងសប្បុរសជនទាំងអស់ សូមរួបរួមគ្នាជាមួយអាជ្ញាធរជាតិអប្សរាក្នុងកិច្ចការថែរក្សានូវសំណង់បេតិកភណ្ឌទាំងអស់ដែលជាមរតករបស់បុព្វបុរសខ្មែរយើងសម្រាប់មនុស្សជាតិជំនាន់ក្រោយៗទៀត ដោយមុននឹងសាងសង់អ្វីមួយត្រូវពិភាក្សាជាមួយក្រុមប្រឹក្សាកិច្ចការវត្តអារាមដែលមានព្រះមេគណជាព្រះប្រធានជាមុនសិន និងត្រូវសុំច្បាប់អាជ្ញាធរជាតិអប្សរាចុះទៅសិក្សាជាមុនសិន។

អាជ្ញាធរជាតិអប្សរារកឃើញឡើងវិញនូវបំណែកហោជាង ដែលរលុះបាត់នៅខ្លោងទ្វារប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០២០

បំណែកហោជាងនៃអគារខាងត្បូង ក្លោងទ្វារទី៤ ខាងកើត

បំណែកសសរផ្ដោបដែល ទើបរកឃើញ

បំណែកហោជាងនៃក្លោងទ្វារ សសរផ្ដោបខ្លោងទ្វារ និងជើងទម្រនៃសិលាចារឹកលេខK៨៤២ ដែលកន្លងបានគិតថាបាត់បង់ ត្រូវបានរកឃើញជាថ្មីឡើងវិញនៅក្នុងបរិវេណប្រាសាទបន្ទាយស្រី។ ការរកឃើញបំណែកទាំងនេះនឹងបំពេញរូបរាងដើមឡើងវិញរបស់ប្រាសាទបន្ទាយស្រីឲ្យកាន់តែប្រសើរ ព្រមទាំងផ្ដល់ជាទិន្ន័យបុរាណវិទ្យាថ្មីៗបន្ថែមទៀតដល់អ្នកស្រាវជ្រាវ។

អាជ្ញាធរជាតិអប្សរានឹងយកបំណែកថ្មដែលបានរកឃើញទៅបំពេញវិញនៅត្រង់ទីតាំងដើមនាពេលអនាគតដ៏ខ្លី៕

អាជ្ញាធរជាតិអប្សរាបន្តការងារស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២០

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបានបន្តការងារកែលម្អផ្លូវថ្នល់ចំនួន ០២ខ្សែជាបន្តទៀតក្រោយបានអាក់ខានដោយសារការរាតត្បាតនៃជំងឺកូវីដ -១៩ ។

ផ្លូវទាំងពីរខ្សែនេះរួមមាន ទី១ ចាប់ពីផ្លូវជាតិលេខ៦ ត្រង់ចំណុចរង្វង់មូលព្រះនរាយណ៍ រហូតដល់មុខព្រលានយន្តហោះ ដែលមានទទឹង ១០ម៉ែត្រ ប្រវែង ២.១៨១ម៉ែត្រ ប្រភេទបេតុងកៅស៊ូ (AC) ពណ៌ខ្មៅនិងទី២ ចាប់ពីផ្លូវជាតិលេខ៦ ត្រង់ចំណុចច្រកចូលប្រាសាទព្រះគោ រហូតជុំវិញប្រាសាទបាគង ដែលមានទទឹង ៥-៦ម៉ែត្រ ប្រវែង ២.៧៨១ម៉ែត្រ ប្រភេទបេតុងកៅស៊ូ (AC) ពណ៌ក្រហមចាស់។

ការកែលម្អផ្លូវថ្នល់នេះក្នុងគោលបំណងសម្រួលការធ្វើដំណើរ របស់ប្រជាលរដ្ឋ និងបម្រើដល់វិស័យទេសចរណ៍ផងដែរ។ សូមបញ្ជាក់ជូនជ្រាបថា ការជួសជុលកែលម្អផ្លូវខាងលើនេះបានចាប់ផ្តើមអនុវត្តតាំងពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ២០២០ កន្លងមកម្លេះ៕

លោកជំទាវ ភឿង សកុណា ប្រគេនបណ្ណថ្លែងអំណរគុណដល់ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ចំពោះការចូលរួមរបស់ព្រះអង្គក្នុងកិច្ចការអភិរក្សបេតិកភណ្ឌជាតិ ពិសេសប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរជាតិអប្សរា ព្រមទាំងក្រុមការងារ បានយកទេយ្យទាន និងជាពិសេសបាននាំយកនូវបណ្ណថ្លែងអំណរគុណប្រគេនដល់ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ជាព្រះរាជាគណៈថ្នាក់ទោ ជាសមាជិកថេរសភាសង្ឃ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ និងជាព្រះប្រធានកិត្តិយស នៃក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ ដែលព្រះអង្គបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការអភិរក្សបេតិកភណ្ឌជាតិ ជាពិសេសប្រាសាទលលៃ ដោយបានសម្របសម្រួលដល់ព្រះសង្ឃវត្តប្រាសាទលលៃ អាចារ្យគណៈកម្មការ និងពុទ្ធបរិស័ទ ចំណុះជើងវត្ត បានសម្រេចព្រមព្រៀងក្នុងការរំកិលសំណង់ពុទ្ធសាសនាទំនើបទាំងអស់ពីលើខឿនប្រាសាទលលៃ មកគង់នៅផ្នែកខាងក្រោមវិញ។

ការរំកិលនូវសំណង់ពុទ្ធសាសនាទំនើបពីលើខឿនប្រាសាទនេះ គឺជាកិច្ចការដ៏អស្ចារ្យនិងមានតម្លៃជាទីបំផុត និងជាប្រវត្តិសាស្ត្រ ហើយទទួលបាននូវការកោតសរសើរយ៉ាងខ្លាំងពីអង្គការយូណេស្កូ។ ជាពិសេសក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ នាពេលកន្លងមក បានចាត់ទុកថាសកម្មភាពនេះគឺជាសកម្មភាពគំរូមួយដែលរមណីយដ្ឋានបេតិកភណ្ឌពិភព-លោកផ្សេងៗទៀតគួរយកតម្រាប់តាម។

មានព្រះបន្ទូលនៅពេលនោះ ព្រះមហាវិមលធម្ម បានសម្តែងនូវព្រះទ័យរីករាយដោយព្រះអង្គផ្ទាល់បាននិមន្តទៅប្រាសាទលលៃ និងបានឃើញលទ្ធលដែលអាជ្ញាធរជាតិអប្សរាកំពុងតែធ្វើការ សិក្សាស្រាវជ្រាវ ដោយបាន បើកបង្ហាញនូវតឹកតាងជាប្រវត្តិសាស្ត្រជាច្រើនដូចជាគ្រឹះកំពែងប្រាសាទលលៃ ខ្លោងទ្វារ កំរាលឥដ្ឋ ព្រមទាំងបុរាណវត្ថុជាច្រើនទៀត ដែលនេះជាភាពដ៏អស្ចារ្យនៃប្រាសាទលលៃ ដែលកន្លងមកពុំមាននណាដឹង ព្រោះដោយហេតុរបស់ទាំងនេះត្រូវបានកប់បាត់នៅក្នុងដីក្រោមទីតាំងអតីតសំណង់ទំនើបដែលទើបបានរំកិលចុះក្រោម។ បើមិនមានការសម្រេចព្រះទ័យរបស់ព្រះសង្ឃក្នុងការរំកិលនូវសំណង់ទាំងនោះមកក្រោមទេ អាចំកំបាំងដ៏មានតម្លៃទាំងនេះនឹងមិនមានថ្ងៃបង្ហាញរូបរាងបានឡើយ។

ព្រះមហាវិមលធម្ម ក៏បានជម្រាបលោកជំទាវរដ្ឋមន្ត្រីដែរថា ក្នុងនាមពុទ្ធចក្រ ព្រះអង្គពុំដែលមានព្រះទ័យរា-រែកក្នុងបុព្វហេតុចូលរួមក្នុងកិច្ចការអភិរក្សសំណង់បេតិក-ភណ្ឌនោះទេ ដោយកន្លងមកព្រះអង្គបានធ្វើការយ៉ាងសកម្មជាមួយក្រុមប្រឹក្សាកិច្ចការវត្តអារាមរបស់អាជ្ញាធរជាតិអប្សរា ពិសេសជាមួយ លោក ស៊ឹម ប៊ុនធឿន ដើម្បីដោះស្រាយបញ្ហានានា ដោយជាក់ស្តែង និងទាន់ពេលវេលា និងទទួលបាននូវលទ្ធផលទុកជាប្រវត្តិសាស្ត្រនេះ។

លោកជំទាវបានអរព្រះគុណម្តងទៀតចំពោះការចូលរួមរបស់គណៈសង្ឃខេត្តសៀមរាប ក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ និងព្រះមហាវិមលធម្ម ចំពោះការចូលរួមអភិរក្ស បេតិកភណ្ឌជាតិ។ លោកជំទាវបានក្រាបថ្វាយបង្គំលាព្រះមហាវិមលធម្មដើម្បីទៅមើលកាងារនៅប្រាសាទលលៃជាមួយអ្នកជំនាញជាបន្ត ដោយបានទទួលពរសព្ទសាធុការអំពីព្រះមហាវិមលធម្មឲ្យបានសម្រេចគ្រប់ភារកិច្ច៕

លោកជំទាវ ភឿង សកុណា អញ្ជើញទៅវត្តប្រាសាទលលៃដើម្បីថ្លែងអំណរគុណព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តសម្រាប់ការថែរក្សាបេតិកភណ្ឌជាតិ

ផ្សាយនៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានអញ្ជើញទៅក្រាបបង្គំសួរសុខទុក្ខនិងប្រគេននូវទេយ្យទានមួយចំនួនដល់ព្រះតេជគុណ បរមោ មុត្ត វិបុល ព្រះប្រធានគណៈគ្រប់គ្រងវត្តប្រាសាទលលៃ ព្រមទាំងថ្លែងអំណរគុណដល់ព្រះអង្គ គណៈកម្មការគ្រប់គ្រងវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តដែលបានស្ម័គ្រព្រះទ័យ ប្រកបដោយព្រះតម្រិះដ៏ត្រឹមត្រូវ ក្នុងការរំកិលកុដិពីលើខឿនប្រាសាទលលៃចុះមកគង់នៅផ្នែកខាងក្រោមវិញ ដើម្បីសង្គ្រោះប្រាសាទលលៃ ។ សក្ខីភាព នេះនឹងទុកជាប្រវត្តិសាស្ត្រសម្រាប់មនុស្សជាតិជំនាន់ក្រោយៗទៀត។

ទន្ទឹមគ្នានេះដែរ លោកជំទាវក៏បានពិនិត្យការរៀបចំឡើងវិញនូវកុដិឈើមួយខ្នង មានបួនបន្ទប់ ដែលបានរំកិលពីលើខឿនប្រាសាទលលៃចុះមកបរិវេណខាងក្រោមដោយ បានពិនិត្យអំពីប្លង់ស្ថាបត្យកម្ម ដែលព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាវត្តអារាមក្នុងតំបន់ឧទ្យានអង្គរ និងព្រះតេជគុណ បរមោ មុត្ត វិបុល ព្រះប្រធានគណៈគ្រប់គ្រងវត្តប្រាសាទលលៃ បានសម្រេចឲ្យអាជ្ញាធរជាតិអប្សរាជួយសាងសង់សម្រាប់ព្រះសង្ឃគង់នៅ។ លោកជំទាវបានផ្តល់អនុសាសន៍ដល់អាជ្ញាធរជាតិអប្សរាដែលជាអ្នករៀបចំនិងកំពុងធ្វើការសាងសង់នោះ ធ្វើយ៉ាងណាឲ្យបានសមរម្យ និងងាយស្រួលដល់ការគង់នៅរបស់ព្រះសង្ឃ សម្រាប់បដិបត្តិតាមបែបព្រះពុទ្ធសាសនា។

លោកជំទាវ ភឿង សកុណា អញ្ជើញចុះពិនិត្យការជួសជុលប្រាសាទកណ្តាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំ និងអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា បានចុះត្រួតពិនិត្យការជួសជុលប្រាសាទកណ្តាលស្រះស្រង់ដើម្បីស្តាប់អំពីបច្ចេកទេសនៃការជួសជុលព្រោះជាប្រាសាទដែលមានទឹកពទ្ធជុំវិញ។

តាមរយៈនៃបទពិសោធន៍និងចាំបាច់បំផុតនោះ អ្នកជំនាញបានជម្រាបអំពីការធ្វើទំនប់ឃាំងទឹកដើម្បីធ្វើការបូមទឹកចេញ ការប្រមូលថ្ម និងការធ្វើកំណាយស្រាវជ្រាវស្វែងយល់បន្ថែមទៀតអំពីរចនាសម្ពន្ធគ្រឹះប្រាសាទ។

លោកជំទាវ ភឿង សកុណា បានវាយតម្លៃខ្ពស់ចំពោះកិច្ចការទាំងនោះ ព្រមទាំងបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ទាំងអស់ដែលកំពុងធ្វើការយ៉ាងយកចិត្តទុកដាក់និងអត់ធ្មត់បំផុតក្នុងការអភិរក្សមរតកដូនតា៕

លោកជំទាវ ភឿង សកុណា អញ្ជើញចុះពិនិត្យគម្រោងជួសជុលខ្លោងទ្វារតាកាវនៃទីក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាគម្រោងនឹងជួសជុលខ្លោងទ្វារតាកាវនាពេលខាងមុខដ៏ខ្លី ដើម្បីស្វែងយល់អំពីផែនការសកម្មភាពក្នុងការជួសជុល **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំ និងអ្នកជំនាញផ្នែកបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បានអញ្ជើញទៅដល់ទីតាំងនៃខ្លោងទ្វារតាកាវកាលពីរសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០។

ជាផែនការសកម្មភាពសម្រាប់ធ្វើការជួសជុល អ្នកជំនាញបានជម្រាបជូនលោកជំទាវអំពីការយកចិត្តទុកដាក់របស់អ្នកជំនាញក្នុងការកំណត់នូវចំណុចហានីភ័យខ្ពស់ និងវិធានការទប់ស្កាត់បន្ទាន់ ការស្រាវជ្រាវវត្ថុបុរាណក្រោមដី ក៏ដូចជាការចងក្រងឯកសារនិងតឹកតាងប្រវត្តិសាស្ត្រអំពីតួនាទីដ៏សំខាន់នៃខ្លោងទ្វារ។

នាឱកាសនោះ លោកជំទាវក៏បានណែនាំដល់អ្នកជំនាញឲ្យប្រមូលចងក្រងឯកសារបច្ចេកទេសនិងផែនការសកម្មភាពជួសជុលទាំងអស់ដើម្បីផ្ញើជូនទៅគណៈកម្មការអាយស៊ីស៊ី-អង្គរ ពិនិត្យនិងផ្តល់អនុសាសន៍ឡើផ្នែកបច្ចេកទេសដើម្បីឱ្យការជួសជុសខ្លោងទ្វារដ៏ទ្រុឌទ្រោមមួយនេះឱ្យបានប្រសើរឡើងវិញ និងស្របតាមធម្មនុញ្ញអង្គរ។

លោកជំទាវ ភឿង សកុណា តាមដានការងារជួសជុលផ្លូវខាងនៅអង្គរធំនិងអញ្ជើញចុះពិនិត្យ រហាត់ទឹកនៅសួនបណ្ដុះកូនឈើប្រាសាទតាកែវដែលទើបជួសជុលរួច

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំ និងអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យមើលការជួសជុលផ្លូវថ្នល់មួយចំនួន ដូចជាកំណាត់ផ្លូវតភ្ជាប់ផ្លូវជាតិលេខ៦ មកប្រាសាទអង្គរវត្តឆ្លងកាត់ព្រលានយន្តហោះអន្តរជាតិសៀមរាប និងផ្លូវវាំងក្រុងអង្គរធំលើជានផ្លូវចាស់ដែលមានស្រាប់នៅខាងកើតព្រះលានជល់ដំរីតាមការឯកភាពរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ។

ជាបន្តមកទៀត លោកជំទាវក៏បានអញ្ជើញចុះទៅពិនិត្យរហាត់ទឹកនៅសួនបណ្ដុះកូនឈើប្រាសាទតាកែវ ដែលទើបជួសជុលរួចរាល់ដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរាក្រោមជំនួយឧបត្ថម្ភថវិកាទាំងស្រុងរបស់វិស័យឯកជន។

លោកជំទាវ បានវាយតម្លៃខ្ពស់នឹងការប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា និងពេញចិត្តចំពោះសមិទ្ធផលដែលសម្រេចបាន រួមនឹងការដាក់ឱ្យដំណើរឡើងវិញនូវរហាត់ទឹកនេះការប្រមូលទឹកសម្រាប់ស្រោចស្រពសួនកូនឈើនៅទីនេះផង និងលើកកម្ពស់រូបភាពទេសភាពវប្បធម៌តាមដងស្ទឹងសៀមរាបផង។

លោកជំទាវ ភឿង សកុណា អញ្ជើញចុះពិនិត្យសកម្មភាពរៀបចំកែលម្អ នៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០២០

ក្នុងពេលដែលប្រាសាទអង្គរវត្ត ត្រូវបានស្ងប់ស្ងាត់ភ្ញៀវទេសចរដោយឥទ្ធិពលជំងឺកូវីដ-១៩ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះត្រួតពិនិត្យសកម្មភាពអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅបរិវេណប្រាសាទអង្គរវត្ត ដើម្បីត្រៀមខ្លួនទុកជាមុនស្វាគមន៍ការត្រឡប់មកវិញនៃភ្ញៀវទេសចរនាពេលអនាគត។

នាពេលនោះ លោកជំទាវបានអញ្ជើញទៅស្វែងយល់អំពីការរកឃើញថ្មីនូវបំណែកព្រះពុទ្ធបដិមាជាច្រើនដែលត្រូវបានគេយកមករក្សាទុកក្នុងរណ្តៅក្រោមដីជាប់នៅនឹងជើងខាងលិចនៃតួប្រាសាទ។ លោកជំទាវ ធ្វើការណែនាំឲ្យប្រមូលយកនូវបំណែកព្រះពុទ្ធបដិមាទាំងនោះ ហើយជួសជុល និងអាចយកទៅរក្សាទុកនៅរួតព្រះពាន់នៃប្រាសាទអង្គរវត្ត ឬសារមន្ទីរ។

ឆ្លៀតឱកាសនាពេលដ៏មានតម្លៃលោកជំទាវក៏បានអញ្ជើញពិនិត្យសកម្មភាពដ៏មមាញឹករបស់អាជ្ញាធរជាតិអប្សរាក្នុងការកែលម្អទេសភាពបៃតងទាំងក្នុង និងក្រៅបរិវេណប្រាសាទអង្គរវត្ត ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាការរៀបចំមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចនៅមុខប្រាសាទអង្គរវត្ត។បន្ថែមលើនោះលោកជំទាវបានផ្តល់នូវអនុសាសន៍ដ៏ថ្លៃថ្លាដើម្បីអាជ្ញាធរជាតិអប្សរាបន្តអនុវត្តនូវរាល់សកម្មភាពអភិវឌ្ឍន៍ប្រកបដោយចីរភាពឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាពខ្ពស់ ជាពិសេសរៀបចំកន្លែងលក់ដូរនៅមុខប្រាសាទអង្គរវត្តឲ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងបរិស្ថានស្អាត៕

លោកជំទាវ ភឿង សកុណា អញ្ជើញត្រួតពិនិត្យវឌ្ឍនភាពនៃការកសាងផ្លូវឡើងភ្នំគូលែនពីស្រុកស្វាយលើ

ផ្សាយនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០២០

ក្នុងឱកាសអញ្ជើញបំពេញភារកិច្ចនៅខេត្តសៀមរាប **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ អមដំណើរដោយអមដំណើរដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាដើម្បីត្រួតពិនិត្យ និងតាមដានការកសាងផ្លូវឡើងភ្នំគូលែនពីស្រុកស្វាយលើ។

ជាមួយនឹងរាល់ការពិនិត្យទៅលើផ្នែកបច្ចេកទេស ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់ទាំងផ្នែកបរិស្ថាន និងព្រៃឈើជាពិសេសបង្ការទប់ស្កាត់ផលលំបាកផ្សេងៗ ដែលអាចកើតមានឡើងនាពេលអនាគត លោកជំទាវក៏បានផ្តល់អនុសាសន៍ឱ្យក្រុមហ៊ុនសាងសង់ចាំបាច់ត្រូវពិភាក្សារាល់គ្រប់បញ្ហាបច្ចេកទេសជាមួយអាជ្ញាធរជាតិអប្សរា និងគោរពយ៉ាងម៉ឺងម៉ាត់តាមអនុសាសន៍របស់គណៈកម្មការអាយស៊ីស៊ី-អង្គរ ព្រោះភ្នំគូលែនពុំមែនជាភ្នំធម្មជាតិធម្មតានោះទេ តែជាអតីតរាជធានីរបស់បុព្វបុរសខ្មែរដែលពេញដោយសម្បត្តិវប្បធម៌ជាតិជាច្រើនដូចជា លិង្គមួយពាន់ ពើងគំនូរព្រះអង្គជប ស្រះដំរី ទេសភាពវប្បធម៌ បរិស្ថានធម្មជាតិ ធនធានធម្មជាតិ និងសំណល់បុរាណវិទ្យាជាច្រើន។

ឆ្លៀតក្នុងឱកាសនោះ លោកជំទាវក៏បានអញ្ជើញចូលសម្តែងនូវការគោរពប្រតិបត្តិនូវជំនឿសាសនានៅទីតាំងព្រះអង្គធំដែរ៕

ក្រុមការងារកាត់ក្រីមែកឈើ ចុះកាត់និងដកហូតដើមឈើ៩ដើមនៅស្ពានមេម៉ាយ

ផ្សាយនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៤ខែមេសា ឆ្នាំ២០២០ ក្រុមការងារចុះកាត់ក្រី មែកឈើនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បានចុះកាត់ក្រី និងដកហូតដើមឈើហានិភ័យចំនួន៩ដើម នៅលើស្ពានមេម៉ាយ ស្ថិតនៅជ្រុងខាងលិចឆៀងខាងជើងបារាយណ៍ខាងលិច។

ដើមឈើដែលត្រូវកាត់នោះរួមមាន កាត់ដកហូតដើមឈើចំនួន៨ដើមមានដើមក្រឡាញ់៤ដើមដើមឡែងគង់១ដើម ដើមស្លែង១ដើម និងដើមពភ្លា១ដើម។ បន្ថែមពីនោះ ក្រុមការងារបានកាត់ក្រីដើមសុគ៌ំ១ដើម ចំនួន៤មែក ដែលសុទ្ធសឹងមានហានិភ័យដល់ស្ពានមេម៉ាយ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះត្រួតពិនិត្យនិងពិភាក្សាអំពីគម្រោងជួសជុលខ្លោងទ្វារខាងកើតប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងក្រុមការងារបានអញ្ជើញដល់ការដ្ឋានជួសជុលប្រាសាទតាព្រហ្ម ដើម្បីពិភាក្សាជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) អំពីផែនការរៀបចំជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម។

ក្នុងកិច្ចពិភាក្សានោះ អាជ្ញាធរជាតិអប្សរាបានឯកភាពឱ្យស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) ចាប់ផ្តើមដំណើរការនៃការជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មឱ្យបានឆាប់ដែលអាចទៅបាន ព្រោះក្នុងស្ថានភាពនេះចំនួនភ្ញៀវទេសចរក៏មានតិចនិងមិនមានការរំខាន។ ម្យ៉ាងវិញទៀត ក្នុងការសម្រួលដល់ដំណើរការជួសជុលផងនិងការចេញចូលរបស់ភ្ញៀវទេសចរផង ស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌាបានកសាងរួចរាល់នូវជណ្តើរឈើដើម្បីឆ្លងកាត់។

ក្នុងឱកាសនោះដែរ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា និងក្រុមការងារក៏បានចុះពិនិត្យការងារកំពុងជួសជុលនៅសាលរបាំ ដែលក្រុមការងារជួសជុលបានបំពេញដោយយកចិត្តទុកដាក់បំផុតស្របតាមអនុសាសន៍ពីអ្នកជំនាញនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ៕

អាជ្ញាធរជាតិអប្សរានឹងផ្តល់បច្ចេកទេសជួសជុលកុដិឈើដ៏ចំណាស់នៅវត្តព្រះព្រហ្មរ័ត្ន

ផ្សាយនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២០

ក្រុមការងារកិច្ចការវត្តអារាមនៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យកុដិឈើដ៏ចំណាស់មួយខ្នង ដែលជាស្ថាបត្យកម្មប្រកបដោយរចនាបថខ្មែរត្រូវបានសាងសង់អំពីឈើ ដំបូលប្រក់ក្បឿង និងមានអាយុកាលប្រមាណជាង៩០ឆ្នាំ ដែលស្ថិតនៅក្នុងវត្តព្រះព្រហ្មរត្ន័ ខេត្តសៀមរាប។ វត្តព្រះព្រហ្មរ័ត្ននេះ ជាវត្តដ៏ចំណាស់មួយក្នុងចំណោមវត្តចំណាស់ដទៃទៀត នៅតាមបណ្តោយដងស្ទឹងខេត្តសៀមរាប។

បច្ចុប្បន្ននេះ ក្រុមការងារកិច្ចការវត្តអារាម កំពុងតែសិក្សាលើគម្រោងនៃការជួសជុលកុដិឈើដ៏ចំណាស់នេះ ហើយគម្រោងនេះ គឺធ្វើឡើងក្នុងគោលបំណង ធ្វើយ៉ាងណាដើម្បីលើកស្ទួយស្នាដៃ និងចូលរួមអភិរក្សនូវសំណង់ស្ថាបត្យកម្មឈើដ៏ចំណាស់ ដែលមានមានតម្លៃមិនអាចកាត់ថ្លៃបានរបស់បុព្វបុរសខ្មែរ ទាំងព្រះសង្ឃ និងពុទ្ធបរិស័ទ។

ក្នុងការជួសជុលនោះ ក្រុមអ្នកជំនាញនឹងរក្សាទម្រង់ដើមទាំងស្រុង មិនឱ្យមានការបាត់បង់ទ្រង់ទ្រាយណាមួយឡើយ គឺធ្វើយ៉ាងណាដើម្បីបន្តរក្សានូវស្នាដៃ និងសទ្ធារបស់បុព្វបុរសខ្មែរយើងឱ្យនៅស្ថិតស្ថេរគង់វង្សចីរកាល។

បច្ចេកទេសអំពីការកាត់ដើមឈើធំៗមិនឱ្យមានហានិភ័យដល់ប្រាសាទ

ផ្សាយនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២០

ប្រាសាទតាព្រហ្មត្រូវបានគេស្គាល់ជាទូទៅថាជាប្រាសាទដែលសម្បូរដើមឈើធំៗដុះក្នុងបរិវេណប្រាសាទ។ ដ្បិតថាដើមឈើទាំងនោះជាទីទាក់ទាញដល់ភ្ញៀវទេសចរ តែវាក៏ជា ប្រភពនៃហានិភ័យដល់ប្រាសាទផងដែរព្រោះដើមឈើទាំងនោះអាចដួលរលំដោយសារកត្តាធម្មជាតិផ្សេងៗដែលក្នុងនោះមានដូចជាខ្យល់ជាដើម។ នៅពេលដែលដើមឈើទាំងនោះដួលលើប្រាសាទ ការងារដែលយកដើមឈើចេញជាបញ្ហាប្រឈមខ្លាំង សម្រាប់ក្រុមការងារព្រៃឈើ ព្រោះប្រសិនបើការងារដកហូតដើមឈើចេញមិនបានត្រឹមត្រូវទៅតាមលក្ខណៈ បច្ចេកទេសនោះទេ វាអាចធ្វើឲ្យរបេះថ្មធ្លាក់មកយ៉ាងងាយ។ ដូច្នេះ ចាំបាច់ត្រូវមានបច្ចេកទេសខ្ពស់ក្នុងការដកហូតដើមឈើទាំងនោះចេញ។

លោក មាយ បូរ៉ា មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន ជម្រាបអំពីបច្ចេកទេសទាំងនេះថា ការកាត់ដើមឈើធំៗដែលដួលគងលើប្រាសាទចាំបាច់ត្រូវរៀបចំរន្ទាឱ្យរឹងមាំនៅផ្នែកខាងក្រោម ហើយត្រូវកាត់ដើមឈើនោះជាចម្រៀកតូចៗបណ្ដោយសាច់ដើម្បីសម្រាលទម្ងន់និងងាយស្រួលលើកយកចេញ។ ការធ្វើបែបនេះ គឺអាចរក្សាសុវត្ថិភាពទាំងក្រុមការងារផង និងបញ្ចៀសការប៉ះពាល់ដល់ប្រាសាទផង៕

ក្រុមភ្នាក់ងារសណ្តាប់ធ្នាប់តាមប្រាសាទរៀបចំដាំបង្គោលឈើ នៅតាមបរិវេណប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២០

ដើម្បីរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ក្នុងរមណីយដ្ឋានអង្គរ ភ្នាក់ងារសណ្តាប់ធ្នាប់តាមប្រាសាទ បានរៀបចំដាំបង្គោលឈើឡើងវិញ តម្រង់បង្គោលដែលទ្រេត និងដកបង្គោលចាស់ពុកផុយ បន្ថែមបង្គោលថ្មីនៅតាមបរិវេណប្រាសាទនានាឱ្យមានភាពល្អប្រសើរជាងមុន។

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា តែងតែចុះពិនិត្យសំណើសុំសាងសង់ ព្រមទាំងជួយសម្រួល និងរៀបចំគំនូសប្លង់ដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរជាប្រចាំដើម្បីបង្កភាពងាយស្រួល បង្ការកុំឱ្យមានកំហុសឆ្គងពេលសាងសង់សំណង់ នាំឱ្យខាតបង់ពេលវេលានិងថវិកា។

ការសម្របសម្រួលទាំងនោះ គឺពេលទទួលបានពាក្យស្នើសុំពីម្ចាស់សំណើហើយ អ្នកជំនាញផ្នែកសាងសង់និងរៀបចំដែនដីនៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ អង្កេតដល់ទីតាំងស្នើសុំផ្ទាល់ ព្រមទាំងផ្ទៀងផ្ទាត់ជាមួយនឹងទិន្នន័យមួយចំនួនទៅតាមនីតិវិធី ដើម្បីធ្វើលិខិតឆ្លើយតបទៅកាន់ពួកគាត់វិញឱ្យបានទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមគោលការណ៍ច្បាប់ដែលកំពុងអនុវត្តជាធរមាន ក្នុងន័យរក្សាឱ្យបាននូវអត្តសញ្ញាណសំណង់មានលក្ខណៈជាខ្មែរ ដើម្បីលើកតម្លៃរបស់អង្គរ។

ជាក់ស្តែង ក្នុងរយៈពេលមួយសប្តាហ៍នៃខែមេសាឆ្នាំ២០២០កន្លងមកនេះ ក្រុមការងារបានចុះពិនិត្យទីតាំងស្នើសុំសរុបចំនួន១៥ករណី ដែលរួមមានសំណើសុំសាងសង់លំនៅដ្ឋាន សាលារៀន ផ្លូវ និងត្រពាំង ព្រមទាំងសំណើសុំផ្ទៀងផ្ទាត់ទិន្នន័យក្បាលដីជាមួយនឹងបុរាណដ្ឋានផងដែរ។

ចំពោះសំណើសុំសាងសង់លំនៅដ្ឋាន របស់ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានការអនុញ្ញាតឱ្យសាងសង់ ក្រុមការងារជំនាញផ្នែកស្ថាបត្យកម្មនៃអាជ្ញាធរជាតិអប្សរានឹងជួយសម្រួល រៀបចំគំនូសប្លង់ជូនពួកគាត់យកទៅសាងសង់ដោយមិនគិតថ្លៃ។ ក្នុងរយៈពេល១សប្តាហ៍ដូចគ្នាដែរ ក្រុមការងារបានរៀបចំគំនូសប្លង់បានចំនួន១២ករណីហើយដែរ៕

ការអភិរក្សសំណង់ស្ថាបត្យកម្មលំនៅដ្ឋានខ្មែរក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០២០

ឧទ្យានអង្គរជាតំបន់បេតិកភណ្ឌពិភពលោក ដែលមានមនុស្សរស់នៅ ហើយជាអ្នកស្រុកចាស់ និងជាអ្នកថែរក្សានូវទំនៀមទម្លាប់ប្រពៃណី ក្នុងការរស់នៅរបស់ខ្លួនតាំងពីដូនតាមក។ ប្រជាពលរដ្ឋម្ចាស់ស្រុកទាំងនោះ ជាផ្នែកមួយដ៏សំខាន់នៃមរតកវប្បធម៌របស់អ្នកស្រុកអង្គរ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ផងដែរ។

ប្រជាពលរដ្ឋដែលជាម្ចាស់ស្រុក ត្រូវបានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានសិទ្ធិទទួលបានការអនុញ្ញាតជាគោលការណ៍ក្នុងការសាងសង់លំនៅដ្ឋានរបស់ខ្លួនក៏ដូចជាសំណង់ឧបសម្ពន្ធមួយចំនួនទៀតផងដែរ។

ក្រោយបានការអនុញ្ញាត មន្ត្រី-បុគ្គលិកជំនាញរបស់នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានចុះទៅដល់ទីតាំងសាងសង់ផ្ទាល់ដើម្បីពិនិត្យតាមដាន និងផ្តល់នូវលក្ខណៈបច្ចេកទេសដោយពុំគិតប្រាក់ ហើយធ្វើយ៉ាងណាឱ្យសំណង់ទាំងនោះអនុលោមតាមលិខិតអនុញ្ញាត និងគោលការណ៍គ្រប់គ្រងសំណង់លំនៅដ្ឋានក្នុងឧទ្យានអង្គរ ដែលសំណង់ទាំងនោះជាសំណង់ស្រាល សង់ខ្ពស់ផុតពីដី ហើយក៏ជាសំណង់បែបប្រពៃណី តពីដូនតាខ្មែរមកដែរ ដែលបង្កឱ្យការរស់នៅសមស្របតាមលក្ខណៈអាកាសធាតុផង មុខរបរប្រចាំថ្ងៃផង និងជំនឿប្រពៃណីរបស់ខ្មែរយើងផង។

១. ក្រុងសៀមរាប បានចំនួន៥៤គ្រួសារ
២. ស្រុកប្រាសាទបាគង បានចំនួន៥១គ្រួសារ
៣. ស្រុកបន្ទាយស្រី បានចំនួន៣៧គ្រួសារ
៤. ស្រុកពួក បានចំនួន២៧គ្រួសារ
៥. ស្រុកអង្គរធំ បានចំនួន៣៥គ្រួសារ

កិច្ចការទាំងនេះ បានធ្វើឱ្យចំនួនសំណង់ដែលមិនមែនជាផ្ទះខ្មែរ និងខុសពីគោលការណ៍បេតិកភណ្ឌ ដែលធ្វើឱ្យប៉ះពាល់ដល់តម្លៃរបស់ឧទ្យានអង្គរ ត្រូវបានថយចុះ ហើយសំណង់បែបប្រពៃណីត្រូវបានលេចរូបរាងឡើងក្នុងឧទ្យានអង្គរជាបន្ត៕

ព្រឹត្តិការណ៍ព័ត៌មាន ប្រចាំខែឧសភា

ក្រុមគ្រប់គ្រងហានិភ័យដើមឈើចុះកាត់ក្រើដើមឈើក្នុងសាលាបឋមសិក្សាបាយ័ន

ផ្សាយនៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០២០

នៅថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ២០២០ ក្រុមគ្រប់គ្រងហានិភ័យដើមឈើរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរាបាន និងកំពុងកាត់ក្រើដើមឈើដែលមានហានិភ័យខ្ពស់ចំនួន៧ដើម នៅសាលាបឋមសិក្សាបាយ័នក្នុងបរិវេណវត្តព្រះសិអារ្យមេត្រិយ៍នៃតំបន់អង្គរធំ។

ដើមឈើដែលត្រូវកាត់ក្រើមែកនោះមាន ដើមឈើទាល ៦ដើម និងដើមស្រទ្បៅ១ដើម ដែលមានមែកងាប់ចំនួន២មែក និងមែករស់ចំនួន១៤មែក ត្រូវបានកាត់ចេញ ដើម្បីធានាសុវត្ថិភាពជូនលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស រួមទាំងព្រះសង្ឃដែលគង់នៅទីនោះមិនឲ្យមានគ្រោះថ្នាក់ដោយថាហេតុដល់អាយុជីវិត និងបង្ការកុំឲ្យមែកឈើទាំងនោះបាក់មកលើអគារសិក្សាផង ម្យ៉ាងជួយសម្រាលតួដើមកុំឲ្យបាក់រលំផង។

ខែឧសភា ឆ្នាំ២០២០

សត្វទោចមកុដ និងសត្វភេ ដែលបានដោះលែងនៅព្រៃឧទ្យានអង្គរកើតបានកូន៣បន្ថែម

ផ្សាយនៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០២០

ចាប់តាំងពីឆ្នាំ២០១៣មក គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការ Wildlife Alliance ទទួលបានជោគជ័យក្នុងការដោះលែងសត្វចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរបានជាច្រើនប្រភេទដូចជា សត្វទោចមកុដចំនួន១០ក្បាល សត្វឈ្លូសចំនួន៤ក្បាល សត្វស្វាព្រាមចំនួន១២ក្បាល សត្វសំពោចក្រអូបចំនួន៥ក្បាល សត្វភេខ្លួនរលោងចំនួន៥ក្បាល ដែលមកដល់ពេលនេះ សត្វទាំងអស់នោះនៅតែមានវត្តមាននៅទីនោះនៅឡើយ ក្រោមការយកចិត្តទុកដាក់តាមដាន និងថែទាំជាប្រចាំពីក្រុមការងារ។

ដោយឡែកសត្វទោចមកុដចំនួន៣គ្រួសារ ដែលក្នុងនោះនៅក្បែរប្រាសាទតានៃមានចំនួន៥ក្បាល ទើបតែកើតបានកូនមួយបន្ថែម ដែលមានអាយុប្រហែល៤សប្តាហ៍ហើយ។ ក្រៅពីនោះសត្វទោចមកុដផ្សេងទៀតដែលបានដោះលែងនាពេលកន្លងមក គឺនៅខ្លោងទ្វារខ្មោចមានចំនួន៤ក្បាល និងនៅខ្លោងទ្វារតាកាវមានចំនួន២ក្បាលកំពុងផ្សាំក្នុងទ្រុង ហើយគ្រោងនឹងដោះលែងនៅរដូវវស្សាខាងមុខនេះ។ សរុបនៅឧទ្យានអង្គរ សត្វទោចមកុដទាំងអស់មានចំនួន១១ក្បាល។ ក្នុងពេលឆាប់ៗខាងមុខនេះក្រុមការងារគ្រោងនឹងយក២ក្បាលបន្ថែមទៀតដាក់នៅក្បែរបឹងសន្ធមារ(ខាងជើងឈៀងខាងលិចក្នុងបរិវេណតំបន់អង្គរធំ) ក្រោយពីសង់ទ្រុងដែកសម្រាប់ផ្សាំរួចរាល់។

ចំពោះសត្វភេខ្លួនរលោង ដែលគម្រោងបានដោះលែងចំនួន៥ក្បាលកន្លងមក ពេលនេះកើតបានកូនចំនួន២បន្ថែម ដែលកូនភេទាំង២នោះមានអាយុប្រហែល៣ខែហើយ។

ដើម្បីឲ្យសត្វព្រៃទាំងអស់នោះបន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់អង្គរ ត្រូវចូលរួមថែរក្សាសត្វទាំងនោះទាំងអស់គ្នា ជៀសវាងពេលប្រទះឃើញមានបំណងមិនល្អ និងមេត្តាកុំផ្តល់ចំណីឲ្យសត្វទាំងនោះ៕

អាជ្ញាធរជាតិអប្សរាគ្រោងដាំនិងចែកចាយកូនឈើចំនួន១១ម៉ឺនដើមក្នុងឆ្នាំ២០២០នេះ

ផ្សាយនៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០២០

ដើម្បីបង្កើនគម្របព្រៃក្នុងរមណីយដ្ឋានអង្គរ ឱ្យបានកាន់តែច្រើនបន្ថែមទៀតនោះ ក្នុងឆ្នាំ២០២០នេះអាជ្ញាធរជាតិអប្សរានឹងបន្តយុទ្ធនាការដាំនិងចែកចាយដើមឈើចំនួន១១ម៉ឺនដើម។ បច្ចុប្បន្ន ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា កំពុងមមាញឹកបណ្ដុះនិងថែទាំកូនឈើទាំងនោះ ត្រៀមសម្រាប់ដាំនារដូវវស្សាខាងមុខ។

លោក ឡី គឹមស៊ី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងជាអ្នកទទួលបន្ទុកការងារបណ្ដុះកូនឈើ និងដាំឈើបានលើកឡើងថា ស្ថានីយបណ្ដុះកូនឈើទាំង៤របស់អាជ្ញាធរជាតិអប្សរា កំពុងមមាញឹកខ្លាំងក្នុងការបណ្ដុះកូនឈើចម្រុះសម្រាប់ត្រៀមដាំក្នុងឆ្នាំ២០២០នេះ។ កូនឈើសរុបមានចំនួនប្រមាណ១១ម៉ឺនដើម ត្រៀមដាំ និងចែកចាយក្នុងខែវស្សាខាងមុខ

នេះ មានទាំងប្រភេទដើមឈើប្រណិត ដើមឈើលម្អ និងប្រភេទដើមឈើព្រៃហូបផ្លែ។

ក្នុងបរិបទនៃជំងឺកូវីដ១៩នេះ ធ្វើឱ្យគម្រោងរៀបចំយុទ្ធនាការទ្រង់ទ្រាយធំៗដែលធ្លាប់រៀបចំកន្លងមក មិនទាន់ច្បាស់លាស់។ លោក ឡី គឹមស៊ី ពន្យល់ថា ប្រសិនបើស្ថានការណ៍ជំងឺកូវីដល្អប្រសើរឡើងវិញ នោះនឹងមានការរៀបចំកម្មវិធីធំៗដែលចូលរួមពីមហាជនខាងក្រៅ តែប្រសិនបើស្ថិតក្នុងស្ថានការណ៍ដូចសព្វថ្ងៃនេះ អាជ្ញាធរជាតិអប្សរានឹងរៀបចំដាំកូនឈើជាលក្ខណៈផ្ទៃក្នុងទៅតាមគោលដៅដែលបានគ្រោងទុក។

គួរឱ្យដឹងដែរថា អាជ្ញាធរជាតិអប្សរាមានស្ថានីយ៍បណ្ដុះកូនឈើចំនួន៤ទីតាំង ទី១ គឺស្ថានីយបណ្ដុះកូនឈើ៨ហិកតា ដែលបណ្ដុះកូនឈើប្រណិត៤ប្រភេទ មានដើមបេង គ្រញូង ប្រេះ និងធ្នង់ ទី២ ស្ថានីយបណ្ដុះកូនឈើប្រាសាទតាកែវ ដែលបណ្ដុះប្រភេទកូនឈើលេខ១ លេខ២ លេខ៣ និងក្រៅលំដាប់ថ្នាក់ទី៣ស្ថានីយបណ្ដុះកូនឈើមណ្ឌល៣ ដែលបណ្ដុះប្រភេទឈើលម្អ និងប្រភេទឈើព្រៃហូបផ្លែ និងទី៤ ស្ថានីយបាឡុង បណ្ដុះ ថែទាំ និងផ្សាំកូនឈើបន្តវេនគ្រប់ប្រភេទ។ ក្នុងឆ្នាំ២០១៩កន្លងទៅ អាជ្ញាធរជាតិអប្សរាបានដាំកូនឈើចំនួនជិត៣ម៉ឺនដើម និងបានចែកចាយទៅខាងក្រៅជាង៧ម៉ឺនដើម៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចរបស់ប្រជាពលរដ្ឋ បានចំនួន ១១១០គ្រួសារ រយៈពេល៤ខែដើមឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២០

យោងតាមរបាយការណ៍របស់លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចេញផ្សាយនៅខែមេសានេះ ក្នុងរយៈពេល៤ខែដើមឆ្នាំ២០២០ ក្រុមការងារសហគមន៍ បានចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះ និងសាងសង់តូចតាចតាមភូមិមួយចំនួនក្នុងតំបន់ឧទ្យានអង្គរបានចំនួន ១៥២៣គ្រួសារ ហើយបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន១១១០គ្រួសារ ។

ករណីអនុញ្ញាតខាងលើបានផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកប្រាសាទបាគង ចំនួន១១៤គ្រួសារ ស្រុកអង្គរធំចំនួន៧៥គ្រួសារ ស្រុកពួកចំនួន ២៥៥គ្រួសារ ស្រុកបន្ទាយស្រីបានចំនួន ៤៩៧គ្រួសារ និងក្រុងសៀមរាបចំនួន ១៦៩គ្រួសារ។ សូមបញ្ជាក់ថា ក្រុមការងារសហគមន៍បានចុះជាប់ជាប្រចាំដើម្បីសម្របសម្រួលករណីសំណើផ្សេងៗ និងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីនិងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ។

សាររំលែកមរណទុក្ខ

ផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២០

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ និងពលករទាំងអស់ មានក្តីរន្ធត់ចិត្តយ៉ាងខ្លាំង ដោយបានទទួលដំណឹងថា **អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណា វិវឌ្ឍនា ប៊ុន ស៊ាងលី** ដែលត្រូវជាមាតា មាតាក្មេក ជីដូន បានទទួលមរណភាព នាថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង២និង១២នាទី ទៀបភ្លឺ ក្នុងជន្មាយុ៩៦ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែក នូវមរណទុក្ខជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រី សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងក្រុមគ្រួសារ ដោយសេចក្តីសង្វេគជាទីបំផុត និងសូមឧទ្ទិសបួងសួងសុំឱ្យវិញ្ញាណក្ខន្ធរបស់ **អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណា វិវឌ្ឍនា** បានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សាររំលែកមរណទុក្ខ
សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា
ព្រមទាំងក្រុមគ្រួសារនៃសពអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា
ធម្មញ្ញាណា វិវឌ្ឍនា ប៊ុន ស៊ាងលី

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ និងពលករទាំងអស់
មានក្តីរន្ធត់ចិត្តយ៉ាងខ្លាំង ដោយបានទទួលដំណឹងថា អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា
ធម្មញ្ញាណា វិវឌ្ឍនា ប៊ុន ស៊ាងលី ដែលត្រូវជាមាតា មាតាក្មេក ជីដូន បានទទួលមរណភាព
នាថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០
វេលាម៉ោង២និង១២នាទី ទៀបភ្លឺ ក្នុងជន្មាយុ៩៦ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែក
នូវមរណទុក្ខជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រី សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និងក្រុមគ្រួសារ
ដោយសេចក្តីសង្វេគជាទីបំផុត និងសូមឧទ្ទិសបួងសួងសុំឱ្យវិញ្ញាណក្ខន្ធរបស់
អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណា វិវឌ្ឍនា បានទៅកាន់សុគតិភព
កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពចូលរួមរំលែកមរណទុក្ខពី
ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា
ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ និងពលករទាំងអស់

អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលកំណាត់ផ្លូវចាប់ពីរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ កាត់តាមមុខព្រលានយន្តហោះ ដល់មុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០២០

គម្រោងជួសជុលកំណាត់ផ្លូវ ចាប់ពីចំណុចរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧កាត់តាមព្រលានយន្តហោះ ប្រាសាទនាងពៅ រហូតដល់ផ្លូវបំបែកចំណតរថយន្តមុខប្រាសាទ

អង្គរវត្ត មានទទឹង១០ម៉ែត្រ ក្រាលបេតុងកៅស៊ូប្រភេទAC ប្រវែងសរុប ៦៧១២ម៉ែត្រ ដែលអាជ្ញាធរជាតិអប្សរាបានដំណើរការអនុវត្តចាប់តាំងពីពាក់កណ្តាលខែមករា ឆ្នាំ២០២០

មកដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ សម្រេចការជួសជុលទាំងស្រុងហើយ។

គម្រោងជួសជុលនេះចែកចេញជាបីកំណាត់៖
កំណាត់ទី១ ចាប់ពីផ្លូវជាតិលេខ៦ ត្រង់រង្វង់មូលព្រះបាទជ័យវរ្ម័នទី៧មកដល់មុខព្រលានយន្តហោះប្រវែង ២១៨១ ម៉ែត្រ ។

កំណាត់ទី២ ចាប់ពីមុខព្រលានយន្តហោះមកដល់មុខប្រាសាទនាងពៅប្រវែង៩៨៥ម៉ែត្រ។ កំណាត់ទី៣ ចាប់ពីប្រាសាទនាងពៅមកដល់មុខប្រាសាទអង្គរវត្ត ប្រវែង៣៥៤៦ ម៉ែត្រ។

ផ្លូវនេះផ្តល់នូវសក្តានុពលច្រើនសម្រាប់បម្រើដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុង/ក្រៅខេត្តសៀមរាប ការដឹកជញ្ជូន សុវត្ថិភាព និងចំណេញពេលវេលា ជាពិសេសភ្ញៀវទេសចរជាតិ-អន្តរជាតិដែលមកទស្សនានៅក្នុងរមណីយដ្ឋានអង្គរ ។

ការប្រទះឃើញត្រីសូល៍ ចម្លាក់នាគ និងថ្មគ្រីស្តាល់នៅប្រាសាទកណ្ដាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២០

ការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់ ដែលដឹកនាំដោយ **ឯកឧត្តម តឹម សុផិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដែលមានលោក ម៉ៅ សុខនី ប្រធានការដ្ឋាន បានរាយការណ៍ស្ដីពី ក្រុមបុរាណវិទូកំពុងកំណាយស្រាវជ្រាវ បានប្រទះឃើញវត្ថុបុរាណចំនួន៣ប្រភេទ គឺចម្លាក់នាគ ខ្វាតពណ៌ស (គ្រីស្តាល់?) និងត្រីសូល៍ នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០។

តាមការបញ្ជាក់ពីក្រុមការងារបានឱ្យដឹងថា ចាប់តាំងពីផ្ដើមកំណាយរហូតមកដល់ពេលនេះក្រុមការងារបានរកឃើញបុរាណវត្ថុជាច្រើនដែលស្ថិតនៅរាយប៉ាយលើដីជុំវិញទួលប្រាសាទ។

ក្នុងនោះបុរាណវត្ថុចំនួនបីប្រភេទដែលគេពុំធ្លាប់បានប្រទះឃើញនៅទីនេះមានជាអាទ៍៖ត្រីសូល៍ធ្វើពីលោហៈចំនួន២ ដែល១នៅមានរូបរាងពេញលេញ និង១ទៀតនៅសល់តែបំណែកចុងស្រួចមួយចំហៀង។ ខ្វាតពណ៌ស (គ្រីស្តាល់?) ជាច្រើនគ្រាប់ ដូចធ្លាប់រកឃើញនៅក្នុងរណ្ដៅកំណាយទីតាំងផ្សេងៗពីមុនដែរ និងបំណែកចម្លាក់ក្បាលនាគមួយធំ ដែលមួយផ្នែកធំកប់នៅក្នុងដីនៅឡើយ។

ការរកឃើញសំណល់បុរាណវិទ្យាទាំងនេះ ក្រុមបុរាណវិទូ នៅមិនទាន់អាចសន្និដ្ឋានបានថាស្ថិតនៅក្នុងសម័យកាល

ណា គេដាក់ដើម្បីអ្វី និងមានអ្វីបន្ថែមទៀតនោះទេ ព្រោះទើបតែជាដំណាក់កាលដំបូងនៃការធ្វើកំណាយស្រាវជ្រាវ។ លទ្ធផលនឹងបង្ហាញច្បាស់លាស់ជាងនេះនៅក្រោយបញ្ចប់ការងារស្រាវជ្រាវ។ បើសិនជាមិនមានអ្វីរារាំង និងរំខានក្នុងអំឡុងពេលកំណាយ កិច្ចការស្រាវជ្រាវនេះគ្រោងនឹងបញ្ចប់នៅក្នុងរយៈពេល៦សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០មក។

ក្នុងការរក្សាទុកដាក់វត្ថុបុរាណវិញ ឯកឧត្តមអគ្គនាយករងបានឱ្យដឹងថា បច្ចុប្បន្នដើម្បីរក្សាពីសុវត្ថិភាព ក្រុមការងារបាននាំយកវត្ថុទាំងនោះមកប្រគល់ជូនសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីជួសជុល សម្អាត និងរក្សាទុក៕

អាជ្ញាធរជាតិអប្សរាបានបោះបង្គោលព្រំកំណត់តំបន់ការពារត្រពាំងបុរាណ ឈ្មោះ ត្រពាំងហៃផ្កា

ផ្សាយនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២០

នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ក្រុមការងារបច្ចេកទេស នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តសៀមរាប សាលាក្រុងសៀមរាប និងអាជ្ញាធរមូលដ្ឋាន បានចុះបោះបង្គោលព្រំកំណត់តំបន់ការពារត្រពាំងបុរាណ ឈ្មោះ ត្រពាំងហៃផ្កា ស្ថិតនៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។



ការបោះបង្គោលព្រំកំណត់តំបន់ការពារត្រពាំងបុរាណខាងលើគឺដើម្បីទប់ស្កាត់ការរុករានទន្ទ្រានចូលកាន់កាប់ដីបរិវេណត្រពាំងបុរាណ ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ ពីសំណាក់ប្រជាពលរដ្ឋ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

ទន្ទឹមនឹងនេះតទៅថ្ងៃអនាគត អាជ្ញាធរជាតិអប្សរា ក៏នឹងមានគម្រោងបោះបង្គោលព្រំកំណត់តំបន់ការពារបុរាណដ្ឋានផ្សេងៗទៀតនៅក្នុងខេត្តសៀមរាបទាំងមូល ដែលមន្រ្តីបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរា បានកំណត់តំបន់ការពាររួចហើយ គឺក្នុងគោលបំណងថែរក្សា ការពារ និងអភិរក្សបុរាណដ្ឋាន សម្រាប់ទុកជាមរតកវប្បធម៌ប្រវត្តិសាស្ត្រ និងជាបេតិកភណ្ឌជាតិ ជាពិសេសសម្រាប់កូនចៅជំនាន់ក្រោយសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនផងនិងដើម្បីបម្រើវិស័យទេសចរណ៍ផង៕

អាជ្ញាធរជាតិអប្សរាអ៊ុតកៅស៊ូលើកំណាត់ផ្លូវជុំវិញប្រាសាទបាយ័ន្ត និងផ្លូវបំបែកទៅខ្លោងទ្វារជីផ្នាំង

ផ្សាយនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២០

នៅដើមខែឧសភា ឆ្នាំ២០២០ នេះនាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរាបានបន្តអនុវត្តគម្រោងជួសជុលកែលម្អផ្លូវចំនួនពីរកំណាត់៖ គឺផ្លូវព័ទ្ធជុំវិញប្រាសាទបាយ័ន្ត និងផ្លូវភ្ជាប់ពីខាងជើងប្រាសាទបាយ័ន្តទៅដល់ខ្លោងទ្វារជីផ្នាំង។

ចំពោះការអនុវត្តការងារជួសជុលកែលម្អផ្លូវជុំវិញប្រាសាទបាយ័ន្ត ដោយអ៊ុតបេតុងកៅស៊ូ AC ពណ៌ដីក្រហម ស្រទាប់ក្រោមខ្មៅស្រទាប់លើក្រហមចាស់ កម្រាស់ ៦ សង់ទីម៉ែត្រ បន្ថែមពីលើផ្លូវចាស់ដែលមានស្រាប់ DBST ប្រវែង១,០២៤ ម៉ែត្រ មានទទឹង៥ម៉ែត្រ ដើម្បីបង្កើនគុណភាព និងលើកសោភ័ណភាពផ្លូវឱ្យកាន់តែល្អប្រសើរ។

រីឯកំណាត់ផ្លូវទី២ផ្តើមចេញពីផ្លូវកែងជ្រុងខាងកើតឈៀងខាងជើងនៃប្រាសាទបាយ័ន្តឆ្ពោះទៅខ្លោងទ្វារជីផ្នាំងប្រវែង ១,៤២៧ម៉ែត្រ មានទទឹង៦ម៉ែត្រ ដែលអ៊ុតបេតុងកៅស៊ូពណ៌ក្រហមចាស់ ប្រភេទAC គ្រោងនឹងបញ្ចប់នៅចុងខែឧសភាខាងមុខនេះ។

ក្រោយពេលសាងសង់ផ្លូវនេះរួចរាល់ អាជ្ញាធរជាតិអប្សរានឹងផ្អាកការប្រើប្រាស់ផ្លូវកៅស៊ូបច្ចុប្បន្នទាំងស្រុងដែលនៅកៀកនឹងព្រះលានជល់ដំរី ហើយកែលម្អផ្លូវនោះជាសួនដាំស្មៅ ដើមឈើ បង្កើនទេសភាពបរិស្ថានស្រស់ស្អាតនៅមុខព្រះលានជល់ដំរី ក៏ដូចជានៅក្នុងបរិវេណក្រុងអង្គរធំទាំងមូល៕

អាជ្ញាធរជាតិអប្សរានិងព្រះសង្ឃសហការគ្នាដើម្បីអភិរក្សសំណង់បេតិកភណ្ឌសាសនា

ផ្សាយនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០២០

ព្រះគ្រូចៅអធិការវត្តព្រះឥន្ទទេពឱ្យដឹងថា ព្រះអង្គបានសម្រេចព្រះទ័យសាងសង់រោងឧបោសថធ្វើអំពីឈើបែបប្រពៃណី ដែលមិនប៉ះពាល់ដល់បុរាណដ្ឋានវិញ បន្ទាប់ពីអ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរាពិគ្រោះយោបល់ឃើញថា សំណង់ធ្វើពីបេតុងជាសំណង់អាចប៉ះពាល់ខ្លាំងដល់បុរាណដ្ឋាន ហេដ្ឋារចនាសម្ពន្ធសំណង់បុរាណនៅខាងក្រោមដីដោយមិនអាចរក្សាបាននូវស្ថាបត្យកម្មដើម។

វត្តព្រះឥន្ទទេពស្ថិតនៅទិសខាងលិចឈៀងខាងត្បូងនៃប្រាសាទបាយ័ន្តដែលជារាជធានីបុរាណនាសម័យអង្គរ ។ រោងឧបោសថនេះ បានចាប់ផ្តើមជួសជុលតាំងពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ហើយក្រុមការងារកិច្ចការវត្តអារាមនៃអាជ្ញាធរជាតិអប្សរា តែងចុះពិនិត្យការដ្ឋាននោះជាប់ជានិច្ច ដើម្បីឱ្យស្របតាមលក្ខណៈបច្ចេកទេស និងប្លង់ស្ថាបត្យកម្មបែបបុរាណខ្មែរ។

គិតមកដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ការជួសជុលបានរួចរាល់ប្រមាណ៧០% ហើយ។ ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងនៅតែបន្តចុះពិនិត្យ រហូតដល់ការជួសជុលបានរួចរាល់១០០%។ព្រះតេជគុណបានអំពាវនាវដល់វត្តអារាមទាំងអស់រាល់សំណង់គឺសុំសាងសង់ពីឈើជំនួសបេតុងវិញ ព្រោះថាការអភិរក្សមរតកវប្បធម៌នេះជាសម្បត្តិវប្បធម៌នៃមនុស្សជំនាន់មុនឱ្យនៅបន្តរស់ទៅដល់អ្នកជំនាន់ក្រោយទៀត៕

ព័ត៌មានទាន់ហេតុការណ៍៖ រកឃើញចម្លាក់អណ្តើកមួយបន្ថែមទៀតនៅការដ្ឋាន ជួសជុលប្រាសាទកណ្តាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៨ ខែឧសភា ឆ្នាំ ២០២០ ក្រុមការងារជួសជុលប្រាសាទកណ្តាលស្រះស្រង់បានប្រទះឃើញចម្លាក់អណ្តើកចំនួន១បន្ថែមទៀត ដែលមានទំហំតូចជាងមុនបន្តិច រួមនឹងត្រីសូល៍ចំនួន២ ដែល១មានរូបពេញលេញ និងមួយទៀតមានត្រឹមមួយបំណែក។

នៅជិតក្បាលចម្លាក់អណ្តើក ក្រុមការងារក៏បានប្រទះឃើញគ្រាប់ខ្វាតព៌ណស(គ្រីស្តាល់ ?)បង្កប់ក្នុងដីនៅទីនោះដែរ។

សូមបញ្ជាក់ថា គ្រាប់ខ្វាតព៌ណស (គ្រីស្តាល់?) នេះ ត្រូវបានមជ្ឈដ្ឋានមួយចំនួនយល់ច្រឡំថាជាគ្រាប់ពេជ្រឬជារបស់មានតម្លៃផ្សេង ប៉ុន្តែគ្រាប់ខ្វាតព៌ណស(គ្រីស្តាល់?) នេះ គឺត្រូវបានរកឃើញភាគច្រើននៅក្នុងរណ្តៅកំណាយស្រាវជ្រាវនៃការដ្ឋានជួសជុលនានា។

អាជ្ញាធរជាតិអប្សរានឹងជម្រាបជូនបន្ថែមទៀតអំពីខ្លឹមសារ នៅថ្ងៃស្អែក៕

ខែឧសភា ឆ្នាំ២០២០

ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម និមន្តពិនិត្យសកម្មភាព ជួសជុលប្រាសាទកណ្ដាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ **ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម** ព្រះរាជាគណៈថ្នាក់ទោ សមាជិកថេរសភាសង្ឃ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ អមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បាននិមន្តស្វែងយល់ការវិវត្តនៃការធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យានៅការដ្ឋានជួសជុលប្រាសាទកណ្ដាលស្រះស្រង់។

ការនិមន្តរបស់ព្រះមហាវិមលធម្មនាពេលនេះគឺស្របនឹងការរកឃើញជា បន្តបន្ទាប់នូវបុរាណវត្ថុដែលជាមរតកវប្បធម៌ដ៏មានតម្លៃដូចជា ត្រីសូល៍ គ្រាប់ខ្វាតព៌ណស (គ្រីស្ដាល់?)ចម្លាក់សត្វនាគ ចម្លាក់អណ្ដើក។ល។ ជាពិសេសនៅរសៀលថ្ងៃនេះក្រុមការងារទើបនឹងបានប្រទះឃើញចម្លាក់សត្វអណ្ដើកថ្មីមួយទៀត។

នាឱកាសនោះ ព្រះមហាវិមលធម្មបានសម្ដែងនូវទឹកព្រះទ័យសប្បាយរីករាយនិងបានថ្លែងនូវអំណរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានខិតខំបំពេញការងារយ៉ាងខ្ជាប់ខ្ជួន និងទទួលបានលទ្ធផលយ៉ាងគាប់ប្រសើរ។ ព្រះមហាវិមលធម្មក៏បានផ្ដល់ឱវាទនិងប្រសិទ្ធិពរជ័យបវរមហាប្រសើរដល់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងក្រុមការងារទាំងអស់ក្នុងការបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមនេះ៕

សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ ០៣៧៦/២០ រប.សជណ

សេចក្តីជូនដំណឹង

ស្តីពី

ការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា៖ ដើម្បីថែរក្សាសុខសុវត្ថិភាពជូនដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ស្ពានបណ្តែតទឹកដើម្បីទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរា នឹងធ្វើការថែទាំស្ពានបណ្តែតទឹកនៅពេលយប់ សម្រាប់រយៈពេល០២ថ្ងៃ គិតចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ចាប់ពីម៉ោង៦៖០០នាទី ល្ងាច រហូតដល់ម៉ោង១២៖០០នាទីយប់ ដែលមានសកម្មភាពដូចខាងក្រោម៖

១. ការងារ លាបថ្នាំការពារបង្កាន់ដៃស្ពានឈើកំពស់1,50ម មានរបារឈើ03ជួរ និងបង្គោលបង្កាន់ដៃ (ខាងកើត និងខាងលិច)

២. ការងារលាបថ្នាំការពារសរសរឈើគគីរកំពស់4,5ម ទំហំ250x250=12ដើម កំពស់3ម=4ដើម និងកំពស់1ម=8ដើម និងឃ្នាបឈើ8ដើម នៅក្រោមស្ពានខាងកើត-ខាងលិច

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៤ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

សៀមរាប ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២០

ភ្នំពេញ៖ អគារលេខ៤៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ

អាជ្ញាធរដើម្បីការពារមណ្ឌលរមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh

សៀមរាប៖ ភូមិបន្ទាយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

ប្រាសាទក្រហមក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២នៅលើខ្នងភ្នំគូលែនទើបបញ្ចប់ការជួសជុលជាលើកដំបូង

ផ្សាយនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២០

ប្រាសាទក្រហមកសាងក្នុងស.វ.ទី៩ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២នៅលើភ្នំគូលែន បានបញ្ចប់ការជួសជុលឱ្យផុតពីហានិភ័យជាលើកដំបូង ដោយក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរានៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរឪក្រោមការដឹកនាំដោយលោកបណ្ឌិត ឈាន រដ្ឋា និងដឹកនាំអនុវត្តផ្ទាល់ដោយលោកពុទ្ធសុទ្ធកាលពីពេលថ្មីៗនេះ។

លោក ឭ ចាន់ណូរ៉ា មន្ត្រីបច្ចេកទេសជួសជុលប្រាសាទក្រហមនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរបានឱ្យដឹងថា ប្រាសាទក្រហមជាប្រាសាទ ឥដ្ឋលាយថ្មភក់ កសាងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ នាស.វ.ទី៩ ឧទ្ទិសដល់ព្រះឥសូរ ស្ថិតនៅលើភ្នំគូលែន កម្ពស់៣៧០ម៉ែត្រពីនីវ៉ូទឹកសមុទ្រ និង១៤គីឡូម៉ែត្រពីព្រះអង្គធំ។ ប្រាសាទនេះមានចំនួនពីរគឺ ប្រាសាទក្រហម១ និងប្រាសាទក្រហម២។

លោកណូរ៉ាបន្តថាមុនការជួសជុលប្រាសាទក្រហម១បានប្រឈមនឹងការបំផ្លាញពីដើមឈើនិងឫសឈើចាក់ចូលទៅក្នុងតួប្រាសាទ ជញ្ជាំង និងដំបូលធ្វើឱ្យប្រាសាទនេះមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង។ ម្យ៉ាងទៀតឥដ្ឋមួយចំនួនពុកផុយដោយសារអាយុកាល និងអាកាសធាតុ បង្កឱ្យរុក្ខជាតិចាក់ចូលទៅបំផ្លាញរចនាសម្ពន្ធប្រាសាទ ហើយកាលពីសម័យមុនមានការលួចជីកកកាយរកវត្ថុបុរាណនៅផ្នែកកណ្តាល ធ្វើឱ្យខូចគ្រឹះឥដ្ឋសម្រាប់ទ្រលិង្គ និងយោនីភាពរាយប៉ាយ នៃវត្ថុសិល្បៈ ការបំផ្លាញពីសត្វកណ្តៀរ និងម្រោម ដែលធ្វើសំបុកក្នុងជញ្ជាំងឥដ្ឋនិងខឿនប្រាសាទ។ កត្តាទាំងនេះទើបតម្រូវឱ្យជួសជុលជាបន្ទាន់ ដើម្បី សង្គ្រោះប្រាសាទឱ្យបានទាន់ពេលវេលា សម្រាប់វិស័យទេសចរណ៍ និងលើកតម្លៃកេរតំណែលដូនតា។

ចំពោះការជួសជុលលើកដំបូងនេះ ក្រុមការងារបានកំណាយបកដីដែលចាក់បង្គស្វែងរកវត្ថុសិល្បៈនិងរៀបទុកដាក់ឥដ្ឋឱ្យមានសណ្តាប់ធ្នាប់ និងធ្វើជំរាលដោះទឹក។ សម្អាតរុក្ខជាតិដើមឈើដែលដុះនៅលើជញ្ជាំងនិងដំបូលប្រាសាទ។ រៀបក្តឹតជញ្ជាំងប្រេះនិងជួសជុលពង្រឹងជញ្ជាំងដែលពុកផុយ។ ជួសជុលពង្រឹងដំបូលដែលបម្រុងជ្រុះធ្លាក់ ជួសជុលនិងដំឡើងក្លោងទ្វារខាងកើតឡើងវិញ។

កិច្ចការជួសជុលប្រាសាទក្រហម១នៅដំណាក់កាលដំបូងនេះ មិនទាន់គ្រប់គ្រាន់ទេលោក បណ្ឌិត ឈាន រដ្ឋា បានលើកឡើងថា ទៅអនាគតនាយកដ្ឋាននឹងស្នើគម្រោងជួសជុលដំណាក់កាលទី២ គឺជួសជុលផ្នែកដំបូល ពង្រឹងរចនាសម្ពន្ធគ្រឹះឥដ្ឋសម្រាប់ទ្រលិង្គនិងយោនី ជួសជុលវត្ថុសិល្បៈបន្ថែមដែលបានរកឃើញនៅ ជុំវិញប្រាសាទដើម្បីឱ្យប្រាសាទនៅរឹងមាំគង់វង្សយូរអង្វែង និងកំណាយស្រាវជ្រាវដើម្បីដឹងព័ត៌មានបន្ថែមពីប្រាសាទនេះ៕

អាជ្ញាធរជាតិអប្សរាបើកទីតាំងទទួលពាក្យចំនួន៣បន្ថែមទៀត ដើម្បីជួយសម្រួលដល់ការស្នើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០២០

កន្លែងទទួលពាក្យចំនួន៣កន្លែងទើបនឹងបង្កើតទីតាំងបន្ថែមទៀត ទី១ នៅមជ្ឈមណ្ឌលសេវាកម្មអតីតបញ្ជរលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ទី២ ច្រកចេញចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ និងទី៣ នៅស្រុកបន្ទាយស្រី បានដាក់ឱ្យដំណើរការហើយ ដើម្បីសម្រួលដល់ការស្នើសុំសាងសង់ផ្សេងៗរបស់ប្រជាពលរដ្ឋរស់នៅក្នុងឧទ្យានអង្គរ។

ជាក់ស្តែងរយៈពេល១មួយសប្តាហ៍ចុងខែមេសាកន្លងទៅ អាជ្ញាធរជាតិអប្សរាបានទទួលពាក្យស្នើសុំសាងសង់ថ្មី និងជួសជុលចំនួន៥២ករណី ហើយក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរបានចុះពិនិត្យសំណើសុំសាងសង់ទាំងនេះបានចំនួន ២៤ករណី ជួយសម្រួល និងរៀបចំគំនូសប្លង់ជូនប្រជាពលរដ្ឋបាន៦ករណី បំណងឱ្យពលរដ្ឋយកទៅសាងសង់ឱ្យបានត្រឹមត្រូវ និងរក្សាបាននូវស្ថាបត្យកម្មមានលក្ខណៈជាខ្មែរ។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើ រហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោលគឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។ ពិសេសការបង្កើតឱ្យមានបញ្ជរទទួលពាក្យឱ្យមានតាមតំបន់ទាំង៣នេះ នឹងជួយសម្រួលដល់ការលំបាកឱ្យមានតិច កាត់បន្ថយពេលវេលា រួមនឹងការចំណាយលើមធ្យោបាយធ្វើដំណើរផង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការជួសជុលប្រាសាទតាអួន

ផ្សាយនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះត្រួតពិនិត្យការជួសជុលប្រាសាទតាអួនដែលបានចាប់ផ្តើមដំណើរការជួសជុលកាលពីចុងខែមីនា ឆ្នាំ២០២០។

ក្នុងឱកាសចុះត្រួតពិនិត្យនាពេលនេះ ក្រុមការងារបានពន្យល់លម្អិតអំពីដំណើរការនៃការជួសជុល និងការវិវត្តនៃការងារជាក់ស្តែងនៅប្រាសាទតាអួន។ ជាមួយនេះដែរ ឯកឧត្តមអគ្គនាយកបានកោតសរសើរក្រុមការងារចំពោះកិច្ចប្រឹងប្រែង ជាពិសេសសូមឱ្យក្រុមការងារគិតគូរហ្មត់ចត់ដល់អនុសាសន៍ដែលអ្នកជំនាញអាយស៊ីស៊ី-អង្គរបានផ្តល់កន្លងមក៕

សារលិខិតថ្វាយព្រះពរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ផ្សាយនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២០

សារលិខិតថ្វាយព្រះពរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃព្រះរាជពិធីចម្រើនព្រះជន្មវស្សាគម្រប់ ៦៧ យាងចូល៦៨ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

សារលិខិតថ្វាយព្រះពរ

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត



ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ
នៃព្រះរាជពិធីចម្រើនព្រះជន្មវស្សាគម្រប់៦៧ យាងចូល៦៨ព្រះវស្សា
ដែលនឹងប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ ខាងមុខនេះ

ទូលព្រះបង្គំយើងខ្ញុំ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា សូមព្រះបរមរាជានុញ្ញាតអភិវន្ទលំឱនកាយវាចាចិត្តក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទ សាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរ គ្រប់ប្រការ និងសូមលើកហត្ថប្រណមបួងសួងគុណព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ឫទ្ធិព្រះបារមីនៃទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេស ព្រះបារមី ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីព្រះអង្គបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រទូទាំងនគរជានិច្ចនិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំ សូមសម្តែងថ្វាយនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដែលព្រះអង្គតែងតែយកអស់ព្រះរាជហឫទ័យ និងព្រះកាយពល គិតគូរជាទីបំផុតចំពោះសុខទុក្ខរបស់ប្រជារាស្ត្រទូទាំងនគរ ដោយព្រះរាជហឫទ័យសប្បុរសប្រពៃថ្លៃថ្លាបំផុត។

សូមក្រាបបង្គំទូលថ្វាយពី
ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា
ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកគ្រប់លំដាប់ថ្នាក់

សួនបណ្តុះកូនឈើមណ្ឌល៣ ត្រៀមកូនឈើប្រមាណ៣ម៉ឺនដើមសម្រាប់ដាំនិងចែកចាយ

ផ្សាយនៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២០

សួនបណ្តុះកូនឈើមណ្ឌល៣ ជាសួនមួយក្នុងចំណោមសួនបណ្តុះកូនឈើទាំង៤របស់អាជ្ញាធរជាតិអប្សរា។ ជារៀងរាល់ឆ្នាំ សួននេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះកូនឈើ សម្រាប់ការដាំដុះ និងចែកចាយដល់ប្រជាពលរដ្ឋដែលមានបំណងយកទៅដាំដុះនៅតំបន់នានាជាពិសេសនៅក្នុងតំបន់អង្គរ។ ឆ្នាំនេះ សួនបណ្តុះកូនឈើមណ្ឌល៣ ដែលបណ្តុះប្រភេទឈើព្រៃហូបផ្លែ និងឈើលម្អ បានត្រៀមកូនឈើប្រមាណ៣ម៉ឺនដើមសម្រាប់ការងារដាំដុះ ក៏ដូចជាការចែកចាយ។

លោកស្រី ថៃ ប៊ុនជា បុគ្គលិកនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកការងារគ្រប់គ្រងនៅសួនបណ្តុះកូនឈើមណ្ឌល៣ បានឱ្យដឹងថា នៅសួននេះមានបណ្តុះប្រភេទឈើមួយចំនួនដូចជា ដើមរំដួល ដើមសេមាន់ ដើមគុយ ដើមផ្ចៀវ ដើមផ្កាត្របែកព្រៃ ដើមផ្កាអ៊ិនតាណែល និងប្រភេទដើមឈើមួយចំនួនទៀតសរុបជាង១០មុខ។ លោកស្រីបន្ថែមថា សួនបណ្តុះកូនឈើមណ្ឌល៣នេះដើរតួយ៉ាងសំខាន់ក្នុងការបណ្តុះឡើងវិញនូវប្រភេទកូនឈើដែលកម្រ ក្នុងបំណងអភិរក្សដើមឈើទាំងនោះឱ្យគង់វង្សទៅថ្ងៃក្រោយ។

ចំណែកការងារបណ្តុះវិញ ដូចទៅនឹងសួនបណ្តុះកូនឈើដទៃទៀតដែរ ក្រុមការងារបានដើររើសគ្រាប់ពូជនៅតាមព្រៃក្នុងរមណីយដ្ឋានអង្គរ តែពូជខ្លះក៏ត្រូវទិញគេដែរ ដោយសារជាប្រភេទឈើកម្រ ឬឆ្នាំខ្លះដើមទាំងនោះខ្វះផ្លែជាដើម។ លោកស្រី ថៃ ប៊ុនជា ប្រាប់ថាក្នុងមួយឆ្នាំ សួនបណ្តុះកូនឈើមណ្ឌល៣ អាចបណ្តុះឈើចម្រុះពី២ទៅជាង៣ម៉ឺនដើម។

ទន្ទឹមនឹងនោះ សម្រាប់ប្រជាពលរដ្ឋដែលមានបំណងស្នើសុំកូនឈើយកទៅដាំ សូមធ្វើការទំនាក់ទំនងទៅកាន់ស្នាក់ការអាជ្ញាធរជាតិអប្សរា ហើយរយៈពេលមួយសប្តាហ៍ពួកគេនឹងទទួលបានកូនឈើយកទៅដាំ។ អាជ្ញាធរជាតិអប្សរា សូមលើកទឹកចិត្តដល់ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់រូប យកកូនឈើទៅដាំនៅតាមសាលារៀន វត្តអារាម និងនៅក្នុងសហគមន៍ ដើម្បីបង្កើនគម្របព្រៃឈើក្នុងប្រទេសកម្ពុជា។

គួរបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាមានស្ថានីយ៍បណ្តុះកូនឈើចំនួន៤ទីតាំង ទី១ គឺស្ថានីយបណ្តុះកូនឈើ៨ហិកតា ដែលបណ្តុះកូនឈើប្រណិត៤ប្រភេទ មានដើមបេង គ្រញូង ប្រេះ និងធ្នង់ ទី២ ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ ដែលបណ្តុះប្រភេទកូនឈើលេខ១ លេខ២ លេខ៣ និងក្រៅលំដាប់ថ្នាក់ ទី៣ ស្ថានីយបណ្តុះកូនឈើមណ្ឌល៣ ដែលបណ្តុះប្រភេទឈើលម្អ និងប្រភេទឈើហូបផ្លែព្រៃ និងទី៤ ស្ថានីយបាទ្បុង បណ្តុះ ថែទាំ និងផ្សាំកូនឈើបន្លែគ្រប់ប្រភេទ។ ក្នុងឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរាគ្រោងដាំកូនឈើនិងចែកចាយកូនឈើប្រមាណ១១ម៉ឺនដើម៕

សប្ដាហ៍ទី១នៃខែឧសភា ក្រុមការងារសហគមន៍អនុញ្ញាតឱ្យប្រជាពលរដ្ឋជួសជុលផ្ទះ និងសាងសង់សំណង់តូចតាច ចំនួន២៩គ្រួសារ

ផ្សាយនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០២០

របាយការណ៍របស់លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា សប្ដាហ៍ទី១ ខែឧសភា ឆ្នាំ២០២០ បង្ហាញថា ក្រុមការងារសហគមន៍ បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យ និងដោះស្រាយសំណើស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចតាមភូមិទាំង១១២ភូ មិ ក្នុងតំបន់ឧទ្យានអង្គរ ដោយអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន២៩គ្រួសារ។

ករណីអនុញ្ញាតសំណើខាងលើផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកអង្គរធំចំនួន០៥គ្រួសារ ស្រុកពួកចំនួន ១៣គ្រួសារ ស្រុកបន្ទាយស្រីបានចំនួន ០៥គ្រួសារ និងក្រុងសៀមរាបចំនួន ០៦គ្រួសារ សរុប២៩គ្រួសារ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១.ការជួសជុលផ្ទះ៖ ការជួសជុលឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ ប្តូរឬតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ។ ២.សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូក ជង្រុកស្រូវ តូបឬរោងលក់ដូរមុខផ្ទះ។ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។ រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

ក្រុមការងារសហគមន៍តែងតែបានចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ៕

លោកជំទាវ ភឿង សកុណា អញ្ជើញពិនិត្យការជួសជុលប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានអញ្ជើញត្រួតពិនិត្យការដ្ឋានជួសជុលប្រាសាទតាព្រហ្ម ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរានិងស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI)។

ក្នុងឱកាសនោះ អ្នកជំនាញឥណ្ឌាបានពន្យល់លោកជំទាវអំពីគម្រោងជួសជុលខ្លោងទ្វារខាងកើតនាពេលខាងមុខដ៏ខ្លី ព្រមទាំងដំណើរការរីកចម្រើននៃការងារជួសជុលសាលរបាំប្រាសាទតាព្រហ្ម។

ឆ្លៀតក្នុងឱកាសនោះ **លោកជំទាវ ភឿង សកុណា** បានសម្តែងនូវការកោតសរសើរចំពោះកិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដែលបានបំពេញភារកិច្ចបានយ៉ាងល្អប្រសើរ ជាពិសេសាទរចំពោះលទ្ធផលដែលសម្រេចបាននាពេលកន្លងមក។ ជាមួយគ្នានេះដែរ លោកជំទាវក៏បានឱ្យអនុសាសន៍ដល់ក្រុមការងារឱ្យយកចិត្តទុកដាក់ ឱ្យក្រុមការងារត្រូវគោរពតាមយ៉ាងខ្ជាប់ខ្ជួននូវអនុសាសន៍ដែលអ្នកជំនាញការអាយស៊ីស៊ី-អង្គរបានផ្តល់ជូន៕

លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន អញ្ជើញពិនិត្យការវិវត្តនៃដំណើរការជួសជុលនៅប្រាសាទកណ្តាលស្រះស្រង់

ផ្សាយនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០២០

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច អមដំណើរដោយលោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប និង

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានអញ្ជើញមកពិនិត្យការវិវត្តនៃដំណើរការជួសជុលនិងប្រារព្ធពិធីបួងសួងសុំសេចក្តីសុខចម្រើនពីវត្ថុស័ក្តិសិទ្ធិនៅទីនោះ និងសូមឱ្យដំណើរការជួសជុលប្រាសាទបានសម្រេចជោគជ័យ ប្រជាជនកម្ពុជាបានចាកផុតពីជំងឺកាចសាហាវ និងសូមឱ្យកម្ពុជាសម្បូរសប្បាយរុងរឿងដូចបុរាណកាល។

ក្នុងឱកាសនេះដែរ ក្រុមការងារអាជ្ញាធរជាតិអប្សរាប្រចាំការដ្ឋានជួសជុលក៏បានជម្រាបជូនលោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រីនិងថ្នាក់ដឹកនាំទាំងអស់នូវដំណើរការជួសជុលនិងលទ្ធផលដែលប្រទះឃើញក្នុងកំណាយស្រាវជ្រាវបុរាណវិទ្យារួមមានរចនាសម្ពន្ធសំណង់ប្រាសាទ ចម្លាក់សត្វអណ្តើក ចម្លាក់ក្បាលនាគ ខ្វាតព័ណស (គ្រីស្តាល់?) និងត្រីសូល៍។

លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអាជ្ញាធរជាតិអប្សរាដែលបានចំណាយកម្លាំងកាយ ប្រាជ្ញា ស្មារតី លើកស្ទួយការអភិរក្សបេតិកភណ្ឌវប្បធម៌ខ្មែរដែលជាមរតករបស់មនុស្សជាតិឱ្យកាន់តែបានល្អប្រសើរ និងឋិតថេរចីរកាលតរៀងទៅ៕

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី អញ្ជើញពិនិត្យសមិទ្ធផលនៃការអភិរក្សសំណង់ព្រះវិហារដ៏ចំណាស់នៅវត្តរាជបូណ៌

ផ្សាយនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០២០

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច អមដំណើរដោយលោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ បានអញ្ជើញពិនិត្យសមិទ្ធផលនៃការអភិរក្សសំណង់ព្រះវិហារដ៏ចំណាស់នៅវត្តព្រះរាជបូណ៌ ដែលព្រះវិហារនេះត្រូវបានអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលកែលម្អនាពេលកន្លងមក។

ព្រះវិហារដ៏ចំណាស់នេះបានរងភាពទ្រុឌទ្រោមតាមសម័យកាល ទើបនឹងបានក្រុមអ្នកជំនាញខាងផ្នែកអភិរក្សធ្វើការជួសជុលដំបូល កែលម្អសសរ លាងសំអាតបដិមា រូបគំនូរបុរាណតាមជញ្ជាំង និងហោជាង។

ឆ្លៀតក្នុងឱកាសនោះដែរ លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ក៏បានអញ្ជើញចូលក្រាបថ្វាយបង្គំ និងសួរសុខទុក្ខ **ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម** ព្រះរាជាគណៈថ្នាក់ទោ សមាជិកថេរសភាសង្ឃ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ដែរ៕

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបពិភាក្សាស្តីពី ស្រូបទាញភ្ញៀវទេសចរជាតិដើម្បីជួយប៉ះប៉ូវដល់អាជីវកម្មទេសចរណ៍ ដែលកំពុងរងផលប៉ះពាល់ដោយសារកូវីដ-១៩

ផ្សាយនៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០

ស្របពេលដែលវិបត្តិនៃជំងឺកូវីដ១៩ កំពុងបន្តជះឥទ្ធិពលយ៉ាងអាក្រក់ដល់ដំណើរការអាជីវកម្មនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា វិស័យសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងសេវាដឹកជញ្ជូនជាដើម គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបបានដាក់ចេញនូវផែនការគន្លឹះមួយចំនួនទាក់ទាញភ្ញៀវទេសចរជាតិមកទស្សនានៅខេត្តសៀមរាប ដើម្បីជួយជ្រោមជ្រែងដល់អ្នកពាក់ព័ន្ធនឹងវិស័យទេសចរណ៍។

យន្តការគន្លឹះដែលគណៈកម្មការគ្រោងដាក់ចេញ ដើម្បីទាក់ទាញទេសចជាតិមានដូចជា ជំរុញឲ្យបណ្តាស្រុក ជាពិសេស ស្រុកដែលមានសក្តានុពលទេសចរណ៍ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវគោលដៅទេសចរណ៍របស់ខ្លួនតាមរយៈមធ្យោបាយងាយៗដូចជាបណ្តាញហ្វេសបុកជាដើម ការជំរុញឲ្យមានកម្មវិធីទេសចរណ៍ខ្នាតតូចដូចជា បោះតង់ ជិះកង់កម្សាន្ត ការរៀបចំសម្អាតបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ និងស្តង់ដារចំណីអាហារដែលធានាសុវត្ថិភាពដល់អ្នកប្រើប្រាស់ជាដើម។

នាកិច្ចប្រជុំស្វែងរកយន្តការទាក់ទាញភ្ញៀវទេសចរជាតិ ព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ នៅសាលាខេត្តសៀមរាប **ឯកឧត្តម ពៅ ពិសិដ្ឋ** អភិបាលរងខេត្តសៀមរាប និងជាតំណាងឯកឧត្តមអភិបាលខេត្តសៀមរាប បានថ្លែងថា ស្ថានភាពបច្ចុប្បន្នយើងមិនអាចរង់ចាំភ្ញៀវទេសចរអន្តរជាតិនោះទេ តែត្រូវរិះរកវិធីសាស្ត្រយ៉ាងណាឲ្យភ្ញៀវជាតិមកទស្សនាតំបន់ទេសចរណ៍ឲ្យបានច្រើន។ ទោះមិនអាចជំនួសភ្ញៀវទេសចរអន្តរជាតិបាន តែភ្ញៀវទេសចរជាតិអាចជួយជំរុញឲ្យសេវាកម្មទេសចរណ៍នានាឲ្យដំណើរការបានមួយចំនួនផងដែរ។

ឯកឧត្តម សុខ សង្វារ អគ្គនាយករង និងជាអនុប្រធានគណៈកម្មការបានគាំទ្រនូវយន្តការដែលអង្គប្រជុំបានលើកឡើង ដើម្បីជំរុញឲ្យចលនាទេសចរណ៍ក្នុងចំណោមភ្ញៀវជាតិ។ ទោះជាយ៉ាងណាឯកឧត្តមបានក្រើនរំឭកដល់អង្គប្រជុំអំពីការរៀបចំព្រឹត្តិការណ៍ទេសចរណ៍គឺត្រូវគិតគូរដល់ការបង្ការពីការរីករាលនៃជំងឺកូវីដ១៩ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដោយសារតែជំងឺនេះមិនទាន់ស្ងប់ស្ងាត់ទាំងស្រុងនោះទេ។

ជាមួយគ្នានេះ ឯកឧត្តម ក៏បានជំរុញឲ្យបង្កើតក្រុមការងារតូចមួយក្នុងចំណោមគណៈកម្មការនេះ ដើម្បីសិក្សាស្រាវជ្រាវបទពិសោធន៍ពីបណ្តាប្រទេសផ្សេងៗ ដែលគេបានរៀបចំឡើងក្នុងវិបត្តិកូវីដនេះដែរ។ ជាពិសេស ឆ្លៀតឱកាសប្រែក្លាយបញ្ហានេះទៅជាឱកាសដើម្បីរៀបចំគោលដៅទេសចរណ៍របស់យើង ដូចជា បញ្ហាបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលបុគ្គលិកមគ្គុទ្ទេសក៍ទេសចរណ៍ជាដើម៕

មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន២០រូប បានទទួលវគ្គបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសនៃការប្រើប្រាស់ Drone

ផ្សាយនៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២០

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលស្តីពីរ "ជំនាញនិងបច្ចេកទេសនៃការប្រើប្រាស់ Drone" ដល់មន្ត្រី-បុគ្គលិកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរាចំនួន២០រូប មកពីនាយកដ្ឋានជំនាញផ្សេងៗគ្នា រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។

វគ្គបណ្តុះបណ្តាលនេះបង្រៀនដោយ លោក រ៉ម វិចិត្រ និងលោក ជារ ប៊ុនថង ជាមន្ត្រីបច្ចេកទេសបម្រើការងារនៅនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា ដើម្បីពង្រឹងសមត្ថភាពនិងចំណេះដឹងដល់មន្ត្រី-បុគ្គលិកច្ចេកទេស លើការងារគ្រប់គ្រងបេតិកភណ្ឌ ដោយប្រើប្រាស់ឧបករណ៍បច្ចេកទេសជំនួយ ជួយសម្រួលដល់ការងារឱ្យកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័សតាមទិសដៅរបស់នាយកដ្ឋាន/អង្គភាពរបស់ខ្លួន។

វគ្គបណ្តុះបណ្តាលនេះ ផ្តោតទៅលើរបៀបវារៈសំខាន់ៗ ដូចជា សេចក្តីណែនាំទូទៅអំពី Drone អនុវត្តន៍ការបង្ហោះ Drone នៅក្នុង Plan Mode ការបង្កើតផែនទី 2D ដោយប្រើរូបថតពី Drone មូលដ្ឋានទ្រឹស្តីនៃការបង្ហោះ Drone នៅក្នុង Manuel Mode អនុវត្តន៍ការបង្ហោះ Drone នៅក្នុង Manuel Mode ការបង្កើត 3D object ដោយប្រើរូបថតពី Drone សំណួរ ចម្លើយ និងក្រៅពីការសិក្សាទ្រឹស្តីនៅក្នុងថ្នាក់រៀន សិក្ខាកាមទាំងអស់នឹងចុះអនុវត្តការប្រើប្រាស់ Drone ជាក់ស្តែងនៅលើទីតាំងផ្ទាល់។

មានប្រសាសន៍ក្នុងថ្ងៃបិទវគ្គបណ្តុះបណ្តាល **ឯកឧត្តម ជុំ សុតមករា** បានអបអរសាទរដល់សិក្ខាកាមទាំង២០រូប ដែលបានបញ្ចប់វគ្គសិក្សានេះប្រកបដោយជោគជ័យ ទាំងទ្រឹស្តីនិងការអនុវត្តន៍។ ឯកឧត្តមក៏បានសំណូមពរដល់សិក្ខាកាមទាំងអស់សូមប្រើនូវចំណេះដឹងទាំងនេះឱ្យចំគោលដៅ និងតួនាទី ក្នុងការបំពេញភារកិច្ចជូនដល់នាយកដ្ឋាន/អង្គភាព ឱ្យបានរីកចម្រើន៕

លោកជំទាវ ភឿង សកុណា អញ្ជើញពិនិត្យការកែលម្អផ្លូវនៅប្រាសាទបាគង

ផ្សាយនៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២០

លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាបានអញ្ជើញត្រួតពិនិត្យវឌ្ឍនភាពនៃការជួលជុលកែលម្អផ្លូវប្រាសាទបាគង ដែលភ្ជាប់ពីផ្លូវជាតិលេខ៦ កាត់តាមប្រាសាទព្រះគោ ឆ្ពោះទៅជុំវិញប្រាសាទបាគង ។

ផ្លូវនេះមានប្រវែង ២.៧៨១ ម៉ែត្រ ទទឹង ៥-៦ ម៉ែត្រ ហើយនឹងត្រូវអ៊ិតបេតុងកៅស៊ូ (AC) កម្រាស់ ៦ ស.ម . ចែកជាពីរស្រទាប់ (ស្រទាប់ក្រោមពណ៌ខ្មៅ និងស្រទាប់លើពណ៌ក្រហមចាស់) ដើម្បីឱ្យសមស្របតាមបទដ្ឋានបេតិកភណ្ឌពិភពលោក។



ឆ្លៀតក្នុងឱកាសនោះ លោកជំទាវរដ្ឋមន្ត្រី បានណែនាំឱ្យក្រុមហ៊ុនអនុវត្ត និងអ្នកបច្ចេកទេសរបស់អាជ្ញាធរជាតិអប្សរាត្រូវយកចិត្តទុកដាក់ខ្ពស់អនុវត្តតាមស្តង់ដារបច្ចេកទេស និងអនុសាសន៍របស់អ្នកជំនាញការអន្តរជាតិអាយស៊ីស៊ី-អង្គរ ព្រោះថាផ្លូវនេះមានសារៈសំខាន់ ណាស់ ដែលនឹងបម្រើនូវផលប្រយោជន៍បងប្អូនប្រជាពលរដ្ឋដែលរស់នៅតំបន់ប្រាសាទបាគង និងសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ៕

ប្រជាជនក្នុងឧទ្យានអង្គរចំនួន១៥០គ្រួសារ ត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន

ផ្សាយនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០២០

តាមរបាយការណ៍របស់នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ចាប់ពីថ្ងៃទី៧ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ក្រុមការងារបានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋដែលសាងសង់លំនៅដ្ឋានចំនួន១៥០គ្រួសារនៅក្នុងឧទ្យានអង្គរ។

លំនៅដ្ឋានទាំង១៥០ គ្រួសារនោះមាននៅក្រុងសៀមរាបចំនួន២៣គ្រួសារ ស្រុកប្រាសាទបាគងចំនួន៣២គ្រួសារ ស្រុកបន្ទាយស្រីចំនួន០៥គ្រួសារ ស្រុកពួកចំនួន៥៤គ្រួសារ និងស្រុកអង្គរធំ បានចំនួន៣៦គ្រួសារ។

ក្នុងរយៈពេលមួយសប្តាហ៍ដើមខែឧសភានេះដែរ ក្រុមការងារនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋាន ក៏បានទទួលពាក្យស្នើសុំសាងសង់ថ្មីនិងជួសជុលតូចតាចចំនួន ៣០ករណី ហើយក្រុមការងារជំនាញក៏កំពុងចុះពិនិត្យផ្ទៀងផ្ទាត់ពីលក្ខខណ្ឌផ្សេងៗទាក់ទងនឹងការកាន់កាប់ ការរស់នៅ និងស្ថានភាពទីតាំងស្នើសុំដាក់ស្តែង។

ក្នុងកិច្ចការចុះពិនិត្យនេះនាយកដ្ឋានសម្រេចបាន១៥ករណី។ ចំពោះប្រជាពលរដ្ឋម្ចាស់សំណើណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មក៏បានជួយសម្រួលនិងរៀបចំគំនូសប្លង់ជូនពួកគាត់បាន៤ករណីដែរ។

ក្រុមការងារព្រៃឈើ បាន និងកំពុងកាត់សម្អាតគល់ឈើពុកផុយ និងក្រីមែកឈើ ដែលមានហានិភ័យខ្ពស់ក្នុងបរិវេណប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២០

ឆ្លើយតបតាមអនុសាសន៍របស់អ្នកជំនាញនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់អង្គរ (ICC-Angkor) ក្នុងកិច្ចប្រជុំពេញអង្គលើកទី២៦ និងប្រជុំបច្ចេកទេសលើកទី៣៣ និងតាមការអង្កេតយ៉ាងយកចិត្តទុកដាក់ពីក្រុមគ្រប់គ្រងហានិភ័យដើមឈើរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បាន និងកំពុងមមាញឹកក្នុងការងារកាត់ដក

ហូតដើមឈើងាប់ គល់ឈើពុកផុយ និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់មកលើប្រាសាទតាព្រហ្មចំនួន ១៣ដើម។ ដើមឈើទាំងនោះរួមមាន ដើមស្ពង់១ដើម ដុះកោងទ្រេតខ្លាំងនៅលើកំពែងប្រាសា ទ ត្រូវកាត់ពាក់កណ្ដាលដើមចេញ គល់ស្ពង់ពុកផុយចំនួន៤កន្លែង ដើមក្រឡាញ់១ដើម ដើមពភ្លា១ដើម និងដើមស្ពង់តូច១ដើមដែលដុះនៅលើកំពែងប្រាសាទក៏ត្រូវកាត់យកចេញ។ ជាមួយគ្នានោះក្រុមការងារនឹងធ្វើការកាត់ក្រី ដើមឈើចំនួន៥ដើម ដែលមានមែកចំនួន៩ត្រូវយកចេញ ក្នុងនោះមានដើមស្ពង់ ចំបក់ ត្រាង ត្រសេក និងពភ្លាប្រើស។

ការងារទាំងនេះ ធ្វើឡើងក្នុងបំណងដើម្បីបង្កភាពងាយស្រួលក្នុងការជួសជុលប្រាសាទ បង្កើតឲ្យមានសោភ័ណភាពប្រសើរជាងមុន ជួយសម្រាលតួដើមកុំឲ្យដួលរលំ ជាពិសេសបង្ការផលប៉ះពាល់ខ្លាំងដល់រចនាសម្ព័ន្ធថ្មកំពែងប្រាសាទ នៅពេលដែលដើមរបស់វាដុះលូតលាស់កាន់តែធំទៅៗ និងរួមចំណែកក្នុងការធានាដល់សុវត្ថិភាពជូនភ្ញៀវទេសចរជាតិ-អន្តរជាតិ ដែលមកទស្សនាប្រាសាទនេះផង។ ការងារនេះអាចនឹងប្រើរយៈពេលយូរ ព្រោះត្រូវប្រើរន្ទារដើម្បីតម្លើងកាត់ដោយសារដើមខ្លះមានកំពស់ខ្ពស់ និងដុះកៀកនឹងប្រាសាទ។

អាជ្ញាធរជាតិអប្សរាធ្វើពិធីយោងបំណែកព្រះពុទ្ធបដិមាចេញពីរណ្ដៅកំណាយមកសិក្សាជួសជុលបន្ត

ផ្សាយនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២០

ពិធីយោងបំណែកព្រះពុទ្ធបដិមាក្នុងរណ្ដៅកំណាយមុខថែវព្រះរយព្រះពាន់នៅប្រាសាទអង្គរវត្ត ត្រូវបានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្ដម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងក្រុមការងារកំណាយ នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០។

ការយោងបំណែកព្រះពុទ្ធបដិមាទាំងអស់ចេញពីរណ្ដៅកំណាយ គឺដើម្បីសិក្សាផ្គុំរូបរាង ជួសជុលអភិរក្ស និងលើកតម្លៃវត្ថុបុរាណ ព្រមទាំងទុកលទ្ធភាពឱ្យអ្នកជំនាញកំណាយស្រាវជ្រាវបុរាណវិទ្យាបញ្ចប់ការងារកំណាយ។

តាមការបញ្ជាក់របស់ឯកឧត្ដមអគ្គនាយកបដិមា១អង្គដែលមានរូបរាងពេញលេញជាងគេ នឹងត្រូវជួសជុលសម្អាត ហើយដាក់សំណើសុំអនុសាសន៍ពីគណៈកម្មការអាយស៊ីស៊ី-អង្គរ ដើម្បីយកទៅដាក់នៅទីតាំងដើម ព្រោះគេបានស្គាល់ច្បាស់ថាបំណែកព្រះពុទ្ធបដិមាទាំងអស់ មានប្រភពនៅថែវព្រះរយព្រះពាន់ ដែលមានកាលបរិច្ឆេទប្រហែលស្ថិតក្នុងសម័យកណ្ដាល។

បំណែកព្រះពុទ្ធបដិមាដែលបានរកឃើញមានចំនួន១០៥ ក្នុងនោះពុទ្ធបដិមាមានរូបមិនពេញលេញមាន៣៥អង្គ និង ១អង្គមានរូបរាងពេញលេញជាងគេ សន្លឹកសីមា១ រួមនឹងបំណែកតូចៗចំនួន១៨០ផងដែរ៕

អាជ្ញាធរជាតិអប្សរាបន្តរៀបចំទេសភាពបរិស្ថានមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាកំពុងរៀបចំកែលម្អផ្លូវថ្នល់ ផ្លូវដើរ សួនច្បារកន្លែងបដិសណ្ឋារកិច្ចនិងផ្តល់សេវាកម្មកម្រិតអន្តរជាតិនៅបរិវេណមុខប្រាសាទអង្គរវត្តជាបណ្តើរៗ។

នាព្រឹកថ្ងៃពុធ ទី២០ ខែឧសភា ឆ្នាំ២០២០ នេះ អាជ្ញាធរជាតិអប្សរាបានសម្រេចរុះរើរោងឈើប្រក់ក្បឿងមួយខ្នងនៅក្បែរត្រពាំងសេះដែលរងការខូចខាតដើម្បីប្រែក្លាយទីតាំងធ្វើជាវាលស្មៅនិងសួនឈើប្រណីត សម្រាប់ជាប្រយោជន៍សាធារណជន និងភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងការដើរកម្សាន្ត ព្រមទាំងលើកគុណតម្លៃរណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា គម្រោងរួមនៅមុខអង្គរវត្តនឹងបញ្ចប់ទាំងស្រុងមុនដំណាច់ឆ្នាំ២០២០នេះ៕

អាជ្ញាធរជាតិអប្សរាលើកទឹកចិត្តព្រះសង្ឃវត្តកេតកន្យារាមអភិរក្សសំណង់ពុទ្ធសាសនាបែបបុរាណ

ផ្សាយនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យព្រះចៅអធិការវត្តកេតកន្យារាម ដែលស្ថិតនៅខាងក្រោយប្រាសាទបន្ទាយក្តីសាងសង់សំណង់ព្រះវិហារព្រះពុទ្ធសាសនាថ្មី ធ្វើអំពីឈើបែបបុរាណ នៅលើខឿនបេតុងមួយជាន់ ហើយគូសប្លង់ប្រគេនដោយឥតគិតថ្លៃ តាមការស្នើសុំ ក្រោយពិនិត្យឃើញថា ព្រះវិហារចាស់មានសភាពទ្រុឌទ្រោមខ្លាំង។

ការអនុញ្ញាតនេះ ក្នុងបំណងអភិរក្សសំណង់ស្ថាបត្យកម្មវត្តបុរាណដែលប្រឈមនឹងការបាត់បង់ឱ្យសម្បូរបែបឡើងវិញ ដើម្បីបំពេញតួនាទីស្របតាមតម្រូវការនៃការប្រើប្រាស់របស់ពុទ្ធសាសនិក ការរក្សាបាននូវទម្រង់សំណង់សាសនាបែបបុរាណខ្មែរ ដែលបង្ហាញអំពីវប្បធម៌ជាតិក្នុងការរួមចំណែកទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិផង។

ទាក់ទងនឹងកិច្ចការអភិរក្សសំណង់សាសនាបែបបុរាណ ក្រុមការងារកិច្ចការវត្តអារាមនៃអាជ្ញាធរជាតិអប្សរា តែងតែចុះពិនិត្យការសាងសង់ជាប់ជានិច្ច ដើម្បីឱ្យស្របតាមលក្ខណៈបច្ចេកទេស និងប្លង់ស្ថាបត្យកម្មបែបបុរាណខ្មែរ។ គិតមកដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០នេះ ការសាងសង់សំណង់ព្រះវិហារថ្មីនេះ បានរួចរាល់ប្រមាណ៣៥% ហើយ។ ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងនៅតែបន្តចុះពិនិត្យ រហូតដល់ការសាងសង់បានរួចរាល់១០០% ចៀសវាងកំហុសឆ្គងផ្សេងៗនៃការសង់សង់៕



អាជ្ញាធរជាតិអប្សរាលើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឧទ្យានអង្គរសង់លំនៅដ្ឋានគំរូខ្មែរបុរាណ

ផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាបានលើកទឹកចិត្តប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ឧទ្យានអង្គរឱ្យចាប់អារម្មណ៍និងការសាងសង់លំនៅដ្ឋានតាមគំរូផ្ទះខ្មែរបុរាណ។ ទាំងនេះគឺ ដើម្បីរួមចំណែកថែរក្សាទំនៀមទម្លាប់ ប្រពៃណីពីបុរាណ ការពារទេសភាពវប្បធម៌ ព្រមទាំងជួយលើកគុណតម្លៃមណ៌យដ្ឋានប្រវត្តិសាស្ត្រអង្គរ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកផង។

អនុប្រធាននាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ លោក ស៊ឹម ប៊ុនធឿន មានប្រសាសន៍ថា រាល់ពលរដ្ឋ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការអនុញ្ញាត មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនិងចុះដល់ទីតាំងសាងសង់ផ្ទាល់ដើម្បី ជួយផ្តល់ជាបច្ចេកទេសក្នុងការសង់លំនៅដ្ឋាន ដើម្បីឱ្យសមស្របតាមគំរូផ្ទះបែបខ្មែរ។

លោកបញ្ជាក់ទៀតថា ផ្ទះខ្មែរជាប្រភេទសំណង់ស្រាល ដែលងាយស្រួលសាងសង់ មិនតម្រូវឱ្យជីកដី ឬជីកគ្រឹះ ដែលអាចមានការប៉ះពាល់ដល់បុរាណវត្ថុដែលកប់ក្នុងដីឡើយ។ ចំណែកសោភ័ណ្ឌភាពមានតម្លៃសម្រាប់ទេសភាពវប្បធម៌។ ផ្ទះខ្មែរមានលក្ខណៈចំហនៅផ្នែកខាងក្រោមសម្រាប់ខ្យល់បក់ចេញចូល ដាក់សម្ភារកសិកម្ម ចងគោ ក្របី ចិញ្ចឹមសត្វផ្សេងៗ ហើយមនុស្សរស់នៅក្រោមផ្ទះជាប្រចាំនៅពេលថ្ងៃ ជាន់ខាងលើសម្រាប់សម្រាកនៅពេលយប់។ «ខ្មែរយើងមិនសាងសង់ផ្ទះតៀមទេ។ ការសាងសង់ផ្ទះបែបនេះ វាសមស្របទៅនឹងលក្ខខណ្ឌអាកាសធាតុក្តៅ កត្តាជីវភាពរស់នៅ និងជំនឿ»។

តាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ប្រភេទគំរូផ្ទះដែលគេតែងឃើញប្រជាពលរដ្ឋខ្មែរសាងសង់មានដូចជា៖ ផ្ទះប៉ិត ផ្ទះរោងដោល ផ្ទះរោងឌឿង និង ផ្ទះកន្តាំងជាដើម។

បច្ចុប្បន្ននេះ បើទោះបីជាវិទ្យាសាស្ត្រផ្នែកសំណង់បានរីកចម្រើនខ្លាំងក៏ពិតមែន ប៉ុន្តែប្រជាជនខ្មែរភាគច្រើន តែងនិយមសង់ផ្ទះសំបែងរបស់ខ្លួនតាមគំរូក្បូនខ្នាតពីបុព្វបុរសខ្មែរដដែល គ្រាន់តែការវិវឌ្ឍផ្លាស់ប្តូរសម្ភារសំណង់មួយចំនួនដើម្បីកាត់បន្ថយពីការប្រើប្រាស់ឈើច្រើនមកឈើតិចឬជំនួសដោយថ្ម ឥដ្ឋ ដែក ស្មាតបត (Smart board wall) ទៅវិញ។ សម្ភារទំនើបទាំងអស់ នេះថ្វីត្បិតជាសម្ភារទំនើបមែន ក៏ប៉ុន្តែវាអាចយកមកប្រើប្រាស់ការសាងសង់សំណង់ហើយ បង្ហាញពីអត្តសញ្ញាណផ្ទះខ្មែរ។

អ្នកស្រី ឃឿន សុខា ជាអ្នកភូមិគោកបេង សង្កាត់គោកចក ក្រុងសៀមរាប មានប្រសាសន៍ថា គាត់បានស្នើសុំលក្ខណៈបច្ចេកទេសពីអាជ្ញាធរជាតិអប្សរា ដើម្បីសាងសង់ផ្ទះបែបខ្មែរបុរាណដោយប្រើសម្ភារទំនើបដូចជា ដែក ស្មាតបូត ដែលចំណាយអស់ថវិកាតិចជាងសម្ភារធ្វើពីឈើ តែរក្សារូបរាងជាផ្ទះបែបខ្មែរដដែល។ ស្ត្រីដដែលបញ្ជាក់ទៀតថា ការសាងសង់ផ្ទះបែបខ្មែរដូច្នេះងាយស្រួល រស់នៅជាងផ្ទះតៀម ថែមទាំងបានចូលរួមចំណែកថែរក្សាទេសភាពវប្បធម៌ និងលើកគុណតម្លៃបេតិកភណ្ឌជាតិផង។ អ្នកស្រីក៏ចង់ឱ្យពលរដ្ឋដែលកំពុងរស់នៅក្នុងឧទ្យានអង្គរ រើសយកការសង់ផ្ទះ បែបខ្មែរបុរាណទាំងអស់គ្នា៕

សេចក្តីជូនដំណឹងស្តីពីការបើកឲ្យដំណើរការឡើងវិញសារមន្ទីរទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយមិនគិតថ្លៃ

ផ្សាយនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

APSARA
លេខ ...

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឱ្យដំណើរការឡើងវិញសារមន្ទីរទាំងបី
ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដោយមិនគិតថ្លៃ

អនុលោមតាមលិខិតលេខ០៩៦សខល ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញនូវសារមន្ទីរនានាជូនភ្ញៀវជាតិ និងអន្តរជាតិបានចូលទស្សនា អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរា នឹងបើកឱ្យដំណើរការឡើងវិញ ជូនភ្ញៀវជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ បានចូលទស្សនា ដោយមិនគិតថ្លៃ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ នេះតទៅ នៅសារមន្ទីរទាំងបីរបស់អាជ្ញាធរជាតិអប្សរារួមមាន៖

១- សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ
២- សារមន្ទីរវាយនកណ្ឌប្រពៃណីអាស៊ី
៣- សារមន្ទីរឡូតានី

ជាមួយគ្នានេះដែរ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលទប់ស្កាត់រលកទីពីរនៃការចម្លងជម្ងឺកូវីដ-១៩ អាជ្ញាធរជាតិអប្សរា នឹងបន្តអនុវត្តនូវវិធានការការពារនានាដូចជា ស្ទែនកំដៅ ប្រើប្រាស់អាល់កុល ឬដែលលាងដៃ និងស្នើសុំឱ្យភ្ញៀវជាតិ និងអន្តរជាតិ រួមជាមួយមន្ត្រី-បុគ្គលិក ដែលបំពេញការងារនៅសារមន្ទីរពាក់ម៉ាស់ ព្រមទាំងរៀបចំឱ្យមានគម្លាតសុវត្ថិភាព មុននឹងចូលទស្សនាសារមន្ទីរទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ដើម្បីការពារហានិភ័យនៃការចម្លងជម្ងឺកូវីដ-១៩នេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ...ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
សៀមរាប ថ្ងៃទី... ខែ... ឆ្នាំ២០២០

ភ្នំពេញ:
អគារលេខ៤៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៨៧១/ ០២៣ ២១៥ ៧៨៦

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

អាជ្ញាធរជាតិអប្សរាចាប់ផ្តើមអ៊ុតគំនូសចរាចរណ៍ និងដាំឧបករណ៍ចំណាំងភ្លើង ចាប់ពីរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ដល់មុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០២០

នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងអន្តរវិស័យ របស់អាជ្ញាធរជាតិអប្សរា កំពុងចាប់ផ្តើមអ៊ុតគំនូសចរាចរណ៍នៅលើកំណាត់ទ្រូងផ្លូវប្រវែង២១៨១ម៉ែត្រ ចាប់ពីរង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ មកដល់ចំណុចព្រលានយន្តហោះ និងកំពុងដាំឧបករណ៍ចំណាំងភ្លើង(គ្រាប់ភ្នែកកង្កែប)លើកំណាត់ទ្រូងផ្លូវប្រវែង៦៧១២ម៉ែត្រទៀត ចាប់ពីចំណុចមុខភោជនីយដ្ឋានប្រាសាទនាងពៅទៅដល់ចំណតឡាន មុខប្រាសាទអង្គរវត្ត។

ការងារនេះធ្វើឡើងដើម្បីជាប្រយោជន៍ឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលនិងឃើញច្បាស់អំពីគំនូសចរាចរណ៍សម្រាប់ធ្វើដំណើរបានងាយស្រួល ព្រមទាំងអាចបញ្ចៀសបានរាល់គ្រោះថ្នាក់ក្នុងពេលដែលយានយន្តគ្រប់ប្រភេទធ្វើដំណើរ ព្រមទាំងផ្តល់ភាពងាយស្រួលដល់អ្នកទេសចរផងដែរ។

ការចាប់ផ្តើមធ្វើគំនូស និងដាក់ចំណាំងភ្លើងនៅលើទ្រូងផ្លូវនេះ ចាប់ពីផ្លូវជាតិលេខ៦ត្រង់រង្វង់មូលព្រះបាទជ័យវរ្ម័នទី៧ មកដល់ព្រលានយន្តហោះ ប្រវែង ២១៨១ម៉ែត្រ ពីមុខព្រលានយន្តហោះទៅដល់ភោជនីយដ្ឋានប្រាសាទនាងពៅ ប្រវែង ៩៨៥ម៉ែត្រ និងចាប់ពីភោជនីយដ្ឋានប្រាសាទនាងពៅមកដល់ផ្លូវបំបែកចំណតរថយន្តមុខប្រាសាទអង្គរវត្ត ប្រវែង ៣៥៤៦ម៉ែត្រនោះ ត្រូវបានអាជ្ញាធរជាតិអប្សរាជួសជុលតាំងពីពាក់កណ្តាលខែមករា រហូតមកដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ បានរួចរាល់ជាស្ថាពរមក។

សូមបញ្ជាក់ថា បន្ទាប់ពីបញ្ចប់ការគូសទ្រូងផ្លូវ ចាប់ពីមុខព្រលានយន្តហោះ រហូតមកដល់មុខប្រាសាទអង្គរវត្តរួចរាល់ អាជ្ញាធរជាតិអប្សរានឹងបន្តទៅគូសគំនូសចរាចរណ៍នៅលើផ្លូវពីរកំណាត់ទៀត គឺកំណាត់ផ្លូវ៦០ម៉ែត្រ ចាប់ពីផ្លូវជាតិលេខ៦ មកដល់រង្វង់មូលអប្សរា និងមួយកំណាត់ទៀតចាប់ពីប្រាសាទប្រែរូប ទៅដល់ស្រះស្រង់ទៀតផងដែរ៕

អាជ្ញាធរជាតិអប្សរាចុះពិនិត្យនិងជួយលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋ ចំនួន១២០គ្រួសារក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២០

ប្រជាពលរដ្ឋដែលជាម្ចាស់ស្រុកក្នុងតំបន់អង្គរ តែងទទួលបានការយកចិត្តទុកដាក់ខ្ពស់ពី សំណាក់អាជ្ញាធរជាតិអប្សរា ក្នុងការអនុញ្ញាតជាគោលការណ៍សាងសង់លំនៅដ្ឋានរបស់ខ្លួនក៏ដូចជាសំណង់ឧបសម្ពន្ធមួយចំនួនទៀត។

ជាក់ស្តែងគិតចាប់ពីថ្ងៃទី២០-២៦ ខែឧសភា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបានចុះទៅពិនិត្យ និងជួយលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋបានចំនួន១២០គ្រួសារដូចខាងក្រោម៖

១. ក្រុងសៀមរាប បានចំនួន៣៣គ្រួសារ
២. ស្រុកប្រាសាទបាគង បានចំនួន៥១គ្រួសារ
៣. ស្រុកបន្ទាយស្រី បានចំនួន២៥គ្រួសារ
៤. ស្រុកពួក បានចំនួន១១គ្រួសារ។

ក្រោយបានការអនុញ្ញាតមន្ត្រី-បុគ្គលិកជំនាញរបស់នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ក៏បានចុះទៅដល់ទីតាំងសាងសង់ផ្ទាល់ ដើម្បីពិនិត្យតាមដាននិងផ្តល់នូវលក្ខណៈបច្ចេកទេសដោយពុំគិតប្រាក់ គឺធ្វើយ៉ាងណាឱ្យសំណង់ទាំងនោះ អនុលោមតាមលិខិតអនុញ្ញាត និងគោលការណ៍គ្រប់គ្រងសំណង់លំនៅដ្ឋានក្នុងឧទ្យានអង្គរ ដែលជាសំណង់ស្រាល សង់ខ្ពស់ផុតពីដី ហើយក៏ជាសំណង់បែបប្រពៃណីតពីដូនតាខ្មែរមកដែរ ។

កិច្ចការទាំងនេះ បានធ្វើឱ្យចំនួនសំណង់ដែលមិនមែនជាផ្ទះខ្មែរនិងខុសពីគោលការណ៍បេតិកភណ្ឌនាំឱ្យប៉ះពាល់ដល់តម្លៃឧទ្យានអង្គរ ត្រូវបានថយចុះ ហើយសំណង់បែបប្រពៃណីត្រូវបានលេចរូបរាងឡើងក្នុងឧទ្យានអង្គរជាបន្ត៕

ម្ចាស់ភោជនីយដ្ឋាន ផ្ទះបាយតានីខ្មែរអង្គរ ស្ម័គ្រចិត្តរុះរើសំណង់ប្រគល់ទីតាំង ជូនអាជ្ញាធរជាតិអប្សរា អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ជាលើកទី២

ផ្សាយនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២០

នេះជាលើកទី២ហើយដែលម្ចាស់ភោជនីយដ្ឋាន «ផ្ទះបាយតានីខ្មែរអង្គរ» បានស្ម័គ្រចិត្តរុះរើសំណង់ភោជនីយដ្ឋានចំនួនមួយខ្នងបន្ថែមទៀត ដែលជាអតីតភោជនីយដ្ឋាន «ភ្នំស្រី» ដើម្បីសម្រួលដល់ការសាងសង់ទីលានបដិសណ្ឋារកិច្ចមុខប្រាសាទអង្គរវត្ត នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០នេះ។

លោក ជ្រុន គឹមសេង អាជីករភោជនីយដ្ឋាន «ផ្ទះបាយតានីខ្មែរអង្គរ» ដែលបានជួលទីតាំង ប្រកបរបរជិត៣ឆ្នាំមកហើយបានលើកឡើងថាការរុះរើសំណង់ភោជនីយដ្ឋាននេះ គឺជាការស្ម័គ្រចិត្តដោយមានការសម្របសម្រួលយ៉ាងល្អពីអាជ្ញាធរជាតិអប្សរា ដើម្បីផ្លាស់ប្តូរទៅកាន់ទីតាំងថ្មីដែលល្អប្រសើរជាងមុន ហើយគាត់សប្បាយចិត្តនឹងការចូលរួមចំណែកលើកតម្លៃរមណីយដ្ឋានអង្គរឱ្យមានសណ្តាប់ធ្នាប់ល្អ បរិស្ថានស្អាត និងអភិវឌ្ឍន៍តាមតម្រូវការទេសចរណ៍ ដើម្បីបម្រើជាសាធារណៈ និងជាឱកាសផ្សព្វផ្សាយវប្បធម៌ជាតិទៅកាន់ពិភពលោក ដែលនាំមកនូវផលចំណេញវិជ្ជមានមិនចេះរីងស្ងួតទៅអនាគត។

អគ្គនាយករងអាជ្ញាធរជាតិអប្សរា **ឯកឧត្តម យិត ចាន់ដារដ្ឋ** បានឱ្យដឹងថា មកដល់ពេលនេះមានសំណង់ភោជនីយដ្ឋានចំនួនប្រាំខ្នងហើយដែលបានរុះរើដោយស្ម័គ្រចិត្ត គឺភោជនីយដ្ឋាន chezsophea ៣ខ្នង និងផ្ទះបាយតានីខ្មែរ២ខ្នង។ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះលោក ជ្រុន គឹមសេង ដែលបានស្ម័គ្រចិត្តរុះរើសំណង់ប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ជាលើកទី២ ដើម្បីកែប្រែបរិវេណមុខប្រាសាទអង្គរវត្តផ្នែកខាងលិចឱ្យមានព្រៃឈើ សួនច្បារ កន្លែងលំហែកាយ កន្លែងផ្តល់សេវាកម្ម និងជាកន្លែងបដិសណ្ឋារកិច្ចប្រកបដោយស្តង់ដារអន្តរជាតិប្រកបដោយគុណភាព។

នៅចុងខែសីហា ឆ្នាំ២០២០ ខាងមុខនេះអាជ្ញាធរជាតិអប្សរានឹងបញ្ចប់ការសាងសង់អគារ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធមួយផ្នែកសម្រាប់ឱ្យអាជីវករលក់ដូរដែលផ្លាស់ប្តូរពីទីតាំងមុខប្រាសាទអង្គរវត្ត ឱ្យចូលមកទីតាំងថ្មីដោយឥតបង់ថ្លៃ។ ដំណាក់កាលបន្ទាប់ អាជ្ញាធរជាតិអប្សរានឹងស្វែងរកដំណោះស្រាយល្អៗដល់អាជីវករអនុវត្តគម្រោងរុះរើសំណង់គ្មានសណ្តាប់ធ្នាប់ផ្សេងៗ ហើយអគារថ្មីដែលកំពុងសាងសង់នឹងរួចរាល់ទាំងស្រុងនាចុងឆ្នាំ២០២០នេះ ដើម្បីផលប្រយោជន៍រួមរបស់ប្រជាជនខ្មែរនិងប្រទេសជាតិទាំងមូល៕

ព្រះសុមង្គល សិលាចារ្យ អាភាករោ ជុំ គឹមឡេង ព្រះមេគណខេត្តសៀមរាបសូមឲ្យបញ្ឈប់សកម្មភាពសាងសង់នៅវត្តទេពប្រណម

ផ្សាយនៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២០

នៅរសៀលថ្ងៃពុធ៦កើត ខែជេស្ឋ ឆ្នាំជូតទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០២០ ព្រះសុមង្គល សិលាចារ្យ អាភាករោ ជុំ គឹមឡេង ព្រះមេគណ ខេត្តសៀមរាប និងជាព្រះប្រធានក្រុមប្រឹក្សាកិច្ចការវត្តអារាម រួមនឹងសមាជិក បាននិមន្តចុះទៅដល់វត្តទេពប្រណម ដែលមានទីតាំងនៅក្នុង បរិវេណ ក្រុងអង្គធំ ដើម្បី ពិនិត្យ នូវការរៀបចំសាងសង់ ខឿនជុំវិញព្រះវិហារ និងសំណង់ មួយចំនួនទៀត ដែលកំពុងសាងសង់ដោយគ្មានការអនុញ្ញាត។

ព្រះសុមង្គលសិលាចារ្យអាភាករោព្រះមេគណខេត្តសៀមរាប និងជាព្រះប្រធានក្រុមប្រឹក្សាកិច្ចការវត្តអារាម បានសូមឲ្យវត្តទេព ប្រណម ផ្អាក ការសាងសង់ទាំងនោះសិន ព្រោះការសាងសង់នេះ អាចធ្វើឱ្យប៉ះពាល់ដល់ តម្លៃ នៃរមណីយដ្ឋានអង្គរ ដែលជាបេតិកភណ្ឌពិភពលោក ដោយរង់ចាំក្រុមការងារជំនាញរបស់អាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងវាយតម្លៃជាមុនសិន។

នៅថ្ងៃ ដដែល នេះ ព្រះអង្គ ក៏ បាននិមន្ត ពិនិត្យ មើលការសាងសង់រោងឧបោសថាគារ នៅវត្តព្រះឥន្ទទេព ដែលសាងសង់អំពីឈើ ប្រក់ក្បឿង ដែលបានរចនាប្លង់ និង ការអនុញ្ញាត ពីអាជ្ញាធរជាតិអប្សរាកន្លងមក។

ព្រះអង្គ បានផ្តល់អនុសាសន៍ ដល់គ្រប់វត្តអារាមទាំងអស់ ដែលស្ថិត នៅក្នុងតំបន់ការពារឧទ្យានអង្គរ សូមកុំធ្វើការសាងសង់នូវអ្វីៗទាំងអស់ ដោយពុំមានការអនុញ្ញាត ពីអាជ្ញាធរជាតិអប្សរា ព្រោះធ្វើឱ្យប៉ះពាល់ដល់គុណតម្លៃនៃសម្បត្តិបេតិកភណ្ឌ ដែលជាមរតករបស់ ជាតិយើង ដែលយើងទាំងអស់គ្នាត្រូវការពារ៕

មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា ចំនួន១០០រូប បានទទួល ការបណ្តុះបណ្តាល ស្តីពី “ការរៀបចំដីធ្លី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ”

ផ្សាយនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២០

កាលពីថ្ងៃទី២៦ខែឧសភាឆ្នាំ២០២០មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំដីធ្លី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ" ជូនមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា ចំនួន១០០នាក់ ។

វគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃនេះ បង្រៀនដោយលោក ស៊ឹម ប៊ុនធឿន អនុប្រធាននាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ក្នុងគោលបំណងដើម្បីពង្រីកចំណេះដឹងជូនមន្ត្រី - បុគ្គលិកឱ្យយល់កាន់តែច្បាស់ពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការរៀបចំដីធ្លី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ និងសំណង់លំនៅដ្ឋានខ្មែរ។

នៅក្នុងពិធីបិទវគ្គបណ្តុះបណ្តាល **ឯកឧត្តម ជុំ សុមករា អគ្គនាយករង** ជាតំណាងឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានលើកឡើងថា ដើម្បីអនុវត្តការងាររៀបចំដីធ្លី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរឱ្យបានជោគជ័យ មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាដែលចុះអនុវត្តការងារនេះផ្ទាល់ ត្រូវមានការយល់ដឹងច្បាស់លាស់ពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានា និងត្រូវចេះពន្យល់បងប្អូនប្រជាពលរដ្ឋឱ្យយល់ពីតម្លៃនៃកិច្ចការពារ និងអភិរក្សសំណង់លំនៅដ្ឋានខ្មែរ និងជំរុញឱ្យបងប្អូនប្រជាពលរដ្ឋចូលរួមថែរក្សាការពារទាំងអស់គ្នា។

ឯកឧត្តមក៏បានកោតសរសើរដល់ក្រុមការងារមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ដែលបានរៀបចំវគ្គបណ្តុះបណ្តាលដ៏សំខាន់នេះឡើង និងបានសំណូមពរដល់សិក្ខាកាមទាំងអស់ឱ្យយកចំណេះដឹងទាំងនេះទៅប្រើប្រាស់ជាគុណប្រយោជន៍សម្រាប់នាយកដ្ឋាន/អង្គភាពរៀងៗខ្លួន និងអាជ្ញាធរជាតិអប្សរា និងជួយផ្សព្វផ្សាយចំណេះដឹងទាំងនេះជូនដល់មន្ត្រីបុគ្គលិក និងពន្យល់ដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងឧទ្យានអង្គរផងដែរ។

អាជីវករនៅមុខប្រាសាទអង្គរវត្តបន្តរុះរើតូបលក់ដូរ

ផ្សាយនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០នេះ អ្នកស្រី ទី កូឡាប ដែលជាអាជីវករនៅមុខប្រាសាទអង្គរវត្ត បាន ស្ម័គ្រចិត្តរុះរើភោជនីយដ្ឋានរបស់ខ្លួននៅមុខប្រាសាទអង្គរវត្ត ប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា ដើម្បីបន្តដាំដើមឈើប្រណិត រៀបចំសួនច្បា រ និងសាងសង់កន្លែងបដិសណ្ឋារកិច្ចនិងសេវាកម្មទេសចរណ៍កម្រិតអន្តរជាតិ ដែលមានបរិស្ថានស្អាត និងសណ្តាប់ធ្នាប់របៀបរៀបរយល្អ។

ក្នុងឱកាសនោះ **ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករង** សូមអំពាវនាវដល់បងប្អូន អាជីវករផ្សេងទៀតនៅមុខប្រាសាទអង្គរវត្តឱ្យស្ម័គ្រចិត្តរុះរើតូបលក់ដូរខ្លួន ដើម្បីចូលរួមជាមួយអាជ្ញាធរជាតិអប្សរាក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍មុខប្រាសាទអង្គរវត្តឱ្យបានទាន់ពេលវេលា សម្រាប់ជាប្រយោជន៍រួម៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមិថុនា

វត្ថុសិល្បៈចំនួន៧១១បំណែកបានចុះបញ្ជីសារពើភណ្ឌនិង៥៣១បំណែកកំពុងដំណើរការចុះបញ្ជីដើម្បីសម្គាល់អត្តសញ្ញាណ

ផ្សាយនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២០

ក្រុមការងារចុះបញ្ជីបេតិកភណ្ឌរូបីនៃអាជ្ញាធរជាតិអប្សរា សម្រេចចុះបញ្ជីវត្ថុសិល្បៈបានចំនួន៧១១បំណែក ដែលប្រមូលបានពីប្រជាជននិងនៅតាមប្រាសាទទាំង៩១ ក្នុងរមណីយដ្ឋានអង្គរ ឱ្យមានសុវត្ថិភាពនិងមានអត្តសញ្ញាណត្រឹមត្រូវ សម្រាប់ជាប្រយោជន៍ប្រើប្រាស់ទៅថ្ងៃក្រោយ។

លោក ឈូក សុម៉ាឡា មន្ត្រីទទួលបន្ទុកចុះបញ្ជីបេតិកភណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការឱ្យដឹងថា បំណែកវត្ថុសិល្បៈទាំង៧១១បំណែកដែលក្រុមការងារបានចុះបញ្ជីសារពើភណ្ឌរួចរាល់នោះ គឺភាគច្រើនជាចម្លាក់ធ្វើពីថ្មភក់ មាន៖ សិលាចារឹក ចម្លាក់ទេវរូប បល្ល័ង្គឬជើងទម្រ បំណែកផ្តែរ បំណែកហោជាង បំណែកសសរពេជ្រ បំណែកក្បាច់លម្អផ្សេងៗ កុលភាជន៍និងវត្ថុធ្វើពីលោហៈមួយចំនួនទៀត។ ក្រៅពីការចុះបញ្ជីវត្ថុសិល្បៈដែលបានទទួលពីប្រជាជន និងកំណាយស្រាវជ្រាវផ្សេងៗខាងលើ ក្រុមចុះបញ្ជីក៏បានចុះបញ្ជីវត្ថុសិល្បៈដែលនៅជុំវិញបរិវេណប្រាសាទទាំង៩១បានមួយចំនួនដែរ។

ការចុះបញ្ជីវត្ថុសិល្បៈដែលនៅតាមប្រាសាទទាំង៩១ នេះគឺមានគោលបំណងចងក្រងឯកសារកំណត់អត្តសញ្ញាណវត្ថុសិល្បៈទាំងនោះដើម្បីចូលរួមទប់ស្កាត់ការចល័តឬបាត់បង់ដោយប្រការណាមួយជាយថាហេតុ។ នៅក្នុងទម្រង់នៃការកំណត់អត្តសញ្ញាណនេះ គឺបានផ្តល់ព័ត៌មានយ៉ាងជាក់លាក់អំពីប្រភេទចម្លាក់ ប្រភព វត្ថុធាតុ ទំហំ ទីតាំង កាលបរិច្ឆេទ ថតរូប និងការពិពណ៌នាផ្សេងៗ ហើយព័ត៌មានទាំងនេះឯងដែលអាចជួយសម្រួលដល់ការងារជួសជុលនិងការទាមទារត្រឡប់មកវិញក្នុងករណីបាត់បង់ណាមួយ។ លោកសុម៉ាឡាបន្តទៀតថា ការងារចុះបញ្ជីពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការរក្សាកេរមរតកបេតិកភណ្ឌ ត្បិតអតីតរាជធានីនៃចក្រភពអង្គរ មានវិសាលភាពធំធេងណាស់ ហើយនៅមានវត្ថុសិល្បៈជាច្រើនទៀតដែលកំពុងនៅរាយប៉ាយលើដីនិងក្រោមដី ដែលត្រូវបន្តចុះបញ្ជីកំណត់អត្តសញ្ញាណវត្ថុទាំងនោះជាបន្តបន្ទាប់។

តួយ៉ាងដូចជាថ្មីៗនេះក្រុមការងារចុះបញ្ជីសារពើភណ្ឌបានប្រមូលចម្លាក់ព្រះពុទ្ធបដិមានិងវត្ថុសិល្បៈផ្សេងទៀតដែលមានចំនួន៥៣១បំណែកពីរោងឆ្នាំខាងត្បូងប្រាសាទអង្គរវត្តយកមករក្សាទុកនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ដើម្បីធ្វើការសិក្សាបន្ថែមរង់ចាំការងារជួសជុលនាពេលខាងមុខ។ កិច្ចការចុះបញ្ជីវត្ថុសិល្បៈបេតិកភណ្ឌរូបីនៅក្នុងរមណីយដ្ឋានអង្គរនៅតែបន្តជាប្រចាំ ដើម្បីចូលរួមថែរក្សា និងការពារវត្ថុសិល្បៈនានានៅតាមប្រាសាទទាំង៩១ ឱ្យមានអត្តសញ្ញាណច្បាស់លាស់ទប់ស្កាត់ការចល័តនិងការបាត់បង់៕

អាជីវករបន្តស្ម័គ្រចិត្តរុះរើតូបនៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ នេះ អ្នកស្រី យ៉ន ចាន់ថា ដែលជាអាជីវករ និងអ្នកស្រី នង ញូន ម្ចាស់ទីតាំងតូបលក់ដូរនៅមុខប្រាសាទអង្គរវត្ត បានស្ម័គ្រចិត្ត រុះរើអាហារដ្ឋានរបស់ខ្លួន និងប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា ដើម្បីបន្តដាំដើមឈើប្រណិត រៀបចំសួនច្បារ និងសាងសង់កន្លែងបដិសណ្ឋារកិច្ច និងសេវាកម្មទេសចរណ៍កម្រិតអន្តរជាតិ ដែលមានបរិស្ថាន ស្អាត និងសណ្តាប់ធ្នាប់របៀបរៀបរយ ល្អ ។

ក្នុងឱកាសនោះ ក៏មានបងប្អូនអាជីវករផ្សេងទៀតមួយចំនួនបានសន្យារុះរើតូបរបស់ខ្លួនក្នុងពេលឆាប់ៗផងដែរ។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករង និងជាតំណាង **ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា** បានបន្តអំពាវនាវដល់បងប្អូនអាជីវករផ្សេងទៀតនៅមុខប្រាសាទអង្គរវត្ត សូម ស្ម័គ្រចិត្តរុះរើតូបលក់ដូរខ្លួន ដើម្បីចូលរួមជាមួយអាជ្ញាធរជាតិអប្សរាក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍មុខប្រាសាទអង្គរវត្តឱ្យបានទាន់ពេលវេលា សម្រាប់ជាប្រយោជន៍រួម៕

ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបន្តរៀបចំសួនមុខបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០នេះ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បានបន្តការងាររៀបចំសួនច្បារមុខបរិវេណប្រាសាទអង្គរវត្ត ដែលការងារនេះធ្វើឡើងក្នុងបំណងកែប្រែបរិវេណនេះឱ្យក្លាយជាសួនបៃតង។

នេះជាកិច្ចការអាទិភាពមួយក្នុងចំណោមការងារអាទិភាពជាច្រើនរបស់អាជ្ញាធរជាតិអប្សរា សំដៅធ្វើយ៉ាងណា រៀបចំតំបន់រមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាត មានភាពបៃតង ស័ក្តិសមជាតំបន់បេតិកភណ្ឌពិភពលោក។

សូមទស្សនា ទិដ្ឋភាពក្រុមការងារបន្តដាំស្មៅ ដាំដើមផ្កាចម្រុះ នៅជុំវិញបរិវេណមុខប្រាសាទអង្គរវត្ត ដែលរូបភាពថតដោយលោក ហាប់ គឹមអាន ដូចតទៅ៖

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចចំនួន៤៧១គ្រួសារ

ផ្សាយនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០២០

ក្នុងខែឧសភា ឆ្នាំ២០២០ របាយការណ៍លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា បង្ហាញថា ក្រុមការងារសហគមន៍បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យនិងដោះស្រាយសំណើស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចតាមភូមិទាំង១១២ភូមិ ក្នុងតំបន់ឧទ្យានអង្គរ ដោយអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន៤៧១គ្រួសារ។

ករណីអនុញ្ញាតសំណើខាងលើផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកបាគង២៩គ្រួសារ ស្រុកអង្គរធចំនួន១៩៨គ្រួសារ ស្រុកពួកចំនួន៩៧គ្រួសារ ស្រុកបន្ទាយស្រីបានចំនួន៦១គ្រួសារ និងក្រុងសៀមរាបចំនួន៨៥គ្រួសារ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១. ការជួសជុលផ្ទះ៖ ការជួសជុលឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ ប្តូរឬតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ។ ២. សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូ ក ជង្រុកស្រូវ តូបឬរោងលក់ដូរមុខផ្ទះ។ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។ រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ។

លើសពីនេះក្រុមការងារក៏បានចែកសាប៊ូលាងដៃនិងការងារមនុស្សធម៌ ដោយឧត្តមថវិកាជូនចំពោះគ្រួសារមួយចំនួនតូចដែលខ្វះខាត ចាស់ជរា ក្មេងកំព្រា គ្រោះថ្នាក់ធម្មជាតិ។ល។ និងនៅតែបន្តចុះពិនិត្យ ដោះស្រាយសំណើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាពនិងទាន់ពេលវេលា៕

អាជ្ញាធរជាតិអប្សរាដំណើរការជួសជុលព្រះវិហារបុរាណវត្តរាជបូណ៌ដំណាក់កាលទី៣

ផ្សាយនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២០

ព្រះវិហារបុរាណនៅវត្តរាជបូណ៌ក្នុងទីរួមខេត្តសៀមរាប បានទទួលការជួសជុលដំណាក់ទី៣ក្រោមការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសនិងឧបត្ថម្ភជាថវិកាពីអាជ្ញាធរជាតិអប្សរា។

ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាឱ្យដឹងថា៖ ការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសនិងឧបត្ថម្ភ ជាថវិកាសម្រាប់ការជួសជុលវត្តរាជបូណ៌ដំណាក់កាលទី៣នេះ គឺដើម្បីរួមចំណែកថែរក្សាមត៌កវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនា ព្រមទាំងជួយអភិរក្សនិងលើកតម្លៃវប្បធម៌នៃសិល្បៈរបស់ខ្មែរពីបុរាណកាលឱ្យរស់រវើកឡើងវិញ។

បច្ចុប្បន្ន វត្តមួយនេះអាចចាត់ទុកជាបូជនីយដ្ឋានផង និងបុរាណដ្ឋានដ៏ល្បីមួយនៅក្នុងខេត្តសៀមរាបផង។ បើរាប់ពីដំបូល តួព្រះវិហារ គ្រឹះ ហោជាង សន្លឹកទ្វារ សន្លឹកបង្អួច ព្រះពុទ្ធបដិមា បល្ល័ង្កព្រះ សសរ រូបគំនូរ ពណ៌ គឺសុទ្ធតែជាវត្ថុគួរឱ្យចាប់អារម្មណ៍បំផុតសម្រាប់អ្នកទេសចរ អ្នកស្រាវជ្រាវជាតិ-អន្តរជាតិ។

ដើម្បីរួមចំណែកថែរក្សាមរតកវប្បធម៌ខ្មែរក្នុងវិស័យព្រះពុទ្ធសាសនានេះឱ្យបានគង់វង្ស អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមគម្រោងអភិរក្ស និងជួសជុលព្រះវិហារវត្តរាជបូណ៌ដំណាក់កាលទី៣ដែលជាដំណាក់កាលជួសជុលបញ្ចប់ក្នុងឆ្នាំ២០២០ ដោយចាប់ផ្តើមតាំងពីថ្ងៃទី២៦ ខែ ឧសភា ហើយគ្រោងនឹងបញ្ចប់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ខាងមុខ ។

ការជួសជុលដំណាក់កាលទី៣នេះ គឺផ្តោតលើការជួសជុលជញ្ជាំង ក្បាច់ជើងជញ្ជាំង បាំងសាច កាំជណ្តើរ ការ៉ូ ក្បាច់លើទ្វារ-បង្អួច និងខឿនព្រះវិហារ ព្រមទាំងពង្រឹងរចនាបថសំណង់ រូបចម្លាក់ ដែលចាស់ទ្រុឌទ្រោមឱ្យបានរឹងមាំឡើងវិញតាមបច្ចេកទេសនិងសម្ភារទំនើបប៉ុន្តែប្រើប្រាស់វត្ថុធាតុដើមបុរាណដដែល។

កាលពីឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរាធ្លាប់បានសហការជាមួយអ្នកជំនាញអ៊ីតាលីជួសជុលព្រះវិហារវត្តរាជបូណ៌ដំណាក់កាលទី១ម្តងមកហើយ ដោយកាលណោះ ការជួសជុលបានសម្អាតសន្លឹកបង្អួច សន្លឹកទ្វារ ពុទ្ធបដិមាធំក្នុងព្រះវិហារ និងពុទ្ធបដិមាតូចៗមួយចំនួន បល្ល័ង្កព្រះ គំនូររចនាសម្ព័ន្ធ សសរ ដែលរងនូវការខូចខាត ប្រេះស្រាំ រលុបបាត់បង់ភាពដើមដោយសារផ្សែងភ្លើងរុំ ធូលីដី បរិយាកាសអាយុកាល ការលាបពណ៌ថ្មី និងការជួសជុលផ្សេងៗ ពីមួយជំនាន់ទៅមួយជំនាន់ជាដើម។ កាលពីឆ្នាំ២០១៩ វត្តរាជបូណ៌ក៏ទទួលបានការជួសជុលដំណាក់កាលទី២ ដោយបានជួលជុលដំបូលព្រះវិហារគ្រឿងបង្គុំដំបូលដើម្បីរក្សាលំនឹង ការសម្លាប់មេរោគ និងសត្វល្អិតកុំឱ្យស៊ីសាច់ឈើ ជួសជុល សម្អាតហោជាងដែលមានចម្លាក់ក្បាច់ និងគ្រឿងលម្អដំបូលទាំងអស់ឡើងវិញទាំងស្រុង៕

សារមន្ទីរទាំង៣របស់អាជ្ញាធរជាតិអប្សរាបើកទ្វារដំណើរការឡើងវិញ

ផ្សាយនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២០

ចាប់ពីថ្ងៃទី២ ខែមិថុនា តទៅ សារមន្ទីរទាំង៣ដែលស្ថិតក្រោមការគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ផ្តើមបើកទ្វារស្វាគមន៍ការទស្សនារបស់ភ្ញៀវទេសចរឡើងវិញ បន្ទាប់ពីបិទទ្វារមួយរយៈអំឡុងពេលការរាតត្បាតជំងឺកូវីដ១៩។ ការបើកទ្វារឡើងវិញនេះគឺមានការគិតគូរខ្ពស់ពីសុវត្ថិភាពភ្ញៀវទេសចរដែលអញ្ជើញមកទស្សនា។

លោក សេង សុធា៉ អនុប្រធាននាយកអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា សារមន្ទីរទាំង៣មានសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ, សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី និងសារមន្ទីរកុលាលភាជន៍ឡតានី បានបំពាក់ឧបករណ៍វាស់កម្តៅ ទឹកអាល់កុលសម្រាប់ត្រួតពិនិត្យនិងការគិតគូរពីសុវត្ថិភាពមិនឱ្យឆ្លងជំងឺកូវីដ១៩។ លោកបន្ថែមថា ភ្ញៀវទេសចរទាំងអស់នឹងតម្រូវឱ្យស្ថិតនៅចំណុចគំលាត២ម៉ែត្រពីគ្នា ប្រសិនបើការទស្សនានោះមានចំនួនច្រើន អំឡុងពេលចូលទស្សនាក្នុងសារមន្ទីរ។

អាជ្ញាធរជាតិអប្សរា នឹងបន្តការបើកទ្វារទស្សនាដោយឥតគិតថ្លៃ ដើម្បីអបអរខួប២៥ឆ្នាំ ថ្ងៃបង្កើតអាជ្ញាធរជាតិអប្សរា ដែលការប្រកាសនេះចាប់ផ្តើមពីដើមខែ មីនា ឆ្នាំ២០២០ រហូតដល់ចុងខែមករា ឆ្នាំ២០២១ ក្នុងគោលដៅដើម្បីផ្សព្វផ្សាយពីប្រវត្តិសាស្ត្រ វប្បធម៌ អារ្យធម៌ ទំនៀមទម្លាប់ប្រពៃណីដល់ភ្ញៀវទេសចរគ្រប់ជាតិសាស្ត្របានដឹងពីកម្ពុជា។

អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និង បទដ្ឋានបេតិកភណ្ឌ បានអំពាវនាវដល់សាធារណជន ក៏ដូចជាភ្ញៀវទេសចរជាតិ និងអន្តរជាតិ សូមអញ្ជើញមកទស្សនាសារមន្ទីរទាំង៣របស់អាជ្ញាធរជាតិអប្សរា គឺសារមន្ទីរបានត្រៀមខ្លួនរួចរាល់ក្នុងការទទួលស្វាគមន៍ទេសចរគ្រប់ជាតិសាសន៍អំឡុងពេលមានជំងឺកូវីដ១៩នេះ។ ការការពារនេះ គឺដើម្បីធានាសុវត្ថិភាពទាំងទេសចរ និងបុគ្គលិករបស់សារមន្ទីរ ធ្វើយ៉ាងណាធានាឱ្យបានពីសុវត្ថិភាពនៃការឆ្លងជំងឺកូវីដ១៩។

គួរបញ្ជាក់ថា សារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ និងសារមន្ទីរកុលាលភាជន៍ឡតានី បើកទ្វារពីថ្ងៃអង្គារ ដល់ថ្ងៃអាទិត្យ ចំណែកសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី បើកទ្វារពីថ្ងៃពុធ ដល់ថ្ងៃចន្ទ៕

សហប្រធានគណៈកម្មការអាយស៊ីស៊ី-អង្គរនិងអាជ្ញាធរជាតិអប្សរា ចុះពិនិត្យតាមដានកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០២០

សហប្រធានគណៈកម្មការអាយស៊ីស៊ី-អង្គរ ការិយាល័យអង្គការយូណេស្កូប្រចាំកម្ពុជា រួមទាំងថ្នាក់ដឹកនាំ និងអ្នកជំនាញអាជ្ញាធរជាតិអប្សរា បានចុះត្រួតពិនិត្យដំណើរការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតាមការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរ ចាប់ពីថ្ងៃទី៦ដល់ទី១០ ខែមិថុនា ឆ្នាំ២០២០។

ការចុះពិនិត្យនេះគឺធ្វើឡើងព្រោះតែកិច្ចប្រជុំបច្ចេកទេសរបស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដែលគ្រោងនឹងប្រព្រឹត្តទៅក្នុងខែមិថុនា ត្រូវបានខកខានដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩នៅជុំវិញពិភពលោក ហើយអ្នកជំនាញចំពោះកិច្ចទាំងផ្នែកអភិរក្ស និងផ្នែកអភិវឌ្ឍន៍ប្រកបដោយចីរភាពពុំបានអញ្ជើញមកដោយផ្ទាល់ដើម្បីពិនិត្យនិងតាមដានពីវឌ្ឍនភាពនៃការអនុវត្តការងារអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ។

ទោះបីស្ថិតក្នុងស្ថានភាពបែបនេះក៏ដោយ សហប្រធានបច្ចេកទេសនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ (ស្ថានទូតប្រទេសជប៉ុននិងប្រទេសបារាំង) បានធ្វើការប្តូរវេនគ្នាចុះមកត្រួតពិនិត្យកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរដើម្បីតាមដានការអនុវត្តការងាររបស់ស្ថាប័នជាតិ អន្តរជាតិ ថាបានអនុវត្តស្របតាមអនុសាសន៍ដែលគណៈកម្មាធិការនេះបានផ្តល់ជូននាពេលមុនដែរឬទេ។

ជាក់ស្តែងនៅថ្ងៃទី៦-៧ ខែមិថុនា សហប្រធានបច្ចេកទេសជប៉ុនបានអញ្ជើញចុះមកត្រួតពិនិត្យ។ រីឯ សហប្រធានបច្ចេកទេសបារាំងនឹងអញ្ជើញចុះមកត្រួតពិនិត្យនៅថ្ងៃទី៨-១០ ខែមិថុនា ខាងមុខ៕

ក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំអាណត្តិទី៥ លើកទី១

ផ្សាយនៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** និង ជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាអាណត្តិទី៥ លើកទី១ ដោយមានការអញ្ជើញចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលនិងអង្គភាពពាក់ព័ន្ធ។

ក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សាភិបាលបានត្រួតពិនិត្យនិងពិភាក្សាលើរបៀបវារៈចំនួន៥ ដូចជា៖ ១) លទ្ធផលនៃការសម្រេចបាននៃអនុសាសន៍ផ្តល់ជូនដោយក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរាអាណត្តិទី៤ លើកទី៤ ២) របាយការណ៍សង្ខេបសកម្មភាពនិងលទ្ធផលការងាររបស់អាជ្ញាធរជាតិអប្សរាឆ្នាំ២០១៩ និងរយៈពេល៣ខែដើមឆ្នាំ២០២០ ៣) របាយការណ៍ហិរញ្ញវត្ថុរបស់អាជ្ញាធរជាតិអប្សរា២០១៧-២០១៩ និងរយៈពេល៣ខែដើមឆ្នាំ២០២០ ៤) ការពិនិត្យអនុម័តលើគម្រោងផែនការថវិកាឆ្នាំ២០២១ ៥) ការពិនិត្យអនុម័តលើអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិអប្សរា។ បន្ថែមលើសនេះទៀត ក្រុមប្រឹក្សាភិបាលក៏បានណែនាំផែនការចង្អុលទិសដៅសម្រាប់អនុវត្តនៅឆ្នាំក្រោយទៀតដែរ៕

អាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យប្រជាពលរដ្ឋជួសជុល និងសាងសង់សំណង់តូចតាចចំនួន១០៨គ្រួសារក្នុងសប្តាហ៍ទី១នៃខែមិថុនា

ផ្សាយនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចជួសជុលផ្ទះសម្បែងនិងសាងសង់សំណង់តូចតាចបានចំនួន ១០៨គ្រួសារ នៅក្នុងស្រុកចំនួន៥ ដែលរស់នៅក្នុងតំបន់ការពារបេតិកភណ្ឌនាសប្តាហ៍ទី១នៃខែមិថុនាឆ្នាំ២០២០។

តាមរបាយការណ៍របស់លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលចេញផ្សាយនៅសប្តាហ៍ទី១ ដើមខែមិថុនា ឱ្យដឹងថា ក្រុមការងារសហគមន៍ បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យ និងដោះស្រាយសំណើស្នើសុំជួសជុលផ្ទះរួមទាំងសាងសង់តូចតាចនៅតាមភូមិទាំង១១២ ក្នុងតំបន់ឧទ្យានអង្គរនៃស្រុកចំនួន៤ និងក្រុងមួយ។

ការអនុញ្ញាតលើសំណើសុំជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចរបស់ប្រជាពលរដ្ឋរួមមាន៥ស្រុក/ក្រុង ដូចជានៅស្រុកបាគងចំនួន៩គ្រួសារនៅស្រុកអង្គរធំចំនួន១៤គ្រួសារ ស្រុកពួកចំនួន២៧គ្រួសារ ស្រុកបន្ទាយស្រីចំនួន១៧គ្រួសារ និងក្រុងសៀមរាបចំនួន៤១គ្រួសារ សរុបទាំងអស់ចំនួន ១០៨គ្រួសារ។

ស្ទើតែរៀងរាល់ថ្ងៃ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ការពារបេតិកភណ្ឌពិភពលោក តែងស្នើសុំជួសជុលផ្ទះឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ សុំតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងដែលមានស្រាប់ បន្ទប់ក្រោមផ្ទះ ព្រមទាំងសាងសង់សំណង់តូចតាចជាដើម។ ឆ្លើយតបនឹងតម្រូវការនេះ ក្រុមការងារសហគមន៍តែងចុះពិនិត្យ ដោះស្រាយ និងអនុញ្ញាតជូនប្រជាពលរដ្ឋជាបន្តបន្ទាប់។

ក្រៅពីនេះ ក្រុមការងារសហគមន៍តែងតែចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ ឱ្យកាន់តែយល់ច្បាស់ពីតួនាទីនិងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ក្នុងការប្រើប្រាស់ដីធ្លីនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងរមណីយដ្ឋានអង្គរដែរ៕

អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្ត បន្តចូលរួមជាមួយអាជ្ញាធរជាតិអប្សរារុះរើតូប លក់វត្ថុអនុស្សាវរីយ៍ និងភោជនីយដ្ឋានធំៗចំនួន២កន្លែងទៀត

ផ្សាយនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២០

អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្ត បន្តចូលរួមជាមួយអាជ្ញាធរជាតិ អប្សរា រុះរើ តូប លក់ វត្ថុអនុ ស្សាវ រីយ៍ និង ភោជនីយដ្ឋានធំៗចំនួន២កន្លែងជាថ្មីទៀត នៅ ជាប់ស្ពានអណ្តែតទឹក និង នៅ ជិត បន្ទប់អនាម័យនៃបរិវេណប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃពុធទី១០ខែ មិថុនា ។

ការ រុះរើ តូបលក់វត្ថុអនុស្សាវរីយ៍ និងភោជនីយដ្ឋាននេះ ធ្វើឡើង បន្ទាប់ពី អាជីវករ ជាអ្នកជួល តូបនិង ម្ចាស់ភោជនីយដ្ឋាន បាន ស្ម័គ្រចិត្ត ប្រគល់ទីតាំង ឱ្យមន្ត្រី អាជ្ញាធរជាតិអប្សរា យកទៅរៀបចំ ធ្វើជាទីលានបដិសណ្ឋារកិច្ច ធ្វើជាសួនច្បារ កែប្រែឱ្យមានសោភ័ណភាព និងបរិស្ថានល្អព្រមទាំង រៀបចំសណ្តាប់ធ្នាប់នៅមុខអង្គរវត្ត ឱ្យកាន់តែមាន របៀបរៀបរយមក។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងនៃ អាជ្ញាធរជាតិអប្សរា ដែលជាអ្នកដឹកនាំ កម្លាំងចុះរុះរើតូបលក់ដូរនោះ មានប្រសាសន៍ថា៖អាជ្ញាធរមានគម្រោងនឹង រុះរើតូប និងភោជនីយដ្ឋាន ទាំងអស់ចេញពីបរិវេណមុខប្រាសាទអង្គរ ឱ្យអស់ យ៉ាងយូរត្រឹមចុងខែ សីហា ឆ្នាំ ២០២០ ខាងមុខ។ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរាដដែលបញ្ជាក់ទៀតថា បើទោះបីជាយ៉ាងណាក៏ការរុះរើតូបទាំងនោះ មិនបានបង្ខិតបង្ខំអាជីវករដែលជាម្ចាស់តូបទេក៏ប៉ុន្តែអាជ្ញាធរជាតិអប្សរា នឹងប្រឹងប្រែងពន្យល់ឱ្យក្រុមអាជីវករទាំងនោះ បានយល់ព្រមរុះរើ ដោយស្ម័គ្រចិត្ត ។

ជាមួយនឹងការរុះរើតូបលក់ដូរ ព្រមទាំងភោជនីយដ្ឋានទាំងនេះដែរអាជ្ញាធរជាតិអប្សរា ក៏កំពុងសាងសង់កន្លែងលក់ដូរថ្មីដើម្បីប្តូរជាមួយអាជីវករ ឱ្យទៅប្រកបរបរ ចិញ្ចឹមជីវិតតទៅទៀតដែលមិនឆ្ងាយពីកន្លែងចាស់ប៉ុន្មានទេ ។ ក្រុមអាជីវករ លក់ដូរវត្ថុអនុស្សាវរីយ៍និងម្ចាស់ភោជនីយដ្ឋានជាច្រើនរូបបានបង្ហាញការស្ម័គ្រចិត្ត ជាបន្តបន្ទាប់ក្នុងការយល់ព្រមរុះរើតូបរបស់ខ្លួន ហើយទទួលយកកន្លែងលក់ដូរថ្មី ។

អ្នកស្រី ម៉ោញ រតនា ម្ចាស់ហាងវត្ថុអនុស្សាវរីយ៍ដ៏ធំមួយ មានប្រសាសន៍ថា៖អ្នកស្រី បានយល់ព្រមរុះរើ ហាងរបស់គាត់ដែលបាន ធ្វើសម្រាប់លក់ដូររយៈពេល ជិត២០ឆ្នាំមកហើយនោះ ។ អ្នកស្រីបញ្ជាក់ទៀតថា អ្នកស្រីក៏ស្រឡាញ់ប្រាសាទអង្គរវត្ត ដូច្នេះការរុះរើតូបរបស់អ្នកស្រីដើម្បី ប្រគល់ទីតាំងទៅ ឱ្យអាជ្ញាធររៀបចំធ្វើជាទីលានបដិសណ្ឋារកិច្ច ធ្វើជាសួនច្បារកែប្រែឱ្យមានសោភ័ណភាព និងបរិស្ថានល្អព្រមទាំងរៀបចំសណ្តាប់ធ្នាប់នៅមុខអង្គរវត្ត ឱ្យកាន់តែមាន របៀបរៀបរយនោះ គឺអ្នកស្រី ពេញចិត្ត និងចូលរួម ។
នេះជាលើកទី៥ហើយដែលអាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្ត បន្តចូលរួមស្ម័គ្រចិត្តជាមួយអាជ្ញាធរជាតិអប្សរា រុះរើតូបលក់វត្ថុអនុស្សាវរីយ៍និងភោជនីយដ្ឋានធំៗចំនួន២កន្លែងទៀត នៅបរិវេណ មុខអង្គរវត្ត ។
ចាប់តាំងតែពី ថ្ងៃទី២ខែមករា រហូតមកដល់ត្រឹមថ្ងៃទី៣០ខែឧសភាឆ្នាំ២០២០ អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្ត បានចូលរួមជាមួយអាជ្ញាធរជាតិអប្សរា អនុវត្តន៍ការរុះរើភោជនីយដ្ឋានដែលមានសំណង់ធំៗ ចំនួន៤កន្លែងរួចមកហើយ ដូចជា ភោជនីយដ្ឋាន Chez sophéa & Mat_ thieu ចំនួន៣ខ្នង ភោជនីយដ្ឋានផ្ទះបាយតានីខ្មែរអង្គរ និងហាង Spice Garden ជាដើម៕

សហប្រធានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បញ្ចប់ការចុះពិនិត្យការដ្ឋានក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២០

ចាប់តាំងពីថ្ងៃទី៦ និងទី១០ ខែ មិថុនា ឆ្នាំ២០២០ សហប្រធានគណៈកម្មាធិការអាស៊ីស៊ី-អង្គរ មន្ត្រីនៃការិយាល័យអង្គការយូណេស្កូប្រចាំកម្ពុជា រួមនិងថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យមើលការដ្ឋានជួសជុលនៃកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ។

ក្នុងការចុះមកពិនិត្យតាមការដ្ឋានការងារទាំងនេះ សហប្រធានបច្ចេកទេស (ស្ថានទូតជប៉ុន និងបារាំង) បានប្តូរវេនគ្នាដោយសហប្រធានបច្ចេកទេសជប៉ុនបានចុះពិនិត្យការងារចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមិថុនា នៅការដ្ឋានដូចជាការដ្ឋានផ្លូវកង់ ផ្លូវមុខព្រះលានជល់ដំរី ទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត ការដ្ឋានស្ពានហាលអង្គរវត្ត ការងារជួសជុលព្រះលានជល់ដំរី ការដ្ឋានប្រាសាទបាយ័ន ខ្លោងទ្វារខាងកើតប្រាសាទតានៃ ខ្លោងទ្វារតាកាវ ការដ្ឋានជួសជុលកំពែងក្រុងអង្គរធំ ការដ្ឋានស្រះស្រង់ និងការងារនៅការដ្ឋានខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី។

ចំណែកសហប្រធានបច្ចេកទេសបារាំង បានបន្តការងារនេះដោយចាប់ពីការដ្ឋាននៅប្រាសាទមេបុណ្យខាងលិច ដែលជាការដ្ឋានមួយទទួលជំនួយថវិកាពីស្ថានទូតបារាំង។

ចេញពីមេបុណ្យ សហប្រធានបារាំងបានបន្តទៅពិនិត្យការដ្ឋានប្រាសាទអកយំ ប្រាសាទទន្លេស្ងួត ប្រាសាទព្រៃប្រាសាទ (ប្រាសាទតាអួន) ប្រាសាទបន្ទាយធំ និងការដ្ឋានប្រាសាទបន្ទាយស្រី៕

អាជ្ញាធរជាតិអប្សរាកំពុងប្រតិបត្តិការជីកកូនស្រះ បូមភក់ និងដឹកទឹកបញ្ចូល ក្នុងកសិន្ធុប្រាសាទបាគង

ផ្សាយនៅថ្ងៃទី ១១ខែ មិថុនា ឆ្នាំ២០២០

ចាប់តាំងពីថ្ងៃទី៦ និងទី១០ ខែ មិថុនា ឆ្នាំ២០២០ សហប្រធានគណៈកម្មាធិការអាស៊ីស៊ី-អង្គរ មន្ត្រីនៃការិយាល័យអង្គការយូណេស្កូប្រចាំកម្ពុជា រួមនិងថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យមើលការដ្ឋានជួសជុលនៃកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ។

ក្នុងការចុះមកពិនិត្យតាមការដ្ឋានការងារទាំងនេះ សហប្រធានបច្ចេកទេស (ស្ថានទូតជប៉ុន និងបារាំង) បានប្តូរវេនគ្នាដោយសហប្រធានបច្ចេកទេសជប៉ុនបានចុះពិនិត្យការងារចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមិថុនា នៅការដ្ឋានដូចជាការដ្ឋានផ្លូវកង់ ផ្លូវមុខព្រះលានជល់ដំរី ទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត ការដ្ឋានស្ពានហាលអង្គរវត្ត ការងារជួសជុលព្រះលានជល់ដំរី ការដ្ឋានប្រាសាទបាយ័ន ខ្លោងទ្វារខាងកើតប្រាសាទតាកែវ ខ្លោងទ្វារតាការ ការដ្ឋានជួសជុលកំពែងក្រុងអង្គរធំ ការដ្ឋានស្រះស្រង់ និងការងារនៅការដ្ឋានខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី។

ចំណែកសហប្រធានបច្ចេកទេសបារាំង បានបន្តការងារនេះ ដោយចាប់ពីការដ្ឋាននៅប្រាសាទមេបុណ្យខាងលិច ដែលជាការដ្ឋានមួយទទួលជំនួយថវិកាពីស្ថានទូតបារាំង។

ចេញពីមេបុណ្យ សហប្រធានបារាំងបានបន្តទៅពិនិត្យការដ្ឋានប្រាសាទអកយំ ប្រាសាទទន្លេស្ងួត ប្រាសាទព្រៃប្រាសាទ (ប្រាសាទតាអួន) ប្រាសាទបន្ទាយធំ និងការដ្ឋានប្រាសាទបន្ទាយស្រី៕

សេចក្តីជូនដំណឹងស្តីពីការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ខែ មិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ០៩៩ /ចសអ.សជណ
/២០

សេចក្តីជូនដំណឹង
ស្តីពី
ការថែទាំស្ពានបណ្តែតទឹកមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា៖ ដើម្បីថែរក្សាសុខសុវត្ថិភាពជូនដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋ ដែលធ្វើដំណើរឆ្លងកាត់ស្ពានបណ្តែតទឹកដើម្បីទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរា នឹងធ្វើការថែទាំស្ពានបណ្តែតទឹកនៅពេលយប់ សម្រាប់រយៈពេល០៤ថ្ងៃ គិតចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ ចាប់ពីម៉ោង៦៖០០នាទីល្ងាច រហូតដល់ម៉ោង១២៖០០នាទីយប់ដែលមានសកម្មភាពដូចខាងក្រោម៖

១. ការងារបិទក្រណាត់ត្រើមលើកាំជណ្តើរចុះទៅស្ពាននៅផ្នែកខាងកើត និងខាងលិច

២. ការងារបោសសម្អាតលើតួស្ពានបណ្តែតទឹក និងនៅក្រោមទម្រក្តារស្ពានឈើ(ខាងកើត និងខាងលិច)

៣. ការងាររិតខ្ចៅពោងបណ្តែតទឹកចេញ និងរិតចូលវិញនៃតួស្ពានទាំងមូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃ......ខែ......ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២០

ភ្នំពេញ:
អគារលេខ៤៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៣១/ ០២៣ ២១៥ ៧៣៦

អាជ្ញាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

ព្រះសង្ឃសហការជាមួយអាជ្ញាធរជាតិអប្សរាដាំកូនឈើ១៥០០ដើមនៅវត្តព្រះឥន្ទទេព

ផ្សាយនៅថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ មានរៀបចំប្រារព្ធពិធីដាំកូនឈើនៅវត្តព្រះឥន្ទទេព (ខាងត្បូងប្រាសាទបាយ័ន) ក្រោមកិច្ចនិមន្តចូលរួមដ៏ខ្ពង់ខ្ពស់ពីសំណាក់ព្រះសុមង្គលសិលាចារ្យ អាភាករោ ជុំ គឹមឡេង ព្រះមេគណខេត្តសៀមរាប គណៈកម្មការ ព្រះសង្ឃ អាចារ្យ ពុទ្ធបរិស័ទ មន្ត្រី បុគ្គលិក ពលករ នៃអាជ្ញាធរជាតិអប្សរា សរុបប្រមាណ ២០០អង្គ-នាក់។

មានសង្ឃដីការក្នុងពិធីនោះ ព្រះអង្គ ជុំ គឹមឡេង ព្រះមេគណខេត្តសៀមរាប មានសង្ឃដីការពីអត្ថប្រយោជន៍ដ៏លើសលប់នៃព្រៃឈើចំពោះមនុស្សជាតិ សត្វ ធម្មជាតិ និងប្រាសាទ ប៉ុន្តែដោយយោងលើកត្តាធម្មជាតិ ការកាប់បំផ្លាញរបស់មនុស្ស ធ្វើឲ្យមានការបាត់បង់អស់មួយផ្នែកធំ។ ព្រះអង្គបានអំពាវនាវ សុំឱ្យមានការចូលរួមទាំងបណ្តុះគំនិត ចេះស្រឡាញ់ធម្មជាតិ និងចូលរួមដាំដើមឈើបន្ថែម ដើម្បីបរិស្ថានក្នុងប្រទេសកម្ពុជា។

ពិធីខាងលើនេះបានរៀបចំដាំដើមឈើទាំង១,៥០០ដើម មានដូចជាប្រភេទឈើ គ្រញូង បេង ធ្នង់ ច្រេស សុក្រំ គគីរ ឈើទាល រំដួល និងក្របៅ។ នេះជាកម្មវិធីលើកទី១នៃការដាំកូនឈើនាដើមរដូវវស្សាឆ្នាំ២០២០នេះ ហើយអាជ្ញាធរជាតិអប្សរានឹងបន្តការងារនេះនៅតាមតំបន់ប្រាសាទ វត្តអារាម និងតំបន់គោលដៅជាច្រើនទៀត ក្នុងបំណងបង្កើនគម្របព្រៃឈើក្នុងតំបន់រមណីយដ្ឋានអង្គរ។

គួររំលឹកដែរថា គំនិតផ្តួចផ្តើមក្នុងការដាំកូនឈើឡើងវិញនេះ ជាផ្នែកមួយនៃដំណើរការក្នុងកិច្ចការរៀបចំប្លង់បច្ចុប្បន្នភាព និងប្លង់មេ វត្តព្រះឥន្ទទេព របស់ក្រុមកិច្ចការវត្តអារាម នៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋាន ក្នុងឧទ្យានអង្គរ ក្នុងការប្រើប្រាស់ផ្ទៃដីវត្តអារាមឲ្យបានសមស្រប ក៏ដូចជាជួយសង្គ្រោះ និងអភិរក្សព្រៃឈើឡើងវិញ ព្រមទាំងបានការនិមន្តចូលរួមនិងកិច្ចខិតខំប្រឹងប្រែងអស់

ពីកំលាំងកាយ ចិត្ត ពីសំណាក់ព្រះមេគណខេត្តសៀមរាប ព្រះមន្ត្រីសង្ឃ និងបានការរួមសហការយ៉ាងជិតស្និតជាមួយនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងទឹក និងនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដើម្បីឲ្យកិច្ចការងារនេះប្រព្រឹត្តិបានដោយជោគជ័យ៕

អាជ្ញាធរជាតិអប្សរានិងមន្ទីរទេសចរណ៍ខេត្តសៀមរាប សហការគ្នារុះរើសំណង់នៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០២០

សំណង់អាគារមុខប្រាសាទអង្គរវត្តត្រូវបានរុះរើជាស្ថាពរ ដោយមានការចូលរួមសហការដោយមន្ទីរទេសចរណ៍ខេត្តសៀមរាប ក្រោមគម្រោងអភិវឌ្ឍន៍របស់អាជ្ញាធរជាតិអប្សរា កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។ នេះជាសំណង់ទី១០ហើយ ដែលត្រូវបានរុះរើដោយស្ម័គ្រចិត្តនិងប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍។

លោក សឿង ស៊ីថា ប្រធានការិយាល័យទីក្រុងស្អាតនៃមន្ទីរទេសចរណ៍ខេត្តសៀមរាប បានឱ្យដឹងថា អាគារនេះបានបន្សល់ទុកនូវការចងចាំដ៏ល្អនិងអនុស្សាវរីយ៍ជាច្រើនដោយធ្លាប់បានប្រើប្រាស់ដំបូងគេបង្អស់នៅមុខប្រាសាទអង្គរវត្តលើផ្នែកសេវាកម្មភេសជ្ជៈនិងបន្ទប់ទឹកស្អាត។ ដោយចំពោះការរុះរើនាពេលនេះ លោកបញ្ជាក់ថាក្រសួងនិងមន្ទីរទេសចរណ៍សប្បាយរីករាយសហការជាមួយអាជ្ញាធរជាតិអប្សរាដើម្បីរួមចំណែកអភិវឌ្ឍន៍ កែលម្អជាសួនច្បារ ដាំដើមឈើឱ្យមានការទាក់ទាញទេសចរណ៍មកលេងកាន់តែច្រើនក្នុងតំបន់បេតិកភណ្ឌយើង។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរា បញ្ជាក់ថា ការរុះរើសំណង់ទាំងអស់មុខប្រាសាទអង្គរវត្ត គឺមិនត្រូវបានលើកលែងអាគារណាមួយទេ សូម្បីសំណង់របស់អាជ្ញាធរជាតិអប្សរាផ្ទាល់។

ឯកឧត្តម ក្នុងនាម អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរគុណចំពោះកិច្ចសហការដ៏ល្អរបស់ក្រសួងនិងមន្ទីរទេសចរណ៍ខេត្តសៀមរាប ក៏ដូចអាជីវករទាំងអស់ ដែលបានលះបង់ទ្រព្យធនរបស់ខ្លួនក្នុងការបម្រើផលប្រយោជន៍រួម និងស្គាល់ពីតម្លៃអង្គរ ដើម្បីទុកលទ្ធភាពជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ទីលានមុខប្រាសាទអង្គរវត្តក្លាយជាទីចាប់អារម្មណ៍បំផុត៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបពិភាក្សាការងារជាមួយនាយកសាលាបារាំងចុងបូព៌ា

ផ្សាយនៅថ្ងៃទី១២ ខែ មិថុនា ឆ្នាំ២០២០

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតអប្សរា បាន អនុញ្ញាតឱ្យលោក Brice Vincent នាយកសាលាបារាំងចុងបូព៌ាប្រចាំខេត្តសៀមរាប ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា។

កិច្ចជំនួបពិភាក្សានេះភាគីទាំងពីរបានជជែកពីកិច្ចការមួយចំនួនទាក់ទងនឹងការងារអភិរក្ស ការងារស្រាវជ្រាវក្នុងតំបន់រមណីយដ្ឋានអង្គរ ការងារបណ្ដុះបណ្ដាលធនធានមនុស្ស ពិសេសកិច្ចគ្រប់គ្រងនិងថែរក្សាបុរាណវត្ថុដែលប្រទះឃើញនៅតាមការដ្ឋានកំណាយស្រាវជ្រាវដែលជាកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរនាពេលកន្លងមក។

ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរាបានថ្លែងអំណរគុណដល់សាលាបារាំងចុងបូព៌ាក្នុងកិច្ចសហការកំណាយរួមទាំងការបណ្ដុះបណ្ដាលធនធានមនុស្សកន្លងមកដែរ។ របាយការណ៍ទាំងនេះមានសារៈសំខាន់ណាស់សម្រាប់អាជ្ញាធរជាតិអប្សរាក្នុងការយកទិន្នន័យទៅអនុវត្តន៍គម្រោងអភិរក្សនិងអភិវឌ្ឍន៍ ការជួសជុលប្រាសាទមេបុណ្យខាងលិច និងប្រាសាទជាច្រើនទៀតនៅក្នុងរមណីយដ្ឋានអង្គរ៕

សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើកាត់ដកហូតដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់នៅ តាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ០៤៦៤/អ.សជណ/២០

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ កាត់សម្អាតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាព នៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម កាត់សម្អាតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានា ដូចខាងក្រោម៖

- កាត់ដកហូតដើមឈើទាលងាប់ចំនួន ០៣ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប។
- កាត់ដកហូតដើមត្រាងងំរី ០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅប្រាសាទបាយ័ន។
- កាត់ដកហូតដើមឈើចំនួន ២ដើម (ដើមក្រឡាញ់រស់០១ដើម និងដើមពភ្លារស់០១ដើម) កាត់សម្អាតគល់ដើមស្ពង់ ពុកចំនួន ០៤ដើម កាត់ដើមស្ពង់ពាក់កណ្តាលដើម ០១ដើម និងកាត់ក្រីមែកឈើ ចំនួន ០៤ដើម (ដើមត្រសេក ដើមចំបក់ ដើមត្រាង និងដើម ពភ្លាប្រើស) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងបរិវេណប្រាសាទតាព្រហ្ម។
- កាត់ដកហូតដើមឈើចំនួន ០៧ដើម (ដើមក្រឡាញ់ ដើមស្រឡៅ ដើមទំពូង ដើមឈើទាល ដើមជន្លួស ដើមអាទិត្យ និងដើមត្រាង) និងកាត់ក្រីមែកឈើចំនួន ០៦ដើម (ដើមឈើទាល០៣ដើម ដើមអាទិត្យ ដើមស្រឡៅ និងដើមអង្កាញ់) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅបរិវេណប្រាសាទបន្ទាយស្រី។
- កាត់ដកហូតដើមចំបក់ងាប់ ចំនួន០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅតាមដងផ្លូវជាប់ស្ពានថ្មខាងជើង ប្រាសាទព្រះខ័ន។
- កាត់ដកហូតដើមឈើចំនួន ០២ដើម (ដើមឈើទាល និងដើមស្ពង់) និងកាត់ក្រីមែកឈើចំនួន ០៤ដើម (ដើមខ្នុរព្រៃ០១ដើម និងដើមត្រាង០២ដើម) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅបរិវេណប្រាសាទព្រះខ័ន។
- កាត់សម្អាតដើមឈើចំនួន ០៣ដើម (ដើមពង្រ ០២ដើម និងដើមឈើទាល ០១ដើម) ស្ថិតនៅប្រាសាទបន្ទាយក្តី។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៧រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

ភ្នាក់ងារការពាររូបភាពអង្គរ និងភ្នាក់ងារទេសចរណ៍ ទទួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាព

ផ្សាយនៅថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ នៅសាលាវត្តអង្គរខាងត្បូង មានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារការពាររូបភាពអង្គរ និងភ្នាក់ងារទេសចរណ៍ ដែលវគ្គបណ្តុះបណ្តាលនេះរៀបចំឡើងរួមគ្នាដោយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ និងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌សារមន្ទីរនិងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរជាតិអប្សរា។

លោក សេង សុជាក់ អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានទាំងពីរខាងលើបញ្ជាក់ថានេះជាពេលវេលាដ៏សមស្របដែលត្រូវពង្រឹងសមត្ថភាពភ្នាក់ងារនៅតាមប្រាសាទ ពិសេសផ្នែកការពាររូបភាព និងភ្នាក់ងារទេសចរណ៍ ដើម្បីឱ្យការបំពេញការងារកាន់តែមានប្រសិទ្ធភាព។ លោកបន្ថែមថា វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពនេះមានចំនួន៣វគ្គសម្រាប់រយៈពេល៩ថ្ងៃ នៅតាមប្រាសាទគោលដៅទាំង៣៩ ដែលមានភ្នាក់ងារចូលរួមទាំងអស់សរុប ៤៦១នាក់។ មេរៀនសំខាន់ៗក្នុងវគ្គបណ្តុះបណ្តាលនេះ មានទី១ ចំណេះដឹងជាមូលដ្ឋាននៃការងារទូទៅរបស់អាជ្ញាធរជាតិអប្សរា ទី២ គុណតម្លៃរបស់រមណីយដ្ឋានអង្គរ និងទី៣ ការផ្លាស់ប្តូរបទពិសោធន៍ការងាររបស់ភ្នាក់ងារក្នុងការធ្វើការកន្លងមក។

ថ្លែងក្នុងពិធីបើកនៅពេលនោះ **ឯកឧត្តម សុខ សង្វារ អគ្គនាយករងអាជ្ញាធរជាតិអប្សរា** បានបង្ហាញការគាំទ្រពេញទំហឹងសម្រាប់វគ្គបណ្តុះបណ្តាលដ៏មានសារសំខាន់នេះ ពិសេសការពង្រឹងសមត្ថភាពភ្នាក់ងារដែលជាកិច្ចការសំខាន់ផ្សារភ្ជាប់ជាមួយកិច្ចការពារវប្បធម៌ក្នុងតំបន់រមណីយដ្ឋានអង្គរ។ ឯកឧត្តមបានលើកទឹកចិត្តភ្នាក់ងារទាំងអស់ដែលបានចូលរួមវគ្គសិក្សានេះ ត្រូវតោងចាប់រាល់មេរៀនដែលវាគ្មិនបានបង្ហាញ និងមានជាសំណួរទៅកាន់វាគ្មិននៅកន្លែងណាដែលមិនច្បាស់ ដើម្បីឱ្យពេលការអនុវត្តការងារមានប្រសិទ្ធភាពល្អ។

ឯកឧត្តមអគ្គនាយករងក៏បានរំលឹកសកម្មភាពមិនសមរម្យមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរនារយៈពេលប៉ុន្មានឆ្នាំមក ដែលត្រូវបានចែកចាយក្នុងបណ្តាញទំនាក់ទំនងសង្គម ហើយបានជះឥទ្ធិពលមិនល្អដល់តម្លៃបេតិកភណ្ឌជាតិយើង។ ឯកឧត្តមបានផ្តាំទៅភ្នាក់ងារទាំងអស់ នៅពេលឃើញភ្ញៀវទេសចរមានអាកប្បកិរិយាមិនសមរម្យក្នុងតំបន់ប្រាសាទត្រូវចេះណែនាំ និងហាមឃាត់រាល់ទង្វើមិនសមរម្យទាំងនោះ។ ទង្វើមិនសមរម្យ បានប៉ះពាល់ដល់តម្លៃវប្បធម៌នៃប្រទេសជាតិយើងទាំងមូល៕

ប្រជាពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរស្វែងយល់ពីអាជ្ញាធរជាតិអប្សរាតាមរយៈ «វេទិកាសាធារណៈ»

ផ្សាយនៅថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០២០

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២០ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា តំណាងអគ្គនាយកអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងវេទិកាសាធារណៈនៅវត្តអង្គម៉ោលសិរីវង្ស ស្ថិតនៅក្នុងភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។

កម្មវិធីនេះ ដឹកនាំដោយឯកឧត្តម ឡេង សេង អនុប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកអង្គរធំ ខេត្តសៀមរាប និងជាអនុរដ្ឋលេខាធិការស្តីទីគណៈរដ្ឋមន្ត្រី ដែលមានស្ថាប័នពាក់ព័ន្ធនានា អាជ្ញាធរមូលដ្ឋាន និងប្រជាជនចូលរួមប្រមាណ១៥០ នាក់។ គោលបំណងការរៀបចំវេទិកាសាធារណៈនេះដើម្បីត្រួតពិនិត្យនិងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមប្រធានបទ៖ ១. ការងារពាក់ព័ន្ធអាជ្ញាធរជាតិអប្សរា ២. បញ្ហាអគ្គិសនី (ភ្លើងលើសគីឡូលើសប្រក្រតី) ៣. វិធានការទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩។

ជាក់ស្តែង នៅក្នុងកម្មវីធីនេះ បានផ្តល់ឱកាសឱ្យប្រជាជនដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរដែលជាតំបន់បេតិកភណ្ឌពិភពលោកលើកនូវបញ្ហានានា និងចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងកិច្ចការងាររបស់អាជ្ញាធរជាតិអប្សរា ពិសេសទាក់ទងនឹងការជួសជុល ការសាងសង់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំពោះថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា។

ឆ្លើយតបនឹងសំណួររបស់ប្រជាពលរដ្ឋ លោកឡុង កុសល ក៏បានពន្យល់អំពីតួនាទីរបស់អាជ្ញាធរជាតិអប្សរានិងលក្ខខណ្ឌរបស់អង្គការយូណេស្កូក្នុងការប្រើប្រាស់ដីធ្លី និងនីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុលនិងសាងសង់ផ្ទះនៅក្នុងរមណីយដ្ឋានអង្គរ។

បន្ថែមពីនេះ រាល់ការស្នើសុំជួសជុលឬសាងសង់ផ្សេងៗសូមឱ្យប្រជាពលរដ្ឋត្រូវចូលរួមសហការជាមួយអាជ្ញាធរជាតិអប្សរាដើម្បីថែរក្សាការពារសម្បត្តិបេតិកភណ្ឌពិភពលោក។ លើសពីនេះ លោកក៏បានស្នើដល់អាជ្ញាធរមូលដ្ឋានខិតខំជាមួយគ្នា អប់រំ ពន្យល់ណែនាំដល់ប្រជាពលរដ្ឋឱ្យចូលរួម និងជួយនាំនូវផលលំបាកផ្សេងៗរបស់ប្រជាពលរដ្ឋមកដល់អាជ្ញាធរជាតិអប្សរា ដើម្បីធ្វើយ៉ាងណាដោះស្រាយការងារឱ្យកាន់តែមានប្រសិទ្ធិភាព៕

សាលិខិតថ្វាយព្រះពរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

ផ្សាយនៅថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០២០

តាមរបាយការណ៍របស់នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា នៅសប្ដាហ៍ទី២ ខែមិថុនា ឆ្នាំ២០២០នេះ ក្រុមការងារនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរប្រចាំច្រកទាំង០៦របស់អាជ្ញាធរជាតិអប្សរា បានទទួលពាក្យស្នើសុំសាងសង់លំនៅដ្ឋាន និងជួសជុលតូចតាចចំនួន៦៨ករណី។

បន្ទាប់ពីទទួលបានសំណើខាងលើ មន្ត្រី-បុគ្គលិកជំនាញបានចុះពិនិត្យដល់ទីតាំងផ្ទាល់ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់របស់ប្រជាពលរដ្ឋម្ចាស់សំណើបានចំនួន៣៦ករណី រួមមាន៖
១.ក្រុងសៀមរាប ចំនួន១៣ករណី
២.ស្រុកពួក ចំនួន០៥ករណី
៣.ស្រុកបន្ទាយស្រី ចំនួន០២ករណី
៤.ស្រុកអង្គរធំ ចំនួន០៧ករណី
៥.ស្រុកប្រាសាទបាគង ចំនួន០៩ករណី។

ដោយឡែក ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់ ដែលមានលក្ខណៈជាលំនៅដ្ឋានខ្មែរជូនពួកគាត់បាន១៣ករណី មានដូចជា៖
១.ក្រុងសៀមរាបបានចំនួន៣ករណី
២.ស្រុកបន្ទាយស្រីបានចំនួន៤ករណី
៣.ស្រុកពួកបានចំនួន២ករណី
៤.ស្រុកប្រាសាទបាគងបានចំនួន២ករណី
៥.ស្រុកអង្គរធំបានចំនួន២ករណី។



អាជ្ញាធរជាតិអប្សរាតែងយកចិត្តទុកដាក់និងពិនិត្យព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែមតាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ។

តូបលក់ដូរទី១១ នៅមុខប្រាសាទអង្គរវត្តត្រូវបានអាជីវករបន្តស្ម័គ្រចិត្តរុះរើចេញ

ផ្សាយនៅថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២០

គម្រោងកែលម្អបរិវេណមុខប្រាសាទអង្គរវត្ត បាននិងកំពុងបន្តសកម្មភាពរបស់ខ្លួនទៅមុខជានិច្ច ក្នុងនោះអាជីវករជាបន្តបន្ទាប់ បានស្ម័គ្រចិត្តរុះរើសំណង់អាគារ និងតូបលក់ដូរ ដើម្បីអនុញ្ញាតឱ្យអាជ្ញាធរជាតិអប្សរាមានលទ្ធភាពក្នុងការសម្រេចឱ្យបានគម្រោងដ៏មានសារសំខាន់មួយនេះ។

នៅព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០នេះ សំណង់តូបលក់ដូរទី១១ហើយ ដែលស្ម័គ្រចិត្តរុះរើចេញពីបរិវេណមុខប្រាសាទអង្គរវត្ត។ លោកស្រី ម៉ោញ ស៊ីណាត ដែលលក់ដូរនៅទីតាំងនេះរយៈពេល២៨ឆ្នាំមកហើយបាននិយាយថា លោកស្រីយល់ព្រមរើតូបលក់ដូរនេះដើម្បីរួមចំណែកកិច្ចការអភិវឌ្ឍន៍ និងការរៀបចំបរិស្ថានមុខអង្គរវត្តឱ្យកាន់តែមានភាពទាក់ទាញ។ លោកស្រីបន្តថា មានសុទិដ្ឋិនិយមចំពោះការងារអភិវឌ្ឍន៍ហើយជឿថាខ្លួនឯងនឹងទទួលផលចំណេញច្រើនចំពោះវិស័យទេសចរណ៍នៅប្រាសាទអង្គរវត្តនេះ។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរាទទួលបន្ទុកកិច្ចការរៀបចំកែលម្អបរិវេណមុខប្រាសាទអង្គរវត្ត បានកោតសរសើរចំពោះការលះបង់ និងការសហការចូលរួមពីម្ចាស់អាជីវកម្មនានា ដែលបានសហការជាមួយអាជ្ញាធរជាតិអប្សរាសម្រេចការងារតាមផែនការដែលបានគ្រោងទុក។ឯកឧត្តមបន្ថែមថា ការចូលរួមនេះជាឥរិយាបថដ៏ប្រពៃប្រកបដោយឆន្ទៈខ្ពស់ចំពោះសង្គមជាតិ និងគិតប្រយោជន៍រួមជាធំ ហើយសូមអំពាវនាវដល់អាជីវករដ៏ទៃទៀតឱ្យស្ម័គ្រចិត្តចូលរួមជាមួយអាជ្ញាធរជាតិអប្សរាក្នុងការរុះរើតូបចាស់ចេញ ដើម្បីទទួលបានតូបថ្មី។

តាមការបញ្ជាក់ពីឯកឧត្តមអគ្គនាយរងអាជ្ញាធរជាតិអប្សរាគ្រោងនឹងបញ្ចប់ការរុះរើសំណង់ទាំងស្រុងនៅជុំវិញបរិវេណមុខប្រាសាទអង្គរវត្ត និងត្រពាំងសេសដែលសរុបជាង១០០តូប ឱ្យបាននៅត្រឹមចុងខែ សីហាខាងមុខនេះ។ ការលក់ដូរនានា នឹងបញ្ចូលទៅក្នុងទីលានបដិសណ្ឋារកិច្ចដែលកំពុងមមាញឹកក្នុងការសាងសង់ និងគ្រោងដំណើរការការលក់ដូរនៅក្នុងខែកញ្ញាឆ្នាំ២០២០នេះ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន ចុះពិនិត្យនិងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២២ ខែ មិថុនា ឆ្នាំ២០២០

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដែលមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ចំនួន២គោលដៅផ្សេងៗគ្នា នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០។

គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយចំនួន៩សំណើ ស្ថិតក្នុងភូមិគិរីមានន្ទ និង ភូមិបង្គោង សង្កាត់អំពិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី២ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយលោកឡុង កុសល បានពិនិត្យចំនួន១៣ សំណើ ស្ថិតក្នុងភូមិទ្រាំង និងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០នេះ ក្រុមការងារសហគមន៍ទាំង២គោលដៅបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋបានចំនួន ១៣សំណើ៕

សំណើចំនួន២០ករណីត្រូវបានអនុញ្ញាតជូនប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ដោយក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០២០

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដោយមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៣គោលដៅ។

នៅក្នុងនោះ គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយចំនួន ០៩សំណើ ស្ថិតក្នុងភូមិដូនឪ និង ភូមិត្លង់ ឃុំលាងដៃ។ ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៦សំណើ។

រីឯគោលដៅទី២ ក្រុមការងារសហគមន៍ប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ**ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយចំនួន ០៧សំណើ ស្ថិតក្នុងភូមិតាកុះ ឃុំព្រះដាក់។

ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៧សំណើ។

ដោយឡែកគោលដៅទី៣ នៃក្រុមការងារសហគមន៍ប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានពិនិត្យ និងដោះស្រាយចំនួន ១១សំណើ ស្ថិតក្នុងភូមិអំពិលពាម ភូមិជ្រលង ភូមិកំភែម ឃុំកែវ និង ឃុំខ្នាត។ ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៧សំណើ។

គោលដៅធំៗទាំង៣ខាងលើ នៅថ្ងៃទីទី២៣ ខែមិថុនា ឆ្នាំ២០២០ នេះ ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋបាន២០ករណី៕

លោកជំទាវ ភឿង សកុណា ដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា តាមវីដេអូ Conference

ផ្សាយនៅថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០នេះ លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បាន ដឹកនាំកិច្ចប្រជុំតាមរយៈវីដេអូ Conference ជាមួយថ្នាក់ដឹកនាំក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក្នុងបំណងដើម្បីពិភាក្សាកិច្ចការ និងដោះស្រាយការងារបន្ទាន់មួយចំនួន៕

សិលាចារឹកមួយផ្ទាំងជាភាសាសំស្រ្កឹតត្រូវបានប្រទះឃើញ នៅក្នុងប្រាសាទទន្លេស្ងួតពេលកំពុងជួសជុល

ផ្សាយនៅថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០២០

ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរាបានប្រទះឃើញសិលាចារឹកជាភាសាសំស្ក្រឹតចារលើផ្ទាំងថ្មភក់ដែលគេយកមករៀបជាគ្រឿងបង្គុំថ្មកម្រាលខ្លោងទ្វារខាងមុខប្រាង្គកណ្តាលនៃប្រាសាទទន្លេស្ងួតក្នុងពេលលាងសម្អាតថ្ម មុនយកទៅរៀបផ្គុំនៅទីតាំងដើមវិញ។ ថ្មចារឹកនេះ អាជ្ញាធរជាតិអប្សរាបានយកមករក្សាទុកក្នុងទីស្នាក់ការនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ នាព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

តាមការបញ្ជាក់របស់លោកអ៊ឹមសុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ ឱ្យដឹងថា ផ្ទាំងថ្មចារឹកនេះអាចពុំមែនជារបស់មន្ទីរពេទ្យទន្លេស្ងួតទេ ប្រហែលជាគេយកចេញពីប្រាសាទណាមួយមកប្រើធ្វើជាថ្មកម្រាល ដោយរៀបដាក់ផ្កាប់ផ្ទៃមានអក្សរចារឹកទៅក្រោម។ ចំណែកផ្ទៃខាងក្រោយពុំមានអក្សរគេដាក់ផ្ងារឡើងលើ ហើយដាប់ធ្វើជាល្បាក់សម្រាប់ទ្រថ្មផ្ទឹមទ្វារ។

ករណីនេះ បានធ្វើឱ្យបាត់បង់តួអក្សរមួយផ្នែក តែក៏នៅមានសេចក្តីច្រើនដែលអាចសិក្សាស្រាវជ្រាវបន្ថែមបាន ហើយនេះក៏មិនចាត់ទុកជាករណីបំផ្លាញដែរ ព្រោះគេកាត់តម្រឹមឱ្យត្រូវចន្លោះដើម្បីធ្វើជាថ្មកម្រាលក្នុងការកសាងប្រាសាទទន្លេស្ងួតពីបុរាណ។ ការយកថ្មចាស់ពីកន្លែងផ្សេងមកកសាងប្រាសាទថ្មីបន្ទាប់ ក៏ជាទម្លាប់ធម្មតានាសម័យបុរាណដែរ។ លក្ខណៈពិសេសនៃសិលាចារឹកនេះ គឺពុំទាន់មានការសិក្សានៅឡើយ ដែលសរសេរជាភាសាសំស្ក្រឹត មានចំនួន ៥៥បន្ទាត់ កម្ពស់១០០ស.ម ទទឹង៤០ស.ម និងកម្រាស់ ២០ស.ម។ បើយោងតាមការសន្និដ្ឋានដំបូងលើលក្ខណៈតួអក្សរឆ្នារៗ និងពិចិត្រ ដែលប្រៀបនឹងសិលាចារឹកនៅប្រាសាទភ្នំជី ស្ថិតនៅខាងជើងប្រាសាទទន្លេស្ងួតនោះ យើងអាចស្មានបានថា សិលាចារឹកនេះ ប្រហែលចារនៅចុងស.វ.ទី១១ ដល់ដើមស.វ.ទី១២។

លោក សុខរិទ្ធី បញ្ជាក់ថា នៅពេលនេះយើងមិនទាន់ដឹងខ្លឹមសារនៅក្នុងសិលាចារឹកនេះទេ គឺត្រូវការពេលវេលាដើម្បីឱ្យអ្នកជំនាញប្រែសម្រួលពីភាសាសំស្ក្រឹត ដើម្បីស្វែងយល់ពីរឿងរ៉ាវផ្សេងៗ និងកាលបរិច្ឆេទនៃអក្សរចារឹកមួយផ្ទាំងនេះ។ តែវាបានផ្តល់ព័ត៌មានសំខាន់មួយឱ្យយើងដឹងអំពីប្រវត្តិនៃការសាងសង់ប្រាសាទទន្លេស្ងួត និងភស្តុតាងបុរាណវិទ្យាដែលបង្ហាញអំពីការតាំងទីមនុស្សសម័យអង្គរនៅក្នុងតំបន់នេះ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ (១១៨១ ដល់ ១២១៨ គ.ស.)៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាអនុញ្ញាតសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋ បានចំនួន៥ករណី

ផ្សាយនៅថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ២០២០

ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដែលមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកពួកដែលស្ថិតនៅក្នុងឧទ្យានអង្គរ។

ការងារនេះ ក្រុមការងារសហគមន៍ប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានពិនិត្យ និងដោះស្រាយចំនួន ០៩សំណើ ស្ថិតក្នុងភូមិប្រឡាយ ភូមិព្រៃធ្លក ឃុំខ្នាត។ ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៥សំណើ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១. ការជួសជុលផ្ទះ៖ ការជួសជុលឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ ប្តូរឬតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ។ ២. សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូក ជង្រុកស្រូវ តូបឬរោងលក់ដូរមុខផ្ទះ។ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។ រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

សូមបញ្ជាក់ថា ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ៕

ក្រុមការងារគ្រប់គ្រងបរិស្ថាន-អង្គរ បើកកិច្ចប្រជុំតាមដាន និងជំរុញការងារបរិស្ថាន ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០នេះ **ឯកឧត្តម សុខ សក្ខិណា** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាអ្នកតំណាងអង្គភាពគ្រប់គ្រងប្រព័ន្ធបរិស្ថាន-អង្គរ បានបើកកិច្ចប្រជុំផ្ទៃក្នុងដើម្បីត្រួតពិនិត្យ តាមដាន និងជំរុញការងារគ្រប់គ្រងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ។

កិច្ចប្រជុំនេះ បានផ្តោតជាសំខាន់លើការងារបរិស្ថានមួយចំនួនដែលស្ថាប័ននេះបានធ្វើការកន្លងមក ពិសេសគោលដៅបន្តធ្វើយ៉ាងណាឱ្យការងារបរិស្ថានក្នុងរមណីយដ្ឋានអង្គរដំណើរការដោយរលូន ក្នុងន័យបន្តកិច្ចសហការជាមួយស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance (JQA) លើការធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន ដែលស្ថាប័ននេះមានតួនាទីជាអ្នកចេញវិញ្ញាបនបត្របញ្ជាក់ពីគុណភាពបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ៕

កំពែងក្រុងអង្គរធំចំនួន៧កន្លែង ស្មើនឹង១៣៥ម៉ែត្រ ត្រូវបានជួសជុលពង្រឹងឱ្យផុតពីគ្រោះថ្នាក់

ផ្សាយនៅថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០២០

កំពែងក្រុងអង្គរធំចំនួន៧កន្លែងក្នុងចំណោម១៨កន្លែង ដែលរងការខូចខាតដោយគ្រោះធម្មជាតិ បរិយាកាស អាយុកាលថ្ម រចនាសម្ពន្ធសំណង់ទ្រុឌទ្រោម និងដីកណ្ដៀរ ត្រូវបានអ្នកជំនាញអាជ្ញាធរជាតិអប្សរាជួសជុលបានសម្រេចប្រវែង១៣៥ម៉ែត្រ ក្នុង៣ដំណាក់កាលផ្សេងគ្នាដោយប្រើប្រាស់ថវិកាជាតិទាំងស្រុង។

ការជួសជុលនេះធ្វើឡើងក្នុងគោលបំណងអភិរក្សនិងពង្រឹងកំពែងក្រុងអង្គរធំឱ្យកាន់តែរឹងមាំដើម្បីរក្សាសោភ័ណភាពកំពែង និងខ្លោងទ្វារអង្គរធំទាំងអស់ឱ្យនៅគង់វង្សយូរអង្វែង។ ដំណើរការជួសជុលបានចាប់ផ្ដើមពីឆ្នាំ២០១៤ សរុបបានប្រវែង១៣៥ម៉ែត្រ ដែលក្នុងនោះមានប្រវែង២០ម៉ែត្រនៅខាងកើតខ្លោងទ្វារជ័យជំនះ និងប្រវែង១១៥ម៉ែត្រនៅខាងលិចខ្លោងទ្វារទន្លេអុំ។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលកំពែងក្រុងអង្គរធំនិងជាមន្ត្រីនាយដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានលើកឡើងថា អាជ្ញាធរជាតិអប្សរាបានរើសយកកន្លែងដែលមានហានិភ័យខ្ពស់មកជួសជុលមុន ព្រោះកន្លែងទាំងនោះបានរងផលប៉ះពាល់ខ្លាំងដោយធម្មជាតិ។

ក្នុងការជួសជុល ក្រុមការងារបានផ្ដោតសំខាន់លើបច្ចេកទេសការរៀបជញ្ជាំងថ្មបាយក្រៀមទៅវិញពីមួយស្រទាប់ទៅមួយស្រទាប់ ការបុកបង្ហាប់ដីឱ្យមាំ ដើម្បីពង្រឹងកំពែងឱ្យមានសុវត្ថិភាពខ្ពស់ការពារការជ្រៀបទឹក បង្កើនគុណភាពសំណង់ សោភ័ណភាព ដោយរក្សាទម្រង់ដើមនៃកំពែង និងស្រាវជ្រាវប្រវត្តិនៃការជួសជុលពីអតីតកាល។

មិនតែប៉ុណ្ណោះ អាជ្ញាធរជាតិអប្សរាក៏គិតគូរពីសុវត្ថិភាពសំណង់ដើម្បីរក្សាភាពគង់វង្ស ដោយការធ្វើជំរាលទឹកហូរ និងដាំស្មៅតាមជើងទេរដើម្បីទប់ការហូរច្រោះ។

ចំពោះការជួសជុលកំពែងអង្គរធំនេះគឺត្រូវការពេលវេលាច្រើនព្រោះត្រូវការសិក្សាស្រាវជ្រាវពីរចនាសម្ពន្ធសំណង់ប្រវត្តិជួសជុល និងចំណុចដែលមានហានីភ័យខ្ពស់។ ពិសេស គឺពេលជួសជុលទាមទារត្រូវគោរពតាមធម្មនុញ្ញអង្គរ ការចុះតាមដានការងារនិងវាយតម្លៃពីអ្នកជំនាញគណៈកម្មការស៊ីស៊ី-អង្គរ រួមទាំងការថែទាំ ការទល់ទ្រ កាត់ក្រីមែកឈើ និងដករុក្ខជាតិដែលដុះលើជញ្ជាំងកំពែងផងទៀតផង។

ចំពោះផែនការអនាគតអាជ្ញាធរជាតិអប្សរាមានគម្រោងជួសជុលកំពែងអង្គរធំដែលរងនូវគ្រោះថ្នាក់ទាំងអស់ឱ្យមានសុវត្ថិភាពតាមរយៈការអភិរក្សជាជំហានៗដើម្បីលើកតម្លៃមរតកជូនតាឱ្យនៅយូរអង្វែង៕

ក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគងពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋបានចំនួន៦សំណើ

ផ្សាយនៅថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០២០

ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកប្រាសាទបាគង ស្ថិតក្នុងតំបន់ឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយលោកស្រី ម៉ៅ ល្អ បានពិនិត្យ និងដោះស្រាយចំនួន ០៨សំណើ ស្ថិតក្នុងភូមិដូននំ ភូមិតាប្រាក់ ឃុំមានជ័យ និងភូមិស្ពានក្អែក ឃុំកណ្ដែក។ ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៦សំណើ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១. ការជួសជុលផ្ទះ៖ ការជួសជុលឬប្ដូរដំបូល ប្ដូរជញ្ជាំង ប្ដូរសសរ ប្ដូរឬតសំយ៉ាប ជួសជុលជណ្ដើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ។ ២. សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូក ជង្រុកស្រូវ តូបឬរោងលក់ដូរមុខផ្ទះ។ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។ រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ៕

អាជ្ញាធរជាតិអប្សរាប្រជុំផ្ទៃក្នុងស្តីពី ដំណើរការគ្រប់គ្រងចរន្តឯកសារ មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា «ម.ស.អ»

ផ្សាយនៅថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដោយមានការចូលរួមពីអគ្គនាយករង ប្រធាននាយកដ្ឋាន មន្ត្រី-បុគ្គលិកពាក់ព័ន្ធនៅតាម នាយកដ្ឋាននីមួយៗ ក្រោមចំណុះនៃអាជ្ញាធរជាតិអប្សរា។

គោលបំណងសំខាន់នៃអង្គប្រជុំ គឺដើម្បីជំរុញឱ្យការអនុវត្តការគ្រប់គ្រងចរន្តឯកសារ មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា "ម.ស.អ " មានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងឆាប់រហ័សស្របតាមយន្តការច្រកចេញចូលតែមួយ ជូនភ្ញៀវទេសចរជាតិ-អន្តរជាតិ និងអ្នកប្រើប្រាស់សេវានានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

ឯកឧត្តម ហង់ ពៅ បានលើកឡើងថា ដំណើរការគ្រប់គ្រងរចន្តឯកសារមជ្ឈមណ្ឌលសេវាកម្មពិតជាមានសារៈសំខាន់ណាស់គឺ បានលើកកម្ពស់ការផ្តល់សេវាសាធារណៈរបស់អាជ្ញាធរជាតិអប្សរឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិ-អន្តរជាតិឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរជាងមុន៕

ក្រុមហ៊ុន លី ប្រាឌឺ លីមីធីដ ប្រគល់រថយន្តបោសសម្អាតដីនិងលាងថ្នល់មួយគ្រឿង ជូនអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០២០

រថយន្តបោសសម្អាតដីនិងលាងថ្នល់មួយគ្រឿងជាអំណោយរបស់ក្រុមហ៊ុន លី ប្រាឌឺ លីមីធីដ បានប្រគល់ជូនអាជ្ញាធរជាតិអប្សរាជាផ្លូវការ នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

លោក លី សាំងឡេង អគ្គនាយកក្រុមហ៊ុន លី ប្រាឌឺ លីមីធីដ មានប្រសាសន៍ក្នុងឱកាសនាពេលនោះថា លោកពេញចិត្តនឹងអ្វីដែលកំពុងកើតមាននៅរមណីយដ្ឋានអង្គរ ហើយការចូលរួមនេះគឺជាការតបស្នងទៅសង្គមវិញក្នុងនាមលោកជាផ្នែកមួយនៃវិស័យឯកជនដែលបានទទួលផលពីការរីកចម្រើនរបស់ប្រទេសជាតិ ពិសេសកំណើនសេដ្ឋកិច្ចដែលមានរមណីយដ្ឋានអង្គរជាកត្តាជំរុញដ៏សំខាន់។

លោកសង្ឃឹមថា រថយន្តនេះនឹងជួយសម្រួលដល់ការងារសម្អាតបរិស្ថាន ជួយកម្លាំងពលកម្មបានច្រើន ចំណេញពេលវេលា និងជួយជំរុញឱ្យរមណីយដ្ឋានអង្គរកាន់តែមានសោភ័ណភាពល្អប្រសើរ។

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ក៏បានថ្លែងអំណរគុណដល់លោកអគ្គនាយក ក្រុមហ៊ុន លី ប្រាឌឺ ដែលបានលះបង់ធនធានផ្ទាល់ខ្លួនដើម្បីចូលរួមចំណែកបម្រើផលប្រយោជន៍សង្គមពិសេសបានចូលរួមលើកកម្ពស់សោភ័ណភាពបរិស្ថានក្នុងរមណីយដ្ឋានអង្គរឱ្យកាន់តែប្រសើរ។ ទង្វើនេះជាកាយវិការដ៏ថ្លៃថ្លាដែលវិស័យឯកជនបានចូលរួមការថែរក្សាមរតកដូនតានិងធ្វើឱ្យរមណីយដ្ឋានអង្គរកាន់តែស្រស់ស្អាតទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាកាន់តែច្រើនថែមទៀតនាពេលអនាគត៕

សិក្ខាកាម៤៥រូបបានទទួលការបណ្តុះបណ្តាលការវិនិយោគសាធារណៈ ៣ឆ្នាំរំកិល

ផ្សាយនៅថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០២០

នៅថ្ងៃទី២៤ដល់២៥ ខែមិថុនា ឆ្នាំ២០២០ មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរសហការជាមួយមន្ត្រីជំនាញពីក្រសួងផែនការ បានរៀបចំវគ្គបណ្តុះបណ្តាលធនធានមនុស្សស្តីពីការប្រើប្រាស់និងរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលដល់មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន៤៥នាក់។

វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងដើម្បីពង្រឹងសមត្ថភាពមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាដែលបម្រើការផ្នែករដ្ឋបាលតាមនាយកដ្ឋាន/អង្គភាពដែលទទួលខុសត្រូវលើផ្នែកថវិកាឱ្យបានយល់ដឹងកាន់តែច្បាស់លាស់ឱ្យស្របតាមកម្មវិធីដែលក្រសួងចង់បាន។ កម្មវិធីបានផ្តោតទៅលើសារតានៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ ដំណើរការរៀបចំវិនិយោគសាធារណៈ ការគ្រប់គ្រងចំណាយវិនិយោគសាធារណៈ ទំនាក់ទំនងរវាងកម្មវិធីវិនិយោគសាធារណៈជាមួយអាទិភាពជាតិ គម្រោងនៅក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល គម្រោងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និយមន័យនិងរបៀបបំពេញទិន្នន័យគម្រោងក្នុងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិលតាមអនឡាញ។

លោក ម៉ុក គន្ធី ប្រធានការិយាល័យបុគ្គលិកនិងសម្ភារៈនៃអាជ្ញាធរជាតិអប្សរា បានលើកឡើងថា កម្មវិធីដែលរៀនពេលនេះ គឺថ្មីសម្រាប់ការអនុវត្តលើការងារចាស់ ដែលធ្វើឱ្យសិក្ខាកាមទាំងអស់មានការពិបាកក្នុងការស្វែងយល់ខ្លះៗ តែក៏បានចេះនូវអ្វីថ្មីៗបន្ថែមទៀត ដែលងាយស្រួលយល់

និងអនុវត្តបានល្អ ឆាប់រហ័សជាងមុនទៅលើការចាយវាយថវិកាចៀសវាងកំហុសឆ្គង។ លោកក៏សំណូមពរឱ្យមានកម្មវិធីបង្រៀននេះឱ្យបានច្រើន ដើម្បីបង្កើនពុទ្ធិ សមត្ថភាពការងារចំពោះគោលការណ៍ថ្មីៗរបស់មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ឯកឧត្តម ជុំ សុធមករា អគ្គនាយករងអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ក្នុងឱកាសបិទកម្មវិធីថា នេះជាមេរៀនថ្មីមួយទៀតសម្រាប់បង្កើនចំណេះដឹងនិងសមត្ថភាពការងាររបស់ធនធានមនុស្សនៅអាជ្ញាធរជាតិអប្សរា។ ឯកឧត្តមរំពឹងថា វគ្គបណ្តុះបណ្តាលនេះ នឹងជួយឱ្យក្រុមការងារអនុវត្តការងារបានងាយស្រួល ហើយបំពេញការងារបានលឿនជាងមុន ដោយគ្មានការខុសឆ្គង៕

ខ្លោងទ្វារខាងលិចនៃប្រាសាទបន្ទាយក្តីកំពុងទទួលបានការជួសជុលដោយអ្នកជំនាញជាស្ត្រី

ផ្សាយនៅថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០២០

មានសភាពដូចប្រាសាទដទៃទៀតដែរប្រាសាទបន្ទាយក្តីរង ការខូចខាត ដួលរលំ និងទីតាំងខ្លះមានសភាពទ្រុឌទ្រោម ខ្លាំង។ ថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមការជួស ជុលខ្លោងទ្វារខាងលិចប្រាសាទដោយក្រុមអ្នកជំនាញជា ស្ត្រី។

បុរាណវិទូអ្នកស្រីនេតស៊ីមននៃនាយកដ្ឋានអភិរក្សប្រាសាទ ក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ដែលកំពុងបំពេញ ការងារនៅការដ្ឋានខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តីឱ្យ ដឹងថា ស្ថានភាពជាក់ស្តែងនៃខ្លោងទ្វារនេះ គឺថ្មរំកិលចេញ ពីទីតាំងដើម រីឯផ្នែកជញ្ជាំងមានភាពរហែកពីខាងក្រោម ទៅលើ។ អ្នកស្រីពន្យល់ពីហានិភ័យនៅការដ្ឋាននោះទៀត ថា សភាពថ្មនៅផ្នែកខ្លះស្ទើររបេះធ្លាក់ ដែលអាចមានហានិ ភ័យខ្ពស់ដល់ទេសចរណ៍ និងទាមទារឱ្យមានការជួសជុល ជាបន្ទាន់។

កញ្ញា ហាន សុច្ចរី ស្ថាបត្យករ នៃគម្រោងជួសជុលខាងលើ បានសិក្សាលម្អិតលើស្ថានភាពថ្មពុកផុយនៅទីនេះ។ តាម ការសិក្សារបស់ស្ថាបត្យកររូបនេះ ការដួលរលំនៃខ្លោងទ្វារ នេះមានកត្តាច្រើនដូចជា អាយុកាលនៃថ្ម អាកាសធាតុ និងការបំផ្លាញពីឫសឈើ។តាមការវាយតម្លៃពីអ្នកជំនាញ ខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តីដែលកំពុងស្ថិតក្នុង គម្រោងកំណាយឆ្នាំដំបូង មានស្ថានភាពខូចខាតប្រហាក់ ប្រហែល៧០ភាគរយ។
រីឯវិស្វករ កញ្ញា ដយ ពេជ្រដឺវ៉ា បានបង្ហើបពីវិធីសាស្រ្តចំនួន ២ដែលក្រុមការងារកំពុងពិចារណានិងរង់ចាំការសម្រេច ពីអ្នកជំនាញការជាតិ-អន្តរជាតិ។ វិធីទី១ គឺការរើថ្មផ្នែក ខ្លះដែលមានហានិភ័យខ្ពស់ រៀបចំតម្រៀបឡើងវិញ ទី២គឺ ការរើថ្មចោលទាំងស្រុង ដើម្បីរៀបចំឡើងវិញ។

ទាក់ទងនឹងប្រវត្តិនៃការជួសជុលវិញ បុរាណវិទូអ្នកស្រី នេត ស៊ីមន លើកឡើងថា ខ្លោងទ្វារខាងលិចនេះមិនធ្លាប់ ទទួលការជួសជុលទេកន្លងមក តែធ្លាប់មានការចុះសម្អាត និងទល់ទ្រដោយប្រើធ្នឹមបេតុងនៅសម័យបារាំងនាឆ្នាំ ១៩២០ ហើយក្រោយមកអាជ្ញាធរជាតិអប្សរាជានិច្ចកាល តែងថែទាំ ពង្រឹងទាល់ទ្រ ដើម្បីការពារហានិភ័យផ្សេងៗ។ ចំណុចហានិភ័យដែលមានសភាពថ្មរំកិលញែកចេញពីគ្នា និងកន្លែងខ្លះរបេះធ្លាក់ផងនោះ ទើបអ្នកជំនាញបង្កើន សមត្ថភាពការងារ និងរំពឹងថាអាចផ្តើមជួសជុលឡើងវិញ នៅឆ្នាំក្រោយ បន្ទាប់ពីការងារកំណាយសិក្សាស្រាវជ្រាវបាន បិទបញ្ចប់៕

សេចក្តីជូនដំណឹងស្តីពីការប្រើប្រាស់ត្រាថ្មីរបស់ស្ថាប័នអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនគ្រប់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ អង្គភាព ពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ តទៅ អាជ្ញាធរជាតិអប្សរានឹងប្រើប្រាស់ត្រាស្ថាប័នថ្មី ជំនួសត្រាស្ថាប័នចាស់ដូចមានគម្រូខាងក្រោម។ ដើម្បីបានព័ត៌មានលំអិត សូមអានសេចក្តីជូនដំណឹងដូចខាងក្រោម។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៥០២/២០ រប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការប្រើប្រាស់ត្រាថ្មីរបស់ស្ថាប័នអាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនគ្រប់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ អង្គភាព ពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា អាជ្ញាធរដើម្បីការពារមណ្ឌលយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅកាត់ថា "អាជ្ញាធរជាតិអប្សរា" ជាភាសាបារាំង "Autorité Nationale APSARA" និងជាភាសាអង់គ្លេស "APSARA National Authority" ត្រូវបានបង្កើតឡើងជាថ្មីជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។ អនុលោមតាមព្រះរាជក្រឹត្យថ្មីនេះ អាជ្ញាធរជាតិអប្សរានឹងប្រើប្រាស់ត្រាស្ថាប័នថ្មី ជំនួសត្រាស្ថាប័នចាស់ដូចមានគម្រូខាងក្រោម ចាប់ពី**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០** នេះតទៅ។

រូបគម្រូត្រាចាស់	រូបគម្រូត្រាថ្មី

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ អង្គភាពពាក់ព័ន្ធទាំងអស់មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃអង្គារ ១០កើត ៥ ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី...៣០......ខែមិថុនា....ឆ្នាំ២០២០
អាជ្ញាធរជាតិអប្សរា

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

ខែមិថុនា ឆ្នាំ២០២០

ទីស្នាក់ការអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្តោយផ្លូវហ្សាលដីហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានផ្សព្វផ្សាយ
ឆ្នាំ២០២១